សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Universite Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ប្រភេទនៃទោសព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **ចាន់ រតនា**
លោក **រុណ សុឃុន**

ណែនាំដោយ
សាស្ត្រាចារ្យជំនួយ **ញឹក ឌុផ្លី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០
ឆ្នាំសរសេរសារណា ២០២៤

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ប្រភេទនៃទោសព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ   លោក **ចាន់ រតនា**
លោក **រុណា សុឃុន**

ណែនាំដោយ
សាស្ត្រាចារ្យជំនួយ **ញឹក ឧត្តី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ចាន់ រតនា** និងខ្ញុំបាទ **រុណ សុឃុន** ជានិស្សិតផ្នែកបរិញ្ញាបត្រ នីតិសាស្ត្រ ជំនាន់ទី២៣ ឆ្នាំសិក្សា២០១៩-២០២៣ នៃសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅទៅកាន់៖**

- លោកឪពុកឈ្មោះ **គង់ ចាន់ថន** និងអ្នកម្តាយ **សា សុខខុម**
- លោកឪពុកឈ្មោះ **រុន សុខា** និងអ្នកម្តាយ **ផាន់ ថន**

ដែលលោកទាំងបួនបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ប្រកបដោយព្រហ្មវិហារធម៌ទាំងបួនគឺ **មេត្តា ករុណា មុទិតា** និង **ឧបេក្ខា** ចំពោះកូនៗតាំងពីតូចដល់ធំពេញវ័យ ហើយថែមទាំងបានផ្តល់ថវិកា និងពេលវេលាព្រមទាំងឱកាសឱ្យយើងខ្ញុំទាំងពីរនាក់បានសិក្សាតាំងពីថ្នាក់មត្តេយ្យ បឋមសិក្សា វិទ្យាល័យរហូតមកដល់ថ្នាក់បរិញ្ញាបត្រ។ យើងខ្ញុំទាំងពីរអាចឈានមកដល់ពេលសព្វថ្ងៃនេះ ដោយសារមានលោកទាំងបួនបានអប់រំទូន្មានប្រៀនប្រដៅឱ្យយើងខ្ញុំក្លាយជាកូនល្អ សិស្សល្អ ពលរដ្ឋល្អ នៅក្នុងសង្គមលោកមិនត្រឹមតែជាអ្នកផ្តល់កំណើតទេ តែលោកទាំងបួនក៏ជាលោកគ្រូអ្នកគ្រូដែលជួយបង្ហាត់បង្រៀនយើងខ្ញុំទាំងពីរឱ្យបានដឹងពីសណ្តាប់ធ្នាប់ក្នុងគ្រួសារ ក៏ដូចជាការរស់នៅមួយចំនួនក្នុងសង្គម ហើយលោកទាំងបួនក៏ជាកម្លាំងចិត្តរបស់យើងខ្ញុំផងដែរ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណទៅកាន់លោកឯកឧត្តមបណ្ឌិត **លុយ ចន្ណា** ជាសាកលវិទ្យាធិការ ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលលោកគ្រូ អ្នកគ្រូតែងតែជួយចែករំលែកចំណេះដឹងមកកាន់យើងខ្ញុំទាំងពីរតាំងពីថ្នាក់មូលដ្ឋានរហូតដល់ឆ្នាំទី៤ ផ្នែកនីតិសាស្ត្រនេះ យើងខ្ញុំនឹងចង់ចាំ និងដឹងគុណដ៏មានតម្លៃមួយនេះជានិរន្តរ៍។

យើងខ្ញុំសូមថ្លែងអំណរគុណលោកសាស្ត្រាចារ្យ **ញឹក ឌុទ្ធី** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការធ្វើឱ្យមានសារណាមួយនេះឡើងប្រកបដោយលទ្ធផលល្អ និងមានប្រសិទ្ធភាព។ លោកគ្រូបានខិតខំប្រឹងប្រែងទាំងកម្លាំងកាយ និងកម្លាំងចិត្ត ពេលវេលាដ៏មានតម្លៃដើម្បីជួយកែសម្រួលសារណារបស់យើងខ្ញុំ។ ប្រសិនបើគ្មានលោកគ្រូទេ ក៏ពួកយើងមិនអាចធ្វើកិច្ចការមួយនេះបានល្អដែរ លោកគ្រូបានផ្តល់នៅអនុសាសន៍ល្អៗ និងបទពិសោធន៍ល្អៗជាច្រើន ដែលពួកយើងមិនបានដឹងពីមុនមក ហើយជាហេតុនាំឱ្យយើងធ្វើកិច្ចការនេះបាន។

ជាចុងក្រោយ យើងខ្ញុំក៏សូមអរគុណយ៉ាងជ្រាលជ្រៅ និងសូមបួងសួងដល់វត្ថុស័ក្តសិទ្ធទាំងឡាយក្នុងព្រះរាជាណាចក្រកម្ពុជា សូមប្រសិទ្ធពរជ័យជូនទៅកាន់លោកគ្រូ អ្នកគ្រូ លោកឪពុក អ្នកម្តាយ លោកសាស្ត្រាចារ្យសូមឱ្យជួបពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់ពេលរយៈ៤ឆ្នាំរួចមក និងបានសិក្សាលើមុខវិជ្ជាជាច្រើនទាំងផ្នែកនីតិឯកជន និងនីតិសាធារណៈ ដោយយើងខ្ញុំបានខិតខំប្រឹងប្រែងតាំងពីឆ្នាំទី១ រហូតមកដល់ឆ្នាំទី៤ យើងខ្ញុំទាំងពីរនាក់បានទទួលឱកាសក្នុងការសរសេរសារណាក្រោមប្រធានបទ **ប្រភេទនៃទោសព្រហ្មទណ្ឌ** ហេតុដែលពួកយើងបានជ្រើសរើសប្រធានបទមួយនេះដោយសារតែពួកយើងមានគោលបំណងឲ្យប្រជាជនកម្ពុជា ក៏ដូចជានិស្សិត បញ្ញវន្តបានយល់ដឹងឱ្យកាន់តែច្បាស់ និងស៊ីជម្រៅពីបញ្ហាផ្សេងៗពាក់ព័ន្ធទៅនឹងប្រភេទនៃទោសព្រហ្មទណ្ឌ ថាតើទោសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌមានប៉ុន្មានប្រភេទ តើប្រភេទនៃទោសព្រហ្មទណ្ឌនីមួយៗច្បាប់បានកំណត់យ៉ាងដូចម្ដេច ម្យ៉ាងវិញទៀតនៅពេលដែលបុគ្គលណាម្នាក់បានប្រព្រឹត្តអំពើមួយកំណត់ថាជាបទល្មើសព្រហ្មទណ្ឌ ថាតើបុគ្គលនោះត្រូវទទួលទោសយ៉ាងដូចម្ដេច? រួមទាំងមានគោលការណ៍អ្វីខ្លះដែលត្រូវអនុវត្តទោសទៅលើបុគ្គលជារូបវ័ន្តបុគ្គល ឬនីតិបុគ្គលយ៉ាងដូចម្ដេច? រួមទាំងមានលក្ខខណ្ឌអ្វីខ្លះដែលអាចឲ្យចៅក្រមអាចប្រកាសទោសទាំងនោះបាន? មិនតែប៉ុណ្ណោះនៅពេលដែលបុគ្គលនោះបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយដែលត្រូវទទួលទណ្ឌកម្ម សួរថាតើបុគ្គលនោះត្រូវទទួលបានស្ថានសម្រាលទោស ឬមានលក្ខខណ្ឌណាមួយអាចត្រូវទទួលស្ថានទម្ងន់ទោសក្នុងអំពើរបស់ខ្លួនបានប្រព្រឹត្ត? លើសពីនេះទៅទៀតសារណាមួយនេះអាចលេចចេញជារូបរាងទៅបាន ដោយសារមានការជួយណែនាំ ផ្ដល់អនុសាសន៍ និងកែតម្រូវផ្សេងៗ ដោយលោកសាស្ត្រាចារ្យ **ញឹក ឧុទ្ធី** ដែលលោកគ្រូ បានខិតខំចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីជួយកែលំអចំណុចខ្វះខាតសារណាមួយនេះ ។

ជាចុងក្រោយយើងខ្ញុំបានធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់កិច្ចការមួយនេះ យ៉ាងយកចិត្តទុកដាក់ យ៉ាងណាក៏ដោយ ក៏យើងខ្ញុំជឿថានៅតែមានចំណុចខ្វះខាតមួយចំនួន ត្រង់ចំណុចណាមួយមិនខាននោះទេ។ ហេតុនេះហើយយើងខ្ញុំទាំងពីរក៏សូមខន្តីអភ័យទោសនូវរាល់ចំណុចខុសឆ្គងទាំងឡាយណា ដែលបានសរសេរទៅហើយមានការខ្វះខាត ខុសឆ្គងនៅត្រង់ពាក្យពេចន៍សម្ដីណាមួយ ដែលកើតចេញពីកំហុសអចេតនានៅការស្រាវជ្រាវមួយនេះ យើងខ្ញុំសូមទទួលនូវរាល់ការរិះគន់ ដើម្បីស្ថាបនា និងកែលម្អ ដើម្បីកិច្ចការស្រាវជ្រាវមួយនេះមានភាពកាន់តែល្អប្រសើរឡើង និងអាចជាប្រយោជន៍បាន។

ចុងក្រោយយើងខ្ញុំទាំងពីរ ដែលជាអ្នកសរសេរកិច្ចការស្រាវជ្រាវមួយនេះ សង្ឃឹមយ៉ាងមុតមាំថា កិច្ចការស្រាវជ្រាវនេះ អាចជាពុទ្ធិ ឬជាឯកសារមួយសម្រាប់ជំនួយស្មារតីដល់មិត្តអ្នកអាន និងចូលរួមឱ្យប្អូនៗនិស្សិតដែលសរសេរជំនាន់ក្រោយៗ ពាក់ព័ន្ធនឹងប្រធានបទ **ប្រភេទនៃទោសព្រហ្មទណ្ឌ** អាចយកធ្វើជាគំរូនៃការ

សិក្សាស្រាវជ្រាវជាបន្តបន្ទាប់ទៀតបានដោយសារតែប្រធានបទមួយនេះបានជួយដល់ប្អូនជំនាន់ក្រោយឲ្យយល់ដឹងឲ្យកាន់ តែច្បាស់ពីប្រភេទនៃគោលការណ៍ឯកត្តកម្មនៅក្នុងរឿងព្រហ្មទណ្ឌ។

## មាតិកា

**សេចក្តីផ្តើម**......................................................................................................

**ជំពូកទី១**

**ទោសដែលត្រូវអនុវត្តចំពោះរូបវ័ន្តបុគ្គល**

**ផ្នែកទី១៖ មូលទោស**

**កថាភាគទី១៖ ប្រភេទនៃមូលទោស** ..............................................................................

១. ទោសដាក់ពន្ធនាគារ.........................................................................................

២. ទោសពិន័យជាប្រាក់ .........................................................................................

**កថាភាគទី២៖ ការប្រកាសទោស**...................................................................................

១. ការប្រកាសទោសចំពោះនីតិជន ..........................................................................

២. ការប្រកាសទោសចំពោះអនីតិជន .......................................................................

២.១. អនិតិជនអាយុក្រោម១៤ឆ្នាំ .......................................................................

២.២. អនិតិជនអាយុចាប់ពី១៤ឆ្នាំ ដល់ក្រោម១៨ឆ្នាំ.................................................

**ផ្នែកទី២៖ ទោសបន្ថែម**

**កថាភាគទី១៖** ប្រភេទនៃទោសបន្ថែមទាំង១៩ចំណុចក្នុងក្រមព្រហ្មទណ្ឌ..................................

**កថាភាគទី២៖** ការប្រកាសទោសបន្ថែម .........................................................................

**កថាភាគទី៣៖** លក្ខខណ្ឌការប្រកាសទោសបន្ថែម ..............................................................

១. ការប្រកាសទោសបន្ថែមចំពោះនីតិជន.................................................................

២. ការប្រកាសទោសបន្ថែមចំពោះអនីតិជន ..............................................................

២.១. អនិតិជនអាយុក្រោម១៤ឆ្នាំ .......................................................................

២.២. អនិតិជនអាយុចាប់ពី១៤ឆ្នាំ ដល់ក្រោម១៨ឆ្នាំ.................................................

**ផ្នែកទី៣៖ ទោសជំនួស**

**កថាភាគទី១៖** ប្រភេទនៃទោសជំនួស .............................................................................

១. ទោសការងារសហគមន៍.........................................................................................

១.១. និយមន័យនៃទោសការងារសហគមន៍.........................................................

១.២. អ្នកមិនទទួលប្រយោជន៍នៃទោសការងារសហគមន៍.........................................

១.៣. របបគតិយុត្តិនៃទោសការងារសហគមន៍ .....................................................

១.៤. គោលការណ៍ជុសជុលការខូចខាតដល់អ្នកដទៃ......................................................
២. ការស្តីបន្ទោស ...........................................................................................................
២.១. និយមន័យនៃការស្តីបន្ទោស..............................................................................
២.២. របបគិតយុត្តិនៃការស្តីបន្ទោស ..........................................................................
**កថាភាគទី២៖** ការប្រកាសទោសជំនួស .........................................................................
១. ការប្រកាសទោសការងារសហគមន៍ .............................................................................
១.១. ការប្រកាសទោសការងារសហគមន៍ចំពោះនីតិជន ..................................................
១.២. ការប្រកាសទោសការងារសហគមន៍ចំពោះអនីតិជន...............................................
ក. អនិតិជនអាយុក្រោម១៤ឆ្នាំ.........................................................................
ខ. អនិតិជនអាយុចាប់ពី១៤ឆ្នាំ ដល់ក្រោម១៨ឆ្នាំ ...................................................
២. ការប្រកាសការស្តីបន្ទោស .........................................................................................
២.១. ការប្រកាសការស្តីបន្ទោសចំពោះនីតិជន ...............................................................
២.២. ការប្រកាសការស្តីបន្ទោសចំពោះអនីតិជន ..........................................................
ក. អនិតិជនអាយុក្រោម១៤ឆ្នាំ.........................................................................
ខ. អនិតិជនអាយុចាប់ពី១៤ឆ្នាំ ដល់ក្រោម១៨ឆ្នាំ ...................................................

**<u>ជំពូកទី២</u>**

**ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល**

**ផ្នែកទី១៖ មូលទោសសម្រាប់នីតិបុគ្គល** ............................................................
**ផ្នែកទី២៖ ទោសបន្ថែមទាំង១៤ចំណុចក្នុងក្រុម** .........................................................
**ផ្នែកទី៣៖ ការប្រកាសទោស**.............................................................................................
**កថាភាគទី១៖** ចំពោះនីតិបុគ្គលសាធារណៈ ........................................................................
**កថាភាគទី២៖** ចំពោះនីតិបុគ្គលឯកជន...............................................................................
**កថាភាគទី៣៖** មូលទោសសម្រាប់នីតិបុគ្គល .........................................................................
**កថាភាគទី៤៖**ទោសបន្ថែមទាំង១៤ចំណុចក្នុងក្រុម.................................................................

## ជំពូកទី៣

## ស្ថានទម្ងន់ទោស និងស្ថានសម្រាលទោស


**ផ្នែកទី១៖ ស្ថានទម្ងន់ទោស** ....................

**កថាភាគទី១៖ ចរិកលក្ខណៈនៃស្ថានទម្ងន់ទោស**....................

១. ក្រុមមានការចាត់តាំង ....................

២. ការគិតទុកជាមុន....................

៣. ការកាប់គាស់ទម្លុះទម្លាយ....................

៤. ការផ្លោះរបងចូល ....................

៥. អាវុធ និងវត្ថុដែលត្រូវបានចាត់ទុកដូចអាវុធ....................

៦. ការពួនស្ទាក់ ....................

**កថាភាគទី២៖ ការមិនរាងចាល** ....................

១. អានុភាពនៃការមិនរាងចាល....................

២.លក្ខខណ្ឌនៃការមិនរាងចាល....................

**ផ្នែកទី២៖ ស្ថានសម្រាលទោស**....................

**កថាភាគទី១៖ និយមន័យនៃស្ថានសម្រាលទោស**....................

**កថាភាគទី២៖** អានុភាពនៃស្ថានសម្រាលទោស ....................

**កថាភាគទី៣៖** ទោសដាក់ពន្ធនាគារអស់មួយជីវិត និងស្ថានសម្រាលទោស....................

**សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍**

**សេចក្តីសន្និដ្ឋាន**....................

**ការផ្តល់អនុសាសន៍** ....................

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

បច្ចុប្បន្ននៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រមព្រហ្មទណ្ឌថ្មី នៃព្រះរាជាណាចក្រកម្ពុជាយើង ត្រូវបានព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាទ្រង់ឡាយព្រះហត្ថលេខា ប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩ ដែលមានចំនួន ០៦គន្ថី ស្មើនឹង៦៧២ មាត្រា ។

ក្រមនេះហាក់ដូចជាការកម្រិតនូវដែនកំណត់សិទ្ធិរបស់បុគ្គលគ្រប់រូបនៅក្នុងសង្គម ដែលបានចងភ្ជាប់គ្នាតាមរយះកិច្ចសន្យាសង្គមនេះឯង មួយវិញទៀតវាអាចជួយអោយបុគ្គលម្នាក់ៗបានដឹងអំពីសិទ្ធិ ឬសកម្មភាពណាខ្លះគួរធ្វើ និងសិទ្ធិ ឬសកម្មភាពណាខ្លះមិនគួរធ្វើ កាលណាជនណាម្នាក់បានប្រើប្រាស់សិទ្ធិ ឬធ្វើសកម្មភាពដែលលើសពីដែនកំណត់នឹងត្រូវទទួលទណ្ឌកម្ម ។

គ្រប់បុគ្គលដែលរស់នៅក្នុងសង្គមទាំងអស់ គ្មាននរណាម្នាក់អាចនិយាយបានថាខ្លួនមិនបានដឹងអំពីច្បាប់នោះទេ ដូច្នេះហើយបានជាក្រសួងយុត្តិធម៌បានសហការជាមួយក្រសួងព័ត៌មាន ដើម្បីធ្វើការផ្សព្វផ្សាយក្រមព្រហ្មទណ្ឌនេះ ដល់ប្រជាពលរដ្ឋយើងទូទាំងប្រទេសឱ្យបានយល់ដឹង យើងខ្ញុំសូមអនុញ្ញាតជម្រាបជូនផងដែរថាការផ្សព្វផ្សាយក្រមព្រហ្មទណ្ឌនេះ គឺជាការចូលរួមចំណែកអនុវត្តនយោបាយកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ហើយក៏ជាការអនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាអតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយសម្តេចបានណែនាំដល់ក្រសួងយុត្តិធម៌ថា ត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងបានជ្រួតជ្រាបទៅដល់ប្រជាជនកម្ពុជាទាំងអស់ ដើម្បីនាំគ្នាចូលរួមអនុវត្តច្បាប់ព្រហ្មទណ្ឌនេះឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។

ក្រោយពីព្រះករុណាព្រះបាទសម្តេច **ព្រះបរមនាថ នរោត្តម សីហមុនីព្រះមហាក្សត្រ** ជាម្ចាស់ជីវិតតម្កល់លើត្បូង នៃព្រះរាជាណាចក្រកម្ពុជាទ្រង់បានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើកាលពីចុងឆ្នាំ២០០៩ រួចមកសួរថាតើក្រមព្រហ្មទណ្ឌចូលជាធរមាន និងមានអានុភាពអនុវត្តចាប់ពីពេលណាមក? ទាក់ទងជាមួយនឹងការចូលជាធរមាន ក៏ដូចជាការអនុវត្តក្រមព្រហ្មទណ្ឌនេះបើយើងគិតអំពីគោលការណ៍ដែលកំណត់នៅក្នុងមាត្រា ៩៣ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជារបស់យើង ក្រមព្រហ្មទណ្ឌនេះបានចូលជាធរមាននៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០០៩ បានន័យថា ២០ (ម្ភៃ) ថ្ងៃ ក្រោយពីថ្ងៃប្រកាសឱ្យប្រើគឺត្រូវចូលជាធរមាននៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ប៉ុន្តែទាក់ទងទៅនឹងការអនុវត្តនូវក្រមព្រហ្មទណ្ឌថ្មីនេះ បើផ្អែកទៅលើបញ្ញត្តិដែលកំណត់នៅក្នុងមាត្រា ៦៧២ បានចែងថា "លើកលែងតែបទប្បញ្ញត្តិទូទៅនៃគន្ថីទី ១ (បទប្បញ្ញត្តិទូទៅ) នៃក្រមនេះ ដែលត្រូវយកទៅអនុវត្តភ្លាមក្រោយការចូលជាធរមាននៃក្រមនេះ បទប្បញ្ញត្តិដទៃទៀតត្រូវយកទៅអនុវត្តក្នុងរយៈពេល ១ ឆ្នាំ ក្រោយការចូលជា

ធរមាននៃក្រមនេះ។ ដូច្នេះយើងត្រូវតែធ្វើជាពីរដំណាក់កាលតាមក្រមព្រហ្មទណ្ឌគឺ នៅដំណាក់កាលទី១ គឺអនុវត្តនូវបទប្បញ្ញត្តិទូទៅដែលមានចែងនៅក្នុងគន្ថីទី១ស្តីអំពីបទប្បញ្ញត្តិទូទៅ ដោយមានទាំងអស់ចំនួន ១៨២ មាត្រា គិតចាប់ពីមាត្រា ១ ដល់មាត្រា ១៨២ ដែលត្រូវអនុវត្តភ្លាមក្រោយពីការចូលជាធរមាននៃក្រមនេះ។ ដូច្នេះហើយបទប្បញ្ញត្តិនៃគន្ថីទី១ នេះត្រូវបានអនុវត្តតាំងពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ នៅទូទាំងប្រទេសកម្ពុជាមកម្ល៉េះ និងដំណាក់កាលទី២ ត្រូវអនុវត្ត ១ ឆ្នាំ ក្រោយចូលជាធរមាននៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។ ដូច្នេះក្រមនេះត្រូវអនុវត្តទាំងស្រុងនៅថ្ងៃទី២១ខែធ្នូ ឆ្នាំ២០១០។

ក្រមព្រហ្មទណ្ឌត្រូវបានចាត់ទុកថាជាច្បាប់ទូទៅ ហើយក៏មានច្បាប់ពិសេសផ្សេងៗទៀតដែលត្រូវយកមកអនុវត្តទន្ទឹមគ្នាផងដែរ ដូចជាច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជនផល ច្បាប់ស្តីពីរបបសារព័ត៌មាន ជាដើម។ ជារួមមក ក្រមព្រហ្មទណ្ឌរមែងចែងពីបទល្មើស ទោស និងការទទួលខុសត្រូវចំពោះបទល្មើស។

គួរយ៉ាង គោលការណ៍ឯកត្តកម្មនៅក្នុងរឿងព្រហ្មទណ្ឌ គឺជាគោលការណ៍ដែលមានកំណត់នៅក្នុងបទបញ្ញត្តិទូទៅនៃក្រមព្រហ្មទណ្ឌ ដែលស្ថិតនៅក្នុងគន្ថីទី១ ដូច្នេះគោលការណ៍ឯកត្តកម្មនេះ ត្រូវបានគេយកទៅអនុវត្តភ្លាមក្រោយការប្រកាសចូលជាធរមានដូចបានរៀបរាប់ខាងលើមក។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ជាគោលការណ៍ បុគ្គលណាដែលបានប្រព្រឹត្តនូវបទល្មើសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ច្បាប់ព្រហ្មទណ្ឌនឹងដាក់ទណ្ឌកម្មទៅលើបុគ្គលនោះ ទៅតាមទោសដែលច្បាប់បានកំណត់ជាធរមាន ម្យ៉ាងវិញទៀតទោសនោះត្រូវបានច្បាប់បែងចែកទៅតាមប្រភេទនៃទោសព្រហ្មទណ្ឌនីមួយៗ ដូចមានចែងក្នុងមាត្រា ៤៣ ដល់មាត្រា ៧៦ នៃក្រមព្រហ្មទណ្ឌ ។

មួយវិញទៀត ជាគោលការណ៍នៅក្នុងការសម្រេចសេចក្តីនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ចៅក្រមជាបុគ្គលដែលមានអំណាចឆន្ទានុសិទ្ធិ នៅក្នុងការវិនិច្ឆ័យសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌ ចំពោះបទល្មើសណាមួយលើបុគ្គលណាម្នាក់ ដើម្បីឱ្យមានភាពត្រឹមត្រូវ និងយុត្តិធម៌ តម្រូវឱ្យចៅក្រមនោះធ្វើការវិនិច្ឆ័យដោយពិចារណាស្របតាមលក្ខខណ្ឌមួយចំនួនដែលកំណត់ដោយច្បាប់។ ដូច្នេះហើយបានជា ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិនូវប្រភេទនៃទោសព្រហ្មទណ្ឌ ស្ថានទម្ងន់ទោស ស្ថានសម្រាលទោស និងរបបនៃការប្រកាសទោសព្រហ្មទណ្ឌ ដើម្បីផ្តល់ជាមូលដ្ឋានដល់ចៅក្រមក្នុងការយកមកពិចារណា វិនិច្ឆ័យ ដើម្បីកំណត់អំពីទំហំនៃទោសព្រហ្មទណ្ឌ ដែលនឹងត្រូវប្រកាសចំពោះជនជាប់ចោទ តើកាលៈទេសៈបែបណាជនជាប់ចោទត្រូវទទួលបានស្ថានសម្រាលទោស និងការប្រព្រឹត្តបែបណាត្រូវទទួលស្ថានទម្ងន់ទោស ។

## ៣. គោលបំណងនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវនូវប្រធានបទមួយនេះ ធ្វើឡើងក្នុងគោលបំណង ដើម្បីសិក្សាស្វែងយល់អំពីទោសព្រហ្មទណ្ឌ ប្រភេទនៃទោសព្រហ្មទណ្ឌ និងការប្រកាសទោសព្រហ្មទណ្ឌ ចំពោះបទល្មើសព្រហ្មទណ្ឌដែលបានប្រព្រឹត្តដោយបុគ្គលណាម្នាក់ ដែលប្បញ្ញត្តិច្បាប់បានកំណត់ទុកជាមុន ហើយកាលៈទេសៈបែបណាមានស្ថានទម្ងន់ទោស និងកាលៈទេសៈបែបណាទទួលបានស្ថានសម្រាលទោស ក៏ដូចជា ពង្រឹង និងពង្រីកនូវសមត្ថភាពចំណេះដឹងផ្ទាល់ខ្លួនបន្ថែមទៀត ដែលទាក់ទងនឹងវិស័យព្រហ្មទណ្ឌផងដែរ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ជាការឆ្លើយតបទៅនឹងបញ្ហាខាងលើ យើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវ និងស្វែងរកឯកសារបន្ថែមដើម្បីសរសេរសារណានេះឡើង។ ក្នុងនោះរួមមានដូចជា ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៩ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៩២ និងរួមទាំងឯកសារដែលពាក់ព័ន្ធមួយចំនួនទៀត ដូចដែលបានលើកឡើងនៅក្នុងឯកសារយោង។ នៅក្នុងការសិក្សាស្រាវជ្រាវនេះដែរ យើងខ្ញុំសូមផ្តោតតែទៅលើច្បាប់ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ប្រធានបទខាងលើនេះ មានសារៈប្រយោជន៍ និងអាចក្លាយជាទុនមួយសម្រាប់ជាឯកសារជំនួយស្មារតីដល់អ្នកអានគ្រប់រូប ព្រមទាំងដើម្បីទុកជាឯកសារដល់សិស្សនិស្សិតជំនាន់ក្រោយៗ អាចយល់ដឹងកាន់តែច្បាស់អំពីគោលការណ៍ឯកត្តកម្មសំខាន់ៗដែលមានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

សារណានេះ ត្រូវបានរៀបរៀងដោយប្រើប្រាស់នូវវិធីសាស្ត្របែបពណ៌នា និងវិភាគ។ ចំពោះការប្រមូលទិន្នន័យ និងឯកសារនានាដែលទាក់ទងនឹងការសិក្សាស្រាវជ្រាវនៃប្រធានបទនេះ យើងខ្ញុំបានស្វះស្វែងរកពត៌មាន និងដកស្រង់ចេញពីប្រភពល្អៗ និងច្បាស់លាស់ ព្រមទាំងច្បាប់សំខាន់ៗរបស់ព្រះរាជា-ណាចក្រកម្ពុជា ក៏ដូចជាឯកសារដែលពាក់ព័ន្ធមួយចំនួនទៀតផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងប្រធានបទសារណាខាងលើនេះ យើងខ្ញុំសូមធ្វើការបែងចែកចេញជា ៣ (បី) ជំពូកធំៗគឺៈ

ជំពូកទី១៖ ទោសដែលត្រូវអនុវត្តចំពោះរូបវន្តបុគ្គល

ជំពូកទី២៖ ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល

ជំពូកទី៣៖ ស្ថានទម្ងន់ទោស និងស្ថានសម្រាលទោស។

# ជំពូកទី១៖

# ទោសដែលត្រូវអនុវត្តចំពោះរូបវ័ន្តបុគ្គល

# ជំពូកទី១៖
# ទោសដែលត្រូវអនុវត្តចំពោះរូបវ័ន្តបុគ្គល

## ផ្នែកទី១៖ មូលទោស

ទោសព្រហ្មទណ្ឌ គឺជាប្រតិកម្មរបស់សង្គម ឬក៏ជាការឆ្លើយតបរបស់សង្គមទៅនឹងអ្នកប្រព្រឹត្តបទល្មើស បានន័យថាប្រឆាំងជាមួយនឹងចារីនៃបទល្មើស។ ចំណែកឯបទល្មើស គឺជាអំពើប្រឆាំងនឹងរដ្ឋ អំពើដែលនាំឲ្យមានគ្រោះថ្នាក់ដល់សង្គម អំពើដែលប្រឆាំងនឹងច្បាប់ព្រហ្មទណ្ឌជាធរមាន នឹងត្រូវផ្តន្ទាទោសក្នុងបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ។[1]

មូលទោស គឺជាទោសមូលដ្ឋាន ដែលចៅក្រមយកទៅប្រើប្រាស់សម្រាប់ការប្រកាសទោសចំពោះជនជាប់ចោទ ដែលបានប្រព្រឹត្តបទល្មើស។[2]

អនុលោមតាមមាត្រា **៤៣** នៃក្រមព្រហ្មទណ្ឌ មូលទោសបានបែងចែកជាពីរប្រភេទគឺ មូលទោសជាទោសដាក់ពន្ធនាគារ និងមូលទោសពិន័យជាប្រាក់។[3]

យោងតាមមាត្រា ៤៤ នៃក្រមព្រហ្មទណ្ឌ នៅពេលដែលបទល្មើសមួយត្រូវផ្តន្ទាទោសឱ្យជាប់ពន្ធនាគារ ឬឱ្យបង់ប្រាក់ពិន័យ ច្បាប់ព្រហ្មទណ្ឌបានកំណត់ពីកម្រិតអប្បបរមា និងអតិបរមា នៃទោសពន្ធនាគារ និងទោសពិន័យជាប្រាក់ដែលត្រូវទទួលរង ។ ក៏ប៉ុន្តែកម្រិតអប្បបរមា និងអតិបរមានេះអាចជូនកាលបន្ថែមទម្ងន់ ឬកាត់បន្ថយ នៅក្នុងលក្ខខណ្ឌទាំងឡាយដែលមានចែងតាមប្បញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌ ។[4]

***សំណួរ៖ តើហេតុអ្វីបានជាប្រទេសកម្ពុជាមិនមានទោសប្រហារជីវិត?***

ជាការពិតណាស់ ចំពោះទោសប្រហារជីវិត គឺជាទោសមួយប្រើសម្រាប់ដាក់ទណ្ឌកម្មលើបុគ្គលណាដែលបានប្រព្រឹត្តបទល្មើសឧក្រិដ្ឋធ្ងន់ធ្ងរបំផុត តួយ៉ាងយើងឃើញថាប្រទេសផ្សេងៗនៅលើពិភពលោកដូចជាប្រទេសវៀតណាម ប្រទេសមីយ៉ាន់ម៉ា ជាដើម ដែលច្បាប់នៃប្រទេសនេះគឺមានទោសប្រហារជីវិត ប៉ុន្តែនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា **៣២** បានកំណត់ពីការលុបចោលនៃទោសប្រហារជីវិត ដូច្នេះប្រទេសកម្ពុជាពុំអនុវត្តនូវទោសប្រហារជីវិតឡើយ ពោលគឺមានតែទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់តែប៉ុណ្ណោះ។[5]

---

[1] សន្ទានុក្រមពាក្យច្បាប់ ផ្នែកព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០១១ លេខរៀងទី១៦៦ ។

[2] សន្ទានុក្រមពាក្យច្បាប់ ផ្នែកព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០១១ លេខរៀងទី១៩៩ ។

[3] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៤៣ ។

[4] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៤៤ ។

[5] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣ ,មាត្រា ៣២ ។

## កថាភាគទី១៖ ប្រភេទនៃមូលទោស

### ១.ទោសដាក់ពន្ធនាគារ

ទោសដាក់ពន្ធនាគារ គឺជាទោសគុក ទោសដែលត្រូវបានបំបាត់ស្ទើរទាំងអស់នូសេរីភាពជាមូលដ្ឋាន ដោយមានការកំណត់កាល។[6]

ស្របជាមួយគ្នានេះដែរ នៅក្នុងការកំណត់ពីទោសដាក់ពន្ធនាគារ ច្បាប់ត្រូវបានកំណត់ពីកម្រិតអប្បបរមា និងអតិបរមានៃទោស។

ទោសដាក់ពន្ធនាគារ អាចជាទោសដាក់ពន្ធនាគារអស់មួយជីវិត ឬជាទោសដាក់ពន្ធនាគារមានរយៈពេលកំណត់ (ចាប់ពី១ថ្ងៃ រហូតដល់ទៅ៣០ឆ្នាំ) ។[7]

អនុលោមតាមមាត្រា ៤៩ នៃក្រមព្រហ្មទណ្ឌ ទោសដាក់ពន្ធនាគារ ១ថ្ងៃ ត្រូវគិត ២៤ម៉ោង ទោសដាក់ពន្ធនាគារ ១ខែ ត្រូវគិត ៣០ថ្ងៃ ទោសដាក់ពន្ធនាគារលើសពី ១ខែ ត្រូវគិតតាមចំនួនថ្ងៃជាក់ស្តែងដែលមាននៅក្នុងខែនោះ ចំណែកឯទោសដាក់ពន្ធនាគារ ១ឆ្នាំ ត្រូវគិត ១២ខែ ។[8]

ចំពោះទណ្ឌិតបានទទួលរងទោសនៅក្នុងពន្ធនាគារចប់សព្វគ្រប់ តាមថិរវេលាដូចបានកំណត់នៅក្នុងសេចក្តីសម្រេចផ្តន្ទាទោសហើយ ជាគោលការណ៍ទណ្ឌិតត្រូវដោះលែងឲ្យមានសេរីភាពវិញ ប៉ុន្តែទណ្ឌិតដែលទោសរបស់ខ្លួនត្រូវបញ្ចប់នៅថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកផ្សេងៗទៀតដែលច្បាប់ ឬបទដ្ឋានគតិយុត្តបានកំណត់ត្រូវតែដោះលែងឲ្យមានសេរីភាពវិញនៅមុនថ្ងៃឈប់សម្រាកនោះ។[9]

***ឧទាហរណ៍៖*** កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ នៅចំណុចមុខធនាគារ MAY BANK អាគារលេខ ៤៣ ផ្លូវព្រះនរោត្តម ភូមិ០៩ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ មានករណី៖ លួចមានស្ថានទម្ងន់ទោស (ឆក់ខ្សែរក) មួយបានកើតឡើង ដែលបង្កឡើងដោយឈ្មោះ **(ក)** និងឈ្មោះ **(ខ)** (គេចខ្លួន) ។ ដោយឈ្មោះ **(ខ)** ជាអ្នកបើកម៉ូតូហើយឈ្មោះ **(ក)** ជាអ្នកអង្គុយពីក្រោយ លុះជិះមកដល់ចំណុចកើតហេតុខាងលើឈ្មោះ **(ខ)** បានឲ្យឈ្មោះ **(ក)** ចុះពីលើម៉ូតូទៅឆក់ខ្សែរកពីជនរងគ្រោះឈ្មោះ **(គ)** តែជនរងគ្រោះក៏បានដឹងខ្លួនទាន់ហើយក៏បានស្រែក ភ្លាមនោះឈ្មោះ **(ក)** ត្រូវបានប្រជាពលរដ្ឋឃាត់ខ្លួននៅកន្លែងកើតហេតុ រួចនាំទៅប៉ុស្តិ៍នគរបាលរដ្ឋបាលផ្សារថ្មី៣ ដើម្បីសាកសួរ ចំណែកឯឈ្មោះ **(ខ)** រត់គេចខ្លួនបាត់ទៅ ។

[6] សន្ទានុក្រមពាក្យច្បាប់ ផ្នែកព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០១១ លេខរៀងទី៤៩ ។

[7] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣០៣។

[8] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៤៩ ។

[9] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៥០ ។

**ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចផ្ដន្ទាទោសឈ្មោះ (ក) ដាក់ពន្ធនាគារចំនួន ០៣ (បី) ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោស តាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។** [10]

**១.ទោសពិន័យជាប្រាក់**

ទោសពិន័យជាប្រាក់ ជាទោសដែលតម្រូវឲ្យទណ្ឌិតបង់ចំនួនប្រាក់ដែលកំណត់ដោយច្បាប់ ហើយទឹកប្រាក់នេះត្រូវកំណត់ជាប្រាក់រៀល ។ ប្រាក់ជាផលនៃពិន័យនេះត្រូវបង់ចូលជាថវិការរដ្ឋ ដោយត្រូវយកទៅទុកក្នុងធនាគារជាតិ។[11]

***ឧទាហរណ៍៖*** កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ ឈ្មោះ (ក) បានបើកម៉ូតូមួយគ្រឿង ម៉ាក HONDA C125 ពណ៌ខ្មៅ ពាក់ផ្លាកលេខ កំពង់ចាម 1K-6025 ជាមួយអ្នករួមដំណើរឈ្មោះ **(គ)** បានធ្វើដំណើរបញ្រ្ចាសទិសចរាចរណ៍តាមបណ្ដោយ៣០ម៉ែត ទិសដៅពីជើងទៅត្បូង លុះមកដល់ចំណុចផ្លូវ៣០ម៉ែត្រ ប្រសព្វផ្លូវបេតុងភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ បានបុកជាមួយរថយន្ត០១ គ្រឿងម៉ាក HIGHLANDER ពណ៌ក្រហម ពាក់ផ្លាកលេខ ភ្នំពេញ 2AG 4690 បើកបរដោយឈ្មោះ **(ខ)** រួចរថយន្តរេចង្កូតទៅបុកខឿនមុខផ្ទះ បណ្ដាលឲ្យអ្នកបើកបរម៉ូតូ ម៉ាក HONDA C125 ឈ្មោះ **(ក)** ស្លាប់នៅកន្លែងកើតហេតុ ចំណែកអ្នករួមដំណើរឈ្មោះ **(គ)** រងរបួសធ្ងន់។

**ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចផ្ដន្ទាទោសឈ្មោះ (ខ) ពិន័យជាប្រាក់ចំនួន ៦,០០០,០០០ (ប្រាំមួយលាន) រៀល ពីបទ បើកបរក្នុងស្ថានភាពស្រវឹង តាមមាត្រា ៧៧ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ។** [12]

## កថាភាគទី២៖ ការប្រកាសមូលទោស

ជាគោលការណ៍ទូទៅនៃការប្រកាសទោស តុលាការអាចប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ទោស និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុក ទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមាយាទរបស់ជនល្មើសក្រោយពេលប្រព្រឹត្តបទល្មើស ជាអាទិ៍ ចំពោះជនរងគ្រោះ។[13]

ចំពោះបទល្មើសខ្លះ ក្រមព្រហ្មទណ្ឌតម្រូវឲ្យផ្ដន្ទាទោសដាក់ពន្ធនាគារផង និងទោសពិន័យជាប្រាក់ក៏ដោយ ក៏មិនមែនបានន័យថាតុលាការមានកាតព្វកិច្ចត្រូវតែប្រកាសទោសទោសទាំងពីរនេះជាមួយគ្នានោះដែរ។

---

[10] សាលក្រមសាលាដំបូងរាជធានីភ្នំពេញ,លេខ៥១៦(យ) ១៩ កក្កដា ឆ្នាំ២០២២។

[11] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៤៣ ។

[12] សាលក្រមសាលាដំបូងរាជធានីភ្នំពេញ,លេខ១២៣៤(យ) ២២ មីនា ឆ្នាំ២០២៤។

[13] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៩៦ ។

ក្នុងករណីបែបនេះ យោងតាមមាត្រា **៩៧** នៃក្រមព្រហ្មទណ្ឌ បានអនុញ្ញាតឲ្យតុលាការប្រកាសមូលទោសដូចខាងក្រោម៖

- ប្រកាសទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ជាមួយគ្នា ឬ
- ប្រកាសទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬ
- ប្រកាសទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ។[14]

## ១.ការប្រកាសមូលទោសចំពោះនីតិជន

អនុលោមតាមមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ បានកំណត់ពីនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌគឺចាប់ពីអាយុ ១៨ឆ្នាំ ឡើងទៅ ពោលគឺបុគ្គលដែលមានអាយុចាប់ពី ១៨ឆ្នាំ ឡើង គឺត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសណាមួយដែលខ្លួនបានប្រព្រឹត្ត ព្រមទាំងមានចែងយ៉ាងច្បាស់ពីទោសប្បញ្ញត្តិទៅតាមមាត្រានីមួយក្នុងក្រមព្រហ្មទណ្ឌ ។[15]

ជាគោលការណ៍ទូទៅ នៃគោលការណ៍ឯកត្តកម្មនៃទោស តុលាការអាចប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ទោស និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុក ទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើស ក្រោយពេលប្រព្រឹត្តបទល្មើស ជាអាទិ៍ ចំពោះជនរងគ្រោះ។[16]

ហេតុដូច្នេះយោងតាមមាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌ គោលការណ៍នៃការប្រកាសមូលទោស តុលាការអាចប្រកាសមូលទោសទោសចំពោះនីតិជនដែលមានអាយុចាប់ ១៨ឆ្នាំឡើងទៅ បានដូចខាងក្រោម៖

- ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ជាមួយគ្នា ឬ
- ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬ
- ទោសទោសពិន័យជាប្រាក់តែមួយមុខបុណ្ណោះ។

***ឧទាហរណ៍៖*** ឈ្មោះ (ក) បានប្រព្រឹត្តបទល្មើសជា **អំពើលួច** តាមមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១,០០០,០០០ (មួយលាន) រៀល ទៅ ៦,០០០,០០០ (ប្រាំមួយលាន) រៀល ។[17]

[14] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៩៧ ។

[15] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៣៨ ។

[16] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៩៦ ។

[17] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៣៥៦ ។

តាមឧទាហរណ៍ខាងលើ ចៅក្រមអាចប្រកាសទោសទៅលើឈ្មោះ (ក) បានដោយឆន្ទានុសិទ្ធិ ដោយផ្តន្ទាទោសដាក់តែទោសពន្ធនាគារ (ទោសគុក) តែមួយមុខប៉ុណ្ណោះ ឬដាក់តែទោសត្រឹមតែពិន័យជាប្រាក់ តែមួយមុខប៉ុណ្ណោះ ឬដាក់ទាំងទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ជាមួយគ្នា ។

ចំពោះអប្បបរមា ទៅអតិបរមា នូវរយៈពេលនៃការផ្តន្ទាទោសដាក់ពន្ធនាគារ និងចំនួនទឹកប្រាក់ពិន័យដែលច្បាប់បានកំណត់ ជាឆន្ទានុសិទ្ធិរបស់ចៅក្រម ក្នុងការសម្រេចសេចក្តីផ្អែកទៅគោលការណ៍ទូទៅនៃការប្រកាសទោស តាមមាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ និងប្បញ្ញត្តិដោយឡែកផ្សេងទៀតដែលច្បាប់បានកំណត់ពីការប្រកាសទោសព្រហ្មទណ្ឌ។

## ២.ការប្រកាសមូលទោសចំពោះអនីតិជន

### ២.១.អនីតិជនអាយុក្រោម១៤ឆ្នាំ

ចំពោះអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ជាគោលការណ៍ តុលាការពុំអាចប្រកាសមូលទោសដល់ជននេះបានទេ ពោលគឺជននេះមិនអាចត្រូវទទួលរងការផ្តន្ទាទោសណាមួយឡើយ ទោះបីជាជននេះបានប្រព្រឹត្តបទល្មើសប្រភេទណាមួយក៏ដោយ ក៏ប៉ុន្តែតុលាការអាចចាត់វិធានការណាមួយដូចមានចែងក្នុងមាត្រា ៤០ នៃក្រមព្រហ្មទណ្ឌបាន។

***វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភមានដូចជា៖***

- ការប្រគល់អនីតិជនឲ្យទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត។
- ការប្រគល់អនីតិជនឲ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន។
- ការប្រគល់អនីតិជនឲ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន។
- ការប្រគល់អនីតិជនឲ្យទៅមន្ទីពេទ្យ ឬស្ថាប័នឯកទេស។
- ការដាក់អនីតិជនឲ្យស្ថិតក្រោមការការពាររបស់តុលាការ។[18]

### ២.២.អនីតិជនអាយុចាប់ពី១៤ឆ្នាំ ដល់ក្រោម១៨ឆ្នាំ

សម្រាប់អនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំ ដល់ក្រោម១៨ឆ្នាំ តុលាការអាចប្រកាសមូលទោសទៅបាន ដោយមើលតាមតាមកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។

ស្របទៅនឹងបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ បានអនុញ្ញាឲ្យមានការឃុំខ្លួនជនត្រូវចោទ ឬជនជាប់ចោទជាបណ្តោះអាសន្ន ចំពោះអនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ក្នុងលក្ខខណ្ឌកំណត់ដោយច្បាប់ និងក្នុងថិរវេលាមួយតិចជាងការឃុំខ្លួនបណ្តោះអាសន្នលើនីតិជន។[19]

---

[18] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៤០ ។

[19] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២១៣ និងមាត្រា ២១៤ ។

ក្នុងន័យនេះដែល ក្រមព្រហ្មទណ្ឌក៏បានប្បញ្ញត្តិអំពីមូលទោសសម្រាប់អនុវត្តលើអនិតិជនដែលមាន អាយុចាប់ពី១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្ដាល
- ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយ មកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ។
- អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្ដាល ប្រសិនបើអប្បបរមានេះលើសពី ១ (មួយ) ថ្ងៃ។
- អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្ដាល

ក្នុងករណីដែលចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមថិរវេលាមួយស្មើ ឬតិចជាង ៥ (ប្រាំ) ឆ្នាំ នោះបទល្មើសដែលចោទប្រកាន់ នោះនៅតែជាបទឧក្រិដ្ឋដដែល។[20]

## ផ្នែកទី២៖ ទោសបន្ថែម

ទោសបន្ថែម គឺជាទោសដែលត្រូវបានបន្ថែមដោយចៅក្រម ទៅលើមូលទោស ពោលជាកម្មវិបាកនៃ មូលទោស ដែលមានគោលបំណងបំពេញបន្ថែមឲ្យមូលទោស ដើម្បីបង្ការការប្រព្រឹត្តបទល្មើសសារជាថ្មី។[21]

នៅមុនពេលក្រមព្រហ្មទណ្ឌថ្មីចូលជាធរមាន ទោសបន្ថែមនេះក៏មានវត្តមានរួចជាស្រេចនៅក្នុងច្បាប់ ព្រហ្មទណ្ឌអន្តរកាលដែលមាននៅមាត្រា ៦៣ថ្មី ចំណុចទី៤ ចែងថា តុលាការអាចបញ្ជាឲ្យបិទផ្សាយសេចក្តី សម្រេចរបស់ខ្លួននៅទីកន្លែងទាំងឡាយដែលតុលាការនឹងបញ្ជាក់ ដោយឲ្យជនជាប់ចោទទទួលបន្ទុកចេញ សោហ៊ុយ ហើយតុលាការអាចចុះផ្សាយសាលក្រមនេះក្នុងសារពត៌មានមួយ ឬច្រើនដោយឲ្យជនជាប់ចោទ ទទួលបន្ទុកចេញសោហ៊ុយរហូតដល់កម្រិតច្រើនបំផុត ១០,០០០,០០០រ (ដប់លាន) រៀល។ [22]

ជាមួយគ្នានេះដែរ មាត្រា ៩៣ នៃច្បាប់ស្តីពីជលផល បានប្បញ្ញត្តិថា ប្រសិនបើរូបវ័ន្តបុគ្គល ឬនីតិបុគ្គល ប្រព្រឹត្តបទល្មើសដូចមានចែងតាមច្បាប់នេះ នឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ និងពិន័យជាប្រាក់ មិនតែប៉ុណ្ណោះ ប្រសិនបើមានវត្ថុតាងនឹងត្រូវរឹបអូសជាសម្បត្តិរដ្ឋបន្ថែមទៀតផង។ ចំពោះការរឹបអូសនេះ គឺជាទោសបន្ថែម បន្ទាប់ពីមានការផ្តន្ទាទោសជាមូលទោស ។[23]

[20] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ១៦០ ។

[21] https://www.khsearch.com/qna/25552

[22] ច្បាប់ព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៩២,មាត្រា ៦៣ថ្មី ។

[23] ច្បាប់ស្តីពីជលផល នស នស/រកម/០១១,២១ ឧសភា ២០០៦,មាត្រា ៨៩ ។

ចំណែកនៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅក្នុងមាត្រា ៩៣ នៃច្បាប់នេះ បានកំណត់ថា គ្រឿងញៀនដែលចាប់យក ឬមិនទាន់បានបំផ្លាញចោល ឬមិនទាន់បានប្រគល់ឲ្យស្ថាប័នមានសមត្ថកិច្ច ទោះបីបទល្មើសមិនត្រូវបានចោទប្រកាន់ លើកលែងចោទប្រកាន់ ឬសម្រេចរួចផុតបទចោទប្រកាន់ ឬផ្តន្ទាទោសក៏ដោយ គឺត្រូវរឹបអូសដាច់ខាត ។[24]

ស្របជាមួយគ្នានេះដែរ ចៅក្រមអាចសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយ ឬច្រើន បានក្នុងករណីដែលមានចែងនៅមាត្រា ១០០ នៃក្រមព្រហ្មទណ្ឌ ។ បទប្បញ្ញត្តិនេះមានន័យថា ចៅក្រមអាចប្រកាសទោសបន្ថែមជាជំនួសមូលទោសបាន ដោយមិនចាំបាច់ប្រកាសមូលទោសទេ កាលបើលក្ខខណ្ឌដែលច្បាប់តម្រូវត្រូវបានបំពេញយ៉ាងច្បាស់លាស់ ។

***ឧទាហរណ៍៖*** ចំពោះបទល្មើស **បរិហារកេរ្តិ៍ជាសាធារណៈ** តាមមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ តុលាការអាចប្រកាសឲ្យផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារពត៌មាន ដែលជាទោសបន្ថែម ជាជំនួសឲ្យការផ្តន្ទាទោសពិន័យជាប្រាក់ក៏បានដែរ។ [25]

នៅក្នុងច្បាប់ដទៃទៀតដូចជា ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនជាដើម អ្នកនីតិបញ្ញត្តិប្រើប្រាស់ពាក្យទោសមានកំហិត និងទោសឥតកំហិត តែតាមការពិតទៅ ទោសមានកំហិតឬទោសឥតកំហិតមានលក្ខណៈដូចគ្នាទៅនឹងទោសបន្ថែមដែរ។

ទោសបន្ថែមមានកំហិត ឬខានមិនបានមានចែងចាប់ពីមាត្រា ៥១ ថ្មី ដល់មាត្រា ៥៤ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដែលចែងថា គ្រឿងញៀនទាំងឡាយណាដែលចាប់បានហើយមិនទាន់បានកំទេចចោលត្រូវតែរឹបអូស។ នេះគឺជាទោសបន្ថែមមានកំហិតដែលតុលាការត្រូវតែប្រកាសដោយខានមិនបាន។[26]

- **ទោសបន្ថែមឥតកំហិត**

ទោសបន្ថែមឥតកំហិត គឺជាទោសបន្ថែមដែលតុលាការប្រកាសក៏បាន មិនបាច់ប្រកាសក៏បានដែរ។ ទោសបន្ថែមឥតកំហិតមានដូចខាងក្រោម៖

-ការរឹបអូសឥតកំហិត ចំពោះឧបភោគភ័ណ្ឌ សម្ភារៈ និងចលនវត្ថុ ដែលមានក្នុងទីកន្លែងកើតបទល្មើស។

-ទោសបន្ថែមឥតកំហិតដែលមានចែងនៅមាត្រា ៦០ ថ្មី នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

សម្រាប់បទល្មើសដែលមានចែងក្នុងជំពូកទី១០ ទី១១ និងទី១២ ព្រមទាំងមាត្រា ៩៣ មាត្រា ៩៧ និងមាត្រា ៩៨ថ្មី នៃច្បាប់ ទោសបន្ថែមឥតកំហិត រួមមានដូចតទៅ:

---

[24] ច្បាប់ស្តីការត្រួតពិនិត្យគ្រឿងញៀន នស/រកម/០១១២/០០១,០២ មករា ២០១២,មាត្រា ៩៣ ។

[25] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១៧),១៣៧ ។

[26] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០០៥,មាត្រា ៥១ថ្មី ដល់មាត្រា ៥៤ថ្មី ។

-ហាមឃាត់ឲ្យចូលមកឬរស់នៅ នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាជាស្ថាពរ ឬសម្រាប់ចិរវេលាពី ១ឆ្នាំ ទៅ ៥ឆ្នាំ ចំពោះជនបរទេស។ ការដាក់ទណ្ឌកម្មនេះនាំទៅដល់ការបណ្តេញទណ្ឌិតចេញពីប្រទេស ក្រោយពីបានរងទោសដាក់ពន្ធនាគាររួចហើយ។ យោងតាមមាត្រា ៧៩ ថ្មី នៃច្បាប់នេះ ការហាមឃាត់ជាស្ថាពររស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា មិនអាចត្រូវលុបចោលទៅថ្ងៃក្រោយ។

-ហាមឃាត់ការស្នាក់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់ចិរវេលាពី ១ឆ្នាំ ទៅ ៥ឆ្នាំ។

-ដកសិទ្ធិពលរដ្ឋ សម្រាប់ចិរវេលាពី ១ឆ្នាំ ទៅ ៥ឆ្នាំ ប៉ុន្តែចិរវេលានេះមិនត្រូវឲ្យលើសពីចិរវេលាផ្តន្ទាទោសឡើយ ។

-មិនឲ្យចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងដកហូតលិខិតឆ្លងដែនសម្រាប់ចិរវេលាពី ១ឆ្នាំ ទៅ ៥ ឆ្នាំ។

-ហាមឃាត់ការបើកបរយានយន្តគ្រប់ប្រភេទ និងដកហូតលិខិតបើកបរ សម្រាប់ចិរវេលាពី ១ខែ ទៅ ៣ ឆ្នាំ។

-ហាមឃាត់ជាស្ថាពរ ឬសម្រាប់ចិរវេលាពី ១ឆ្នាំ ទៅ ៥ឆ្នាំ ប្រកបអាជីពដែលសាមីខ្លួនបានប្រព្រឹត្តល្មើសក្នុងពេលប្រកបអាជីពនោះ។

ក្នុងករណីទាំងឡាយដែលមានចែងក្នុងមាត្រា ៣២.១ថ្មី ដល់មាត្រា ៣៦ថ្មី និងមាត្រា ៣៧.២ ថ្មី ដល់មាត្រា ៤០ ថ្មី នៃច្បាប់នេះ ទោសបន្ថែមឥតកំហិតរួមមាន៖

-បិទទ្វារសម្រាប់ចិរវេលាពី ១ឆ្នាំ ទៅ ៥ឆ្នាំ ទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្តឡើងដោយអាជីវករ ឬដោយការសមគំនិតរបស់អាជីវករជាអាទិ៍ ចំពោះសណ្ឋាគារផ្ទះឈ្នួល មានចលនវត្ថុប្រើប្រាស់ស្រាប់ កន្លែងទទួលឲ្យនៅ និងបរិភោគ តៀមលក់ភេសជ្ជៈ ភោជនីយដ្ឋាន សមាគម កំសាន្ត កន្លែងរាំច្រៀង និងកន្លែងទស្សនីយភាព ឬសាខារបស់ទីតាំងនោះ ឬកន្លែងអ្វីមួយបើកសម្រាប់សាធារណជន ឬប្រើប្រាស់ដោយសាធារណជន។

-ដកហូតលិខិតអនុញ្ញាតឲ្យធ្វើអាជីវកម្ម ពី ១ឆ្នាំ ដល់ ៥ឆ្នាំ។[27]

ក្រៅពីនេះ ទោសបន្ថែមក៏ត្រូវបានចែងនៅក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលប្រកាសឲ្យប្រើនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដោយមាត្រា ៤៨ នៃច្បាប់បានចែងថា : ចំពោះបទល្មើសដែលមានចែងនៅក្នុងច្បាប់នេះ អាចត្រូវទទួលទោសបន្ថែមដូចតទៅ៖

-រឹបអូសឧបករណ៍សម្ភារៈ ឬវត្ថុទាំងឡាយដែលត្រូវបានប្រើប្រាស់ឬនឹងត្រូវប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស

- រឹបអូសសម្ភារៈទាំងឡាយដែលជាកម្មវត្ថុនៃបទល្មើស

- រឹបអូសប្រាក់ចំណូល ឬទ្រព្យដែលរកបាន ឬជាផលនៃបទល្មើស

[27] ច្បាប់ស្តីការត្រួតពិនិត្យគ្រឿងញៀន នស/រកម/០១១២/០០១,០២ មករា ២០១២,មាត្រា ៦០ថ្មី ។

-បិទការផលិតដែលបម្រើដល់ការប្រព្រឹត្តបទល្មើស

-ការដាក់កំហិតលើសិទ្ធិពលរដ្ឋ និង

-ការហាមឃាត់ការស្នាក់នៅ។[28]

## កថាភាគទី១៖ ប្រភេទនៃទោសបន្ថែមទាំង១៩ចំណុចក្នុងក្រមព្រហ្មទណ្ឌ

អនុលោមតាមមាត្រា ៥៣ នៃក្រមព្រហ្មទណ្ឌ បានចែងអំពីប្រភេទនៃទោសបន្ថែម ដែលមាន១៩ចំណុច រួមមាន៖

- **ការដកសិទ្ធិខ្លះជាពលរដ្ឋ**

សិទ្ធិពលរដ្ឋដែលអាចដកហូតបានមានចំនួន ៦ ប្រភេទគឺ :

-សិទ្ធិបោះឆ្នោត

-សិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត

-សិទ្ធិបំពេញការងារជាមន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈ

-សិទ្ធិទទួលការចាត់តាំងជាអ្នកជំនាញ ជាអាជ្ញាកណ្តាល ឬជាអាណត្តិគាហក របស់តុលាការ

-សិទ្ធិទទួល និងពាក់គ្រឿងឥស្សរិយយសទាំងអស់

-សិទ្ធិធ្វើជាសាក្សីដែលទទួលសម្បថនៅមុខតុលាការ[29]

ទោសបន្ថែមនេះត្រូវអនុវត្ត ក្រោយពេលបានទទួលរងទោសដាក់ពន្ធនាគាររួចហើយ លើកលែងតែមានសេចក្តីសម្រេចផ្សេងពីនេះរបស់តុលាការ ។ ទោសដកសិទ្ធិពលរដ្ឋអាចត្រូវប្រកាសជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេលយ៉ាងច្រើន ៥ (ប្រាំ) ឆ្នាំ ។

***ឧទាហរណ៍៖*** តុលាការបានសម្រេចធ្វើការផ្តន្ទាទោស សំខាន់ ពីបទ ប្រមាថទីបញ្ចុះសព ដោយសារតែសំខាន់ បានជីកគាស់ផ្នូរសពមួយបំផ្លាញចោល ដើម្បីយកដីធ្វើជាកម្មសិទ្ធិរបស់គាត់។ បន្ថែមលើមូលទោសតុលាការបានសម្រេចធ្វើការផ្តន្ទានូវទោសបន្ថែម ដោយដកសិទ្ធិក្នុងការឈរឈ្មោះឲ្យគេបោះឆ្នោតសម្រាប់រយៈពេល ៥ឆ្នាំ ។[30]

- **ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះបានប្រព្រឹត្តនៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ**

ក្នុងករណីដែលបទល្មើសបានប្រព្រឹត្តនៅក្នុងពេលដែលប្រកបវិជ្ជាជីវៈណាមួយ ទោសបន្ថែមអាចជាការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈនោះ តែការហាមឃាត់នេះមិនអនុវត្តទៅលើៈ

---

[28] ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨,មាត្រា ៤៨ថ្មី ។

[29] រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣,មាត្រា ៣៤ថ្មី ដល់មាត្រា ៥០។

[30] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣១១ ។

-ការបំពេញអាណត្តិដែលជ្រើសតាំងដោយការបោះឆ្នោតជាសាធារណៈ

***ឧទាហរណ៍៖*** ការបំពេញមុខងារជាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ខណ្ឌ ក្រុង ខេត្តរាជធានី ជាដើម។

-ការទទួលខុសត្រូវខាងសហជីព។

***ឧទាហរណ៍៖*** ការហាមឃាត់ធ្វើជាប្រតិភូបុគ្គលិក ឬប្រតិភូសហជីព តាមច្បាប់ស្តីពីការងារ។

–ចំពោះបទល្មើសរំលោភលើច្បាប់ស្តីពីរបបសារព័ត៌មាន។

***ឧទាហរណ៍៖*** អ្នកសារព័ត៌មានដែលបានប្រព្រឹត្តបទល្មើសបំពានលើច្បាប់ស្តីពីរបបសារព័ត៌មាន មិនអាចទទួលរងនូវទោសបន្ថែមហាមឃាត់ប្រកបវិជ្ជាជីវៈ ជាអ្នកសារព័ត៌មានបានឡើយ។

នៅក្នុងការប្រកាសទោសបន្ថែមនេះ តុលាការត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់ពីមុខរបរដែលត្រូវហាមឃាត់។ ទោសបន្ថែមខាងលើត្រូវអនុវត្ត ក្រោយពេលទទួលរងទោសដាក់ពន្ធនាគាររួចហើយ លើកលែងតែមានសេចក្តីសម្រេចផ្សេងពីនេះរបស់តុលាការ។ មិនតែប៉ុណ្ណោះ ទោសហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ អាចត្រូវប្រកាសជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេលយ៉ាងច្រើន ៥ឆ្នាំ ។

***ឧទាហរណ៍៖*** តុលាការបានសម្រេចផ្តន្ទាទោស ចិន្តា ដែលមានតួនាទីជាអភិបាលនៃក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតមួយ ពីបទ ស៊ីសំណូករបស់អភិបាល ដោយសារតែ ចិន្តា បានទទួលអំណោយពី រដ្ឋា ដើម្បីជួយសម្រួលឲ្យរដ្ឋាទទួលបានសិទ្ធិក្នុងការចុះកិច្ចសន្យាជាមួយនឹងក្រុមហ៊ុន។ ក្នុងករណីបែបនេះ ដោយបន្ថែមពីលើមូលទោស តុលាការអាចសម្រេចហាមឃាត់ ចិន្តា មិនឲ្យធ្វើជាអភិបាលនៃក្រុមហ៊ុនសម្រាប់រយៈពេល ៥ឆ្នាំ ក្រោយពីបានទទួលរងទោស ទោសដាក់ពន្ធនាគាររួចរាល់អស់ហើយ ។[31]

➢ **ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ**

ទោសបន្ថែមខាងលើត្រូវអនុវត្តក្រោយពេលបានទទួលរងនូវទោសដាក់ពន្ធនាគាររួចហើយ លើកលែងតែមានសេចក្តីសម្រេចផ្សេងពីនេះរបស់តុលាការ។ ទោសហាមឃាត់ចំពោះការបើកបរយានយន្ត គឺមិនត្រូវមានរយៈពេលឲ្យលើសពី ៥ឆ្នាំ ឡើយ ។

***ឧទាហរណ៍ ៖*** តុលាការបានសម្រេចផ្តន្ទាទោស កុសល ពីបទ លួច ដោយសារតែ កុសល និងមិត្តភក្តិបានជិះម៉ូតូឆក់យកកាបូបដៃរបស់ជនរងគ្រោះជាស្ត្រី ហើយក្នុងការធ្វើសកម្មភាពម្តងៗ កុសល តែងតែគេចខ្លួនបានយ៉ាងស្រួល ដោយសារតែភាពប៉ិនប្រសប់ក្នុងការបើកបរម៉ូតូគេចវេះពីការតាមចាប់ខ្លួន របស់សមត្ថកិច្ច។ ហេតុដូច្នេះ បន្ថែមពីលើមូលទោស តុលាការអាចសម្រេចហាមឃាត់ កុសល បើកបរយានយន្តគ្រប់ប្រភេទទាំងអស់សម្រាប់រយៈពេល ៥ឆ្នាំ ក្រោយពី កុសល បានទទួលរងទោសដាក់ពន្ធនាគាររួចរាល់អស់ហើយ ។[32]

➢ **ការព្យួរលិខិតបើកបរ**

---

[31] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣១២ ។

[32] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣១៣។

ទោសបន្ថែមខាងលើ ត្រូវអនុវត្តក្រោយពេលទទួលរងទោសដាក់ពន្ធនាគាររួចហើយ លើកលែងតែមានសេចក្តីសម្រេចផ្សេងពីនេះរបស់តុលាការ។ ទោសព្យួរលិខិតបើកបរមិនត្រូវមានរយៈពេលលើសពី ៥ឆ្នាំ ឡើយ ។ ទណ្ឌិតត្រូវប្រគល់លិខិតបើកបររបស់ខ្លួនទៅឲ្យក្រឡាបញ្ជីតុលាការ។ លិខិតបើកបរត្រូវរក្សាទុកតាមលក្ខខណ្ឌដែលកំណត់ដោយប្រកាសដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[33]

➢ **ការហាមឃាត់ចំពោះការស្នាក់នៅ**

ទោសហាមឃាត់ចំពោះការស្នាក់នៅ គឺជាការហាមឃាត់ដល់ទណ្ឌិតចំពោះ ការមានមុខនៅទីកន្លែងខ្លះលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។ ការហាមឃាត់ចំពោះការស្នាក់នៅមិនអាចមានរយៈពេលលើសពី ១០ឆ្នាំ ចំពោះបទឧក្រិដ្ឋ និង ៥ឆ្នាំ ចំពោះបទមជ្ឈិម ។ តុលាការមានសមត្ថកិច្ចជាអ្នកកំណត់បញ្ជីនៃទីកន្លែង ដែលត្រូវហាមឃាត់ស្នាក់នៅ និងចិរវេលានៃការហាមឃាត់។ ការដាក់ទោសនេះត្រូវរួមបញ្ចូលទាំងវិធានការតាមដានទៀតផង ។ វិធានការតាមដាន ស្តែងឡើងតាមរយៈការចូលបង្ហាញខ្លួនតាមដីកាកោះរបស់អាជ្ញាធរតុលាការ ឬរដ្ឋបាលដែលតុលាការបានចាត់តាំង និងការចូលបង្ហាញខ្លួនឲ្យបានទៀងទាត់តាមការកំណត់នៅស្នាក់ការនគរបាល ឬកងរាជអាវុធហត្ថ តាមការចាត់តាំងរបស់តុលាការ។ តុលាការត្រូវកំណត់បែបបទនៃវិធានការតាមដាន ហើយព្រះរាជអាជ្ញាត្រូវជូនដំណឹងពីសេចក្តីសម្រេចនេះដល់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ។ ទោសហាមឃាត់ការស្នាក់នៅត្រូវអនុវត្ត ក្រោយពេលដែលទណ្ឌិតបានទទួលរងនូវទោសដាក់ពន្ធនាគាររួចហើយ លើកលែងតែមានសេចក្តីសម្រេចផ្សេងរបស់តុលាការ។

***ឧទាហរណ៍៖*** តុលាការបានសម្រេចផ្តន្ទាទោស រដ្ឋា ពី បទអាស ប្រព្រឹត្តទៅលើអនីតិជនអាយុតិចជាង ១៥ឆ្នាំ ដោយសារតែ រដ្ឋា តែងតែមានទម្លាប់រកក្មេងៗអាយុពី ១០ឆ្នាំ ទៅ ១២ឆ្នាំ ឲ្យមកលេងប្រដាប់ភេទរបស់ខ្លួន ។ បន្ថែមពីលើមូលទោស តុលាការអាចសម្រេចហាមឃាត់ រដ្ឋា មិនឲ្យស្នាក់នៅរាជធានីភ្នំពេញ (ជាទីកន្លែងដែល រដ្ឋា បានប្រព្រឹត្តបទល្មើសជាញឹកញាប់) ក្នុងរយៈពេល ៥ឆ្នាំ ។[34]

➢ **ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា**

ទោសហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្ត ក្រោយពេលដែលទណ្ឌិតបានទទួលរងទោសដាក់ពន្ធនាគាររួចរាល់អស់ហើយ លើកលែងតែមានសេចក្តីសម្រេចផ្សេងពីនេះរបស់តុលាការ។

ទោសបន្ថែមខាងលើមានរយៈពេលមិនអាចលើសពី ៥ ឆ្នាំ ឡើយ ដោយទណ្ឌិតត្រូវប្រគល់លិខិតឆ្លងដែនរបស់ខ្លួនទៅឲ្យក្រឡាបញ្ជីតុលាការ ។ ទណ្ឌិតមិនអាចសុំលិខិតឆ្លងដែនវិញបានទេ ក្នុងរយៈពេលដែល

[33] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣១៤។

[34] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣១៥ ។

កំពុងទទួលរងនូវទោសនេះ ។ លិខិតឆ្លងដែនត្រូវរក្សាទុកតាមលក្ខខណ្ឌដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

***ឧទាហរណ៍៖*** តុលាការបានសម្រេចផ្តន្ទាទោស ដាលី ពីបទ ប្រគល់ឲ្យរដ្ឋបរទេសនូវព័ត៌មានជាអាទិ៍ដែលអាចធ្វើឲ្យអន្តរាយការការពារជាតិ ។ បន្ថែមពីលើមូលទោស តុលាការអាចសម្រេចហាមឃាត់ ដាលី មិនឲ្យចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់រយៈពេល ៥ឆ្នាំ ក្រោយពីបានទទួលរងទោសដាក់ពន្ធនាគាររួចរាល់អស់ហើយ។[35]

➢ **ការហាមឃាត់ចំពោះការចូលនិងស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា**

ទោសបន្ថែមខាងលើនេះ អាចយកទៅអនុវត្តបានចំពោះតែទណ្ឌិតដែលជាជនបរទេសតែប៉ុណ្ណោះ។ ដូច្នេះការហាមឃាត់ខាងលើអាចជាការហាមឃាត់ស្ថាពរ ឬជាការហាមឃាត់មានរយៈពេល ៥ ឆ្នាំ យ៉ាងច្រើនបំផុត។ ព្រមជាមួយគ្នានេះ ការដាក់ទោសនេះនឹងនាំឲ្យមានការបណ្តេញទណ្ឌិតជាជនបរទេសចេញពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជា នៅពេលដែលបានបញ្ចប់ទោសដាក់ពន្ធនាគាររួចអស់ហើយនោះ ។

ជាទូទៅ ទោសបន្ថែមខាងលើត្រូវតែអនុវត្តក្រោយពេលដែលទណ្ឌិត បានទទួលរងទោសដាក់ពន្ធនាគារចប់សព្វគ្រប់រួចហើយ។

***ឧទាហរណ៍៖*** តុលាការបានសម្រេចផ្តន្ទាទោសឈ្មោះ ហ្វីលីប មានសញ្ជាតិអង់គ្លេស ពី បទរំលោភសេពសន្ថវៈ លើនារីរងគ្រោះជាពលរដ្ឋខ្មែរ ។ បន្ថែមពីលើមូលទោស តុលាការអាចប្រកាសទោសបន្ថែម ការហាមឃាត់ចំពោះការចូលឬការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាជាស្ថាពរ មានន័យថាក្រោយពីបានទទួលរងទោសដាក់ពន្ធនាគារនៅប្រទេសកម្ពុជារួចហើយ ហ្វីលីប នឹងត្រូវបណ្តេញចេញពីប្រទេសកម្ពុជា ហើយនឹងមិនអនុញ្ញាតឲ្យចូលមកប្រទេសកម្ពុជាជារៀងរហូត។[36]

➢ **ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស**

ចំពោះការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើសណាមួយ តុលាការអាចសម្រេចរឹបអូសនូវវត្ថុដែលប្រើជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើស នៅពេលដែលតុលាការសម្រេចដាក់ទោសជាមូលទោសលើជនជាប់ចោទនោះ។

***ឧទាហរណ៍៖*** ឈ្មោះ (ក) បានជាប់ចោទពី **បទលួច** តាមមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ដោយខ្លួនបានធ្វើសកម្មភាពលួចម៉ូតូរបស់ជនរងគ្រោះ ដោយពេលធ្វើសកម្មភាពខ្លួនបានប្រើប្រាស់ឧបករណ៍សោរតេ ដើម្បីឆ្កឹះសោរម៉ូតូបានសម្រេច ។ ចៅក្រមបានផ្តន្ទាទោសជនជាប់ខាងលើដាក់ពន្ធនាគាររយពេល ១ឆ្នាំ ពីបទ លួច

[35] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣១៦ ។

[36] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣១៧ ។

និងរឹបអូសបំផ្លាញចោល វត្ថុតាងឧបករណ៍សោរតេ។ ដោយសារវត្ថុខាងលើ ជនជាប់ចោទបានប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ដូច្នេះបន្ទាប់ពីតុលាការប្រកាសមូលទោសដល់ជនជាប់ចោទហើយ តុលាការក៏បានប្រកាសទោសបន្ថែមដូចជា រឹបអូសវត្ថុដែលជនជាប់ចោទប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើសជាដើម ។

➢ **ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស**

ចំពោះវត្ថុ ឬមូលនិធិ ដែជាកម្មវត្ថុនៃបទល្មើស ក៏ស្រដៀងនឹងការរឹបអូសវត្ថុខាងលើផង ប៉ុន្តែចំពោះទ្រព្យសម្បត្តិដែលត្រូវបានរឹបអូសនឹងក្លាយជាកម្មសិទ្ធិរបស់រដ្ឋ កាលបើការរឹបអូសនេះបានក្លាយជាស្ថាពរ លើកលែងតែមានបទបញ្ញត្តិដោយឡែកដែលចែងអំពីការប្រគល់ផ្សេងពីនេះ។

***ឧទាហរណ៍៖*** តុលាការបានសម្រេចផ្តន្ទាទោសឈ្មោះ ធីតា ពីបទ គំរាមកំហែងថានឹងសម្លាប់ តាមមាត្រា ២៣៣ នៃក្រមព្រហ្មទណ្ឌ ដោយសារតែ ធីតា បានធ្វើការគំរាមកំហែងនារីម្នាក់ទៀតដែលជាស្ត្រីកំណាន់ចិត្តប្តីរបស់នាងតាមទូរស័ព្ទ។ បន្ថែមពីលើមូលទោស តុលាការអាចប្រកាសទោសបន្ថែម គឺការរឹបអូសទូរស័ព្ទដែលជាវត្ថុប្រើប្រាស់សម្រាប់ការប្រព្រឹត្តបទល្មើសបាន។[37]

➢ **ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិ ដែលកើតចេញពីបទល្មើស**

***ឧទាហរណ៍៖*** កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ផ្សារកណ្តាលបានចុះបង្ក្រាបករណីជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចមណ្ឌល២ ភូមិប្រជាធម្ម សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ បានចាប់យកវត្ថុតាងថ្នាំញៀន ប្រភេទមេតំហ្វេតាមីន(ម៉ាទឹកកក) ចំនួន០៤កូនថង់តូច ស្មើនឹងទម្ងន់ ០.២ក្រាម ទូរស័ព្ទដៃចំនួន០៤គ្រឿង ដបច្នៃសម្រាប់ប្រើប្រាស់ថ្នាំញៀនចំនួន០១ ដែកកេះចំនួន០៤ និងបំពង់ជ័រមួយចំនួន ព្រមទាំងធ្វើការឃាត់ខ្លួនជនសង្ស័យចំនួន០៣នាក់ មានឈ្មោះ **(ក)** ភេទប្រុស អាយុ២៥ឆ្នាំ,ឈ្មោះ **(ខ)** ភេទប្រុស អាយុ២៧ឆ្នាំ និងឈ្មោះ **(គ)** ភេទប្រុស អាយុ២៦ឆ្នាំ។

សេចក្តីសម្រេចរបស់សាលាដំបូងខេត្តបន្ទាយមានជ័យ បានសម្រេចផ្តន្ទាទោសជនជាប់ចោទទាំងបីខាងលើដាក់ពន្ធនាគារ មិនតែប៉ុណ្ណោះទ្រព្យសម្បត្តិដែលពួកគេប្រើសម្រាប់ប្រព្រឹត្តបទល្មើស ដូចជាដបច្នៃសម្រាប់ប្រើប្រាស់ថ្នាំញៀនចំនួន០១ ដែកកេះចំនួន០៤ បំពង់ជ័រមួយចំនួន និងថ្នាំញៀន ប្រភេទមេតំហ្វេតាមីន (ម៉ាទឹកកក) ចំនួន០៤កូនថង់តូច ស្មើនឹងទម្ងន់ ០.២ក្រាម ត្រូវរឹបអូសនិងបំផ្លាញចោល ចំណែកឯទូរស័ព្ទដៃចំនួន០៤គ្រឿង តុលាការក៏បានរឹបអូសផងដែរ។ [38]

**- រឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុ ដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត**

[37] វុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣១៨ ។

[38] សាលក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ, លេខ២៩(ជ) ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៧។

***ឧទាហរណ៍៖*** ឈ្មោះ (ក) បានប្រើប្រាស់ឧបករណ៍ដូចជា ទូរស័ព្ទដៃ កំព្យូទ័រ កាម៉េរ៉ា ភ្លើង និងសម្ភារៈផ្សេងៗទៀត ក្នុងការផលិតវីដេអូអាសអាភាស សមត្ថកិច្ចក៏បានឆែកឆេរផ្ទះរបស់ឈ្មោះ (ក) ក៏ឃាត់ខ្លួនរូបគេ និងចាប់វត្ថុខាងលើមកតុលាការដើម្បីចាត់ការតាមនីតិវិធី។

តាមមាត្រា ៣៩ នៃច្បាប់ស្តីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវផ្តន្ទាទោសពី ១ខែ ទៅ ១ឆ្នាំ និងពិន័យជាប្រាក់ពី ២០០,០០០ រៀល ទៅ ២,០០០,០០០ រៀល ។ អំពើរបស់ជនជាប់ចោទខាងលើ ត្រូវបានចៅក្រមផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ៨ខែ និងពិន័យជាប្រាក់ចំនួន ១,០០០,០០០ រៀល ព្រមទាំងដាក់ទោសទោសបន្ថែមតាមមាត្រា ៤៨ នៃច្បាប់នេះ ដោយរឹបអូសសម្ភារៈ និងចលនវត្ថុ របស់ជនជាប់ចោទដោយជនជាប់ចោទប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើស ។

- **ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត**

***ឧទាហរណ៍៖*** កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ ឈ្មោះ **(ក)** ជិះម៉ូតូម៉ាក ហុងដាសេ១២៥ ពណ៌ខ្មៅ ផលិតឆ្នាំ២០២៣ ពាក់ផ្លាកលេខ ភ្នំពេញ 1KD-0445 ដែលជាបក្សពួកបានមកឌុបជនជាប់ចោទឈ្មោះ **(ខ)** និងឈ្មោះ **(គ)** ដែលជាបក្សពួកម្នាក់ទៀត ក៏បានជិះម៉ូតូមួយគ្រឿងម៉ាកហុងដាសេ១២៥ ពណ៌ខ្មៅ ផលិតឆ្នាំ២០១៦ មិនចាំផ្លាកលេខ ជិះចេញពីផ្ទះជួលគ្មានលេខ ស្ថិតនៅភូមិទ្រា សង្កាត់ស្ទឹងមានជ័យទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ លុះជិះមកដល់ចំណុចមុខសម្តពណ្ឌប៉ែល ស្ថិតនៅផ្លូវលេខ១៩៩ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ជនត្រូវចោទឈ្មោះ **(ក)** បានបើកម៉ូតូទៅពីក្រោយអែបខាងឆ្វេង ដៃជនរងគ្រោះឈ្មោះ **(ឃ)** បន្ទាប់មកជនជាប់ចោទឈ្មោះ **(ខ)** បានធ្វើសកម្មភាពឆក់យកខ្សែករផ្លាកទីនរបស់ជនរងគ្រោះបានសម្រេច បណ្តាលឲ្យដួលម៉ូតូភ្លាមនោះឈ្មោះ **(ក)** បានរត់ឡើងជិះម៉ូតូជាមួយជនជាប់ចោទឈ្មោះ **(គ)** ហើយគេចខ្លួនបាត់ ចំណែកជនជាប់ចោទឈ្មោះ **(ខ)** ត្រូវបានសមត្ថកិច្ច ដែលល្បាតនៅជិតនោះធ្វើការឃាត់ខ្លួនតែម្តង។

**សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចដូចខាងក្រោម៖**

- ***ផ្តន្ទាទោសជនជាប់ចោទឈ្មោះ (ខ) ដាក់ពន្ធនាគាររយៈពេល ០៣(បី) ឆ្នាំ ០៦ (ប្រាំមួយខែ) ពីបទ លួចមានស្ថានទម្ងន់ទោស និងរឹបអូសវត្ថុតាង ម៉ូតូម៉ាក ហុងដាសេC១២៥ ពណ៌ខ្មៅ ផ្លាកលេខ ភ្នំពេញ 1KD-0445 ជាទ្រព្យសម្បត្តិរដ្ឋ។***[39]

យោងតាមមាត្រា ៥៣ នៃក្រមព្រហ្មទណ្ឌ ការរឹបអូសយានជំនិះរបស់ជនជាប់ចោទខាងលើ គឺជាទោសបន្ថែមទៅលើមូលទោសដែលជនជាប់ចោទខាងលើបានប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស។

- **ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ**

ការហាមឃាត់នេះត្រូវអនុវត្តទៅលើអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការហាមឃាត់អាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ឆ្នាំ យ៉ាងច្រើន ។

[39] សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, លេខ ៥៨ ក្រ១១ (ឃ) ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤។

***ឧទាហរណ៍៖*** តុលាការបានសម្រេចផ្តន្ទាទោស ចន្ថា ពីបទ បង្កឲ្យមានរបួសដោយអចេតនា ដោយសារតែការធ្វេសប្រហែសធ្វើឲ្យកាំភ្លើងខ្លីរបស់ខ្លួនជ្រុះ បណ្តាលឲ្យរាលកែផ្ទុះមួយគ្រាប់ទៅត្រូវជនម្នាក់កំពុងឈរនៅក្បែរនោះឲ្យទទួលរងរបួសយ៉ាងធ្ងន់ធ្ងរ ។ ក្នុងសភាពដូចខាងលើនេះ តុលាការអាចប្រកាសទោសបន្ថែមពីលើមូលទោស គឺត្រូវហាមឃាត់ការយកអាវុធតាមខ្លួនសម្រាប់រយៈពេលចំនួន ២ឆ្នាំ ។[40]

- **ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ**

លទ្ធកម្មសាធារណៈគឺជាកិច្ចសន្យាដែលបានស្នើឡើងដោយរដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈ និងសហគ្រាសដែលត្រូវបានធ្វើសម្បទាន ឬត្រួតត្រាដោយរដ្ឋ ឬដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ នាំឲ្យមានការហាមឃាត់ចំពោះការចូលរួមដោយផ្ទាល់ ឬដោយប្រយោលក្នុងលទ្ធកម្មសាធារណៈទាំងឡាយដែលរៀបចំដោយរដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈ សហគ្រាសដែលទទួលសម្បទានពីរដ្ឋ ឬពីរដ្ឋបាលថ្នាក់ក្រោមជាតិ ឬដែលត្រួតពិនិត្យដោយរដ្ឋ ឬដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ទោសបណ្តេញចេញនេះអាចជាការបណ្តេញចេញជាស្ថាពរ បានន័យថាមិនអនុញ្ញាតឲ្យចូលរួមក្នុងលទ្ធកម្មសាធារណៈជារៀងរហូត ឬជាការបណ្តេញចេញបណ្តោះអាសន្នសម្រាប់រយៈពេល ៥ឆ្នាំ យ៉ាងច្រើន។

***ឧទាហរណ៍៖*** ក្រុមហ៊ុនឯកជនមួយដែលមានកម្មវត្ថុបើកភោជនីយដ្ឋានត្រូវបានតុលាការផ្តន្ទាទោសពីបទផ្តល់អាហារដែលមានសារជាតិពុលតាមមាត្រា ២២៦ នៃក្រមព្រហ្មទណ្ឌ ។ បន្ថែមពីលើមូលទោស តុលាការអាចប្រកាសបន្ថែម ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ដែលមានចែងនៅមាត្រា ២៣០ កថាខណ្ឌទី ២ ចំណុចទី ៤ នៃក្រមព្រហ្មទណ្ឌ។[41]

- **ការបិទគ្រឹះស្ថាន**

ទោសបិទគ្រឹះស្ថាន នាំឲ្យមានការហាមឃាត់ចំពោះការធ្វើសកម្មភាពនៅក្នុងគ្រឹះស្ថានដែលនៅក្នុងឱកាសធ្វើសកម្មភាពនោះ បទល្មើសត្រូវបានប្រព្រឹត្តឡើង។ ទោសបិទគ្រឹះស្ថានអាចជាការបិទគ្រឹះស្ថានជាស្ថាពរ ឬជាការបិទគ្រឹះស្ថានជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ ឆ្នាំយ៉ាងច្រើន ។

***ឧទាហរណ៍១៖*** ម្ចាស់ភោជនីយដ្ឋានមួយកន្លែងត្រូវបានផ្តន្ទាទោសពីបទ សម្រួលដោយចេតនាឲ្យជនណាម្នាក់ប្រើប្រាស់ដោយខុសច្បាប់នូវគ្រឿងញៀន នៅក្នុងភោជនីយដ្ឋានរបស់ខ្លួន តុលាការអាចសម្រេចជាទោសបន្ថែម ដោយត្រូវបង្គាប់ឲ្យបិទទ្វារភោជនីយដ្ឋាននេះ ។

[40] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣១៩ ។

[41] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣២០ ។

***ឧទាហរណ៍២៖*** ម្ចាស់ផ្ទះសំណាក់មួយកន្លែងត្រូវបានផ្តន្ទាទោសពីបទ **បទយល់ព្រមឲ្យធ្វើសកម្មភាពពេស្យាចារនៅក្នុងគ្រឹះស្ថាន** ដែលបានប្រព្រឹត្តនៅក្នុងផ្ទះសំណាក់របស់គាត់។ ក្នុងករណីបែបនេះ តុលាការអាចប្រកាសទោសបន្ថែមឲ្យបិទទ្វារផ្ទះសំណាក់នេះបាន ។[42]

- **ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណៈជន ឬដែលប្រើប្រាស់ដោយសាធារណៈជន**

ទោសបន្ថែមនេះ សំដៅទៅលើការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហសម្រាប់សាធារណជន ឬដែលត្រូវបានប្រើប្រាស់ដោយសាធារណជន។ ទោសនេះអាចជាការហាមឃាត់ជាស្ថាពរ ឬជាការហាមឃាត់ជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ឆ្នាំយ៉ាងច្រើន។

***ឧទាហរណ៍៖*** ដូចក្នុងឧទាហរណ៍ខាងលើ ម្ចាស់ផ្ទះសំណាក់មួយកន្លែងត្រូវបានតុលាការផ្តន្ទាទោសពីបទយល់ព្រមឲ្យធ្វើសកម្មភាពពេស្យាចារនៅក្នុងគ្រឹះស្ថាន ប្រព្រឹត្តនៅក្នុងផ្ទះសំណាក់របស់គាត់។ ហេតុដូច្នេះបន្ថែមពីលើមូលទោស តុលាការអាចប្រកាសទោសបន្ថែម ដោយតម្រូវឲ្យបិទទ្វារផ្ទះសំណាក់ និងហាមឃាត់ម្ចាស់ផ្ទះសំណាក់ក្នុងការបើកធ្វើអាជីវកម្មផ្ទះសំណាក់ណាមួយក្នុងរយៈពេល ៥ឆ្នាំ ទៀតផង ។

***ឧទាហរណ៍៖*** តុលាការបានសម្រេចផ្តន្ទាទោសចំពោះម្ចាស់កុងស៊ីទទួលបញ្ជាំម្នាក់ពីបទ ថាបានទទួលផលចោរកម្ម។ ដូច្នេះដោយត្រូវបន្ថែមពីលើមូលទោស តុលាការអាចសម្រេចហាមឃាត់ម្ចាស់កុងស៊ីទទួលបញ្ជាំបញ្ជាំរបស់ខ្លួនជាស្ថាពរបាន ។[43]

- **ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស**

ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ត្រូវអនុវត្តនៅទីកន្លែងដែលបាន ចង្អុលបង្ហាញដោយតុលាការ និងក្នុងរយៈពេលមួយដែលបានកំណត់ដោយតុលាការ។ ការបិទផ្សាយមិនអាចមានរយៈពេលលើសពី ២ខែបានទេ។ ការបិទផ្សាយអាច ធ្វើទាំងស្រុង ឬតាមសម្រង់ ឬតាមនិទ្ទេសធម្មតា ។ សោហ៊ុយបិទផ្សាយជា បន្ទុករបស់ទណ្ឌិត។

ក្នុងករណីមានការបំបាត់ចោល ការលាក់បំបាំង ឬការហែកចោលសេចក្តីប្រកាសនេះ ត្រូវតែធ្វើការបិទផ្សាយជាថ្មី ។ ប៉ុន្តែ ការបិទផ្សាយលើកនេះត្រូវចេញសោហ៊ុយដោយអ្នកបំបាត់ចោលអ្នកលាក់បំបាំង ឬអ្នកដែលបានហែកចោលសេចក្តីប្រកាសខាងលើនេះ ។

ទោសបន្ថែមខាងលើនេះមានគោលបំណងធ្វើឲ្យប៉ះពាល់ដល់កិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ទណ្ឌិតដោយសារតែតុលាការសម្រេចផ្តន្ទាទោសលើទណ្ឌិតអំពីបទ ល្មើសដែលទណ្ឌិតបានប្រព្រឹត្ត។

---

[42] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣២១ ។

[43] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣២២ ។

***ឧទាហរណ៍៖*** តុលាការបានសម្រេចផ្តន្ទាទោស ជីវី ពីបទ ឆបោក។ បន្ថែមពីលើមូលទោសនៃបទល្មើសនេះ តុលាការអាចបង្គាប់ឲ្យបិទផ្សាយសេចក្តីសម្រេចអំពីទណ្ឌកម្មដែលបានផ្តន្ទាលើ ជីវី នៅមុខលំនៅដ្ឋានផ្ទាល់របស់ ជីវី និងសាលាសង្កាត់ដែល ជីវី រស់នៅសម្រាប់រយៈពេល ១ខែ ដោយឲ្យជីវីជាអ្នកទទួលបន្ទុកចេញសោហ៊ុយនៃការបិទផ្សាយនេះ។[44]

➢ **ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ**

ទោសផ្សាយសេចក្តីសម្រេចរបស់តុលាការ ត្រូវចុះផ្សាយក្នុងសារព័ត៌មាន សរសេរតាមបែបបទ និងក្នុងថិរវេលាដែលកំណត់ដោយតុលាការ។ សោហ៊ុយក្នុងការចុះផ្សាយជាបន្ទុករបស់ទណ្ឌិត។ ក្នុងករណីមិនព្រមគោរពតាមទណ្ឌិតអាចត្រូវបង្ខំដល់រូបកាយ។ ប្រសិនបើតុលាការបានបង្គាប់ឲ្យធ្វើការផ្សព្វផ្សាយសេចក្តីសម្រេចតាមរយៈសារព័ត៌មាន សារព័ត៌មានមិនអាចធ្វើការបដិសេធការផ្សព្វផ្សាយនេះបានទេ។

***ឧទាហរណ៍ ៖*** តុលាការបានសម្រេចផ្តន្ទាទោស ជីវ៉ា ពី បទគំរាមកំហែងហែកកេរ្តិ៍ ដោយសារតែ ជីវ៉ា បានគំរាមយកប្រាក់ចំនួន ១០លានរៀល ពីសង្សាររបស់ខ្លួន ជាថ្នូរទៅនឹងការមិនផ្សព្វផ្សាយរូបភាពអាសអាភាសរបស់នាង។ បន្ថែមពីលើមូលទោស តុលាការបានបង្គាប់ឲ្យធ្វើការផ្សព្វផ្សាយសេចក្តីសម្រេចពីទណ្ឌកម្មលើ ជីវ៉ា នៅលើទំព័រសារព័ត៌មានកោះសន្តិភាពរយៈពេល ៣ ថ្ងៃ ២ជាប់ៗគ្នា ដោយឲ្យ ជីវ៉ា ជាអ្នកទទួលបន្ទុកចេញសោហ៊ុយនៃការផ្សព្វផ្សាយនេះ ។[45]

➢ **ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍**

ទោសផ្សាយជាសាធារណៈនូវសេចក្តីសម្រេចតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ត្រូវអនុវត្តតាមបែបបទដែលកំណត់ដោយតុលាការ។ ការផ្សាយនេះមិនអាចមានរយៈពេលលើសពី ៨ ថ្ងៃបានទេ ដោយការផ្សព្វផ្សាយ អាចធ្វើឡើងទាំងស្រុង ឬតាមសម្រង់ ឬតាមនិទ្ទេសក៏បាន ។ សោហ៊ុយនៃការផ្សព្វផ្សាយគឺជាបន្ទុករបស់ទណ្ឌិត ។

***ឧទាហរណ៍៖*** ដូចក្នុងឧទាហរណ៍ខាងលើទាក់ទងនឹងអំពើរបស់ ជីវ៉ា តុលាការអាចសម្រេចឲ្យធ្វើការផ្សាយសេចក្តីសម្រេចទណ្ឌកម្មលើ ជីវ៉ា តាមទូរទស្សន៍ ខ.ទ.ក. និងវិទ្យុ FM ៩៦ សម្រាប់រយៈពេល ៣ ថ្ងៃជាប់ៗគ្នា ដោយឲ្យ ជីវ៉ា ជាអ្នកទទួលបន្ទុកចេញសោហ៊ុយនៃការផ្សព្វផ្សាយនេះ។ ក្រៅពីទោសបន្ថែមដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ បទបញ្ញត្តិដោយឡែកអាចបង្កើតជាទោសបន្ថែមផ្សេងៗទៀតបាន ។[46]

[44] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣២៤ ។
[45] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣២៥ ។
[46] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣២៦ ។

**កថាភាគទី២៖ ការប្រកាសទោសបន្ថែម**

តាមមាត្រា ៥៤ នៃក្រមព្រហ្មទណ្ឌ ទោសបន្ថែមដែលបានរៀបរាប់ខាងលើអាចនឹងប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែងយ៉ាងជាក់លាក់ចំពោះ បទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុដែលត្រូវបានចោទប្រកាន់។ ហេតុដូច្នេះ ប្រសិនបើច្បាប់ពុំបានចែងសោះថាចំពោះបទល្មើសណាមួយអាចត្រូវប្រកាសទោសបន្ថែមណាមួយឲ្យជាក់លាក់ទេ តុលាការក៏មិនអាចប្រកាសនូវទោសបន្ថែមបានឡើយ។[47]

***ឧទាហរណ៍៖*** សម្រាប់ **បទទ្វេពន្ធភាព** ដែលមានចែងនៅមាត្រា ៣៥០ នៃក្រមព្រហ្មទណ្ឌ ពុំឃើញមានបទបញ្ញត្តិណាមួយនៃក្រមដែលចែងពីទោសបន្ថែមសម្រាប់បទល្មើសនេះឡើយ ។ ហេតុនេះចំពោះ បទទ្វេពន្ធភាព តុលាការមិនអាចប្រកាសនូវទោសបន្ថែមណាមួយបានជាដាច់ខាត។[48]

តុលាការអាចប្រកាសជាទោសបន្ថែមក៏បាន មិនប្រកាសក៏បានដែរ លើកលែងតែករណីដែលច្បាប់បានកំណត់ថា ទោសបន្ថែមត្រូវតែប្រកាសជាកាតព្វកិច្ច។ ក្នុងករណីខាងក្រោយនេះ តុលាការត្រូវតែប្រកាសនូវទោសបន្ថែមជាដាច់ខាតទៅលើមូលទោសសម្រាប់បទល្មើសនោះ។

***ឧទាហរណ៍៖*** តាមមាត្រា ៥២ថ្មី កថាខណ្ឌទី២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ក្នុងករណីផ្តន្ទាទោសលើបទល្មើសដែលមានចែងក្នុងមាត្រា ៣៩ថ្មី តុលាការដែលបានកាត់សេចក្តី ត្រូវបញ្ជាឲ្យរឹបអូសធនធាន ឬទ្រព្យសម្បត្តិជាកម្មវត្ថុនៃបទល្មើស ព្រមទាំងប្រតិលាភទាំងឡាយ និងអត្ថប្រយោជន៍ផ្សេងៗទៀតដែលកើតចេញពីធនធាន និងទ្រព្យសម្បត្តិទាំងនោះ។ ហេតុដូច្នេះ តុលាការត្រូវតែប្រកាសនូវទោសបន្ថែម ការរឹបអូសធនធានខាងលើនេះក្នុងករណីដែលតុលាការសម្រេចផ្តន្ទាទោសជនល្មើសតាមមាត្រា ៥២ថ្មី កថាខណ្ឌទី២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។[49]

-តាមមាត្រា ៨ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង ចែងថា ការផលិត ការនាំចូលដើម្បីធ្វើអាជីវកម្ម ការលក់ឧបករណ៍ល្បែងស៊ីសងគ្រប់ប្រភេទដោយគ្មានការអនុញ្ញាតពីរាជរដ្ឋាភិបាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០,០០០ (ប្រាំសែន) រៀល ដល់ ៥,០០០,០០០ (ប្រាំលាន) រៀល និងដាក់ពន្ធនាគារពី ១ (មួយ) ខែ ដល់ ១ (មួយ) ឆ្នាំ ។

ឧបករណ៍ជាវត្ថុតាងខាងលើនេះត្រូវរឹបអូស។ យោងតាមបទបញ្ញត្តិនេះ តុលាការត្រូវតែប្រកាសការរឹបអូសឧបករណ៍ដែលជាវត្ថុតាងខាងលើនេះដោយខានមិនបាន។[50]

---

[47] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៥៤ ។

[48] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៣៥០ ។

[49] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣២៧ ។

[50] ច្បាប់ស្តីពីការបង្ក្រាល្បែងស៊ីសង ឆ្នាំ១៩៩៦,មាត្រា ៨ ។

ក្រៅពីនេះ គួរកត់ចំណាំថាមាត្រា ១០០ នៃក្រមព្រហ្មទណ្ឌអនុញ្ញាតឲ្យតុលាការសម្រេចជំនួសមូលទោស ដោយទោសបន្ថែមមួយ ឬទោសបន្ថែមច្រើន បានសេចក្ដីថា កាលបើលក្ខខណ្ឌត្រូវបានបំពេញ តុលាការអាចជ្រើសរើសយកការប្រកាសទោសបន្ថែមជំនួសមូលទោស ដោយមិនចាំបាច់ប្រកាសមូលទោសឡើយ។

ការប្រកាសទោសបន្ថែមជំនួសមូលទោសអាចធ្វើទៅបានក្នុងករណីដូចខាងក្រោម :

–ជនជាប់ចោទទទួលទោសពិន័យក្នុងឋានៈជាមូលទោសតែមួយគត់។

–ជនជាប់ចោទទទួលទោសដាក់ពន្ធនាគារដែលអតិបរមាស្មើ ឬតិចជាង ៣ឆ្នាំ។

***ឧទាហរណ៍៖*** បញ្ញា បានឈរជេរបញ្ចោរ សុភាព នៅខាងមុខផ្ទះរបស់ សុភាព ដោយពាក្យអាសអាភាសជាច្រើន។ អំពើរបស់ បញ្ញា គឺ ជាការជេរប្រមាថជាសាធារណៈ ដែលត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ១សែនរៀលទៅ ១០លានរៀល តាមមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ។ ក្នុងករណីបែបនេះ តុលាការអាចប្រកាសទោសបន្ថែមជំនួសមូលទោស (ទោសពិន័យ) ដោយគ្រាន់តែតម្រូវឲ្យធ្វើការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ហើយមិនបង្គាប់ឲ្យបញ្ញាបង់ប្រាក់ពិន័យតាមមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌឡើយ។[51]

ជាចុងក្រោយ គួរគូសបញ្ជាក់ជាបន្ថែមទៀតថា ការមិនគោរពតាមទោសបន្ថែមដែលត្រូវបានប្រកាសដោយតុលាការ គឺជាបទល្មើសព្រហ្មទណ្ឌដាច់ដោយឡែកមួយទៀត។ ជាក់ស្ដែងមាត្រា ៦១ថ្មី នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន តម្រូវឲ្យផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ ជនណាដែលបានប្រព្រឹត្តល្មើសនឹងការហាមឃាត់ទាំងឡាយដែលមានចែងនៅមាត្រា ៦០ថ្មី ហើយក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសក៏អាចត្រូវទទួលជាបន្ថែមនូវទោសពិន័យជាប្រាក់ចាប់ពី ២លានរៀល ដល់ ១០លានរៀលផងដែរ។ ដូចគ្នានេះដែរ ក្រមព្រហ្មទណ្ឌក៏ចាត់ទុកជាបទល្មើសមួយដោយឡែក នូវរាល់ការបំពានលើទោសបន្ថែមដែលបានប្រកាសដោយតុលាការដូចជា៖

-បទបំពានលើបម្រាមស្នាក់នៅ (មាត្រា ៥៧៦)

–បទមិនគោរពតាមវិធានការត្រួតពិនិត្យ (មាត្រា ៥៧៧)

–បទបំពានលើទោសបិទផ្សាយ (មាត្រា ៥៧៨)

–បទបំពានលើទោសហាមឃាត់ផ្នែកវិជ្ជាជីវៈ (មាត្រា ៥៧៩)

–បទបំពានលើទោសដែលកម្រិតសិទ្ធិខ្លះ (មាត្រា ៥៨០)

–បទមិនគោរពការរឹបអូស (មាត្រា ៥៨១)

–បទបដិសេធមិនប្រគល់លិខិតបើកបរ (មាត្រា ៥៨២)។

***ឧទាហរណ៍៖*** តុលាការបានសម្រេចផ្ដន្ទាទោស ចន្ថា ពីបទ បង្កឲ្យមានរបួសដោយអចេតនាដោយសារតែការធ្វេសប្រហែសធ្វើឲ្យកាំភ្លើងខ្លីរបស់ខ្លួន ផ្ទុះបណ្ដាលឲ្យរាលកែផ្ទះមួយគ្រាប់ទៅត្រូវជនម្នាក់កំពុងឈរនៅ

[51] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣២៨ ។

ក្បែរនោះឲ្យទទួលរងរបួសយ៉ាងធ្ងន់ធ្ងរ។ ឧបមាថាតុលាការបានប្រកាសទោសបន្ថែមពីលើមូលទោសគឺត្រូវហាមឃាត់ការយកអាវុធតាមខ្លួនសម្រាប់រយៈពេលចំនួន ២ឆ្នាំ ។ ក៏ប៉ុន្តែមួយឆ្នាំក្រោយមក ចន្ថា ត្រូវបានឃាត់ខ្លួនដោយមន្ត្រីនគរបាលយុត្តិធម៌ ដោយមានអាវុធ K59 នៅជាប់នឹងខ្លួន។ ក្នុងសម្មតិកម្មនេះ ចន្ថា បានបំពានលើទោសបន្ថែមដែលតុលាការបានសម្រេចរួចហើយ។ ហេតុដូច្នេះ ចន្ថា បានប្រព្រឹត្តបទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៥៨០ នៃក្រមព្រហ្មទណ្ឌ ។[52]

## កថាភាគទី៣៖ លក្ខខណ្ឌការប្រកាសទោសបន្ថែម

ជាគោលការណ៍ ទោសបន្ថែមអាចនឹងត្រូវបានប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែងដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ដែលត្រូវបានចោទប្រកាន់តាមបញ្ញត្តិនីមួយៗ។

### ១.ការប្រកាសទោសបន្ថែមចំពោះនីតិជន

ការប្រកាសទោសបន្ថែមចំពោះនីតិជន អាចត្រូវប្រកាសបាន លុះត្រាតែទោសនោះមានចែងក្នុងបញ្ញត្តិយ៉ាងជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ដែលតុលាការបានចោទប្រកាន់ ប៉ុន្តែប្រសិនបើទោសបន្ថែមនោះជាកាតព្វកិច្ចវិញ ចៅក្រមត្រូវតែប្រកាសទោសបន្ថែមនោះជាដាច់ខាត ។

អនុលោមតាមមាត្រា ៥៤ នៃក្រមព្រហ្មទណ្ឌ ករណីដែលច្បាប់កំណត់ថា ទោសបន្ថែមត្រូវតែប្រកាសជាកាតព្វកិច្ច នោះបានសេចក្តីថាតុលាការត្រូវតែប្រកាសទោសបន្ថែមជាដាច់ខាត។[53]

***ឧទាហរណ៍៖*** តាមមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២ គ្រឿងញៀនដែលបានចាប់យក ហើយដែលមិនទាន់បានបំផ្លាញចោល ឬមិនទាន់ប្រគល់ឱ្យស្ថាប័នមានសមត្ថកិច្ចទេ គឺត្រូវតែរឹបអូស។[54] ដូចគ្នានេះដែរមាត្រា ៨៩ នៃច្បាប់ស្តីពីជលផលបានតម្រូវឱ្យត្រូវតែរឹបអូសយកនូវរាល់វត្ថុតាងនៃបទល្មើស។[55]

ស្របជាមួយគ្នានេះ ចៅក្រមអាចសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយ ឬច្រើន ក្នុងករណីដែលមានចែងនៅមាត្រា ១០០ នៃក្រមព្រហ្មទណ្ឌ។ បទបញ្ញត្តិនេះមានអត្ថន័យថា ចៅក្រមអាចប្រកាសទោសបន្ថែមជាជំនួសមូល ទោសបាន ដោយមិនចាំបាច់ប្រកាសមូលទោសទេ កាលបើលក្ខខណ្ឌដែលច្បាប់ តម្រូវត្រូវបានបំពេញយ៉ាងច្បាស់លាស់។[56]

---

[52] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣២៩ ។

[53] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៥៤ ។

[54] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២,មាត្រា ៩៣ ។

[55] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២,មាត្រា ៨៩ ។

[56] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៥៤ ។

***ឧទាហរណ៍៖*** ចំពោះបទបរិហារកេរ្តិ៍ជាសាធារណៈ តុលាការអាចប្រកាសឱ្យផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ដែលជាទោសបន្ថែមជាជំនួសឱ្យការផ្ដន្ទាទោសពិន័យជាប្រាក់ក៏បានដែរ។

ជាមួយគ្នានេះ ច្បាប់ស្ដីពីការការដឹកជញ្ជូនតាមផ្លូវទឹក ឆ្នាំ២០២៤ ដែលត្រូវបានអនុម័តឲ្យប្រើនៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២៤ ថ្មីៗនេះ យោងមាត្រា ២៦៩ បានកំណត់ថា ចំពោះរូបវន្តបុគ្គលដែលប្រព្រឹត្តបទល្មើស ដែលមានចែងចាប់ពីមាត្រា ២៥៦ ដល់មាត្រា ២៥៩ កថាខណ្ឌទី២ នៃមាត្រា ២៦០ កថាខណ្ឌទី២ នៃមាត្រា ២៦១ មាត្រា ២៦២ កថាខណ្ឌទី១នៃមាត្រា ២៦៣ មាត្រា ២៦៤ ដល់មាត្រា ២៦៦ កថាខណ្ឌទី២នៃមាត្រា ២៦៧ និងមាត្រា ២៦៨ នៃច្បាប់នេះ តុលាការអាចប្រទោសបន្ថែមមួយ ឬច្រើន ដូចក្នុងមាត្រា ៥៣ (ប្រភេទនៃទោសបន្ថែម) នៃក្រមព្រហ្មទណ្ឌ។[57] ដូច្នេះ បន្ទាប់ពីតុលាការផ្ដន្ទាទោសចំពោះបទល្មើសណាមួយដែលរួមមានទណ្ឌកម្មរដ្ឋបាល (ពិន័យជាលាយលក្ខអក្សរ) និងទណ្ឌកម្ម (ពិន័យអន្តរការណ៍ ពិន័ជាប្រាក់ និងទោសដាក់ពន្ធនាគារ) រួចហើយ តុលាការអាចប្រកាសទោសបន្ថែមទៅលើទោសដែលមានចែងខាងលើបាន ។[58]

## ២. ការប្រកាសទោសបន្ថែមចំពោះអនីតិជន

### ២.១. អនីតិជនអាយុក្រោម ១៤ឆ្នាំ

ចំពោះអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ជាគោលការណ៍ តុលាការពុំអាចប្រកាសមូលទោសដល់ជននេះបានទេ ពោលគឺជននេះមិនអាចត្រូវទទួលរងការផ្ដន្ទាទោសណាមួយឡើយ ទោះបីជាជននេះបានប្រព្រឹត្តបទល្មើសប្រភេទណាមួយក៏ដោយ ក៏ប៉ុន្តែតុលាការអាចចាត់វិធានការណាមួយដូចមានចែងក្នុងមាត្រា ៤០ នៃក្រមព្រហ្មទណ្ឌបាន។

### ២.២. អនីតិជនអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ

ជាគោលការណ៍ ការប្រកាសទោសចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ក្រមព្រហ្មទណ្ឌបានកំណត់អំពីទោសបន្ថែមនៅមាត្រា ១៦១ នៃក្រមនេះ ពោលគឺទោសដែលត្រូវអនុវត្តលើអនីតិជនមានដូចខាងក្រោម៖

- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស។
- ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។
- ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាកើតចេញពីបទល្មើស។
- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត។

[57] ច្បាប់ស្ដីពីការដឹកជញ្ជូនតាមផ្លូវទឹក ឆ្នាំ២០២៤,មាត្រា ២៦៩ ។

[58] ច្បាប់ស្ដីពីការដឹកជញ្ជូនតាមផ្លូវទឹក ឆ្នាំ២០២៤ មាត្រា ២៥៣ និងមាត្រា ២៥៤ ។

- ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

ការរឹបអូសចលនវត្ថុខាងលើដែលនាំឲ្យមានការប៉ះពាល់ដល់សិទ្ធិរបស់តតិយជន មិនអាចប្រកាសដោយតុលាការបានទេ ក៏ប៉ុន្តែដោយឡែកទ្រព្យសម្បត្តិដែលត្រូវបានរឹបអូសដោយតុលាការនឹងក្លាយជាសម្បត្តិរដ្ឋ កាលបើការរឹបអូសនេះក្លាយជាស្ថាពរ លើកលែងតែមានប្បញ្ញត្តិពិសេសដែលចែងពីការប្រគល់ផ្សេងៗ។[59]

## ផ្នែកទី៣៖ ទោសជំនួស

ទោសជំនួស គឺជាទោសមួយប្រភេទដែលតុលាការយកមកប្រកាសជំនួសឲ្យមូលទោស ។ ក្នុងករណីនេះ តុលាការមិនអាចប្រកាសការផ្តន្ទាទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បាននោះទេ។ [60]

តាមអត្ថន័យខាងលើ មានន័យថានៅពេលដែលចៅក្រម ឬតុលាការប្រកាសនូវទោសជំនួសនេះ ចៅក្រម ឬតុលាការមិនអាចប្រកាសមូលទោសទេ ពោលគឺមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬក៏ទោសពិន័យជាប្រាក់ទេ ដោយប្រកាសទោសជំនួសនេះជំនួសឲ្យមូលទោសតែម្តង ។[61]

## កថាភាគទី១៖ ប្រភេទនៃទោសជំនួស

យើងឃើញនៅក្នុងក្រមព្រហ្មទណ្ឌ បានកំណត់ពីប្រភេទនៃទោសជំនួស ដោយបែងចែកជាពីរប្រភេទគឺ ទោសការងារសហគមន៍ និងទោសស្តីបន្ទោស ។ ទោសទាំងពីរប្រភេទនេះ យើងឃើញមានចែងចាប់ពីមាត្រា ៧២ ដល់មាត្រា ៧៦ នៃក្រមព្រហ្មទណ្ឌ ។ [62]

### ១. ការងារសហគមន៍

### ១.១. និយមន័យនៃការងារសហគមន៍

ការងារសហគមន៍ គឺជាកាតព្វកិច្ចត្រូវបំពេញក្នុងចិរវេលាចន្លោះពី ៣០ ម៉ោង ទៅ ២០០ ម៉ោង នូវការងារគ្មានកម្រៃជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងៗទៀត ដល់សមាគម ឬដល់អង្គការមិនមែនរដ្ឋាភិបាល ។[63]

---

[59] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ១៦១ ។

[60] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣៣០ ។

[61] កៅ សីហា, រៀបរៀង, សៀវភៅ ទោសព្រហ្មទណ្ឌ ២០១៣, ៦២។

[62] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៧២ ដល់មាត្រា ៧៦ ។

[63] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៧២ ។

### ១.២. អ្នកមិនទទួលប្រយោជន៍នៃការងារសហគមន៍

នៅក្នុងគ្រប់ករណីទាំងអស់ ការងារសហគមន៍មិនអាចបំពេញជាផលប្រយោជន៍នៃរូបវ័ន្តបុគ្គលនោះទេ ពុំអាចបំពេញជាប្រយោជន៍ដល់រូបវន្តបុគ្គលបានទេ។[64]

### ១.៣. របរគតិយុត្តនៃទោសការងារសហគមន៍

ការងារសហគមន៍ ត្រូវតែស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ ជាអាទិ៍ ការងារនៅពេលយប់ អនាម័យ សន្តិសុខ ហើយនិងការងាររបស់ស្ត្រី។ ការងារសហគមន៍អាចត្រួតគ្នាបានជាមួយនឹងការអនុវត្ត សកម្មភាពវិជ្ជាជីវៈបាន។[65]

### ១.៤. គោលការណ៍ជុសជុលការខូចខាតដល់អ្នកដទៃ

រដ្ឋត្រូវតែទទួលរ៉ាប់រងចេញសោហ៊ុយជួសជុលការខូចខាតនានា ដែលបានបង្កឡើងដោយទណ្ឌិតនៅក្នុងពេលកំពុងអនុវត្តការងារសហគមន៍។ ក្នុងករណីបែបនេះ រដ្ឋត្រូវធ្វើឧបាទេសកម្មដោយពេញច្បាប់ទៅក្នុងសិទ្ធិរបស់ជនរងគ្រោះ។[66]

## ២. ការស្តីបន្ទោស

### ២.១. និយមន័យនៃការស្តីបន្ទោស

ការស្តីបន្ទោស គឺជាការប្រមាន ការប្រដៅ អំពីទោសកំហុសឆ្គងរបស់បុគ្គលដែលប្រព្រឹត្តបទល្មើស ដើម្បីប្រមានដល់បុគ្គលនោះកុំឲ្យប្រព្រឹត្តបទល្មើសតទៅទៀត។

ការស្តីបន្ទោស ក៏ជាយន្តការថ្មីមួយដែលឲ្យចៅក្រមមានឆន្ទានុសិទ្ធិ ក្នុងការប្រកាសការស្តីបន្ទោសនេះ ជំនួសឲ្យមូលទោស ដែលជាទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។[67]

### ២.២. របបគតិយុត្តនៃការស្តីបន្ទោស

តុលាការអាចប្រកាសការស្តីបន្ទោស កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារដែលមានអតិបរមាតិចជាង ឬស្មើនឹង ៣ ឆ្នាំ ហើយប្រសិនបើបានបំពេញលក្ខខណ្ឌបីយ៉ាងគឺ :

- ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈបង្កដោយបទល្មើសបានបញ្ចប់។
- ការខូចខាតត្រូវបានជួសជុលហើយ និង
- ជនជាប់ចោទបង្ហាញការធានាក្នុងការចូលទៅរួមរស់ក្នុងសង្គមវិញ។[68]

---

[64] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៧៣ ។

[65] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៧៤ ។

[66] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣៣១ ។

[67] ប្រសាសន៍ឧបនាយករដ្ឋមន្ត្រី កើត រិទ្ធ រដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌

[68] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៧៦ ។

## កថាភាគទី២៖ ការប្រកាសទោសជំនួស

ជាគោលការណ៍នៃការប្រកាសទោសជំនួស តុលាការអាចប្រកាសទោសជំនួសបាន លុះត្រាតែទោសនោះត្រូវជំនួសដោយមូលទោស ពោលគឺតុលាការមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬទោពិន័យជាប្រាក់នោះទេ ដោយជំនួសដោយទោសជាការងារសហគមន៍ និងការស្តីបន្ទោសជាដើម។[69]

### ១. ការប្រកាសទោសការងារសហគមន៍

#### ១.១. ការប្រកាសទោសការងារសហគមន៍ចំពោះនីតិជន

យោងតាមមាត្រា ១០១ នៃក្រមព្រហ្មទណ្ឌ សម្រាប់ការប្រកាសទោសការងារសហគមន៍ ចៅក្រម ឬតុលាការអាចប្រកាសបាន លុះត្រាតែដូចករណីខាងក្រោម៖

- ជនជាប់ចោទត្រូវមានវត្តមាននៅសវនាការ
- ជនជាប់ចោទយល់ព្រមធ្វើការងារសហគមន៍នេះ។

ស្របពេលជាមួយគ្នានេះផងដែរ មុនពេលប្រកាសសាលក្រម ឬសាលដីកា តុលាការត្រូវប្រាប់ជនជាប់ចោទថាសាមីខ្លួនមានសិទ្ធិប្រកែកមិនព្រមធ្វើការងារនេះ ហើយចម្លើយរបស់ជនជាប់ចោទត្រូវតែមានចុះនៅក្នុងសាលក្រម ឬសាលដីកា។ [70]

ម្យ៉ាងវិញទៀត តុលាការត្រូវតែកំណត់អំពីថិរវេលានៃការងារនិងរយៈពេលដែលត្រូវបំពេញឲ្យបានច្បាស់លាស់ ហើយរយៈពេលនេះមិនអាចលើសពី ០១ឆ្នាំ បានទេ។[71]

ចំពោះបែបបទនៃការអនុវត្តទោសការងារសហគមន៍ត្រូវកំណត់ដោយព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញាត្រូវចង្អុលប្រាប់ឈ្មោះនីតិបុគ្គលដែលត្រូវទទួលអត្ថប្រយោជន៍ពីការងារនេះ ។ លើសពីនេះទៅទៀត ទោសនេះត្រូវអនុវត្តក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា ។[72]

***ឧទាហរណ៍ទី១៖*** ឈ្មោះ (ក) បានលួចមាន់របស់អ្នកជិតខាង ហើយត្រូវបានឃាត់ខ្លួន ។ ហេតុដូច្នេះតុលាការអាចប្រកាសឲ្យឈ្មោះ (ក) ធ្វើការងារសហគមន៍ ដោយឲ្យឈ្មោះ (ក) ធ្វើការងារបោសសម្អាតទីស្នាក់ការឃុំដែលឈ្មោះ (ក) រស់នៅ សម្រាប់រយៈពេល ៥០ ម៉ោង ។ ក្នុងករណីនេះ តុលាការមិនបានសម្រេចផ្តន្ទា

[69] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៩៨ ។

[70] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ១០១ ។

[71] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ១០២ ។

[72] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ១០៣ ។

ទោសឲ្យឈ្មោះ (ក) ជាប់ពន្ធនាគារឡើយ ដោយសម្រេចយកតែទោសការងារសហគមន៍ដែលជាទោសជំនួស មកអនុវត្តសម្រាប់ឈ្មោះ (ក) វិញ ។[73]

***ឧទាហរណ៍ទី២៖*** ស្រីម៉ិច បានប្រព្រឹត្ត អំពើលួច ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌឲ្យជាប់ពន្ធនាគារពី ៦ខែ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ១លានរៀល ទៅ ៦លានរៀល។ ក្នុងករណីនេះ អតិបរមា នៃទោសដាក់ពន្ធនាគារសម្រាប់ជនជាប់ចោទគឺ ៣ឆ្នាំ។ ហេតុដូច្នេះ តុលាការអាចប្រកាសតែទោសការងារសហគមន៍ជំនួសឲ្យការប្រកាសមូលទោសដែលបានចែងនៅមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌបាន ។ តុលាការអាចសម្រេចឲ្យ ស្រីម៉ិច ធ្វើការងារសហគមន៍ចំនួន ១០០ម៉ោង (ចិរវេលា) សម្រាប់អំឡុងពេល ២ខែ (រយៈពេល) ដោយមិនឲ្យ ស្រីម៉ិច ទទួលរងនូវការផ្តន្ទាទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់ឡើយចំពោះអំពើលួច នេះទេ។

ជាអញ្ញាតកម្ម កាលបើតុលាការប្រកាសទោសការងារសហគមន៍ ដោយមានការយល់ព្រមពីជនជាប់ចោទនៅក្នុងសវនាការរួចហើយ ទណ្ឌិតត្រូវតែគោរពកាតព្វកិច្ចធ្វើការងារដែលកើតចេញពីការងារសហគមន៍ ដោយខានមិនបាន។ អំពើបំពានដោយទណ្ឌិតលើកាតព្វកិច្ចដែលជាលទ្ធផលនៃទោសការងារសហគមន៍ នឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ២ឆ្នាំ និងពិន័យជាប្រាក់ពី ២លានរៀល ទៅ ៤លាន រៀល យោងតាមមាត្រា ៥៨៣ នៃក្រមព្រហ្មទណ្ឌ។[74]

## ១.២. ការប្រកាសទោសការងារសហគមន៍ចំពោះអនីតិជន

### ១.២.១. អនីតិជនអាយុក្រោម១៤ឆ្នាំ

ចំពោះអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ក្រមព្រហ្មទណ្ឌពុំបានប្បញ្ញតិឲ្យមានការផ្តន្ទាទោសដល់អនីតិជននេះឡើយ ពោលគឺជននេះពុំទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួនប្រព្រឹត្តឡើយ ទោះបីជាអំពើនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ។

តាមមាត្រា ៣៩ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ ដែលប្បញ្ញត្តិអំពីវិធានការអនុវត្តចំពោះអនីតិជន គឺអនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំ ឡើងទៅ ទើបត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ប្រសិនបើកាលៈទេសៈបទល្មើស និងបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ ដូច្នេះមានន័យថាអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ តុលាការមិនអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌដល់ជននេះឡើយ ។

[73] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១៧),១៣៨ ។

[74] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣៣២។

#### ១.២.២. អនីតិជនអាយុចាប់ពី១៤ឆ្នាំ ដល់ក្រោម១៦ឆ្នាំ

ចំពោះអនីតិជនដែលមានអាយុចាប់ ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ ដោយមាត្រា ១៦២ នៃក្រមព្រហ្មទណ្ឌ បានកំណត់ទោសដែលត្រូវអនុវត្តទៅលើអនីតិជនដែលមានអាយុចាប់ ១៦ឆ្នាំ ឡើងទៅ ដូច្នេះអនីតិជនដែលមានអាយុក្រោម១៦ឆ្នាំ គឺតុលាការមិនអាចអនុវត្តទោសការងារសហគមន៍បានទេ ។

#### ១.២.៣. អនីតិជនអាយុចាប់ពី១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ

យោងតាមមាត្រា ១៦២ នៃក្រមព្រហ្មទណ្ឌ ទោសជាការងារសហគមន៍ដែលអនុវត្តទៅលើអនីតិជនមានអាយុយ៉ាងតិច១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ តុលាការអាចប្រកាសទោសនេះបាន លុះត្រាតែបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ថិរវេលានៃការងារមិនអាចលើសពី ១០០ (មួយរយ) ម៉ោង
- ការងារសហគមន៍ត្រូវមានលក្ខណៈជាការបណ្តុះបណ្តាល
- អប់រំកែប្រែ ឬសម្របសម្រួលក្នុងការឲ្យចូលរួមរស់ក្នុងសង្គមវិញ ។[75]

## ២. ការប្រកាសការស្ដីបន្ទោស

### ២.១. ការប្រកាសការស្ដីបន្ទោសចំពោះនីតិជន

ជាទូទៅតុលាការអាចប្រកាសការស្តីបន្ទោស កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារដែលមានអតិបរមាតិចជាង ឬស្មើនឹង ៣ ឆ្នាំ ហើយប្រសិនបើបានបំពេញលក្ខខណ្ឌបីយ៉ាងគឺ :

➢ **ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈបង្កដោយបទល្មើសបានបញ្ចប់**

មានន័យថា ទោសស្តីបន្ទោសនេះ គឺប្រើប្រាស់សម្រាប់ស្ថានភាពបទល្មើសដែលមានលក្ខណៈមិនធ្ងន់ធ្ងរ ពិសេសពេលមានបទល្មើសរួចទៅ មតិសាធារណៈជនមិនសូវចាប់អារម្មណ៍ទេ ព្រោះអត់ទៅប៉ះពាល់ខ្លាំងខ្លាដែលធ្វើឲ្យចលាចរទៅដល់សណ្តាប់ធ្នាប់សាធារណៈតទៅទៀតទេ ដោយសារថាជាបទល្មើតូចតាច ។

***ឧទាហរណ៍៖*** បទល្មើសចរាចរណ៍ជាបទលហុ តាមមាត្រា ៨៨ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ត្រូវផ្តន្ទាទោសត្រឹមពិន័យអន្តរការណ៍(ពិន័យរដ្ឋប្បវេណី) តែប៉ុណ្ណោះ ពុំមានទោសដាក់ពន្ធនាគារទេ ។

ករណី **បើកបរដោយខុសទិសដែលតម្រូវឲ្យធ្វើចរាចរណ៍ ឬបើកបរជាន់គំនួសបង្ហូតកណ្តាលទ្រូងផ្លូវ** ដោយសារបទល្មើសនេះមិនមានភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈ និងជាបទលហុស្រាល ភាគច្រើនមន្រ្តីនគរបាលចរាចរណ៍ផ្លូវគោកតែងតែអប់រំ ណែនាំ តែប៉ុណ្ណោះ មិនពិន័យជាប្រាក់ឡើយ ។

➢ **ការខូចខាតត្រូវបានជួសជុលហើយ**

បានសេចក្តីថា ក្រោយពេលប្រព្រឹត្តបទល្មើសរួចហើយ គឺជនល្មើសបានជុសជុលនូវព្យសនកម្ម ឬការខូចខាត ដូចជាការសងសំណងជម្ងឺចិត្តវិញជាដើម។

[75] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ១៦២ ។

***ឧទាហរណ៍៖*** ឈ្មោះ (ក) បានទៅផឹកកាហ្វេជាមួយមិត្តភក្តិ នៅហាងកាហ្វេមួយកន្លែង ដោយសារមានទំនាស់ពាក្យសម្តីជាមួយមិត្តភក្តិ ក៏របូតដៃធ្វើកែវទឹកមួយបែក ភ្លាមនោះខ្លួនក៏បានដឹងកំហុសដែលខ្លួនបានប្រព្រឹត្ត ខ្លួនក៏សុំទោសទៅម្ចាស់ហាង និងបានចេញថ្លៃសំណងដែលខ្លួនបានធ្វើឲ្យបែកកែវមួយ។ ហេតុដូច្នេះដោយការសងសំណងការខូចខាតត្រូវបានផុសផុលហើយ ជនល្មើសត្រឹមទទួលការស្តីបន្ទោសបន្តិចបន្តួចចំពោះអំពើរបស់ខ្លួនតែប៉ុណ្ណោះ ។

➢ **ជនជាប់ចោទបង្ហាញការធានាក្នុងការចូលទៅរួមរស់ក្នុងសង្គមវិញ**

តាមខ្លឹមសារនេះ គឺជនជាប់ចោទបានបង្ហាញឆន្ទៈ ការសោកស្តាយ វិប្បដិសារីចំពោះកំហុសរបស់ខ្លួនដែលបានប្រព្រឹត្តបទល្មើស ដូចជាខ្លួនទើបបានប្រព្រឹត្តលើកទី១ ដែលជាបទល្មើសលហុជាដើម ហើយគាត់ធានាថាលើកក្រោយមិនប្រព្រឹត្តម្តងទៀតនោះទេ និងសុខចិត្តរៀនសូត្រដើម្បីអប់រំកែប្រែខ្លួនឯងដើម្បីធ្វើសមាហរណកម្មចូលរួមទៅរួមរស់ក្នុងសង្គមវិញបាន។[76]

***ឧទាហរណ៍៖*** ឈ្មោះ (ក) បានទៅហូបបាយសាច់ជ្រូក តម្លៃ ១ចាន ៥០០០៛ នៅហាងមួយកន្លែង ខ្លួនដឹងថាខ្លួនពុំមានប្រាក់នោះទេ ដោយហេតុថាខ្លួនឃ្លានពេក ទើបសម្រេចចិត្តទៅហូបបាយដោយពុំបានឲ្យប្រាក់គេទេ ម្ចាស់ហាងឃើញបែបនេះក៏អត់ទោសឲ្យ រួចក៏បានណែនាំឈប់ឲ្យធ្វើបែបនេះតទៅទៀត រួចឈ្មោះ (ក) ក៏បានសន្យាថាឈប់ធ្វើដូចនេះទៀតហើយ ខ្លួនសន្យានឹងរកការងារធ្វើដើម្បីធ្វើជាពលរដ្ឋល្អក្នុងសង្គមវិញ។

អនុលោមតាមមាត្រា ៩៨ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ ការស្តីបន្ទោសជំនួសឲ្យមូលទោស មានន័យថា ប្រសិនបើតុលាការប្រកាសទោសការស្តីបន្ទោសចំពោះបទល្មើសមួយ ហេតុដូច្នេះតុលាការមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់ចំពោះបទល្មើសមួយនោះទៀតបានទេ ជារួមទោសជាការស្តីបន្ទោសនេះគឺជំនួសឲ្យមូលទោសតែម្តង ។ [77]

***ឧទាហរណ៍៖*** សុខា បានប្រព្រឹត្ត បទធ្វើឲ្យខូចខាតដោយចេតនា តាមមាត្រ ៤១០ នៃក្រមព្រហ្មទណ្ឌដោយបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់អ្នកជិតខាងដែលបណ្តាលមកពីទំនាស់ពាក្យសម្តីជាមួយគ្នា។ ក្រោយពីបានប្រព្រឹត្តបទល្មើសរួចហើយ សុខា បានដឹងកំហុសរបស់ខ្លួន ហើយក៏បានចេញសងការខូចខាតដល់អ្នកជិតខាងរបស់ខ្លួនដែរ ព្រមទាំងបានសម្តែងនូវការសោកស្តាយពីអំពើដែលខ្លួនបានប្រព្រឹត្ត។

ក្នុងករណីបែបបនេះ តុលាការអាចប្រកាសត្រឹមតែជាការស្តីបន្ទោស ជំនួសឲ្យមូលទោសបាន ពោលគឺតុលាការគ្រាន់តែស្តីបន្ទោស សុខា ពីការប្រព្រឹត្តបទល្មើស ដោយមិនឲ្យ សុខា ទទួលរងនូវការផ្តន្ទាទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់ឡើយ ។[78]

---

[76] កៅ សីហា, រៀបរៀង, សៀវភៅ ទោសព្រហ្មទណ្ឌ ២០១៣, ១០៨។

[77] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៩៨ ។

[78] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣៣៤។

*ឧទាហរណ៍៖* ឈ្មោះ ក បានចូលបរិភោគអាហារនៅក្នុងភោជនីយដ្ឋានមួយកន្លែង ដោយដឹងថាខ្លួនមិនមានប្រាក់គ្រប់គ្រាន់សម្រាប់បង់ទេ។ អំពើបែបនេះ គឺជាបទបន្លំ ។ ដូច្នេះ ជំនួសឲ្យការប្រកាសទោសដាក់ពន្ធនាគារ និងពិន័យជាប្រាក់ តុលាការអាចសម្រេចប្រកាសការស្ដីបន្ទោសទៅលើឈ្មោះ ក បន្ទាប់ពីឈ្មោះ ក បានយល់ព្រមទទួលស្គាល់កំហុសរបស់ខ្លួន ហើយក្រុមគ្រួសាររបស់ឈ្មោះ ក បានបង់ប្រាក់ថ្លៃអាហារឲ្យម្ចាស់ភោជនីយដ្ឋានរួចហើយដែរ។[79]

### ២.២. ការប្រកាសការស្ដីបន្ទោសចំពោះអនីតិជន

#### ក. អនីតិជនអាយុក្រោម ១៤ឆ្នាំ

ចំពោះអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ជាគោលការណ៍ តុលាការពុំអាចប្រកាសមូលទោសដល់ជននេះបានទេ ពោលគឺជននេះមិនអាចត្រូវទទួលរងការផ្ដន្ទាទោសណាមួយឡើយ ទោះបីជាជននេះបានប្រព្រឹត្តបទល្មើសប្រភេទណាមួយក៏ដោយ ក៏ប៉ុន្តែតុលាការអាចចាត់វិធានការណាមួយដូចមានចែងក្នុងមាត្រា ៤០ នៃក្រមព្រហ្មទណ្ឌបាន។

#### ខ. អនីតិជនអាយុក្រោម ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ

ជាការបកស្រាយ នៅក្នុងក្រមព្រហ្មទណ្ឌ ដែលប្បញ្ញត្តិពីទោសដែលត្រូវអនុវត្តចំពោះអនីតិជន ចែងចាប់ពីមាត្រា ១៦០ ដល់មាត្រា ១៦២ នៃក្រមព្រហ្មទណ្ឌ បានកំណត់តែគោលការណ៍នៃការប្រកាសទោសជាមូលទោស ទោសបន្ថែម និងទោសជាការងារសហគមន៍តែប៉ុណ្ណោះ ដោយយើងពុំឃើញមានមាត្រាចែងពីការប្រកាសទោសការស្ដីបន្ទោសចំពោះអនីតិជនឡើយ ។

ដោយឡែកមាត្រា ៧៦ នៃក្រមព្រហ្មទណ្ឌ បានចែងពីរបបគតិយុត្តនៃការស្ដីបន្ទោស មិនកំណត់ពីករណីជានីតិជន ឬអនីតិជន ឡើយ ជាទឡ្ហីករនៃការបកស្រាយមាត្រាខាងលើនេះ យើងឃើញថា ប្រសិនបើលក្ខខណ្ឌទាំងបីនៅក្នុងមាត្រាខាងលើនេះបានបំពេញ រូបវន្តបុគ្គលដែលជានីតិជន ឬអនីតិជន ដែលមានអាយុចាប់ពី១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ តុលាការអាចយកលក្ខខណ្ឌនេះមកអនុវត្តចំពោះបុគ្គលទាំងពីរនេះបាន ពីព្រោះថាប្បញ្ញត្តិនៃមាត្រា ៧៦ ជាប្បញ្ញត្តិទូទៅនៅក្នុងក្រមព្រហ្មទណ្ឌ សម្រាប់ការអនុវត្តទោសការស្ដីបន្ទោសចំពោះនីតិជន និងទាំងអនីតិជនដែលមានអាយុចាប់ ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ។[80]

ជាការសន្និដ្ឋាន តុលាការអាចប្រកាសទោសការស្ដីបន្ទោសចំពោះនីតិជន និងអនីតិជនមានអាយុចាប់ពី១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ បានដូចគ្នា ឲ្យតែបុគ្គលទាំងពីរបានបំពេញនូវលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៧៦ នៃក្រមព្រហ្មទណ្ឌបានកំណត់ ។

---

[79]សៀវភៅ នីតិព្រហ្មទណ្ឌ និងគ្រួសា សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០២២។

[80] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៧៦ ។

# ជំពូកទី២៖
# ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល

## ជំពូកទី២៖
## ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល

នីតិបុគ្គល ជាក្រុមមនុស្ស ឬទ្រព្យសម្បត្តិដែលតាមលក្ខខណ្ឌខ្លះមានបុគ្គលភាពគតិយុត្តហើយដែលច្បាប់ទទួលស្គាល់ថាមានសិទ្ធ និងកាតព្វកិច្ច ដូចរូបវន្តបុគ្គលដែរ។

នីតិបុគ្គល សំដៅអង្គភាព ឬ ស្ថាប័ន ដែលបង្កើតឡើងដោយច្បាប់ (ក្រុមហ៊ុន សហគមន៍ អង្គការ) នីតិបុគ្គលបណ្ដុំទៅដោយរូបវន្តបុគ្គល។ហើយនីតិបុគ្គលទទួលបានបុគ្គលភាពគតិយុត្តចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីបង្កើតវា[81]និងបញ្ចប់ទៅវិញនៅពេលនៅកាលបរិច្ឆេទនៃការរលាយ[82]។

ទាំងរូបវន្តបុគ្គល និង ទាំងនីតិបុគ្គលការប្រព្រឹត្តទៅមានដំណើរធម្មជាតិដូចគ្នាដូចជា៖

- ការកើត
- ការស្លាប់
- ការមានឈ្មោះ
- ការមានទៅលំនៅ
- ការមានទ្រព្យសម្បត្តិ
- ការមានសញ្ជាតិជាដើម។

តែខុសគ្នាត្រង់ថារូបវន្តបុគ្គលមានសិទ្ធិលើសពីនីតិបុគ្គលដូចជា៖

- សិទ្ធិមានគ្រួសារ
- សិទ្ធិខាងនយោបាយជាដើម។

សិទ្ធិទាំងពីរខាងលើនេះ នីតិបុគ្គលគ្មានទាល់តែសោះ។ នីតិបុគ្គលមាន នីតិបុគ្គលនៃនីតិសាធារណៈ និងនីតិបុគ្គលនៃនីតិឯកជន។

### ផ្នែកទី១ មូលទោសសម្រាប់នីតិបុគ្គល

ជាក់ស្ដែងចំពោះមូលទោសដែលត្រូវបានអនុវត្តន៍ចំពោះនីតិបុគ្គល គឺមានតែទោសពិន័យជាប្រាក់ និងទោសបន្ថែមទាំង១៤ចំណុចតែប៉ុណ្ណោះពីព្រោះនីតិបុគ្គលគ្រឹះស្ថានស្ថាប័នសាធារណៈ ឬ ឯកជនណាមួយហេតុនេះហើយ គេមិនអាចចាប់គ្រឹះស្ថាន ស្ថាប័នទាំងនេះដាក់ពន្ធនាគារបាននោះឡើយ។

[81] ក្រមរដ្ឋប្បវេណី នស/រកម/១២០៧/០៣០,០៨ធ្នូ ២០០៧,មាត្រា៤៩ ។

[82] ក្រមរដ្ឋប្បវេណី នស/រកម/១២០៧/០៣០,០៨ធ្នូ ២០០៧,មាត្រា៦៤ ។

ចំពោះទោសដែលត្រូវយកមកអនុវត្តន៍ចំពោះនីតិបុគ្គលយើងឃើញថានៅក្នុងក្រមព្រហ្មទណ្ឌបានបញ្ញត្តិនៅក្នុងមាត្រា ១៦៧ ដល់មាត្រា ១៨៣ ដែលការប្រកាសទោសទៅលើនីតិបុគ្គលគឺត្រូវអនុវត្តន៍ ដូចគ្នាទៅ និង រូបវន្តបុគ្គលដែលទោសពិន័យក្នុងឋានៈជាមូលទោសនេះយើងប្រើប្រាស់ដូចគ្នាជាមួយនិងទោសពិន័យសម្រាប់រូបវន្តបុគ្គលដោយការកម្រិតទោសពិន័យគឺចន្លោះពីអប្បបរមា និងអតិប្បរមានៃទោសពិន័យគឺតុលាការ ធ្វើការប្រកាសទោសដោយពិចារណាពីការដាក់ពិន័យក្នុងចន្លោះកម្រិតទោសពីអប្បបរមា និងអតិប្បរមាសមស្របចំពោះបទល្មើសដែលបានបញ្ញត្តិ។

នីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសណាមួយដែលជាក់លាក់ដែលច្បាប់បានចែងយ៉ាងច្បាស់អំពីការទទួលខុសត្រូវរបស់នីតិបុគ្គលនៅក្នុងបទល្មើសប្រភេទនោះ។ ឧទាហរណ៍ នីតិបុគ្គលមិនទទួលខុសត្រូវចំពោះបទមនុស្សឃាតក្នុងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌនោះទេ តែនីតិបុគ្គលត្រូវទទួលខុសត្រូវចំពោះ បទមនុស្សឃាតដោយអចេតនាដោយសារតែមាត្រា ២០៩ នៃក្រមព្រហ្មទណ្ឌបានកំណត់។

## ផ្នែកទី២ ទោសបន្ថែមទាំង១៤ចំណុចក្នុងក្រមព្រហ្មទណ្ឌ

តាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌទោសបន្ថែមដែលត្រូវអនុវត្តចំពោះនីតិបុគ្គលគឺមានចែងក្នុងមាត្រា ១៦៨ ដែលនៅក្នុងមាត្រានេះបានចែងទោសបន្ថែមត្រូវអនុវត្តទៅលើនីតិបុគ្គលទាំង ១៤ ចំណុច[83]។

ដោយយោងតាមក្រមព្រហ្មទណ្ឌមាត្រា១៦៨ បានចែងអំពីទោសបន្ថែមត្រូវអនុវត្តទៅលើនីតិបុគ្គលមានដូចតទៅ៖

១-ការរំលាយចោល ។

២-ការដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ ។

៣-ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬ ច្រើន ។

៤-ការបណ្ដេញចេញពីលទ្ធកម្មសាធារណៈ ។

៥-ការហាត់ឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ។

៦-ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន ក្រៅពីឧបករណ៍អាចជួញដូរបាន ដែលកំណត់ដោយធានាគារ ។

៧-ការហាមឃាត់ចំពោះការប្រើប្រាស់ប័ណ្ណទូទាត់ ។

៨-ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬ ប្រព្រឹត្តបទល្មើស ។

៩-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណជនឬ ដែលបានប្រើប្រាស់ ដោយសាធារណៈជន ។

---

[83] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ១៦៨ ។

១០-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស។

១១-ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

១២-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

១៣-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត ។

១៤-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ការផ្សាយសសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការផ្សាយតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍។

បទប្បញ្ញត្តិដោយឡែកអាចបង្កើតទោសបន្ថែមដទៃទៀតបាន។

- **ចំណុចទី១ ការរំលាយចោល៖**

ដោយទៅបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា(ការរំលាយចោល និងការជម្រះបញ្ជីនៃនីតិបុគ្គល)៖

សេចក្តីសម្រេចដែលបង្គាប់ឲ្យរំលាយនីតិបុគ្គល នាំឲ្យមានការបញ្ជូននីតិបុគ្គលនេះទៅតុលាការមានសមត្ថកិច្ច ដើម្បីធ្វើការជម្រះបញ្ជី។[84]

ការរំលាយនីតិបុគ្គលចោលគឺជាសេចក្តីសម្រេចមួយរបស់តុលាការដែលក្រៅអំពីទោសពិន័យជាប្រាក់ តុលាការអាចប្រកាសរំលាយក្រុមហ៊ុន សមាគមន៍ ឬនីតិបុគ្គលណាមួយចោលដែលវាគឺជាប្រភេទ នៃទោសមួយដែលមានលក្ខណៈធ្ងន់ធ្ងរសម្រាប់នីតិបុគ្គល។

- **ចំណុចទី២ ការដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ៖**

ការដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការមិនអាចលើសពី ៥ (ប្រាំ) ឆ្នាំទេ។ សេចក្តីសម្រេចការដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការនាំឲ្យមានការចាត់តាំងអាណត្តិគាហកតុលាការដែលតុលាការបញ្ជាក់បេសកម្ម។ ជារៀងរាល់ ៦ (ប្រាំមួយ) ខែ យ៉ាងតិច អាណត្តិគាហកតុលា ការធ្វើរបាយការណ៍ ជូនព្រះរាជអាជ្ញាអំពីដំណើរការនៃបេសកកម្មរបស់ខ្លួន។

ក្រោយពីបានឃើញរបាយការណ៍របស់អាណត្តិគាហកតុលាការ ព្រះរាជអាជ្ញាអាចប្តឹងទៅតុលាការដែលបានប្រកាសឲ្យធ្វើការដាក់ក្រោមការតាមដានរបស់តុលាការ។ តុលាការអាចប្រកាសនូវទោសថ្មីមួយ។

តុលាការសម្រេចក្នុងពេលសវនាការសាធារណៈ ក្រោយពីបានស្តាប់យោបល់របស់តំណាងអយ្យការ អាណត្តិគាហកតុលាការ និងដាយថាហេតុ មេធាវីរបស់នីតិបុគ្គលនោះ។[85]

- **ចំណុចទី៣ ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬ ច្រើន៖**

[84] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ១៧០ ។

[85] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ១៧១ ។

ការហាមឃាត់ចំពោះការធ្វើសកម្មភាព អាចជាស្ថាពរ ឬ ជាបណ្តោះអាសន្ន សម្រាប់ចិរវេលា ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

តុលាការបញ្ជាក់អំពីសកម្មភាពដែលត្រូវហាមឃាត់។[86]

➢ **ចំណុចទី៤ ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ៖**

ទោសបណ្តេញចេញពីលទ្ធកម្មសាធារណៈ នាំឲ្យមានការហាមឃាត់ចំពោះការចូលរួម ដោយផ្ទាល់ ឬ ដោយប្រយោលនៅក្នុងគ្រប់លទ្ធកម្មសាធារណៈដែលរៀបចំដោយ ៖

១-រដ្ឋ ។

២-រដ្ឋបាលថ្នាក់ក្រោមជាតិ ។

៣-គ្រឹស្ថានសាធារណៈ ។

៤-សហគ្រាសដែលទទួលសម្បទានពីរដ្ឋ ឬ ពីរដ្ឋបាលថ្នាក់ក្រោមជាតិ ឬ ដែលត្រួតពិនិត្យដោយរដ្ឋ ឬ ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ទោសនេះ អាចជាស្ថានពរ ឬ ជាបណ្តោះអាសន្ន សម្រាប់ចិរវេលាមួយមិនលើសពី ៥(ប្រាំ) ឆ្នាំ ។[87]

➢ **ចំណុចទី៥ ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈឲ្យធ្វើការសន្សំសំចៃ៖**

ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈឲ្យធ្វើការសន្សំសំចៃអាចជាស្ថាពរឬជាបណ្តោះអាសន្ន សម្រាប់រយៈពេល៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

ការហាមឃាត់នេះនាំឲ្យមានការហាមឃាត់ដល់នីតិបុគ្គលចំពោះការអំពាវនាវដើម្បីឲ្យដាក់ឧបករណ៍អាចជួញដូរបានរបស់ខ្លួនទៅក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬ ក្រុមហ៊ុនមូលបត្រ ។

ការហាមឃាត់នេះនាំឲ្យមានការហាមឃាត់ចំពោះការផ្សព្វផ្សាយជាសាធារណៈដែរ ។[88]

➢ **ចំណុចទី៦ ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន ក្រៅពីឧបករណ៍អាចជួញដូរបាន ដែលកំណត់ដោយធនាគារ៖**

ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន អាចជាស្ថាពរ ឬ ជាបណ្តោះអាសន្ន សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។[89]

➢ **ចំណុចទី៧ ការហាមឃាត់ចំពោះការប្រើបណ្ណទូទាត់៖**

ចំពោះការហាមឃាត់ប្រើប្រាស់បណ្ណទូទាត់ ក៏ដូចគ្នាដែរ ។[90]

---

[86] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ១៧២

[87] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ១៧៣

[88] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ១៧៤

[89] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, កថាខ័ណ្ឌ១ មាត្រា ១៧៥

[90] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, កថាខ័ណ្ឌ២ មាត្រា ១៧៥

- **ចំណុចទី៨ ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬ ប្រព្រឹត្តបទល្មើស៖**

ទោសបិទគ្រឹះស្ថាននាំឲ្យមានការហាមឃាត់ចំពោះការប្រព្រឹត្តនៅក្នុងគ្រឹះស្ថាននេះនូវសកម្មភាពដែលបទល្មើសបានកើតឡើងនៅក្នុងឱកាសដែលធ្វើសកម្មភាពនេះ។

ទោសនេះអាចជាស្ថាពរ ឬ ជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។[91]

- **ចំណុចទី៩ ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬ ដែលបានប្រើប្រាស់ដោយសាធារណជន៖**

ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានមួយ ដែលបើកចំហដល់សាធារណៈជន ឬ ដែល ប្រើប្រាស់ដោយសាធារណជន អាចជាស្ថាពរ ឬ ជាបណ្តោះអាសន្នក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។[92]

- **ចំណុចទី១០ ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស៖**

ឧបករណ៍ សម្ភារៈឬ វត្ថុអ្វីមួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស។[93]

ឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុនៅទីកន្លែងដែលបទល្មើសបានកើតក៏ប៉ុន្តែ ការរឹបអូសមិនអាច ត្រូវប្រកាសបានទេ ប្រសិនបើការរឹបអូសនោះប៉ះពាល់ដល់សិទ្ធិរបស់តតិយជន។[94]

- **ចំណុចទី១១ ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស៖**

វត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស(ដោយយោងទៅតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រ កម្ពុជាមាត្រា ១៧៩ ការរឹបអូស និងសិទ្ធិតតិយជន)[95] ។

- **ចំណុចទី១២ ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស៖**

ផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស។[96]

- **ចំណុចទី១៣ ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត៖**

ឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុនៅទីកន្លែងដែលបទល្មើសបានកើតក៏ប៉ុន្តែ ការរឹបអូស មិនអាច ត្រូវប្រកាសបានទេ ប្រសិនបើការរឹបអូសនោះប៉ះពាល់ដល់សិទ្ធិរបស់តតិយជន។[97]

---

[91] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ១៧៦ ។

[92] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ១៧៧ ។

[93] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, កថាខ័ណ្ឌ១ មាត្រា ១៧៩ ។

[94] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, កថាខ័ណ្ឌ៤ មាត្រា ១៧៩ ។

[95] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, កថាខ័ណ្ឌ២ មាត្រា ១៧៩ ។

[96] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, កថាខ័ណ្ឌ៣ មាត្រា ១៧៩ ។

[97] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, កថាខ័ណ្ឌ៤ មាត្រា ១៧៩ ។

- **ចំណុចទី១៤ ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស ការផ្សាយសេចក្ដី សម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការផ្សាយតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍៖**

ការបិទផ្សាយសេចក្ដីសម្រេច ត្រូវអនុវត្តនៅទីកន្លែងដែលចង្អុលប្រាប់ដោយតុលាការ និងសម្រេចរយៈពេលមួយដែលកំណត់ឡើងដោយតុលាការ។ ការបិទផ្សាយមិនអាចលើសពី ២ (ពីរ) ខែ ។ ការបិទផ្សាយជា បន្ទុករបស់នីតិបុគ្គលដែលត្រូវផ្ដន្ទាទោស ។

ក្នុងករណីដែលដកបំបាត់ចេញលាក់កំបាំង ឬហែងចោលសេចក្ដីប្រកាសបិទផ្សាយនោះ ត្រូវធ្វើការបិទផ្សាយជាថ្មីម្ដងទៀត ។ សោហ៊ុយនៃការបិទផ្សាយនេះ ត្រូវចេញដោយជនល្មើសដែលជាអ្នកដកបំបាត់ចោលលាក់បំបាំង ឬ ហែកចោល។[98]

ការផ្សាយសេចក្ដីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍ ៖

ទោសផ្សាយសេចក្ដីសម្រេច តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ត្រូវអនុវត្តតាមបែបបទដែលកំណត់ឡើងដោយតុលាការ ។ ការផ្សាយនេះមិនអាចលើសពី ៨ (ប្រាំបី) ថ្ងៃ ។ ការផ្សាយនេះ អាច ផ្សាយតាំងស្រុងតាមសម្រង់ ឬ តាមនិទ្ទេស។ សោហ៊ុយនៃការផ្សាយជាបន្ទុករបស់នីតិបុគ្គលដែលត្រូវផ្ដន្ទាទោស ។

ទោសផ្សព្វផ្សាយសេចក្ដីសម្រេចរបស់តុលាការត្រូវចុះផ្សាយក្នុងសារព័ត៌មានសរសេរតាមបែបបទ និងក្នុងចិរវេលាដែលកំណត់ដោយតុលាការ ។ សោហ៊ុយក្នុងការចុះផ្សាយជាបន្ទុករបស់នីតិបុគ្គល ។ បើ តុលាការបានបង្គាប់ការផ្សព្វផ្សាយសេចក្ដីសម្រេច សារព័ត៌មានមិនអាចបដិសេធការចុះផ្សាយនេះបានទេ ។[99]

## ផ្នែកទី៣៖ ការប្រកាសទោស

យើងបានដឹងរួចហើយថានីតិបុគ្គល សំដៅអង្គភាព ឬ ស្ថាប័ន ដែលបង្កើតឡើងដោយច្បាប់ (ក្រុមហ៊ុន សហគមន៍ អង្គការ) នីតិបុគ្គលបណ្ដុំទៅដោយរូបវន្តបុគ្គល។ ហើយនីតិបុគ្គលទទួលបានបុគ្គលភាពគតិយុត្តចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីបង្កើតវានិងបញ្ចប់ទៅវិញនៅពេលនៅកាលបរិច្ឆេទនៃការរលាយ។នីតិបុគ្គលមាន នីតិបុគ្គលនៃនីតិសាធារណៈ(នីតិបុគ្គលដែលជារដ្ឋ) និង នីតិបុគ្គលនៃនីតិឯកជន(នីតិបុគ្គលមិនមែនជារដ្ឋ)។ ដែលយើងធ្វើការបកស្រាយដូចខាងក្រោម៖

### កថាភាគទី១៖ ចំពោះនីតិបុគ្គលនៃនីតិសាធារណៈ

ដើម្បីយល់ច្បាស់ពីអត្ថន័យន័យពាក្យ **នីតិបុគ្គលសាធារណៈ** យើងត្រូវយល់ន័យនៃពាក្យសំខាន់ មួយចំនួនសិនដូចជា **នីតិ** និង **បុគ្គល** ។ នីតិ គឺជាបណ្ដាវិធានទាំងឡាយ ដែលគ្រប់គ្រងទៅលើជីវភាពរស់នៅ ប្រចាំថ្ងៃរបស់មនុស្ស ដែលរស់នៅក្នុងសង្គមហើយដែលដាក់ទណ្ឌកម្មដោយអំណាចសាធារណៈ។ នីតិ ជា បណ្ដា

[98] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ១៨០ ។

[99] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ១៨១ ។

វិធានទាំងឡាយ ដែលអនុម័តឡើងដោយ នីតិបញ្ញត្តិក្នុងគោលបំណងដើម្បីបម្រើ ផលប្រយោជន៍ សាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ទំនៀមទម្លាប់ល្អរបស់ជាតិ និងមានការដាក់ទណ្ឌកម្មក្នុងករណីមាន ការរំលោភបំពាន។ នីតិបុគ្គល គឺជាក្រុមបុគ្គល ឬ មូលនិធិដែលច្បាប់និមិត្តបង្កើតឡើងសម្រាប់បម្រើគោលដៅ និង ផលប្រយោជន៍រួមរបស់បុគ្គលមួយក្រុម។ការនិមិត្តដោយច្បាប់នេះ ដើម្បីបង្កើតឲ្យមានឡើងនូវអ្វីដែលហៅថា បុគ្គលភាពគតិយុត្ត ហើយដែលសម្បទានេះនាំឲ្យបុគ្គលក្លាយទៅជាបុគ្គលច្បាប់ដែលពោលពេញទៅដោយសិទ្ធិ និងកាតព្វកិច្ច។[100]

នីតិបុគ្គលនៃនីតិសាធារណៈ(នីតិបុគ្គលដែលជារដ្ឋ)គឺជាក្រុមមនុស្សដែលច្បាប់បានអនុញ្ញាតឲ្យធ្វើសកម្មភាពដូចជាបុគ្គល ដើម្បីជាប្រយោជន៍សាធារណៈនិងគ្មានគោលបំណងដើម្បីទទួលបានប្រាក់ចំណេញដែល វា មានលក្ខណៈខុសគ្នាអំពីនីតិបុគ្គលនៃនីតិឯកជន។ នីតិបុគ្គលនៃនីតិសាធារណៈ គឺជាក្រុមមនុស្សដែលច្បាប់ បានអនុញ្ញាតឲ្យធ្វើសកម្មភាព ដូចជាបុគ្គល ដើម្បីជាផលប្រយោជន៍សាធារណៈ។[101]

នីតិបុគ្គលនេះទទួលសិទ្ធិអំណាចរបស់ខ្លួន ដោយរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និង លិខិតបទដ្ឋានដទៃទៀត ដែលស្របនឹងច្បាប់នេះ។[102]

ចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានបង្កើតឡើងសម្រាប់តែមនុស្សប៉ុណ្ណោះ។ ក្រមព្រហ្មទណ្ឌបានបញ្ចូលការទួលខុសត្រូវរបស់នីតិបុគ្គលនៅក្នុងមាត្រា ៤២ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិថា នៅក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិបុគ្គល លើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើស ដែលប្រព្រឹត្តដោយអង្គការ ឬ អ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍ របស់នីតិបុគ្គល។ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល ក្នុងអំពើដដែលនោះទេ។

ដោយអនុលោមតាមមាត្រា ៤២ នៃក្រមព្រហ្មទណ្ឌ នីតិបុគ្គលគ្រប់ប្រភេទសុទ្ធតែអាចទទួលខុសត្រូវព្រហ្មទណ្ឌ រួមបញ្ចូលតាំងនីតិសាធារណៈផងដែរ។ ប៉ុន្តែរដ្ឋដែលជានីតិបុគ្គលសាធារណៈមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។

ដែលជានីតិបុគ្គលសាធារណៈមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ព្រោះថានៅក្នុងនីតិរដ្ឋធម្មនុញ្ញ និងនីតិអន្តរជាតិសាធារណៈគេឲ្យនិយមន័យរដ្ឋតាមបែបសង្គមសាស្ត្រដូចតទៅ រដ្ឋជាសង្គមនយោបាយ មួយគឺមានន័យថា ជាក្រុមប្រជាជនមួយក្រុមដែលស្ថិតនៅក្រោមអំណាចនយោបាយរួមមួយ ក្នុងព្រំដែនទឹក ដីមួយដែលមាន កំណត់។ រដ្ឋជាក្រុមមនុស្សដែលរស់នៅលើទឹកដីមួយ និងមានការដឹកនាំដោយអំណាច នយោបាយមួយ។ ពាក្យរដ្ឋ

[100] សាស្ត្រចារ្យ ហៀង សាង ,រៀបរៀង សៀវភៅនីតិរដ្ឋបាល (បោះពុម្ពលើកទី៦ ឆ្នាំ២០២)៧។

[101] យោងតាមសន្ធានុក្រមនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

[102] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នស/រកម/០៣០១/០៥,០៩ មីនា ២០០១ ,មាត្រា ១៣។

គឺសំដៅទៅលើអំណាចដែលស្ថិតនៅលើអង្គការទាំងបី គឺអង្គការនយោបាយ អង្គការរដ្ឋបាល និង អង្គការតុលាការ។[103]ហេតុនេះហើយក្រមព្រហ្មទណ្ឌគឺមិនអាចចែងដើម្បីរំលាយ រដ្ឋ ប្រទេសមួយបានឡើយ ដោយសារតែរដ្ឋជាអ្នកគ្រប់គ្រងសង្គម ហើយរដ្ឋជាអ្នកបង្កើតច្បាប់ដើម្បីដាក់ទោសទៅលើសមាជិក សង្គម ណាមួយបានប្រព្រឹត្តបទល្មើស។

នីតិបុគ្គលដែលជារដ្ឋទទួលខុសត្រូវព្រហ្មទណ្ឌក្នុងករណីបទល្មើសដែលយុត្តាធិការតុលាការ ICC ករិតដែនកំណត់ចំពោះបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរបំផុតដែលធ្វើឲ្យមានការព្រួយបារម្ភដល់សហគមន៍អន្តរជាតិទាំងមូល។ តុលាការមានយុត្តាធិការអនុឡោមតាមច្បាប់លក្ខន្តិកៈនេះចំពោះបទល្មើសព្រហ្មទណ្ឌដូចជាៈ

១-បទល្មើសព្រហ្មទណ្ឌប្រល័យពូជសាសន៍

២-បទល្មើសព្រហ្មទណ្ឌប្រឆាំងនឹងមនុស្សជាតិ

៣-បទល្មើសព្រហ្មទណ្ឌសង្គ្រាម

៤-បទល្មើសព្រហ្មទណ្ឌនៃការឈ្លានពាន។[104]

**កថាភាគទី២៖ នីតិបុគ្គលនៃនីតិឯកជន**

នីតិបុគ្គលឯកជន គឺជាក្រុមមនុស្ស ឬមូលនិធិ ដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់ នៃសិទ្ធិ និងកាតព្វកិច្ចដែលស្ថិតក្រោមវិធានទាំងឡាយ ដែលគ្រប់គ្រងទំនាក់ទំនងគតិយុត្ត រវាងបុគ្គលឯកជន និង បុគ្គល ឯកជន ហើយស្ថិតក្រោមនីតិសាធារណៈទេ។ហើយនីតិបុគ្គលឯកជន ជាបណ្តុំនៃរូបវន្តបុគ្គលដែលបង្កើតឡើង ដោយច្បាប់ ក្នុងគោលដៅស្វែងរក ផលចំណេញ និង បម្រើផលប្រយោជន៍រូបវន្តបុគ្គល ដែលជាសមាជិករបស់ ខ្លួន។

ទោសមួយចំនួនអាចអនុវត្តចំពោះនីតិបុគ្គលដូចជាទោសពិន័យជាប្រាក់ក្នុងនាមមូលទោស ឬការដកហូតសិទ្ធិក្នុងនាមជាទោសបន្ថែម[105]។ទោសមួយចំនួនទៀតមិនអនុវត្តចំពោះនីតិបុគ្គលបាននោះឡើយ ដូចជាទោសដាក់ពន្ធនាគារ ឬទោសការងារសហគមន៍។នីតិបុគ្គលក៏អាចត្រូវបានរំលាយដោយតុលាការបាន។ ដូចនេះទោសដែលអនុវត្តចំពោះរូបវន្តបុគ្គលនិងនីតិបុគ្គលគឺខុសគ្នាដោយយោងទៅតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា[106]។នៅក្នុងមាត្រា ១៦៧ ដល់ មាត្រា១៨២ ក្នុងជំពូកទី៧ មាតិកាទី៣ គន្ថីទី១ នៃក្រម ព្រហ្មទណ្ឌបានចែងអំពីរបបនៃទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល។

103 សាស្ត្រាចារ្យ សុខ ចិន្តា,រៀបរៀង សៀវភៅនីតិរដ្ឋធម្មនុញ្ញ(ពុម្ពលើកទី២ ឆ្នាំ ២០២១ )២០។

104 មាត្រា ៥ នៃលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

105 ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ១៦៧ ។

106 ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ១៨២ ។

**កថាភាគទី៣៖ មូលទោសពិន័យក្នុងឋានៈជាមូលទោស**

នីតិបុគ្គលទទួលរងនៅទោសពិន័យក្នុងឋានៈជាមូលទោស។ទោសពិន័យក្នុងឋានៈជាមូលទោសនេះ មិនមែនមានន័យថា រាល់បទល្មើសដែលបានចោទប្រកាន់ទៅលើនីតិបុគ្គលនេះជាបទលហុនោះ ទេ។ បទល្មើសដែលត្រូវបានប្រព្រឹត្តដោយនីតិបុគ្គល ត្រូវបានចាត់ទុកជាបទល្មើស បទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ វាអាស្រ័យទៅតាមទម្ងន់នៃបទល្មើសនីមួយៗដែលច្បាប់តម្រូវឲ្យនីតិបុគ្គលទទួលខុសត្រូវ។

ចំពោះបែបបទដែលមានចែងទាក់ទងជាមួយនិងទោស យើងឃើញថា ទោសពិន័យក្នុងឋានៈ ជា មូលទោសនេះយើងប្រើប្រាស់ដូចគ្នា ជាមួយនិងទោសពិន័យសម្រាប់រូបវន្តបុគ្គល។

**កថាភាគទី៤៖ ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល**

ទោសបន្ថែម ជាទោសដែលតុលាការសម្រេចក៏បាន មិនសម្រេចក៏បាន លើកលែងតែច្បាប់ តម្រូវឲ្យប្រកាសជាកាតូកិច្ច បន្ថែមលើមូលទោស។ ជាទោសដែលតុលាការមិនអាច សម្រេចដាច់តែឯងបានទេ គឺថាតុលាការ នឹងសម្រេចទោសបន្ថែមណាមួយបាន លុះត្រាតែតុលាការបានសម្រេចពីមូលទោសណាមួយសិនពីព្រោះថាទោសបន្ថែមគ្រាន់តែជាកម្មវិបាកនៃមូលទោសប៉ុណ្ណោះ[107]។

តាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌទោសបន្ថែមដែលត្រូវអនុវត្តចំពោះនីតិបុគ្គលគឺមានចែងក្នុងមាត្រា ១៦៨ ដែលនៅក្នុងមាត្រានេះបានចែងទោសបន្ថែមត្រូវអនុវត្តទៅលើនីតិបុគ្គលទាំង ១៤ ចំណុច[108]។

[107] សាស្ត្រាចារ្យ មីន សំអុល ,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ ២០២០),៩៨។

[108] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ១៦៧

# ជំពូកទី៣
# ស្ថានទម្ងន់ទោស និងស្ថានសម្រាលទោស

# ជំពូកទី៣
# ស្ថានទម្ងន់ទោស និងស្ថានសម្រាលទោស

ចៅក្រមមានតួនាទីជាអ្នកអនុវត្តច្បាប់ ដោយមិនត្រូវដាក់ទោសតិចជាងអប្បរមានៃទោស ឬច្រើនជាងអតិបរមានៃទោស ដែលបានកំណត់ដោយច្បាប់នោះឡើយ។ ក៏ប៉ុន្តែនៅមានស្ថានភាពមួយចំនួន ដែលអនុញ្ញាតឲ្យចៅក្រមអាចធ្វើផ្ទុយពីអ្វីដែលបានបរិយាយខាងលើនេះបាន។ដោយនៅក្នុងបរិបទនេះចៅក្រម ត្រូវគិតគូរអំពីស្ថានទម្ងន់ទោស និងស្ថានសម្រាលទោស ។[109]

## ផ្នែកទី១ ស្ថានទម្ងន់ទោស

ស្ថានទម្ងន់ទោសគឺជាស្ថានភាពមួយដែលច្បាប់បានចែងយ៉ាងជាក់លាក់ ហើយកាលបើផ្សាភ្ជាប់ទៅនឹងអំពើដែលបានបង្កជាបទល្មើស នឹងធ្វើឲ្យទោសដែលតុលាការត្រូវផ្តន្ទាកាន់តែមានសភាពធ្ងន់ធ្ងរឡើង។[110]

ស្ថានទម្ងន់ទោសសំដៅលើស្ថានភាពបន្ទាប់បន្សំដោយឡែកដែលនាំឲ្យមានការបន្ថែមទម្ងន់ទោសតាម រយៈសេចក្តីសម្រេចរបស់តុលាការដែលសម្រេចឲ្យជនជាប់ចោទទទួលនូវទោសជាអតិបរមាកាលណាកាលៈ ទេសៈនៃបទល្មើស ឬ បុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ។ការសម្រេចដាក់ទម្ងន់ទោសទៅលើជន ជាប់ចោទណាម្នាក់ ជាសិទ្ធិរបស់ចៅក្រមដែលត្រូវពិនិត្យ ពិចារណា ថ្លឹងថ្លែងឲ្យបានល្អិតល្អន់ នូវរាល់ កាលៈទេសៈនៃ បទល្មើស។

***ឧទាហរណ៍៖*** កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ១០ និង៣០នាទី មុនពេលកើតហេតុជនជាប់ចោទមានឈ្មោះ **ក** ភេទប្រុស អាយុប្រហែល២០ឆ្នាំ ជិះម៉ូតូម៉ាក ហុងដាសេ១២៥ ពណ៌ខ្មៅ ផលិតឆ្នាំ២០២៣ ពាក់ផ្លាកលេខ ភ្នំពេញ ដែលជាបក្សពួកបានមកឌុបជនជាប់ចោទឈ្មោះ **ខ** ភេទប្រុស អាយុ១៩ឆ្នាំ និងឈ្មោះ **គ** ភេទប្រុស អាយុ ប្រហែល២១ឆ្នាំ ដែលជាបក្សពួកម្នាក់ទៀតក៏បាន ជិះម៉ូតូមួយគ្រឿងម៉ាក ហុងដាសេ១២៥ ពណ៌ខ្មៅ ផលិតឆ្នាំ២០១៦ មិនចាំផ្លាកលេខ ជិះចេញពីផ្ទះជួល គ្មានលេខ ស្ថិតនៅ ភូមិA សង្កាត់B ខណ្ឌC រាជធានីភ្នំពេញ លុះជិះមកដល់ចំណុចមុខសម្តពណ្យប៉ែល ស្ថិតនៅផ្លូវលេខ 0 ភូមិ0 សង្កាត់C ខណ្ឌD រាជធានីភ្នំពេញ ជនត្រូវចោទឈ្មោះ **ក** បានបើកម៉ូតូទៅពីក្រោយអែបខាងឆ្វេង ដៃជនរងគ្រោះឈ្មោះ S ភេទស្រី អាយុ៣៥ឆ្នាំ បន្ទាប់មកជនជាប់ចោទឈ្មោះ **ខ** បានធ្វើសកម្មភាព ឆក់យកខ្សែករផ្លាកទីនរបស់ជនរងគ្រោះបានសម្រេច ខណៈនោះជនរងគ្រោះស្រែកថាចោរៗ និងចាប់ទាញដៃរបស់ ជនជាប់ចោទឈ្មោះ **ខ** បណ្តាលឲ្យដួលម៉ូតូភ្លាមនោះឈ្មោះ **ក** បានរត់ឡើងជិះម៉ូតូជាមួយ ជនជាប់ចោទឈ្មោះ **គ** ហើយគេចខ្លួនបាត់ ចំណែកជនជាប់ចោទ

[109] សាស្ត្រចារ្យ មីន សំអុល ,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ ២០២០),៥៥។

[110] សាស្ត្រចារ្យ មីន សំអុល ,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ ២០២០),៥៩។

ឈ្មោះ ខ ត្រូវបានសមត្ថកិច្ច ដែលល្បាតនៅជិតនោះធ្វើការឃាត់ខ្លួន និងបញ្ជូនខ្លួនមកប៉ុស្តិ៍នគរបាលរដ្ឋបាលទំនប់ទឹក ហើយជនរងគ្រោះក៏បានដាក់ ពាក្យបណ្ដឹង ដើម្បីឲ្យសមត្ថកិច្ចចាត់ការតាមនីតិវិធីតែម្ដង ។

ហេតុដូច្នេះតុលាការ ផ្ដន្ទាទោសឈ្មោះ ខ ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារ កំណត់រយៈពេល ០៣ឆ្នាំ ០៦ខែ (បីឆ្នាំប្រាំមួយខែ) ។ពីបទលួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខសម្ភពណ្ឌប៉ែល ស្ថិតនៅផ្លូវលេខ0 ភូមិ0 សង្កាត់C ខណ្ឌD រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។[111]

***ឧទាហរណ៍៖*** កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ នៅចំណុចមុខធនាគារ M BANK អាគារលេខ៤៣ ភូមិ០៩ សង្កាត់A ខណ្ឌB រាជធានីភ្នំពេញ មានករណី» លួចមានស្ថានទម្ងន់ទោស (ឆក់ខ្សែរក) មួយបានកើតឡើងដែលបង្ក ឡើងដោយជនត្រូវចោទឈ្មោះ **ក** ភេទប្រុស អាយុ២៣ឆ្នាំ (ឃុំខ្លួន) និង ជនត្រូវចោទឈ្មោះ **ខ** ភេទប្រុស អាយុ២៤ឆ្នាំ (គេចខ្លួន) ។ កាលកំឡុងថ្ងៃកើតហេតុ ជនសង្ស័យឈ្មោះ **ក** ភេទប្រុស អាយុ២៣ឆ្នាំ បានដើរចេញទៅម្ដុំផ្សារអំពៅ ដើម្បីទិញទឹកក្រឡុក ពេលទៅដល់ក៏បានជួបជាមួយជនសង្ស័យឈ្មោះ **ខ** ភេទប្រុស ដោយជិះម៉ូតូម៉ាក ហុងដា សេ១២៥ ពណ៌ខ្មៅ មិនចាំផ្លាកលេខបន្ទាប់ពីនិយាយគ្នាបានមួយសន្ទុះក៏បានបបួលគ្នាជិះម៉ូតូឆក់ទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋតាមដងផ្លូវដោយជនសង្ស័យឈ្មោះ**ខ**ជាអ្នកបើកម៉ូតូហើយជនសង្ស័យឈ្មោះ **ក** ជាអ្នកអង្គុយពីក្រោយ លុះជិះមកដល់ចំណុច កើតហេតុខាងលើជនសង្ស័យឈ្មោះ **ខ** បានឲ្យជនសង្ស័យឈ្មោះ **ក** ចុះពីលើម៉ូតូទៅឆក់ខ្សែរកពីជនរងគ្រោះដែលកំពុងតែឈរនោះហើយជនសង្ស័យឈ្មោះ **ក** បានដើរទៅជិតជនគ្រោះនោះបម្រុងនិងឆក់ខ្សែរកទៅហើយតែជនរងគ្រោះក៏បានដឹងខ្លួនទាន់ហើយក៏បានស្រែកឆោឡោភ្លាមនោះជនសង្ស័យឈ្មោះ**ខ** ក៏បានជិះម៉ូតូគេចខ្លួនបាត់ស្របពេលនោះក៏មានកម្លាំងសមត្ថកិច្ចល្បាតរបស់ប៉ុស្តិ៍នគរបាលរដ្ឋបាលផ្សារថ្មីឃើញនិងបានអន្តរាគមន៍ឃាត់ខ្លួនជនសង្ស័យនាំទៅកាន់ប៉ុស្តិ៍នគរបាលរដ្ឋបាលផ្សារថ្មី៣ដើម្បីសាកសួរតែម្ដងនៅចំពោះមុខសមត្ថកិច្ចជនសង្ស័យបានឆ្លើយសារភាពថា៖ នៅថ្ងៃកើត ហេតុរូបខ្លួននិងបក្ខពួកឈ្មោះ **ខ** ពិតជាបានធ្វើសកម្មភាពឆក់ខ្សែកជនរងគ្រោះប្រាកដមែន ។

ហេតុដូច្នេះតុលាការផ្ដន្ទាទោស ឈ្មោះ **ក** ភេទប្រុស អាយុ២៣ឆ្នាំ កើតឆ្នាំ១៩៩៨ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៣ (បី) ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោស (ឆក់ខ្សែក) ប្រព្រឹត្តនៅចំណុចមុខធនាគារ M BANK អាគារលេខ៤៣ ភូមិ០៩ សង្កាត់A ខណ្ឌB រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ បទល្មើស ដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។[112]

[111] សាលក្រមសាលាដំបូងរាជធានីភ្នំពេញ , លេខ៥៨(ឃ)ចុះថ្ងៃទី ២២ ខែមករា ឆ្នាំ២០២៤

[112] សាលក្រមសាលាដំបូងរាជធានីភ្នំពេញ , លេខ៥១៦(ឃ)ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០២២

នៅក្នុងការកំណត់ស្ថានទម្ងន់ទោសនេះគឺឈរលើគោលការណ៍ពីរគឺៈ

-ចរិតលក្ខណៈនៃស្ថានទម្ងន់ទោស

-ការមិនរាងចាល

**កថាភាគទី១ៈ ចរិតលក្ខណៈនៃស្ថានទម្ងន់ទោស**

នៅក្នុងរឿងក្តីព្រហ្មទណ្ឌមូលដ្ឋាននៃគោលការណ៍នីត្យានុកូលភាពដែលត្រូវបង្កើតឡើង ដើម្បីការពារសិទ្ធិសេរីភាពបុគ្គលក្នុងការធ្វើសកម្មភាពផ្សេងៗ។ដែលក្រមព្រហ្មទណ្ឌបានចែងយ៉ាងច្បាស់នូវ គោលការណ៍នីត្យានុកូលភាព ដែល អំពើមួយដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះ មានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន។មានតែទោសដែល មានចែងនៅក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តិប៉ុណ្ណោះ ទើបអាចប្រកាសបាន។[113]

ចំពោះការប្រកាសទោសរបស់តុលាការ គឺតុលាការតែងតែ ពិនិត្យ ពិចារណា ថ្លឹងថ្លែងទៅលើស្ថានទម្ងន់ទោស និងស្ថានសម្រាលទោសចំពោះចរិកគ្រោះថ្នាក់នៃអំពើនោះ ដែលជនល្មើសបានប្រព្រឹត្ត។

ដោយអនុលោមតាមមាត្រា ៧៧ ដល់មាត្រា៨២ នៃក្រមព្រហ្មទណ្ឌ តុលាការអាចប្រកាសផ្តន្ទាជា អតិបរមាបាននៃទោសបាន កាលបើជនជាប់ចោទបានប្រព្រឹត្តបទល្មើសក្នុងកាលៈទេសៈណាមួយដូចខាងក្រោមៈ

-ក្រុមមានការចាត់តាំង

-ការគិតទុកជាមុន

-ការកាប់គាស់ទម្លុះទម្លាយ

-ការផ្លោះរបងចូល

-អាវុធ និងវត្ថុដែលត្រូវបានចាត់ទុកដូចអាវុធ

-ការពួនស្ទាក់។

**១.ក្រុមមានការចាត់តាំង**

ក្រុមមានការចាត់តាំង គឺជាការប្រមូលផ្តុំដែលបង្កើតឡើង ឬ ជាសន្និដ្ឋិភាពដែលបានធ្វើឡើងដើម្បីត្រៀម រៀបចំ ឬ ប្រព្រឹត្តបទល្មើសមួយ ឬ ច្រើន។[114]

***ឧទាហរណ៍ៈ*** ឈ្មោះ **(ក)** ឈ្មោះ **(ខ)** និងឈ្មោះ **(គ)** បានប្រមូលផ្តុំគ្នា ហើយរៀបចំសកម្មភាពធ្វើការទិញលក់វត្ថុដែលខ្លួនបានទិញក្នុងតម្លៃថោកៗពីចោរ ទៅលក់ដើម្បីបានប្រាក់ចំណេញចែកគ្នា ដោយនៅក្នុងសកម្មភាពនេះ ឈ្មោះ **(ក)** ជាអ្នកដើរប្រមូលទិញ ឈ្មោះ **(ខ)** ជាអ្នកយកទៅលាក់ទៅលាក់នៅក្នុងផ្ទះរបស់គាត់ ហើយមួយរយៈក្រោយមក ឈ្មោះ **(គ)** ជាអ្នកយកវត្ថុទាំងនោះទៅលក់យកប្រាក់ចំណេញ ។ អំពើរបស់ឈ្មោះ

[113] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៣ ។

[114] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៧៧ ។

**(ក)** ឈ្មោះ **(ខ)** និងឈ្មោះ **(គ)** ជាបទទទួលផលចោរកម្ម ដែលប្រព្រឹត្តឡើងជាក្រុមមានការចាត់តាំង ហើយត្រូវផ្តន្ទាទោសតាមមាត្រា **៤០១** នៃក្រមព្រហ្មទណ្ឌ។[115]

**២.ការគិតទុកជាមុន**

ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមុនសកម្មភាពប្រព្រឹត្តបទល្មើស។[116]

***ឧទាហរណ៍៖*** ឈ្មោះ (ក) មានគំនុំគុំគួនជាមួយនឹងឈ្មោះ (ខ) ដោយសារតែទំនាស់រឿងព្រំដី ។ ដើម្បីបន្ធូរកំហឹងរបស់ខ្លួន ឈ្មោះ (ក) បានរៀបចំគម្រោងថានឹងចាំលបវាយឈ្មោះ (ខ) នៅថ្ងៃស្អែកតាមដងផ្លូវ នៅពេលដែលឈ្មោះ (ខ) វិលត្រឡប់មកពីកន្លែងធ្វើការវិញ។ លុះដល់ស្អែកឡើង នៅវេលាម៉ោងប្រហែល ៨ យប់ ឈ្មោះ (ក) បានបិទមុខ ស្លៀកសំលៀកបំពាក់ពណ៌ខ្មៅ នៅរង់ចាំឈ្មោះ (ខ) តាមដងផ្លូវតាមការគ្រោងទុក។ ក្នុងខណៈដែលឈ្មោះ (ខ) បានមកដល់ ឈ្មោះ (ក) បានចេញស្ទាក់ ហើយដាល់ឈ្មោះ (ខ) ចំនួនពីរដៃបណ្តាលឲ្យរងរបួស ហើយក៏គេចខ្លួនចេញទៅវិញបាត់។ អំពើរបស់ឈ្មោះ (ក) ជាបទ ហិង្សាដោយចេតនា ក៏ប៉ុន្តែអំពើនេះបានប្រព្រឹត្តដោយមានការគិតទុកជាមុន ព្រោះថាឈ្មោះ (ក) បាននឹកគិតអំពីគម្រោងរបស់ខ្លួនថាត្រូវធ្វើយ៉ាងដូចម្តេចរួច ហើយទើបធ្វើសកម្មភាពជាក្រោយ។ បើតាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ បទហិង្សាដោយចេតនាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ឆ្នាំ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២លានរៀល ទៅ ៦លានរៀល។ ផ្ទុយទៅវិញ ក្នុងករណីមានការគិតទុកជាមុន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ឆ្នាំ ទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី៤លានរៀល ទៅ ១០លានរៀល ។[117]

***ឧទាហរណ៍៖*** ស្ត្រីឈ្មោះ **ក** ជាភរិយាបានរៀបចំផែនការជួលឃាតកក្នុងតម្លៃ១,០០០ដុល្លារ ដើម្បីបញ្ចប់ជីវិតប្តីខ្លួនឯងរួចយកសពទៅបោះចោលក្នុងប្រឡាយនៅស្រុកA ខេត្តB។ រំលងបានប៉ុន្មានថ្ងៃជនជាប្រពន្ធ និងឃាតកស៊ីឈ្នួលត្រូវបានកម្លាំងនគរបាលរួមដៃគ្នារវាង នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ, នគរបាលរាជធានីC និងខេត្តB ស្រាវជ្រាវឈានដល់ការបង្ក្រាបបាន នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៣។

តាមចម្លើយសារភាពរបស់ឈ្មោះ**ក**(ប្រពន្ធជនរងគ្រោះ)បានឆ្លើយសារភាពថាខ្លួនបានរៀបគម្រោងដើម្បីសម្លាប់ប្តីរបស់ខ្លួនដោយជួលឈ្មោះ**ខ** អាយុ៣៣ឆ្នាំ មុខរបរបើកឡានក្រឡុកស៊ីម៉ង់ មានទីលំនៅភូមិX សង្កាត់X ខណ្ឌX រាជធានីC ក្នុងតម្លៃ១,០០០ដុល្លារ ក្រោយពីរៀបចំគម្រោងរួចលុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង០៦៖០០ល្ងាចនាទី ខ្លួនបានឲ្យឈ្មោះ **ខ** មកពួននៅក្នុងផ្ទះរបស់ខ្លួន។

[115] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣៦៨។

[116] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៧៨ ។

[117] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣៧១។

មូលហេតុនៃការរៀបចំគម្រោងសម្លាប់ប្តីតាមការបញ្ជាក់របស់ប្រពន្ធឈ្មោះ **ក** បានឲ្យដឹងថាៈ ប្តីរបស់ខ្លួនឈ្មោះ **គ** ដើរលេងចោលផ្ទះពីរ ឬបីថ្ងៃទើបមកផ្ទះម្តង ពេលមកដល់យប់ជ្រៅរករឿងវៃប្រពន្ធរហូត ហេតុដូចនេះហើយក៏ជួលគេ១,០០០ដុល្លារ ឲ្យសម្លាប់ប្តី។

ដូចនេះតុលាការផ្តន្ទាទោសតាមមាត្រា២០០នៃក្រមព្រហ្មទណ្ឌ «បទឃាតកម្មគិតទុកជាមុន» ឃាតកម្មគិតទុកជាមុន គឺអំពើសម្លាប់មនុស្សដោយគិតទុកជាមុន ឬដោយការពួនស្ទាក់។ ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមុនអំពើបៀតបៀន ទៅលើរូបបុគ្គលនៃជនរងគ្រោះ។ ការពួនស្ទាក់ជាអំពើឃ្លាំចាំបុគ្គលណាម្នាក់ក្នុងរយៈពេលមួយរយៈ ដើម្បីប្រព្រឹត្តអំពើបៀតបៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ។ ឃាតកម្មគិតទុកជាមុនត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។[118]

**៣.ការកាប់គាស់ទម្លុះទម្លាយ**

ការកាប់គាស់ទម្លុះទម្លាយគឺជាអំពើបង្ខំធ្វើឲ្យខូចខាត ឬ បំផ្លិចបំផ្លាញគ្រឿងបិទទ្វារ ឬ របង ទោះបីមានប្រភេទយ៉ាងណាក៏ដោយ។

ត្រូវបានចាត់ទុកដូចជាការកាប់គាស់ទម្លុះទម្លាយៈ

-ការប្រើប្រាស់កូនសោក្លែង។

-ការប្រើប្រាស់កូនសោដែលបានមកដោយឧបាយកលទុច្ចរិត។

-ការប្រើប្រាស់គ្រប់ឧបករណ៍ ដើម្បីធ្វើឲ្យគ្រឿងបិទមានដំណើរការដោយគ្មានការបង្ខំ ការខូចខាត ឬ ការបំផ្លិចបំផ្លាញទេ។[119]

***ឧទាហរណ៍៖*** អំពើលួចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០៦ ខែ ទៅ ០៣ ឆ្នាំ និងពិន័យជាប្រាក់ពី ១លានរៀល ទៅ ៦លានរៀល តាមមាត្រា ៣៥៦ នៃ ក្រមព្រហ្មទណ្ឌ ។ ក៏ប៉ុន្តែ បើក្នុងករណីដែលអំពើលួចនេះប្រព្រឹត្តដោយមានការកាប់គាស់ទម្លុះទម្លាយ ដូចជាការគាស់ទ្វារចូលផ្ទះ ដើម្បីបានចូលយកទ្រព្យសម្បត្តិរបស់ជនរងគ្រោះ អំពើនេះតម្រូវឲ្យផ្តន្ទាទោសដាក់ពន្ធនាគារពី ០៣ឆ្នាំ ទៅ ១០ឆ្នាំ តាមអត្ថន័យនៃមាត ៣៥៧ នៃក្រមព្រហ្មទណ្ឌ។ [120]

***ឧទាហរណ៍៖*** ការប្រើប្រាស់ឧបករណ៍បច្ចេកទេសទំនើបដែលធ្វើឲ្យទូរសុវត្ថិភាពរបើកដោយឯកឯង ត្រូវចាត់ទុកជាការកាប់គាស់ទម្លុះទម្លាយដែរ។[121]

[118] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ២០០ ។

[119] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៧៩ ។

[120] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញៈ រោងពុម្ពជោគជ័យ,២០១២),៣៦៨។

[121] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញៈ រោងពុម្ពជោគជ័យ,២០១២),៣៦៩។

**៤.ការផ្លោះរបងចូល**

ការផ្លោះរបងចូល គឺជាអំពើចូលទៅក្នុងទីកន្លែងណាមួយដោយឆ្លងរបង ឬដោយចូលតាមទ្វារ ឬបង្អួច ដែលមិនមែនសម្រាប់ធ្វើជាផ្លូវចូលទេ។[122]

**៥.អាវុធ និងវត្ថុដែលត្រូវបានចាត់ទុកដូចអាវុធ**

អាវុធ គឺជាវត្ថុទាំងអស់ដែលធ្វើឡើងដើម្បីសម្លាប់ ឬ ធ្វើឲ្យមានរបួស។

ត្រូវបានចាត់ទុកដូចជាអាវុធ វត្ថុដទៃទៀត ដែលអាចធ្វើឲ្យមានគ្រោះថ្នាក់ដល់មនុស្សនៅក្នុងករណីដូចតទៅ៖

-វត្ថុត្រូវបានប្រើប្រាស់សម្រាប់សម្លាប់ ធ្វើឲ្យរបួស ឬគំរាមកំហែង។

-វត្ថុមានទីដៅសម្រាប់សម្លាប់ ធ្វើឲ្យរបួស ឬ គំរាមកំហែង។

ការប្រើប្រាស់សត្វដើម្បីសម្លាប់ ធ្វើឲ្យមានរបួស ឬ គំរាមកំហែង ត្រូវចាត់ទុកដូចបានប្រើប្រាស់ អាវុធដែរ។[123]

***ឧទាហរណ៍៖*** ការកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤ លានរៀល ទៅ១០លានរៀល តាមមាត្រា ៣៦៤ នៃក្រមព្រហ្មទណ្ឌ។[124] ក៏ប៉ុន្តែបើក្នុងករណីដែលអំពើកំហែងយកត្រូវបានប្រព្រឹត្តឡើងដោយមានការប្រើប្រាស់អាវុធ ឬដោយការគំរាមកំហែងនឹងអាវុធ (ដូចជាការប្រើប្រាស់កូនកាំបិតដើម្បីគំរាមកំហែងជាដើម) ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ៧ឆ្នាំ ទៅ ១៥ឆ្នាំ តាមខ្លឹមសារនៃមាត ៣៦៦ នៃក្រមព្រហ្មទណ្ឌ។[125]

**៦.ការពួនស្ទាក់**

ការពួនស្ទាក់ គឺជាអំពើឃ្លាំចាំជនរងគ្រោះនៅទីកន្លែងណាមួយ ក្នុងរយៈពេលមួយរយៈដើម្បីប្រព្រឹត្ត បទល្មើស។[126]

***ឧទាហរណ៍៖*** បទឃាតកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ តាមអត្ថន័យមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ។[127] ក៏ប៉ុន្តែបើក្នុងករណី ដែលអំពើសម្លាប់មនុស្សដោយការពួនស្ទាក់ មាត្រា ២០០ នៃ

---

[122] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៨០ ។

[123] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៨១ ។

[124] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៣៦៤ ។

[125] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៣៦៦ ។

[126] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៨២ ។

[127] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ១៩៩ ។

ក្រមព្រហ្មទណ្ឌ តម្រូវឲ្យផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត (ក្រោមបទល្មើសឈ្មោះថាបទឃាតកម្មគិតជាមុន )។[128]

**កថាភាគទី២៖ ការមិនរាងចាល**

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា គឺជាបណ្តុំនៃបទបញ្ញត្តិព្រហ្មទណ្ឌមួយ ដែលក្នុងនោះខ្លឹមសារ ជារួមផ្តោតទៅលើសញ្ញាណបទល្មើស ទោសដែលត្រូវផ្តន្ទាទោស ក៏ដូចជាវិធានព្រហ្មទណ្ឌមួយចំនួនទៀត។ គោលបំណងនៃការបង្កើតបទបញ្ញត្តិព្រហ្មទណ្ឌនេះ គឺដើម្បីផ្តន្ទាទោសចំពោះបុគ្គលទាំងឡាយណាបានប្រព្រឹត្ត អំពើដែលបង្កគ្រោះថ្នាក់ដល់សង្គមជាតិ ក៏ដូចជាទប់ស្កាត់កុំឲ្យកើតមានការប្រព្រឹត្តអំពើល្មើសជាបន្តបន្ទាប់ទៀត។

ក្នុងនោះដែរ មានបទបញ្ញត្តិពិសេសមួយ ដើរតួនាទីសំខាន់ផងដែរក្នុងការទប់ស្កាត់កុំឲ្យបទល្មើស ព្រហ្មទណ្ឌកើតមានជាថ្មី គឺបទបញ្ញត្តិស្តីពីការមិនរាងចាល ដែលមានន័យថាបុគ្គលម្នាក់បានផ្តន្ទាទោស ជាស្ថាពរលើបទល្មើសមួយ ហើយបុគ្គលនោះបានប្រព្រឹត្តបទល្មើសជាថ្មីទៀតនៅក្នុងកំឡុងពេលមួយ គឺចូលក្នុងលក្ខខណ្ឌនៃការមិនរាងចាល ដែលនឹងត្រូវបន្ថែមទម្ងន់ទោសចំពោះបទល្មើសថ្មីនោះ។

បទបញ្ញត្តិស្តីអំពីការមិនរាងចាលត្រូវបាន កំណត់ក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដោយក្នុងនោះ សញ្ញាណជារួមនៃការមិនរាងចាល សំដៅទៅលើស្ថានភាពដែលបុគ្គលម្នាក់បានប្រព្រឹត្តបទឧក្រិដ្ឋ ឬមជ្ឈិម និងត្រូវបានផ្តន្ទាទោសជាស្ថាពរ ហើយគាត់បានប្រព្រឹត្តបទឧក្រិដ្ឋ ឬមជ្ឈិមទៀត នៅក្នុងរយៈពេលមួយដែលក្រមព្រហ្មទណ្ឌបានកំណត់។ពាក្យថាផ្តន្ទាទោសស្ថាពរត្រង់ចំណុចនេះ គឺទាល់តែសេចក្តីសម្រេចផ្តន្ទាទោស នោះ មិនអាចមានផ្លូវតវ៉ាទៀត។

**១.អានុភាពនៃការមិនរាងចាល**

ការមិនរាងចាលមានអានុភាព នាំឲ្យមានការបន្ថែមទម្ងន់អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិម នៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងកថាភាគនេះ។[129] មានន័យថា ការមិនរាង ចាលនាំឲ្យមានការបន្ថែមទម្ងន់ទោសទៅលើអតិបរមានៃទោសដាក់ពន្ធនាគារដែលកំណត់ដោយច្បាប់។ទោះបីជាយ៉ាងណាក្តីអានុភាពនៃការមិនរាងចាល មិនបានធ្វើឲ្យមានការកែប្រែប្រភេទនៃបទល្មើសពី បទមជ្ឈិម ទៅ បទឧក្រិដ្ឋឡើយ។[130]

---

[128] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ២០០ ។

[129] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៨៣ ។

[130] សាស្ត្រចារ្យ មីន សំអុល ,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ ២០២០),៦៣។

**២.លក្ខខណ្ឌនៃការមិនរាងចាល**

ចំពោះលក្ខខណ្ឌនៃការមិនរាងចាលត្រូវបានផ្តោតសំខាន់ទៅលើចំណុច២ គឺទីមួយបទល្មើសដែលបានផ្តន្ទាទោសស្ថាពរនិងបទល្មើសដែលបានប្រព្រឹត្តថ្មី និងទីពីរ គឺរយៈពេលដែលបុគ្គលនោះបានប្រព្រឹត្តបទល្មើសថ្មីបន្ទាប់ពីបានផ្តន្ទាទោសស្ថាពរលើបទល្មើសទី១។

អនុលោមតាមមាត្រា ៨៤ នៃក្រមព្រហ្មទណ្ឌ បានកំណត់អំពីលក្ខខណ្ឌនៃការមិនរាងចាលក្នុងករណីណាមួយដូចខាងក្រោម៖

- **កាលបើបុគ្គលណាម្នាក់ត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយ ពីបទឧក្រិដ្ឋ បុគ្គលនោះបានប្រព្រឹត្តបទឧក្រិដ្ឋថ្មីទៀតក្នុងរយៈពេល ១០ឆ្នាំ**

ជាការកត់សម្គាល់ ត្រូវធ្វើការកត់សម្គាល់ថា រយៈពេលនេះចាប់ផ្តើមគិតពីថ្ងៃដែលសេចក្តីសម្រេចរបស់តុលាការផ្តន្ទាទោសចំពោះបទល្មើសលើកទីមួយបានចូលជាស្ថាពររួចហើយ។

ក្នុងករណីដូចនេះ ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទ ឧក្រិដ្ឋថ្មីមិនលើសពី ២០ឆ្នាំ ទេ អតិបរមានេះត្រូវឡើងទ្វេដង។

***ឧទាហរណ៍៖*** សំខាន់ ត្រូវបានឃាត់ខ្លួន និងឃុំខ្លួនបណ្តោះអាសន្ននៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០០។ ឧបមាថាតុលាការបានសម្រេចផ្តន្ទាទោស សំខាន់ បទរំលោភសេពសន្ថវៈ តម្រូវឲ្យជាប់ពន្ធនាគារចំនួន ០៦ ឆ្នាំ។ បន្ទាប់មកសេចក្តីសម្រេចផ្តន្ទាទោសក៏បានចូលជាស្ថាពរនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០០១។ ចុងបញ្ចប់ ពោលគឺនៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៦ សំខាន់ ត្រូវបានដោះលែងឲ្យមានសេរីភាពឡើងវិញ បន្ទាប់ពីបានទទួលរងនូវការអនុវត្តទោសដាក់ពន្ធនាគាររួចរាល់ហើយ ស្រាប់តែប៉ុន្មានឆ្នាំក្រោយមកទៀត គឺនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ២០១០ សំខាន់ បានធ្វើឃាតលើគូសត្រូវរបស់ខ្លួនម្នាក់ទៀត ដោយសារទំនាស់ពាក្យសំដី ហើយត្រូវបានឃាត់ខ្លួនជាថ្មីម្តងទៀត។ ក្នុងករណីបែបនេះ គឺ សំខាន់ ស្ថិតក្នុងស្ថានភាពមិនរាងចាល ពីព្រោះថាបើគិតពីថ្ងៃទី១០ ខែមករា ឆ្នាំ២០០១ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១០ សំខាន់ បានប្រព្រឹត្តបទឃាតកម្មក្នុងរយៈពេល ១០ឆ្នាំ ដោយចាប់គិតពីថ្ងៃដែលសេចក្តីសម្រេចផ្តន្ទទោសរបស់តុលាការចំពោះបទល្មើសទី១ បានចូលជាស្ថាពររួចមក។ ជាលទ្ធផល អតិបរមានៃទោសដាក់ពន្ធនាគារចំពោះ បទឃាតកម្ម ដែលជាបទល្មើសថ្មី ត្រូវអនុវត្តទ្វេឡើង ពោលគឺតុលាការត្រូវគិតថា ទោសដាក់ពន្ធនាគារដែលត្រូវអនុវត្តលើ សំខាន់ សម្រាប់ បទឃាតកម្ម គឺចាប់ពីទោសដាក់ពន្ធនាគារចំនួន ១០ឆ្នាំ (អប្បបរមានៃទោស) ទៅ ៣០ឆ្នាំ (អតិបរមានទោស )។

ផ្ទុយទៅវិញ ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋ ថ្មីមានរយៈពេលរហូតដល់ ៣០ឆ្នាំ នោះអតិបរមានៃទោសគឺត្រូវដាក់ពន្ធនាគារ រហូតអស់មួយជីវិត។[131]

[131] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ ពាងពុម្ពជោគជ័យ,២០១២),៣៥៤។

***ឧទាហរណ៍៖*** នៅក្នុងសម្មតិកម្មខាងលើ ប្រសិនបើ សំខាន់ បានជ្រើសរើសធ្វើឃាតលើគូសត្រូវរបស់ខ្លួនដោយការប្រើថ្នាំពុលវិញ បទឧក្រិដ្ឋថ្មីនេះ នឹងត្រូវផ្តន្ទាទោសតាមមាត្រា ២០១ នៃក្រមព្រហ្មទណ្ឌ ដែលជាធម្មតាត្រូវផ្តន្ទទោសដាក់ពន្ធនាគារពី ១៥ ទៅ ៣០ ឆ្នាំ។ ក៏ប៉ុន្តែក្នុងករណីដែល សំខាន់ បានប្រព្រឹត្តបទល្មើសថ្មីក្នុងស្ថានភាពមិនរាងចាល តុលាការត្រូវគិតពិចារណាថា ទោសដាក់ពន្ធនាគារដែលត្រូវអនុវត្តលើរូប សំខាន់ សម្រាប់ បទឃាតកម្មដោយការច្ញើថ្នាំបំពុល គឺចាប់ពីទោសដាក់ពន្ធនាគារ ១៥ឆ្នាំ (អប្បបរមានៃទោស ) ទៅដល់ទោសដាក់ពន្ធនាគាររអស់មួយជីវិត ( អតិបរមានៃទោស )។[132]

- **កាលបើបុគ្គលណាម្នាក់ត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទឧក្រិដ្ឋ បុគ្គលនោះបានប្រព្រឹត្តបទមជ្ឈិមនៅក្នុងរយៈពេល ៥ឆ្នាំ**

ក្នុងករណីបែបនេះ អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទមជ្ឈិមដែលបានប្រព្រឹត្តថ្មីនូវឡើងទ្វេដង ទោះបីជាអតិបរមានៃទោសដាក់ពន្ធនាគារដែលទ្វេឡើងត្រូវលើសពី ៥ឆ្នាំ ក៏ដោយ ក៏បទល្មើសថ្មីនេះនៅតែជាបទមជ្ឈិមដដែល ។

***ឧទាហរណ៍៖*** បញ្ញា ត្រូវបានឃាត់ខ្លួន និងឃុំខ្លួនបណ្តោះអាសន្ននៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៥ តុលាការក៏បានសម្រេចផ្តន្ទាទោស សំខាន់ ពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ដោយតម្រូវឲ្យជាប់ពន្ធនាគារចំនួន ០៤ ឆ្នាំ ។ សេចក្តីសម្រេចផ្តន្ទាទោសបានចូលជាស្ថាពរនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៩ បញ្ញា ត្រូវបានដោះលែងឲ្យមានសេរីភាព បន្ទាប់ពីបានទទួលរងនូវការអនុវត្តទោសដាក់ពន្ធនាគាររួចរាល់ហើយ ស្រាប់តែក្រោយមកទៀត នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១០ បញ្ញា បានខ្ចីម៉ូតូពីមិត្តភក្តិរបស់ខ្លួន ហើយក៏បានយកទៅលក់យកប្រាក់ចាយអស់។

ដូច្នេះបទល្មើសដែល បញ្ញា បានប្រព្រឹត្ត ជាថ្មីនេះគឺជា **បទរំលោភលើទំនុកចិត្ត** ពោលគឺជាបទមជ្ឈិមដែលតាមមាត ៣៩២ នៃក្រមព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០៦ ទៅ ០៣ ឆ្នាំ និងពិន័យជាប្រាក់ពី ១លាន រៀល ទៅ ៦ លានរៀល។ ក៏ប៉ុន្តែដោយហេតុថា បញ្ញា ស្ថិតក្នុងស្ថានភាពមិនរាងចាល ទោសដែលត្រូវផ្តន្ទាលើរូប បញ្ញា សម្រាប់បទល្មើសថ្មីនេះគឺ ទោសដាក់ពន្ធនាគារពី ០៦ខែ (អប្បបរមានៃទោស) ទៅ ០៦ ឆ្នាំ (អតិបរមានៃទោស ) និងទោសពិន័យជាប្រាក់ពី ១លានរៀល ទៅ ៦លានរៀល។

ក្នុងករណីខាងលើនេះ ថ្វីត្បិតតអតិបរមានៃទោសដែលត្រូវផ្តន្ទាលើ បញ្ញា មានរយៈពេលរហូតដល់ ០៦ ឆ្នាំ ក៏ពិតមែន ក៏បទល្មើសនេះនៅតែជាបទមជ្ឈិមជាដដែល ពោលគឺមិនមែនជាបទឧក្រិដ្ឋនោះទេ។[133]

---

[132] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ ពាងពុម្ពជោគជ័យ,២០១២),៣៥៥។

[133] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ ពាងពុម្ពជោគជ័យ,២០១២),៣៥៦។

- **កាលបើបុគ្គលណាម្នាក់ត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទមជ្ឈិម ដោយត្រូវជាប់ពន្ធនាគារស្មើ ឬលើសពី ០៣ឆ្នាំ ហើយបុគ្គលនោះបានប្រព្រឹត្តបទឧក្រិដ្ឋជាថ្មី ក្នុងរយៈពេល ០៥ឆ្នាំ**

ក្នុងករណីខាងលើនេះ គេត្រូវពិនិត្យមើលទៅលើអតិបរមានៃទោសដែលច្បាប់បានកំណត់ ចំពោះបទឧក្រិដ្ឋដែលទើបតែប្រព្រឹត្តជាថ្មី។ ប្រសិនបើក្នុងករណីដែលអតិបរមានៃទោសចំពោះបទល្មើសថ្មីមិនលើសពី ២០ឆ្នាំ ទេ អតិបរមានៃទោសត្រូវឡើងទ្វេដង។ ផ្ទុយមកវិញ ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារ ចំពោះបទឧក្រិដ្ឋថ្មីមានរយៈពេល ៣០ឆ្នាំ នោះអតិបរមានៃទោសដែលត្រូវអនុវត្ត ក្នុងករណីមិនរាងចាល គឺតម្រូវឲ្យដាក់ពន្ធនាគារអស់មួយជីវិត ។

***ឧទាហរណ៍៖*** ជីវ៉ា ត្រូវបានតុលាការសម្រេចផ្តន្ទាទោសតម្រូវឲ្យជាប់ពន្ធនាគារចំនួន ០៣ឆ្នាំ ពីបទ **ហិង្សាដោយចេតនា** ដោយព្យួរទោសធម្មតា សេចក្តីសម្រេចផ្តន្ទាទោសនេះបានចូលជាស្ថាពរនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩។ លុះមកដល់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០ ជីវ៉ា បានប្រព្រឹត្ត **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការបក្តអំពើប្រើហិង្សា** ដែលតាមមាត ៣៥៧ នៃក្រមព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០៣ឆ្នាំ ទៅ ១០ឆ្នាំ។ ក្នុងករណីនេះ ទោសដែលតុលាការត្រូវផ្តន្ទាលើរូប ជីវ៉ា សម្រាប់បទល្មើសថ្មីគឺ ការដាក់ពន្ធនាគារ ០៣ឆ្នាំ (អប្បបរមានៃទោស ) ទៅ ២០ឆ្នាំ (អតិបរមានៃទោស )។

នៅក្នុងឧទាហរណ៍ដដែលខាងលើនេះ ប្រសិនបើ ជីវ៉ា ត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ២ឆ្នាំ **បទហិង្សាដោយចេតនា** វិញ ទោះបីជា ជីវ៉ា បានប្រព្រឹត្តបទឧក្រិដ្ឋជាថ្មីនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០ ក៏ដោយ ជីវ៉ា មិនមែនស្ថិតក្នុងភាពមិនរាងចាលដែរ ពីព្រោះថាអំពើរបស់ ជីវ៉ា មិនបានចូលត្រូវតាមលក្ខខណ្ឌដែលបានកំណត់នៅមាត ៨៧ នៃក្រមព្រហ្មទណ្ឌ ទេ ដូច្នេះសម្រាប់បទល្មើសថ្មីដែលប្រព្រឹត្តដោយ ជីវ៉ា តុលាការត្រូវផ្តន្ទាទោសតាមការកំណត់របស់ច្បាប់ជាធម្មតា។[134]

- **កាលបើបុគ្គលណាម្នាក់ ត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទមជ្ឈិម ហើយបុគ្គលនោះបានប្រព្រឹត្តបទមជ្ឈិមដដែលនៅក្នុងរយៈពេល ០៥ឆ្នាំ**

លុះត្រាតែជនល្មើសបានប្រព្រឹត្តបទមជ្ឈិមដដែល នៅក្នុងរយៈពេល ០៥ឆ្នាំ ដែលខុសពីករណីផ្សេងទៀតនៃការមិនរាងចាលដូចបានរៀបរាប់ខាងលើ ដោយក្រមព្រហ្មទណ្ឌពុំបានតម្រូវឲ្យមានការប្រព្រឹត្តបទល្មើសដដែល នោះឡើយ។

បញ្ហាដែលតែងតែចោទឡើងសម្រាប់ការអនុវត្ត គឺការវាយតម្លៃថាបទមជ្ឈិមថ្មីបែបណាដែលជា បទមជ្ឈិមដដែលនោះ ? ប្រសិនបើបទមជ្ឈិមទីមួយដែលជនល្មើសបានប្រព្រឹត្តគឺជា **បទលួច** ហើយបទមជ្ឈិមទីពីរក៏ជា **បទលួច** ដែរនោះ បានសេចក្តីថាបទមជ្ឈិមថ្មីនេះគឺពិតជាបទមជ្ឈិមដដែល ហើយ។

---

[134] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣៥៨។

ដោយឡែកសម្រាប់បទល្មើសខ្លះ ទោះបីជាអំពើដែលជាធាតុផ្សំសត្យានុម័តនៃបទល្មើសមានភាពខុសប្លែកគ្នា ក៏ច្បាប់បានចាត់ទុកថាជាបទល្មើសតែមួយ ដូចជាករណី អំពើប្រព្រឹត្តឡើងដោយចេតនា ដោយដាក់បញ្ចូលនូវសារជាតិពុលនាំឲ្យខូចសុខភាពទៅក្នុងទឹកសម្រាប់ហូបជាសាធារណៈ សកម្មភាពនេះត្រូវបានចាត់ទុកថាជា **អំពើហិង្សាដោយចេតនា** តាមខ្លឹមសារនៃមាត្រា ២២៧ នៃក្រមព្រហ្មទណ្ឌ ។

ហេតុដូច្នេះ អំពើខាងលើនេះត្រូវចាត់ទុកថាជាបទមជ្ឈិមដដែល តាមបទប្បញ្ញត្តិស្តីពីការមិនរាងចាលបាន។ យ៉ាងណាមិញបទល្មើសខ្លះទៀតត្រូវបានចាត់បញ្ចូល ថាជាបទល្មើសប្រហាក់ប្រហែលគ្នា ហើយត្រូវបានប្បញ្ញត្តិនៅក្នុងផ្នែកតែមួយដូចគ្នា ជាក់ស្តែងដូចជាករណីនៃ **បទប្រទូស្តកេរខ្មាស បទបង្អាញកេរភេទ បទរុកគួនខាងផ្លូវភេទ** ដែលក្រមព្រហ្មទណ្ឌបានចាត់ទុកថាជាបទល្មើសបំពានខាងផ្លូវភេទដទៃទៀត ។ ដូចគ្នានេះដែរ **អំពើលួច ការកំហែងយក និងការគំរាមកំហែងហែកកេរ្តិ៍** ត្រូវបានប្បញ្ញត្តិនៅក្រោមជំពូកទី១ ស្តីពី ការលួច និងបទល្មើសប្រហាក់ប្រហែលនៃមាតិកាទី១ នៃគន្ថីទី៣ នៃក្រមព្រហ្មទណ្ឌ។ [135]

បើយ៉ាងដូច្នេះ តើបទល្មើសទាំងនេះត្រូវរាប់បញ្ចូលថាជាបទមជ្ឈិមដដែល ដើម្បីអាចឲ្យអនុវត្តបទប្បញ្ញត្តិស្តីពីការមិនរាងចាលបានដែរឬទេ? បើយោងតាមគោលការណ៍នៃការបកស្រាយច្បាប់ព្រហ្មទណ្ឌយ៉ាងតឹងរឹង មិនគួរគប្បីចាត់ទុកថាបទល្មើសទាំងនោះ គឺជាបទមជ្ឈិមដដែល ដើម្បីអាចឲ្យយកបទប្បញ្ញត្តិនៃការមិនរាងចាលមកអនុវត្ត នោះឡើយ ពីព្រោះថាមាត្រា ៨៤ និងមាត្រា ៨៨ នៃក្រមព្រហ្មទណ្ឌប្រើពាក្យបទមជ្ឈិមដដែល គឺមិនមែនបទមជ្ឈិមប្រហាក់ប្រហែលទេ ទោះបីជាយ៉ាងណាក្តី យុត្តិសាស្ត្ររបស់តុលាការកម្ពុជាអាចកំណត់ផ្សេងពីនេះបាន កាលបើមានហេតុផលគតិយុត្តដ៏ត្រឹមត្រូវ។

ដើម្បីពង្រីកវិសាលភាពនៃការអនុវត្តបទបញ្ញត្តិនៃមាត្រា ៨៨ នៃក្រមព្រហ្មទណ្ឌ មាត្រា ៨៩ នៃក្រមព្រហ្មទណ្ឌតម្រូវឲ្យចាត់ទុក **បទលួច បទរំលោភលើទំនុកចិត្ត បទឆបោក** ថាជាបទល្មើសដូចគ្នាដដែល ចំណែកឯបទល្មើស **ទទួលផលចោរកម្ម** ត្រូវប្រដូចជាបទល្មើសដែលជាប្រភពនៃទ្រព្យសម្បត្តិ ដែលទទួលលាក់បំបាំង ហើយបទល្មើស **សំអាតប្រាក់** ត្រូវប្រដូចជាបទល្មើសដែលការសំអាតប្រាក់នេះបានសម្រេច។

ហេតុដូច្នេះ ប្រសិនបើបុគ្គលម្នាក់ត្រូវបានផ្តន្ទាទោសជាស្ថាពរ **បទលួច** រួចហើយ ក្រោយមកក៏បានប្រព្រឹត្ត **បទរំលោភលើទំនុកចិត្ត** ទៀត គឺមានន័យថាបុគ្គលនេះបានប្រព្រឹត្តបទល្មើសដដែល តាមអត្ថន័យនៃមាត្រា ៨៨ នៃក្រមព្រហ្មទណ្ឌ ដែលជាមូលហេតុនាំឲ្យតុលាការកំណត់ថាបុគ្គល នេះបានប្រព្រឹត្តបទល្មើសថ្មីក្នុងស្ថានភាពមិនរាងចាល។ [136]

លើសពីនេះទៅទៀត កាលបើលក្ខខណ្ឌនៃការមិនរាងចាលមានគ្រប់គ្រាន់ អតិបរមានៃទោសដាក់ពន្ធនាគារសម្រាប់បទមជ្ឈិមថ្មីត្រូវតែទ្វេឡើង។ ស្របនឹងនេះផងដែរ ក្នុងករណីដែលអតិបរមានៃទោសដាក់

[135] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣៥៩។

[136] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣៦០។

ពន្ធនាគារត្រូវកើនឡើងលើសពី ០៥ឆ្នាំ ដោយសារតែអានុភាពនៃការមិនរាងចាលក៏ដោយ បទល្មើសនោះនៅតែជាបទមជ្ឈិមដដែល ។

***ឧទាហរណ៍៖*** ដារ៉ា ត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ០១ឆ្នាំ ពី **បទលួច**។ ទន្ទឹមនឹងនេះសេចក្តីសម្រេចផ្តន្ទាទោសបានក្លាយជាស្ថាពរនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០។ ស្រាប់តែនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១០ ដារ៉ា បានឆបោកមិត្តរួមថ្នាក់របស់គាត់យកបានទូរស័ព្ទមួយគ្រឿង។ ក្នុងករណីនេះ ដារ៉ា ត្រូវបានចាត់ទុកថាស្ថិតក្នុងស្ថានភាពមិនរាងចាល ពីព្រោះថា **អំពើលួច** ត្រូវបានចាត់ទុកថាជាបទមជ្ឈិមដដែល ជាមួយនឹង **បទឆបោក**។ ហេតុដូច្នេះ ទោសដែលត្រូវផ្តន្ទាលើឈ្មោះ ដារ៉ា ចំពោះ **បទឆបោក** គឺការដាក់ពន្ធនាគារពី ០៦ខែ (អប្បបរមានៃទោស) ទៅ ០៦ឆ្នាំ (អតិបរមានៃទោស) និងពិន័យជាប្រាក់ពី ១លានរៀល ទៅ ៦លានរៀល។[137]

ក្រៅពីនេះ ក្រមព្រហ្មទណ្ឌបានអនុញ្ញាតឲ្យតុលាការយកការមិនរាងចាល មកធ្វើជាមូលហេតុនៃការបន្ថែមទម្ងន់ទោសដាក់ពន្ធនាគារបានលុះត្រាតែមានចែងយ៉ាងជាក់លាក់នៅក្នុងលិខិតចោទប្រកាន់ ។

ជាងនេះទៅទៀត តុលាការអាចអនុវត្តបទបញ្ញត្តិស្តីពីការមិនរាងចាលបាន កាលបើជននេះបានទទួលរងនូវការផ្តន្ទាទោសជាស្ថាពរតែប៉ុណ្ណោះ ពោលគឺជាសេចក្តីសម្រេចដែលមិនអាចមានផ្លូវតវ៉ាបានទៀតទេ។ លើសពីនេះទៅទៀតសោត ទោះបីជាទោសដែលកើតចេញពីការផ្តន្ទាទោសនោះត្រូវផុតអាជ្ញាយុកាលក៏ដោយ ក៏តុលាការត្រូវយកមកគិតសម្រាប់កំណត់ពីភាពមិនរាងចាលបានដែរ លើកលែងតែករណីដែលទោសនោះត្រូវបានលើកលែងទាំងស្រុងតាមការលើកលែងទោសជាទូទៅ ដោយអនុលោមតាមបទបញ្ញត្តិនៃមាត្រា ៩០ ថ្មី កថាខណ្ឌទី ៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ។

***ឧទាហរណ៍៖*** តុលាការបានសម្រេចធ្វើការផ្តន្ទាទោស មករា ដោយតម្រូវឲ្យជាប់ពន្ធនាគារពី **បទលួច** ។ បន្ទាប់មកសេចក្តីសម្រេចផ្តន្ទាទោសខាងលើក៏បានចូលជាស្ថាពរ នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩។ ក៏ប៉ុន្តែនៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០១០ អង្គការនីតិបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅតាមមាត្រា ៩០ ថ្មី នៃរដ្ឋធម្មនុញ្ញ ដោយក្នុងនោះទោសដែលទទួលរងដោយ មករា ក៏ទទួលបាននូវការលើកលែងទោសជាទូទៅដែរ។ លុះក្រោយមកនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១០ មករា បានប្រព្រឹត្តបទល្មើសថ្មីមួយទៀត។ ក្នុងករណីនេះ ទោសពីបទលួចដែលតុលាការបានសម្រេចផ្តន្ទាលើ មករា គឺតុលាការមិនអាចយកមកពិចារណា ដើម្បីធ្វើជាមូលដ្ឋានកំណត់ថា មករា ត្រូវស្ថិតក្នុងភាពមិនរាងចាលឡើយ ដោយសារតែទោសនេះត្រូវបានទទួលការលើកលែងទោសជាទូទៅរួចទៅហើយ។[138]

[137] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣៦១។

[138] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ រោងពុម្ពជោគជ័យ,២០១២),៣៦២។

គួរកត់សម្គាល់ជាបន្ថែមទៀតថា ការផ្តន្ទាទោសពីបទលហុគឺមិនអាចឲ្យតុលាការយកមកពិចារណា ដើម្បីធ្វើជាមូលដ្ឋានកំណត់ពីភាពមិនរាងចាលរបស់ចារីឡើយ ពីព្រោះថាក្រមព្រហ្មទណ្ឌសំដៅតែទៅលើបទឧក្រិដ្ឋ និងបទមជ្ឈិម តែប៉ុណ្ណោះ។ ក្រៅពីនេះ គឺមានតែអតិបរមានៃទោសដាក់ពន្ធនាគារប៉ុណ្ណោះដែលត្រូវដំឡើង ក្រមព្រហ្មទណ្ឌពុំបានអនុញ្ញាតឲ្យដំឡើងអតិបរមានៃទោសពិន័យជាប្រាក់នោះឡើយ។

រួមសេចក្តីមក ដើម្បីបង្ហាញឲ្យឃើញច្បាស់ពីអត្ថិភាពនៃភាពមិនរាងចាល ការកំណត់ពីអត្តសញ្ញាណកម្មលើចារីគឺជារឿងចាំបាច់បំផុត ជាពិសេសគឺនៅពេលដែលចារីបានខិតខំលាក់បាំងពីអត្តសញ្ញាណពិតប្រាកដរបស់ខ្លួន។ គួរកត់សម្គាល់ថាអត្តសញ្ញាណកម្មចារីអាចធ្វើបានតាមវិធីសាស្ត្រច្រើនយ៉ាង រួមមានដូចជា ការយកស្នាមខ្មៅដៃរបស់ជនជាប់ចោទមកធ្វើការប្រៀបធៀបជាមួយនឹងស្នាមខ្មៅដៃ និងព័ត៌មានផ្សេងៗទៀត ដែលត្រូវបានកត់ត្រាទុកក្នុងសំណុំរឿងដោយអាជ្ញាធរមានសមត្ថកិច្ច ។ ម្យ៉ាងវិញទៀត ដើម្បីបង្ហាញភស្តុតាងពីប្រវត្តិនៃការផ្តន្ទាទោសរបស់ជនណាម្នាក់ អាជ្ញាធរតុលាការអាចស្នើសុំបញ្ជីថ្កោលទោសរបស់ជនដែលពាក់ព័ន្ធពីក្រសួងយុត្តិធម៌មកពិនិត្យផ្ទៀងផ្ទាត់បាន។[139]

## ផ្នែកទី២៖ ស្ថានសម្រាលទោស

អ្នកនីតិបញ្ញត្តិកំណត់ទោសដែលត្រូវផ្តន្ទា ដោយគិតចាប់ពី អប្បបរមា រហូតដល់អតិបរមា។ នៅក្នុង ការដាក់ទោសចៅក្រមអាចដាក់ទោសកម្រិតណាមួយក៏បានដែរឲ្យតែនៅក្នុងកម្រិតដែលច្បាប់កំណត់ (យោងលើមូលហេតុផ្សេងៗដែលចៅក្រមយល់ថាជាការគួរ)។លើសពីនេះ ចៅក្រមអាចបន្ថយទោសមកក្រោមអប្បបរមានៃទោសប្រសិនបើមានស្ថានសម្រាលទោស។[140]

ស្ថានសម្រាលទោស ជាផ្នែកមួយនៃសេចក្តីសម្រេចរបស់តុលាការ ដែលត្រូវអនុវត្តលើជនជាប់ចោទ ណាម្នាក់ដោយបន្ថយទោសដែលត្រូវអនុវត្តនោះ ឲ្យថយចុះក្រោមអប្បបរមានៃទោសដែលកំណត់នៅក្នុង លក្ខ ខណ្ឌច្បាប់។

### កថាភាគទី១៖ និយមន័យនៃស្ថានសម្រាលទោស

ស្ថានសម្រាលទោស ដែលតុលាការអាចធ្វើសេចក្តីសម្រេចផ្តល់ឲ្យជនជាប់ចោទ គឺសំដៅទៅលើកាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ តុលាការអាចសម្រេចឲ្យជនជាប់ចោទបានទទួលនូវស្ថានសម្រាលទោស។ ស្ថានសម្រាលទោសអាចត្រូវផ្តល់ឲ្យជនជាប់ចោទបានដែរ ទោះបីជាជន នោះ ត្រូវបានថា ស្ថិតនៅក្នុងភាពមិនរាងចាលក៏ដោយ។[141]

[139] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ ធាងពុម្ពជោគជ័យ,២០១២),៣៦៣។

[140] សាស្ត្រចារ្យ មីន សំអុល ,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ ២០២០),៥៥។

[141] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៩៣ ។

ក្រមព្រហ្មទណ្ឌពុំបានពន្យល់ពីពាក្យថា កាលៈទេសៈនៃបទល្មើសបែបណា ឬមួយបុគ្គលិកលក្ខណៈ នៃជនជាប់ចោទបែបណានោះទេដែលតុលាការលើកយកមកពិចារណាដើម្បីផ្តល់នូវស្ថានសម្រាលទោស ឲ្យជនជាប់ចោទ។ក្នុងន័យនេះក្រមព្រហ្មទណ្ឌបានទុកលទ្ធភាពជាពិសេសឲ្យតុលាការពិចារណាទៅតាមករណីជាក់ស្តែងនីមួយៗនិងសម្រាប់ជនជាប់ចោទម្នាក់ៗថា តើគួរតែផ្តល់នៅស្ថានសម្រាលទោសឲ្យ ឬក៏មិនផ្តល់ឲ្យជនជាប់ចោទណាម្នាក់។ហេតុនេះប្រសិនបើជនជាប់ចោទបានប្រព្រឹត្តនូវបទល្មើសដោយសារតែការរុញច្រាន និងដោយសារតែអំពើបង្កហេតុពីសំណាក់ជនរងគ្រោះជាមុន ឬក៏ជនជាប់ចោទបានប្រព្រឹត្តបទល្មើសក្នុងស្ថានភាពនៃការ ការពារខ្លួនហួសព្រំដែន ដែលបានកំណត់ច្បាប់តុលាការអាចសម្រេចផ្តល់នូវស្ថានសម្រាលទោសឲ្យដល់ជនជាប់ ចោទបាន។លើសពីនេះទៅទៀតតុលាការអាចពិចារណាទៅលើប្រវត្តិគ្រួសារ សភាពផ្លូវចិត្ត យុវភាពរបស់ជន ជាប់ចោទ ដើម្បីសម្រេចថា តើគួរផ្តល់នូវស្ថានសម្រាលទោសឲ្យជនជាប់ចោទ ឬមិនគួរផ្តល់ឲ្យទេ។[142]

ដោយយោងទៅតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ការមិនទទួលខុសត្រូវដោយសារមូលហេតុវិបល្លាសស្មារតីដែលជានៅក្នុងកថាខណ្ឌទី២កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើសនៅពេលដែលជននោះកើតវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវរបស់ខ្លួនជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល។[143] នេះជាស្ថានភាពមួយដែលក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាតម្រូវឲ្យតុលាការត្រូវយកមកគិតគូរពិចារណាក្នុងកាលកំណត់នៅទោស ដែលត្រូវមើលទៅលើតថភាពជាក់ស្តែង **វិបល្លាសស្មារតី** ដែលបានកាត់បន្ថយនូវ ការយល់ដឹងរបស់ជនជាប់ចោទ នេះជាមូលហេតុដែលតុលាការ ត្រូវតែយកមកគិតគូរ និងថ្លឹងថ្លែង ក្នុងការកំណត់ ដល់ការជួយសម្រាលទោសឲ្យជនជាប់ចោទជាចាំបាច់។

## កថាភាគទី២៖ អានុភាពនៃស្ថានសម្រាលទោស

ការប្រកាសទោសរបស់តុលាការត្រូវធ្វើឡើងនៅក្នុងក្របខណ្ឌអប្បរមា និងអតិបរមានៃទោសដែលច្បាប់បានកំណត់តែបើសិនជាជាតុលាការរកឃើញថាកាលៈទេសៈនៃបទល្មើសឬបុគ្គលិកនៃជនជាប់ចោទមានលក្ខណៈពិសេស ដែលតុលាការយល់ឃើញថាត្រូវផ្តល់នូវស្ថានសម្រាលទោសឲ្យជនជាប់ចោទតុលាការ អាច បន្ថយអប្បរមានៃមូលទោសតាមមាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌ អានុភាពនៃស្ថានសម្រាលទោសដូចខាងក្រោម៖

១-ប្រសិនបើអប្បរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១០(ដប់) ឆ្នាំអប្បរមានៃទោសនេះ ត្រូវបន្ថយមកត្រឹម២(ពីរ)ឆ្នាំ។[144]

---

[142] សាស្ត្រចារ្យ មីន សំអុល ,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ ២០២០),៥៦។

[143] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩,កថាខណ្ឌទី២ មាត្រា ៣១។

[144] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩,កថាខណ្ឌទី១ មាត្រា ៩៤។

***ឧទាហរណ៍ទី១៖*** ជនជាប់មានពិរុទ្ធភាពពី បទឃាតកម្ម ដែលបានកំណត់នៅក្នុងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌត្រូវផ្តន្ទាទោសដាក់ពន្ធធានាគារពី ១០ឆ្នាំ(អប្បរមានៃទោស)ទៅ ១៥ឆ្នាំ(អតិប្បរមានៃទោស)។ ក្នុងករណីនេះដែលតុលាការសម្រេចផ្តល់នូវស្ថានសម្រាលទោសឲ្យជនជាប់ចោទ អប្បរមា និងអតិបរមានៃទោសសម្រាប់ បទឃាតកម្ម ចំពោះជនជាប់ចោទរូបនេះគឺទោសដាក់ពន្ធធានាគារ ២ឆ្នាំ(អប្បរមានៃទោស) ទៅ១៥ឆ្នាំ(អតិបរមានៃទោស)។

២-ប្រសិនបើអប្បរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៥(ប្រាំ)ឆ្នាំហើយតិចជាង ១០(ដប់)ឆ្នាំ អប្បរមានៃទោសនេះ ត្រូវបន្ថយត្រឹម១ (មួយឆ្នាំ)។[145]

ឧទាហរណ៍៖ ជនជាប់មានពិរុទ្ធភាពពី បទទារុណកម្ម និងអំពើឃោឃៅ ដែលបានកំណត់នៅក្នុង មាត្រា ២១០ នៃក្រមព្រហ្មទណ្ឌបទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធធានាគារពី៧ ឆ្នាំ (អប្បរមានៃទោស)ទៅ ១៥ឆ្នាំ(អតិបរមានៃទោស)។ក្នុងករណីនេះដែលតុលាការសម្រេចផ្តល់នូវស្ថានសម្រាលទោសឲ្យជនជាប់ចោទ អប្បរមា និងអតិបរមា នៃទោសសម្រាប់បទទារុណកម្ម និងអំពើឃោឃៅ ចំពោះជនជាប់ចោទរូបនេះ គឺទោសដាក់ពន្ធនាគារ ១ ឆ្នាំ(អប្បរមានៃទោស) ទៅ ១៥ឆ្នាំ(អតិបរមានៃទោស)។

៣-ប្រសិនបើអប្បរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ២(ពីរ)ឆ្នាំ ហើយតិចជាង ៥(ប្រាំ)ឆ្នាំ អប្បបរមានៃទោសនេះ ត្រូវបន្ថយមកត្រឹម៦(ប្រាំមួយ)ខែ។[146]

ឧទាហរណ៍៖ ជនជាប់មានពិរុទ្ធភាពពី បទរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គល ផ្សេងទៀត ដែលតាមខ្លឹមសារនៃមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ បទល្មើសនេះត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី២ ឆ្នាំ (អប្បរមានៃទោស) ទៅ ៥ឆ្នាំ (អតិបរមានៃទោស)។ក្នុងករណីនេះដែលតុលាការសម្រេចផ្តល់នៅស្ថាន សម្រាលទោសឲ្យជនជាប់ចោទ អប្បរមា និងអតិបរមានៃទោសសម្រាប់បទ រំលោភលើទំនុកចិត្ត ពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ចំពោះជនជាប់ចោទរូបនេះគឺទោសដាក់ពន្ធនាគារ ៦ខែ (អប្បរមានៃទោស)ទៅ ៥ឆ្នាំ (អតិបរមានៃទោស)។

៤-ប្រសិនបើអប្បរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៦(ប្រាំមួយ)ថ្ងៃ ហើយតិចជាង២(ពីរ)ឆ្នាំ អប្បបរមានៃទោសនេះ ត្រូវបន្ថយមកត្រឹម ១(មួយ) ថ្ងៃ។[147]

ឧទាហរណ៍៖ ជនជាប់មានពិរុទ្ធភាពពី បទលួច ដែលខ្លឹមសារនៃមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ បទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ (អប្បរមានៃទោស) ទៅ ៣ឆ្នាំ (អតិបរមានៃទោស)។ ក្នុងករណីនេះ

145 ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩,កថាខណ្ឌទី២ មាត្រា ៩៤។
146 ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩,កថាខណ្ឌទី៣ មាត្រា ៩៤។
147 ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩,កថាខណ្ឌទី៤ មាត្រា ៩៤។

ដែលតុលាការសម្រេចផ្តល់នូវស្ថានសម្រាលទោសឲ្យជនជាប់ចោទអប្បរមា និងអតិបរមានៃទោស សម្រាប់ បទលួច ចំពោះជនជាប់ចោទរូបនេះគឺ ទោសដាក់ពន្ធនាគារ ១ថ្ងៃ (អប្បរមានៃទោស) ទៅ ៣ឆ្នាំ (អតិបរមានៃទោស)។

៥-អប្បរមានៃទោសពិន័យ ត្រូវបន្ថយមកត្រឹមពាក់កណ្តាល។[148]

ឧទាហរណ៍៖ ជនជាប់មានពិរុទ្ធភាពពី បទលួច ដែលខ្លឹមសារនៃមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌបទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ (អប្បរមានៃទោស) ទៅ ៣ឆ្នាំ (អតិបរមានៃទោស)និង ពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន)រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន)រៀល។[149]ក្នុង ករណីនេះតុលាការសម្រេចផ្តល់នូវស្ថានសម្រាលទោសឲ្យជនជាប់ចោទ អប្បរមា និងអតិបរមានៃទោស ដាក់ពន្ធនាគារត្រូវបន្ថយតាមខ្នាតដូចក្នុងឧទាហរណ៍ខាងលើ ចំណែកឯអប្បរមានៃទោសពិន័យនៅក្នុង បទលួច ចំពោះជនជាប់ចោទរូបនេះគឺ ទោសពិន័យជាប្រាក់ ៥ សែនរៀល (អប្បរមា) ទៅ ៦លានរៀល (អតិបរមា)។

**កថាភាគទី៣៖ ទោសដាក់ពន្ធនាគារអស់មួយជីវិត និងស្ថានសម្រាលទោស**

ចំពោះស្ថានសម្រាលទោសនៃទោសដាក់ពន្ធនាគារអស់មួយជីវិតនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា កាលណាបទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចៅក្រមដែលផ្តល់ស្ថានសម្រាលទោស អាចប្រកាសទោសដាក់ពន្ធនាគារ ក្នុងចន្លោះរវាង ១៥ (ដប់ប្រាំ) និង ៣០ (សាមសិប) ឆ្នាំ ។[150] មានន័យថា ប្រសិនបើជាបទល្មើសណាមួយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតហើយតុលាការបាន ពិនិត្យឃើញច្បាស់ថាអ្នកនោះត្រូវទទួលបាននូវស្ថានសម្រាលទោសណាមួយដែលគួរឲ្យគាត់ទទួលទោសធូរស្រាលនោះ គឺចៅក្រមប្រកាសចន្លោះពី ១៥ឆ្នាំ ទៅ ៣០ឆ្នាំ។

***ឧទាហរណ៍៖*** ជនជាប់ចោទម្នាក់ត្រូវបានរកឃើញថាមានពិរុទ្ធភាពពី បទឃាតកម្មគិតទុកជាមុន ដែលតាមមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ បទល្មើស នេះត្រូវតែផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។ ក្នុងករណីដែលតុលាការបាន សម្រេចផ្តល់នូវស្ថានសម្រាលទោសឲ្យដល់ជនជាប់ចោទ ប្រកាសទោសដាក់ពន្ធនាគារក្នុងចន្លោះពី ១៥ ទៅ ៣០ឆ្នាំ។

ដូចដែលបានរៀបរាប់ជូនខាងដើមរួចមកហើយថា ការកំណត់មូលទោសលើបទល្មើសណាមួយដែលចោទប្រកាន់ទៅលើអនីតិជន គឺពិតជាមានភាពខុសប្លែកគ្នាពីមូលទោសដែលតុលាការនឹងត្រូវសម្រេចផ្តន្ទាទោសសម្រាប់បទល្មើសនីតិជន ដោយអត្ថន័យនៃមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌបានតម្រូវឲ្យបន្ថយមកតាមខ្នាតដែលបានចងដោយបទបញ្ញត្តិនេះ។[151]

---

[148] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩,កថាខណ្ឌទី៥ មាត្រា ៩៤។

[149] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៣៥៦។

[150] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៩៥។

[151] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ ពាងពុម្ពជោគជ័យ,២០១២),៣៤៩។

បន្ថែមពីលើនេះទៅទៀត ក្នុងករណីដែលជនជាប់ចោទជាអនីតិជន ហើយទទួលបាននូវស្ថានសម្រាលទោសពីតុលាការ អប្បបរមានៃមូលទោសសម្រាប់ឲ្យតុលាការសម្រេចផ្តន្ទាលើអនីតិជន ត្រូវតែបន្ថយមកតាមខ្នាតដែលមានចែងនៅត្រង់មាត្រា ១៦៤ នៃក្រមព្រហ្មទណ្ឌវិញ។

-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកនៅត្រឹម ១ (មួយ) ឆ្នាំ ។

-ប្រសិនបើអប្បបរមានៃទោសជាប់ពន្ធនាគារស្មើ ឬលើសពី ៥ (ប្រាំ) ឆ្នាំ និងតិចជាង ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៦ (ប្រាំមួយ) ខែ ។

-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ២ (ពីរ) ឆ្នាំ និងតិចជាង ៥ (ប្រាំ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៣ (បី) ខែ ។

-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារ ស្មើ ឬលើសពី ៦ (ប្រាំមួយ)ថ្ងៃ និងតិចជាង ២ (ពីរ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយត្រឹម ១ (មួយ) ថ្ងៃ ។

-អប្បបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។[152]

***ឧទាហរណ៍៖*** ជនជាប់ចោទជាអនីតិជនមានអាយុ ១៧ឆ្នាំ ត្រូវបានរកឃើញថាមានពិរុទ្ធភាពពីបទឃាតកម្មលើបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ ដែលតាមខ្លឹមសារនៃមាត្រា ៣០ នៃច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម បទល្មើស នេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ឆ្នាំ ដល់ ៣០ឆ្នាំ ឬ អស់មួយជីវិត។ ក្នុងករណីនេះដំបូងត្រូវកំណត់អំពីមូលទោសនៃបទល្មើសដែលត្រូវចោទប្រកាន់ ហើយដែលត្រូវអនុវត្តលើអនីតិជន តាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌសិន។ តាមអត្ថន័យនៃមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ មូលទោសនៃបទល្មើសខាងលើដែលត្រូវយកទៅអនុវត្តលើជនជាប់ចោទជាអនីតិជនគឺត្រូវដាក់ពន្ធនាគារ ពី ១០ឆ្នាំ (អប្បបរមា) ដល់ ១៩ឆ្នាំ ឬ ២០ឆ្នាំ (អតិបរមា) ។ ក៏ប៉ុន្តែ ប្រសិនបើតុលាការបានសម្រេចផ្តល់នូវស្ថានសម្រាលទោសឲ្យដល់ជនជាប់ចោទ មូលទោសដែលត្រូវយកទៅអនុវត្តលើជនជាប់ចោទជាអនីតិជនត្រូវបានបន្ថយដូចតទៅគឺទោស ដាក់ពន្ធនាគារពី ១ឆ្នាំ (អប្បបរមា) ដល់ ១៩ឆ្នាំ ឬ ២០ឆ្នាំ (អតិបរមា)។[153]

ជាទូទៅទោសដាក់ពន្ធនាគារអស់មួយជីវិតនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩ បានចែងដូចខាងក្រោម៖

[152] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ១៦៤។

[153] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,រៀបរៀង,សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ ពោធិពុម្ពជោគជ័យ,២០១២),៣៥០។

- បទឧក្រិដ្ឋប្រល័យពូជសាសន៍។[154]
- បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ។[155]
- បទឧក្រិដ្ឋសង្គ្រាម។[156]
- បទឃាតកម្មគិតទុកជាមុន។[157]
- បទឃាតកម្មដោយមានទារុណកម្មអំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ។[158]
- បទរាជឃាតកម្ម។[159]
- បទប្រគល់ឲ្យរដ្ឋបរទេសនូវដែនដីជាតិទាំងស្រុងឬមួយផ្នែក។[160]
- បទប្រគល់ឲ្យរដ្ឋបរទេសនូវកងយោធពលខេមរភូមិន្ទ។[161]
- បទឧបឃាតដោយមានស្ថានទម្ងន់ទោសដែលទាក់ទងទៅនឹងជនល្មើស។[162]

[154] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ១៨៣។
[155] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ១៨៨។
[156] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ១៩៣។
[157] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ២០០។
[158] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ២០៥។
[159] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៤៣៣។
[160] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៤៤០។
[161] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៤៤១។
[162] ក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៤៥២។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សរុបមក ទោស គឺជាទណ្ឌកម្មព្រហ្មទណ្ឌដែលមានចែងនៅក្នុងច្បាប់ ហើយដែលចៅក្រមអាចយកទៅអនុវត្តទៅលើចារីនៃបទល្មើសបាន។ ហើយមុខងារនៃទោស គឺការបំភិតបំភ័យ ការបង្ក្រាប ការបញ្ចូលចារីទៅក្នុងសង្គមវិញ ( មុខងារនេះឯងដែលជាមុខងារសំខាន់ជាងគេសម្រាប់អនុវត្តពេលបច្ចុប្បន្ន)។យោងតាមស្មារតីនៃក្រមព្រហ្មទណ្ឌ ទោសត្រូវបានគេសំដៅដល់ទណ្ឌកម្មមួយដែល ត្រូវបានប្រកាសដោយតុលាការសម្រាប់អនុវត្តចំពោះបុគ្គលណា ដែលបានប្រព្រឹត្តបទល្មើសដូចមានចែងនៅក្នុងច្បាប់ ហើយទោសត្រូវបានប្រកាសដោយឈរលើមូលដ្ឋានព្យសនកម្ម នៃបទល្មើសដែលបង្កឱ្យមានការខូចខាតដល់ជនរងគ្រោះ ។

ប្រភេទនៃទោសព្រហ្មទណ្ឌដែលបានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជារបស់យើងគឺ បែងចែកទោសព្រហ្មទណ្ឌជា ៣ ប្រភេទ គឺ មូលទោស ទោសបន្ថែម ទោសជំនួស ដែលទោសទាំង៣នេះតុលាការយកទៅអនុវត្តចំពោះបុគ្គលណាដែលបានប្រព្រឹត្តបទល្មើស ដោយយោងទៅតាមមាត្រា៣ នៃព្រហ្មទណ្ឌគោលការណ៍នីត្យានុកូលភាពដែលមានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន។ មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើស ត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន។ ក្នុងស្ថានភាពដើម្បីឲ្យការប្រើប្រាស់នូវទោសនោះមានផលប្រយោជន៍សម្រាប់សង្គម ពីព្រោះប្រសិនបើផលប្រយោជន៍នៃទោសមិនមានសម្រាប់សង្គម គេអត់ប្រើប្រភេទទោសនោះទេ។ ហេតុដូច្នេះការប្រើប្រាស់ទោសធ្ងន់ធ្ងរទៅលើបុគ្គលណាមួយដែលប្រព្រឹត្តបទល្មើស ដោយសារកាលៈទេសៈនៃការជម្រុញឲ្យគាត់ប្រព្រឹត្តបទល្មើសដូច្នេះប្រសិនបើយើងដាក់ទោសធ្ងន់ធ្ងរ គោលដៅនៃទោសគឺអត់ប្រយោជន៍ទេព្រោះដាក់ទៅនាំឲ្យគ្មានតុល្យភាពរវាងថរិកគ្រោះថ្នាក់នៃអំពើ ហើយនិងថរិកគ្រោះថ្នាក់សម្រាប់សង្គម ហើយនិងពេលវេលានៃទោសដែលត្រូវប្រើសម្រាប់បុគ្គលនោះអញ្ចឹងវានាំឲ្យមានគុណវិបត្តិមកវិញសម្រាប់ទោសព្រហ្មទណ្ឌ។

ហេតុនេះហើយប្រសិនបើរកឃើញថាបុគ្គលនោះគួរគប្បីទទួលរងនៅទោសប្រភេទណា បានជានៅក្នុងក្រមព្រហ្មទណ្ឌចែង ដោយសារគេគោរពនូវគោលការណ៍នីត្យានុកូលភាពដែលមានចែងនៅក្នុងមាត្រា ៣ ។ ការរកឃើញមានពីពិរុទ្ធភាពរបស់ចារី នៃបទល្មើសរួចមក ចៅក្រមត្រូវកំណត់អំពីការផ្តន្ទាទោសដែលចារីនឹងត្រូវទទួលរង។ ដូចនេះទោសទាំងឡាយដែលបានកំណត់ឡើងក្នុងលក្ខណៈជាទ្រឹស្តី ដោយច្បាប់សម្រាប់បទល្មើសនីមួយៗនឹងត្រូវយកមកប្រកាសជាក់ស្តែងដោយចៅក្រម។

បរិបទនៃការពិតជាក់ស្តែងចៅក្រមត្រូវតែគិតគូរពិចារណាពីតថភាពផ្ទាល់ខ្លួន ឬស្ថិតិស្ថានភាពណាមួយដែលមានការពាក់ព័ន្ធ នឹងប្រព្រឹត្តបទល្មើស ឲ្យមានភាពល្អិតល្អន់ជាមុនសិនមុននឹងធ្វើការប្រកាសណាមួយ។ ដោយអនុលោមទៅតាមបុគ្គលិកលក្ខណៈរបស់ចារីផ្ទាល់ផងដែរ។ ហេតុដូច្នេះ ទើបមានភាពខុសគ្នាក្នុងការប្រកាសទោសម្តងៗ ចំពោះបទល្មើសដូចគ្នា ប៉ុន្តែបែរជាខុសគ្នាពីករណីមួយទៅករណីមួយផ្សេងទៀត ចំណែកឯទោសដែលត្រូវបានកំណត់ដោយច្បាប់វិញ គឺគ្រាន់តែចង្អុលបង្ហាញរបស់អ្នកច្បាប់អំពីរបៀបនៃការផ្តន្ទាទោសលើបទល្មើសប៉ុណ្ណោះ។ ការដាក់ទោសយ៉ាងដូច្នេះ គឺធ្វើឡើងទៅតាមគោលការណ៍ឯកត្តកម្មនៃទោស ដែលមាន

ចែងនៅក្នុងមាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌថា តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាន និងបន្ទុកទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមាយាទរបស់ជនល្មើស ក្រោយពេលប្រព្រឹត្តបទល្មើសជាអាទិ៍ទៅលើជនរងគ្រោះ។

ដោយឡែកចៅក្រមមានតួនាទីជាអ្នកអនុវត្តច្បាប់ ដោយមិនត្រូវដាក់ទោសតិចជាងអប្បរមានៃទោស ឬច្រើនជាងអតិបរមានៃទោសដែលបានកំណត់ដោយច្បាប់នោះឡើយ។ ក៏ប៉ុន្តែនៅមានស្ថានភាពមួយចំនួនដែលអនុ ញ្ញាតឲ្យចៅក្រមអាចធ្វើផ្ទុយពីអ្វីដែលបានបរិយាយខាងលើនេះបាន។ ដោយនៅក្នុងបរិបទនេះចៅក្រមត្រូវគិតគូរអំពីស្ថានសម្រាលទោស និង ស្ថានទម្ងន់ទោស។

អ្នកនីតិបញ្ញត្តិកំណត់ទោសដែលផ្តន្ទា ដោយគិតចាប់ពី អប្បបរមា រហូតដល់ អតិបរមា។ នៅក្នុងការដាក់ទោស ចៅក្រមអាចដាក់ទោសកម្រិតណាមួយក៏បានដែរ ឲ្យតែនៅក្នុងកម្រិតដែលច្បាប់កំណត់ (យោងលើមូលហេតុផ្សេងៗដែលចៅក្រមយល់ថាជាការគួរ)។

# អនុសាសន៍

## ការផ្តល់អនុសាសន៍

សូមឲ្យសាកលវិទ្យាល័យនានា ដែលមានមហាវិទ្យានីតិសាស្ត្រ មេត្តាខិតខំព្យាយាមបើកសិក្ខាសាលាស្តីពី "ប្រភេទនៃទោសព្រហ្មទណ្ឌ" ដោយអញ្ជើញវាគ្មិនជំនាញៗ មកផ្តល់បទបង្ហាញដើម្បីចូលរួមផ្សព្វផ្សាយក្រមព្រហ្មទណ្ឌជាពិសេសប្រភេទនៃទោសព្រហ្មទណ្ឌឲ្យកាន់តែទូលំទូលាយក្នុងគោលបំណងធ្វើយ៉ាងណាឲ្យមានការយល់ដឹងដល់មហាជនក្នុងប្រទេស ហើយជាចូលរួមពង្រឹងនីតិរដ្ឋនៅប្រទេសកម្ពុជា។

សូមឲ្យនិស្សិតច្បាប់ទាំងឡាយ មេត្តាព្យាយាមសិក្សាស្រាវជ្រាវដើម្បីចែករំលែកនូវចំណេះដឹងរបស់ខ្លួនអំពីច្បាប់ព្រហ្មទណ្ឌជាពិសេសប្រភេទនៃទោសព្រហ្មទណ្ឌ ដើម្បីជួយបញ្ចេញនូវទស្សនៈថ្មី ដែលសមស្របហើយអាចយកទៅអនុវត្តបាន ក៏ដូចជាចូលរួមនៅក្នុងផ្សព្វផ្សាយនិងការចែករំលែកផ្លូវច្បាប់ជាពិសេសការអនុវត្តទោសព្រហ្មទណ្ឌនៅក្នុងប្រទេសកម្ពុជា ដើម្បីឲ្យប្រជាជនកាន់តែយល់ដឹងច្បាស់ទៅលើផ្លូវច្បាប់។

សូមបងប្អូននិស្សិតច្បាប់ទាំងអស់មេត្តាសិក្សាអំពីគោលគំនិតនៃទោសព្រហ្មទណ្ឌនៅក្នុងក្រមព្រហ្មទណ្ឌបានច្បាស់លាស់ព្រោះការអនុវត្តទោសព្រហ្មទណ្ឌគឺអាចប៉ះពាល់ទៅដល់សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋខ្មែរយ៉ាងខ្លាំង ប្រសិនបើគ្មានចំណេះដឹងអំពីមូលដ្ឋាននៃច្បាប់ព្រហ្មទណ្ឌច្បាស់លាស់ ដែលជាពិសេសបទប្បញ្ញត្តិដែលចែងអំពីទោសនោះទេ។

សំណូមពរដល់បណ្តាប្រជាពលរដ្ឋកម្ពុជាទាំងអស់ មេត្តាព្យាយាមសិក្សាស្វែងយល់ អំពីច្បាប់ដែលរដ្ឋាភិបាលបានដាក់ចេញ និងត្រូវតែទទួលយក និងជួយគ្នាអនុវត្តទាំងអស់គ្នាដើម្បីធានាឲ្យច្បាប់មួយមាននិរន្តភាព និងជួយឲ្យប្រទេសកម្ពុជាក្លាយទៅជានីតិរដ្ឋយ៉ាងពិតប្រាកដ។

សំណូមពរជូនចំពោះជាបងប្អូនដែលគាត់ស្វែងពីច្បាប់ខ្លះៗធ្វើការចែករំលែកឲ្យប្រជាជនផ្សេងៗដែលគាត់មិនបានដឹងសោះដើម្បីឲ្យពួកគាត់បានស្វែងយល់ខ្លះពីច្បាប់មួយចំនួនជាពិសេសគឺច្បាប់ព្រហ្មទណ្ឌដើម្បីរស់នៅក្នុងសង្គមប្រកបដោយ សន្តិភាព និង យុត្តិធម៌។

## អនុសាសន៍មួយចំនួនទាក់ទងនឹងប្រធានបទ

### ១.ប្រជាពលរដ្ឋ

- ត្រូវគោរព និងអនុវត្តច្បាប់នៅក្នុងប្រទេសឲ្យបានខ្ជាប់ខ្ជួន
- ជៀសវាងការប្រព្រឹត្តបទល្មើស ដោយអារម្មណ៍មួយពេលដោយមិនដឹងខ្លួន
- បង្កើនចំណេះដឹងពាក់ព័ន្ធទៅនឹងប្រព័ន្ធយុត្តាធិការ។

### ២.ចៅក្រមជំនុំជម្រះ

- ត្រូវកាត់ក្តីប្រកបដោយយុត្តិធម៌ទាំងជនល្មើស និងជនរងគ្រោះ
- ការជំនុំជម្រះត្រូវតែយុត្តិធម៌ និងឆាប់រហ័ស

- ត្រូវកំណត់កាលបរិច្ឆេទជំនុំជម្រះឲ្យបានច្បាស់លាស់ ជៀសវាងមានការភ័ន្តច្រឡំ
- ត្រូវពិចារណា និងថ្លឹងថ្លែងអំពីអំពើ និងទំហំព្យសនកម្មដែលបានកើតឡើង ជាពិសេសមូលដ្ឋានច្បាប់ព្រហ្មទណ្ឌដែលបានកំណត់ជាធរមាន
- វៀរចាកនូវអគតិទាំង៤ ក្នុងពេលបំពេញមុខងារ និងប្រកាន់ខ្ជាប់នៅសុគតិទាំង ០៥គឺ ៖ វិរិយសម្បយុត្ត(សេចក្តីអត់ធ្មត់ សេចក្តីព្យាយាម) សុចរិតយុត្តិធម៌(ទៀងត្រង់) បញ្ញត្តិគារវោ (គោរពច្បាប់ជាគោល) សមទណ្ឌោ( កាត់ក្តីដោយយុត្តិធម៌ មិនលម្អៀង) និងបញ្ញាវុធវិនិច្ឆ័យ ((ប្រើប្រាស់ប្រាជ្ញារបស់ខ្លួនដែលមានធ្វើជាអាវុធសម្រាប់ការវិច្ឆ័យ)។
- ក្នុងនាមជាអ្នកផ្តល់នូវភាពយុត្តិធម៌ ការសម្រេចសេចក្តីត្រូវឈរលើឧត្តមគតិរបស់ខ្លួន។

**ក្រៅពីអនុសាសន៍មួយចំនួនខាងលើយើងខ្ញុំសូមសំណូមពរដូចខាងក្រោម៖**

- សូមឲ្យអ្នកអនុវត្តច្បាប់ទាំងអស់អនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់
- មានឆន្ទៈរួម គឺយុត្តិធម៌ជូនបុគ្គលស្លូតត្រង់
- ការពារ និងផ្តល់យុត្តិធម៌ជូនបុគ្គលស្លូតត្រង់
- ដាក់ទណ្ឌកម្មចំពោះបុគ្គលដែលល្មើសច្បាប់ឲ្យសមនឹងទង្វើដែលគេបានប្រព្រឹត្ត
- លុបបំបាត់ឲ្យបាននូវអំពើពុករលួយ និងភាពអយុត្តិធម៌នៅក្នុងសង្គម
- គោរពច្បាប់ឲ្យបានតឹងរ៉ឹង ផ្តល់ទំនុកចិត្តដល់ប្រជាពលរដ្ឋដើម្បីឲ្យពួកគាត់មានភាពជំនឿលើប្រព័ន្ធយុត្តិធម៌
- បង្កើតនូវបទដ្ឋានគតិយុត្តិថ្មី ឬវិសោធនកម្មច្បាប់ចាស់ដែលខ្វះចន្លោះ ដើម្បីផលប្រយោជន៍សាធារណៈ
- មន្ត្រីអនុវត្តគួរតែគោរព និងអនុវត្តនូវអភិក្រមរបស់ខ្លួនឲ្យបានខ្ជាប់ខ្ជួន ដូចកាលដែលខ្លួនធ្វើសម្បថ។ល។

## ឯកសារយោង៖

### I. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

១. រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

២. ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩។

៣. ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

៤. ច្បាប់ព្រហ្មទណ្ឌអន្តរកាល (UNTAC) ឆ្នាំ១៩៩២។

៦. ច្បាប់ស្តីពី យុត្តិធម៌អនីតិជន ឆ្នាំ២០១៦។

៧. ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២

៨. ច្បាប់ស្តីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨។

៩. ច្បាប់ស្តីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦។

១០. ច្បាប់ស្តីពីការការដឹកជញ្ជូនតាមផ្លូវទឹក ឆ្នាំ២០២៤។

១០. សារាចរស្តីពី ការអនុវត្តបទប្បញ្ញត្តិ នៃការព្យួរទោសសាកល្បងនៃក្រសួងយុត្តិធម៌ ឆ្នាំ២០១៤។

១១. សារាចរស្តីពី ការអនុវត្តបទប្បញ្ញត្តិនៃ ការអនុវត្តទោសការងារសហគមន៍ ឆ្នាំ២០១៤។

### II. លិខិតបទដ្ឋានគតិយុត្តអន្តរជាតិ

១. កតិកាសញ្ញាអន្តរជាតិសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ២០០៩។

២. ប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨។

### III. វចនានុក្រម និងសទ្ទានុក្រម

១. កម្មវិធីវចនានុក្រមអេឡិចត្រូនិចរបស់តម្រាច្បាប់ ឆ្នាំ២០២២។

២. សទ្ទានុក្រមច្បាប់ភូមិបាល ឆ្នាំ២០០១។

៣. សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំងផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណីដែលត្រូវរៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះផ្សាយដោយទីស្តីការគណៈរដ្ឋមន្ត្រី នៅឆ្នាំ២០០៧។

៤. សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌ ដែលត្រូវបានរៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះផ្សាយដោយទីស្តីការគណៈរដ្ឋមន្ត្រី នៅឆ្នាំ២០១១។

## IV. សៀវភៅ និងស្នាដៃនិពន្ធ

១. នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្រ្តាចារ្យ រុន ពណ្ណារិទ្ធ និងកែសម្រួលដោយលោកស្រីសាស្រ្តាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២។

២.នីតិព្រហ្មទណ្ឌ និងគ្រួសារ រៀបរៀងដោយលោកសាស្រ្តាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្រ្តាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១៧។

៣.នីតិព្រហ្មទណ្ឌ និងគ្រួសារ រៀបរៀងដោយលោកសាស្រ្តាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្រ្តាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០២២។

៤. នីតិព្រហ្មទណ្ឌទូទៅ របស់សាស្រ្តាចារ្យ ជូន ប៊ុនធី ឆ្នាំ២០២០។

៥. សៀវភៅមរតកយុត្តិធម៌ខ្មែរ រៀបរៀងដោយបណ្ឌិត ហ៊ែល ចំរើន ឆ្នាំ២០០៩-២០១០។

៦. សៀវភៅទោសព្រហ្មទណ្ឌ រៀបរៀងដោយលោកមេធាវី កៅ សីហា ឆ្នាំ២០១៣។

## V. ប្រភពផ្សេងៗ

១. ទោសព្រហ្មទណ្ឌ វគ្គ១ https://youtu.be/gqJnaysbUkM ។

២. ទោសព្រហ្មទណ្ឌ វគ្គ២ https://youtu.be/heFkCuuIUpY ។

៣. ការពន្យល់អំពី "មូលទោស" និង "ទោសបន្ថែម" https://youtu.be/jNeFvdGkxxI?

៤. របបនៃការប្រកាសទោស វគ្គ១ https://youtu.be/6sAordnnbI8 ។

៥. របបនៃការប្រកាសទោស វគ្គ២ https://youtu.be/Qvl5cXrUUdE ។

## ឧបសម្ព័ន្ធ

- **ឧបសម្ព័ន្ធទី១៖** ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ចាប់ពីមាត្រា២៤ ដល់មាត្រា១៨២។
- **ឧបសម្ព័ន្ធទី២៖** សាលក្រមព្រហ្មទណ្ឌ។
- **ឧបសម្ព័ន្ធទី៣៖** សាលដីកាព្រហ្មទណ្ឌ ។
- **ឧបសម្ព័ន្ធទី៤៖** សារាចរស្តីពីការអនុវត្តបទប្បញ្ញត្តិនៃការអនុវត្តទោសការងារសហគមន៍ ឆ្នាំ២០១៤។

# ឧបសម្ព័ន្ធទី១

# ក្រមព្រហ្មទណ្ឌ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រមព្រហ្មទណ្ឌ
# នៃ
# ព្រះរាជាណាចក្រកម្ពុជា



២០១០

ក្រសួងយុត្តិធម៌

Ministère de la Justice

# ឧបសម្ព័ន្ធទី២

# សាលក្រមព្រហ្មទណ្ឌ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

-លេខ ៥៨ ក្រ១១ "ឃ"
ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤
-សំណុំរឿងព្រហ្មទណ្ឌលេខ ៣៦៨៥
ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣
-សំណុំរឿងស៊ើបសួរលេខ ២៦៨៣
ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣
-សំណុំរឿងជំនុំជម្រះលេខ ៣៣៩៤
ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣

# តាមនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ វេលាម៉ោង ០៩ និង ០០ នាទី ព្រឹក នៅសាលសវនាការទី២ ដោយមានសមាសភាព៖

## ក្រុមប្រឹក្សាជំនុំជម្រះ

-លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
-លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា
-លោកស្រី ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

## តំណាងអយ្យការ

-លោក ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

## ក្រឡាបញ្ជីសវនាការ

-លោកស្រី ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៦៨៥ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

ឈ្មោះ ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើតនៅភូមិត្រា សង្កាត់ស្ទឹងមានជ័យទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះជួលគ្មានលេខ ផ្លូវលំ ភូមិត្រា សង្កាត់ស្ទឹងមានជ័យទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ ម្តាយឈ្មោះ ទោសពីមុន ធ្លាប់ជាប់មណ្ឌលមិកាសង្គ្រោះរយៈពេល០៦ខែ ។

មានមេធាវី ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ

ដីកាបង្គាប់ឃុំខ្លួនលេខ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។ មណ្ឌលអប់រំកែប្រែទី១ (ម១)

ជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខសម្ភពណ្ឌប៊ែល ស្ថិតនៅផ្លូវលេខ១៩៩ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរបុគ្គលិកក្រុមហ៊ុន មានអាសយដ្ឋានផ្ទះលេខ៩ ផ្លូវP១០ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។

## អង្គហេតុនៃការចោទប្រកាន់មានដូចតទៅ ៖

កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ១០ និង៣០នាទី មុនពេលកើតហេតុជនជាប់ចោទមានឈ្មោះ ទី ភេទប្រុស អាយុប្រហែល២០ឆ្នាំ ជិះម៉ូតូម៉ាក ហុងដាសេ១២៥ ពណ៌ខ្មៅ ផលិតឆ្នាំ២០២៣ ពាក់ផ្លាកលេខ ភ្នំពេញ ដែលជាបក្សពួកបានមកឌុបជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ១៩ឆ្នាំ និងឈ្មោះ ដែលជាបក្សពួកម្នាក់ទៀតក៏បាន ជិះម៉ូតូមួយគ្រឿងម៉ាក ហុងដាសេ១២៥ ពណ៌ខ្មៅ ផលិតឆ្នាំ២០១៦ មិនចាំផ្លាកលេខ ជិះចេញពីផ្ទះជួល គ្មានលេខ ស្ថិតនៅ ភូមិត្រា សង្កាត់ស្ទឹងមានជ័យទី២

ខណ្ឌមានជ័យ រាជធានីភ្នំពេញ លុះជិះមកដល់ចំណុចមុខសម្ពណ្ឌប៉ែល ស្ថិតនៅផ្លូវលេខ១៩៩ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ជនត្រូវចោទឈ្មោះ បានបើកម៉ូតូទៅពីក្រោយរែបខាងឆ្វេង ដៃជនរងគ្រោះឈ្មោះ ភោទស្រី អាយុ៣៥ឆ្នាំ បន្ទាប់មកជនជាប់ចោទឈ្មោះ បានធ្វើសកម្មភាព ឆក់យកខ្សែករផ្លាកទីនរបស់ជនរងគ្រោះបានសម្រេច ខណៈនោះជនរងគ្រោះស្រែកថាចោរៗ និងចាប់ទាញដៃរបស់ ជនជាប់ចោទឈ្មោះ បណ្ដាលឱ្យដួលម៉ូតូភ្លាមនោះឈ្មោះ បានរត់ឡើងជិះម៉ូតូជាមួយ ជនជាប់ចោទឈ្មោះ ហើយគេចខ្លួនបាត់ ចំណែកជនជាប់ចោទឈ្មោះ ត្រូវបានសមត្ថកិច្ច ដែលល្បាតនៅជិតនោះធ្វើការឃាត់ខ្លួន និងបញ្ជូនខ្លួនមកប៉ុស្តិ៍នគរបាលរដ្ឋបាលទំនប់ទឹក ហើយជនរងគ្រោះក៏បានដាក់ ពាក្យបណ្ដឹង ដើម្បីឱ្យសមត្ថកិច្ចចាត់ការតាមនីតិវិធីតែម្ដង ។

- បានឃើញរបាយការណ៍សំយោគលេខ ០៣៥/២៣ រ.ប.ក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣ របស់ អធិការដ្ឋាននគរបាលខណ្ឌបឹងកេងកង នៃស្នងការនគរបាលរាជធានីភ្នំពេញ ។
- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២៦៨៧ អ.យ.ដ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៣២៦៤ អ.យ.ដ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ របស់អយ្យការអម សាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញដីកាសម្រេចលើកលែងចោទប្រកាន់លេខ ៤២៥២ (ជ) ស.ដ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤២៤៧ (ជ) ស.ដ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញដីការក្សាទុកជនត្រូវចោទឱ្យនៅក្នុងឃុំជាបណ្ដោះអាសន្នលេខ ៧២៩៩ (ជ) ដ.ឃ.ដ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ បានឆ្លើយនាពេលសវនាការថា៖

កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោងប្រហែល ១០ និង០០នាទី ខ្លួននៅផ្ទះជួលនៅភូមិទ្រា សង្កាត់ ស្ទឹងមានជ័យទី២ ខណ្ឌមានជ័យ ក៏មានបក្ខពួកខ្លួនចំនួន០២នាក់ ឈ្មោះ និងឈ្មោះ ជិះម៉ូតូ០១គ្រឿង ម៉ាកហុងដា ពណ៌ខ្មៅ សេរីឆ្នាំ២០១៦ មិនពាក់ស្លាកលេខ ជិះមកជួបខ្លួនរួចបបួលគ្នាដើររកឆក់ទ្រព្យសម្បត្តិគេធ្វើដំណើរតាមផ្លូវ ។ ពេល នោះនាំគ្នាធ្វើដំណើរចេញពីផ្ទះខ្លួន ដោយខ្លួនមានម៉ូតូ០១គ្រឿង ម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ សេរីឆ្នាំ២០២៣ ឱ្យ ឈ្មោះ ជាអ្នកបើកម៉ូតូ ចំណែកខ្លួនជិះពីខាងក្រោយចាំឆក់ ចំណែកបក្សពួកខ្ញុំម្នាក់ទៀតឈ្មោះ ជិះម៉ូតូមួយគ្រឿងម៉ាក ហុងដា សេ១២៥ សេរីឆ្នាំ២០១៦ ពណ៌ខ្មៅ ជាអ្នកបិទគូទ ពេលពួកខ្ញុំជិះមកដល់ចំណុចមុខសម្ពណ្ឌប៉ែល (ផ្លូវ១៩៩ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ) ពីជើងទៅត្បូង ក៏បានឃើញមនុស្សស្រីម្នាក់ដើរម្នាក់ឯងមានពាក់ ខ្សែករ ខ្លួនបានឱ្យឈ្មោះ ជិះម៉ូតូទៅរែបពីខាងស្ដាំដៃនារីនោះ រួចខ្លួនធ្វើសកម្មភាពយកដៃខាងស្ដាំឆក់ខ្សែករពីនារីនោះ តែត្រូវបាននារីនោះចាប់ដៃខ្លួនជាប់ បណ្ដាលឱ្យពួកខ្លួនបានដួលម៉ូតូហើយរត់ ភ្លាមនោះនារីម្នាក់នោះបានស្រែកថាចោរៗ ឆក់ខ្សែករឱ្យគេជួយ ស្រាប់តែក៏មានសមត្ថកិច្ចល្បាតមកឃើញឃាត់ខ្លួនបាន រួមនឹងម៉ូតូ០១គ្រឿង ម៉ាកហុងដា សេ១២៥ សេរីឆ្នាំ២០២៣ ពណ៌ខ្មៅ យកមកប៉ុស្តិ៍នគរបាលរដ្ឋបាលទំនប់ទឹក មកសាកសួរតែម្ដង។ ចំណែកបក្សពួកខ្លួនពីរនាក់ ទៀតឈ្មោះ និងឈ្មោះ បានជិះម៉ូតូរត់គេចខ្លួនបាត់។

- ចម្លើយដែលខ្លួនបានឆ្លើយនៅសមត្ថកិច្ចកាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ និងចម្លើយបានឆ្លើយនៅ អយ្យការ ព្រមទាំងចម្លើយបានឆ្លើយនៅដំណាក់កាលស៊ើបសួរ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣ ជាចម្លើយត្រឹមត្រូវ ពិតប្រាកដមែនហើយ ។

- តាមអំណាចជនរងគ្រោះឈ្មោះ បានឆ្លើយនៅសមត្ថកិច្ចថា៖

មុនពេលកើតហេតុថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោងប្រហែល១០ និង៣០នាទី ខ្លួនបានដើរចេញពីកន្លែងហូបបាយយីហោស្រីម៉ៅ នៅផ្លូវលេខ១៩៩ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ មកដល់ចំណុចជាប់មុខសម្ភពណ្ឌបែល ផ្លូវលេខ១៩៩ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ក៏មានជនសង្ស័យ (ជនជាប់ចោទ) ០៣នាក់ ជិះម៉ូតូពីរគ្រឿង ម៉ាក ហុងដា សេ១២៥ ស៊េរីឆ្នាំ២០២៣ ចំនួន០១គ្រឿង និងស៊េរីឆ្នាំ២០១៦ ចំនួន០១គ្រឿង ជិះពីជើង ទៅត្បូង ដោយខ្លួនដើរពីជើងទៅត្បូង ស្រាប់តែជនសង្ស័យ (ជនជាប់ចោទ) ចំនួន០២នាក់ ជិះម៉ូតូម៉ាក ហុងដា សេ១២៥ ស៊េរីឆ្នាំ ២០២៣ ពណ៌ខ្មៅ ពាក់ផ្លាក លេខ ភ្នំពេញ មករែបខ្លួនពីខាងឆ្វេងដៃ ហើយជនសង្ស័យ (ជនជាប់ចោទ) ០១នាក់ដែលជិះពីខាងក្រោយយកដៃខាងស្តាំឆក់យកខ្សែករផ្លាកទីនជិត០៤តំឡឹង ភ្លាមនោះខ្លួនស្រែកថាចោរៗឆក់ខ្សែករ ដើម្បីឱ្យគេជួយ ភ្លាមនោះពួកវាក៏បានរត់ ហើយសមត្ថកិច្ចដែលកំពុងល្បាតនៅជិតនោះក៏បានដេញចាប់បានគ្នាវាចំនួន ០១នាក់ ឈ្មោះ ភេទប្រុស រួមនឹងម៉ូតូ ០១គ្រឿង ម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ ២០២៣ ពាក់ផ្លាកលេខ ភ្នំពេញ យកមកទីនេះតែម្តង ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

- តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ និងអំណាចចម្លើយរបស់ដើមបណ្តឹងឈ្មោះ និងភស្តុតាងនៅក្នុងសំណុំរឿង ឃើញថាពិតជាមានអំពើ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខសម្ភពណ្ឌបែល ស្ថិតនៅផ្លូវលេខ១៩៩ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង១០ និង៣០នាទី បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។ តំណាងអយ្យការរក្សាបទចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

- សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ៖ ឆ្លងតាមសវនាការសាកសួរដេញដោលនេះ កូនក្តីខ្លួនបានសារភាពដឹងកំហុសពីការដែលខ្លួនបានប្រព្រឹត្តក្នុងអំពើនេះតាំងពីដំណាក់កាលដំបូងរហូតពេលជំនុំជម្រះ រីឯក៏ជាការប្រព្រឹត្តលើកទីមួយមានចំណេះដឹងទាប រស់ក្នុងជីវភាពក្រលំបាក គ្មានមុខរបរទីពឹងដូច្នេះសុំតុលាការមេត្តា បន្ធូរបន្ថយទោសដោយអនុគ្រោះផងចុះ ។

## សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ បាននិយាយសម្តីចុងក្រោយ ស្នើសុំឱ្យតុលាការបន្ធូរបន្ថយទោស ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយបង្អស់របស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារភស្តុតាងនានាក្នុងសំណុំរឿង

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់រួចហើយ

## សំអាងហេតុ

១- តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤២៤៧ ជ.ផង ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានបញ្ជូនជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ ពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខសម្ភពណ្ឌបែល ស្ថិតនៅផ្លូវលេខ១៩៩ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ មកជំនុំជម្រះ ។

២- កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ ពិតជាមានអំពើ លួចមានស្ថានទម្ងន់ទោស ដែលបង្កដោយជនជាប់ចោទឈ្មោះ ប្រព្រឹត្តនៅចំណុចមុខសម្តពណ្ឌបែល ស្ថិតនៅផ្លូវលេខ១៩៩ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

៣- តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ១០ និង៣០នាទី ខ្លួននិងបក្សពួក ពិតជាបានរួមគ្នាធ្វើសកម្មភាពយកដៃទាញស្ពាយផ្ទះខ្សែករពីជនរងគ្រោះឈ្មោះ នៅចំណុចសម្តពណ្ឌបែល ផ្លូវលេខ១៩៩ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រ ចម្លើយនេះមានភាពស៊ីសង្វាក់ទៅនឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ និងភស្តុតាងក្នុងសំណុំរឿង អាចឱ្យតុលាការពិនិត្យ និងពិចារណាជឿទុកចិត្តបានក្នុងការសម្រេចតាមច្បាប់ ។

៤- ចំពោះឈ្មោះ ភេទប្រុស អាយុប្រហែល២០ឆ្នាំ និងឈ្មោះ ភេទប្រុស អាយុប្រហែល២១ឆ្នាំ ដែលជាបក្សពួកក្នុងអំពើចូលរួមប្រព្រឹត្តបទល្មើសនេះ (គ្មានសាវតាជាតិ) ត្រូវបានចៅក្រមស៊ើបសួរសម្រេចលើកលែងចោទប្រកាន់តាមដីកាលើកលែងចោទប្រកាន់លេខ ៤២៥២ (ជ) ដ.ជ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣ នោះតុលាការគ្រាន់តែបញ្ជាក់នៅក្នុងអង្គហេតុប៉ុណ្ណោះ ។

៥- អំពើរបស់ជនជាប់ចោទឈ្មោះ គឺពិតមានចេតនាទុច្ចរិត ធ្វើសកម្មភាពមានគ្នីគ្នា ឆក់យកខ្សែករពីជនរងគ្រោះ ជាស្ត្រីតាមផ្លូវសាធារណៈ គឺជាអំពើ លួចមានស្ថានទម្ងន់ទោស ដែលអំពើនេះធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់ជនរងគ្រោះអាចបង្កគ្រោះថ្នាក់ដល់រូបរាងកាយទៀតផង ជាពិសេសគឺសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ និងអសន្តិសុខសង្គម ដែលច្បាប់កំណត់ថាបទល្មើសព្រហ្មទណ្ឌមានចែងក្នុងមាត្រា ៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ បញ្ញត្តិឱ្យផ្តន្ទាទោសដាក់ពន្ធនាគារពី ០៣ (បី) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

៦- ជនជាប់ចោទឈ្មោះ ជានិតិជន មានការយល់ដឹងចំពោះអំពើដែលខ្លួនបានប្រព្រឹត្តពោល គឺពុំមានសញ្ញាណណាមួយដែលនាំឱ្យមានការសង្ស័យអំពីបញ្ហាស្មារតីឡើយ គប្បីទទួលខុសត្រូវនូវទង្វើរបស់ខ្លួនបានប្រព្រឹត្ត តាមច្បាប់ជាធរមាន ។

៧- តាមសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការនាពេលសវនាការបានបញ្ជាក់ពីភស្តុតាងដាក់បន្ទុកដែលកំណត់ពីពិរុទ្ធភាពគ្រប់គ្រាន់ និងរក្សាការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរដែលនោះ ព្រមទាំងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទឈ្មោះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៨- តាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានលើកពីហេតុផលពីកូនក្តីពុំមានចំណេះដឹងពុំយល់ដឹងពីអំពើប្រព្រឹត្តរបស់ខ្លួនថាធ្ងន់ធ្ងរនោះទេ ដោយសារការអូសទាញពីបក្សពួកប្រព្រឹត្តខុសច្បាប់បែបនេះណាមួយជីវភាពក្រលំបាករស់នៅផ្ទះជួលគ្មានមុខរបរទីពឹងនេះដែលនាំឱ្យដើរផ្លូវខុស ដូច្នេះស្នើសុំឱ្យតុលាការបន្ធូរបន្ថយទោសឱ្យកូនក្តីនោះ ដើម្បីកែខ្លួនបានម្តងទៀតដោយអនុគ្រោះ គប្បីតុលាការពិចារណា និងសម្រេចតាមច្បាប់ ។

៩- មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ

- ឈ្មោះ ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ

ពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខសម្តពណ្ឌបែល ស្ថិតនៅផ្លូវលេខ១៩៩ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង១០ និង៣០នាទី តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

១០- ចំពោះដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ គ្រាន់តែបានដាក់ពាក្យបណ្តឹង និងបានឆ្លើយនៅសមត្ថកិច្ចព្រមទាំងសំណូមពរឱ្យជួយចាត់ការតាមនីតិវិធីច្បាប់ចំពោះជនដែលប្រព្រឹត្តមកលើខ្លួនក្នុងរឿងហេតុនេះប៉ុណ្ណោះ ពីព្រោះខ្លួនបានទទួលរបស់របរ (ខ្សែកផ្លាទីន) វិញហើយនៅសមត្ថកិច្ច ។

១១- វត្ថុចាប់យកមានដូចក្នុងកំណត់ហេតុ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ មាន ម៉ូតូ ០១គ្រឿង ម៉ាក Honda Dream ពណ៌ខ្មៅ ពាក់ផ្លាកលេខ (មិនប្រាកដ) មកដល់

ពេលនេះពុំមានម្ចាស់ប្រកបប្រជាឡើយ ហើយជាភស្តុតាងសម្រាប់ជាឧបករណ៍ឲ្យជនជាប់ចោទប្រព្រឹត្តបទល្មើសនេះ ដូច្នេះគួរតែរឹបអូសទុកជាសម្បត្តិរដ្ឋតាមច្បាប់ ។

## ហេតុដូច្នេះសម្រេច

១- ផ្តន្ទាទោសឈ្មោះ ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារ កំណត់រយៈពេល ០៣ឆ្នាំ ០៦ខែ (បីឆ្នាំប្រាំមួយខែ) ។

ពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណតមុខសង្កាត់ណូប៊ែល ស្ថិតនៅផ្លូវលេខ១៩៩ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

២- វត្ថុចាប់យកមានដូចក្នុងកំណត់ហេតុ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ មាន ម៉ូតូ ០១គ្រឿង ម៉ាក Honda Dream ពណ៌ខ្មៅ ពាក់ផ្លាកលេខ (មិនប្រក្រតី) ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទឈ្មោះ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ និងប្រកាសសាធារណៈ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤ ។

ភាគីមានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់បានកំណត់ ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃចន្ទ ១២កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ,ថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤
**ក្រឡាបញ្ជី**

បានឃើញ
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**
-លេខ ១៧៦៥ "ឃ"
ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣
-សំណុំរឿងព្រហ្មទណ្ឌលេខ ៤៩៦៨
ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២២
-សំណុំរឿងស៊ើបសួរលេខ ៣៧៤០
ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២២
-សំ ◉រឿងជំនុំជម្រះលេខ ៤៨២០
ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២

## គាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ០៩ និង០០នាទី នៅសាលសវនាការទី៨ ដោយមានសមាសភាព៖

### ចៅក្រមជំនុំជម្រះ

- លោក ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

### តំណាងអយ្យការ

-លោក ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោកស្រី ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៩៦៨ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

ឈ្មោះ ភេទប្រុស អាយុ៣៥ឆ្នាំ កើតឆ្នាំ១៩៨៧ ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ កំរិតវប្បធម៌គ្មាន មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅភូមិស្វាយស ឃុំតាយោគ ស្រុកស្ទោង ខេត្តកំពង់ធំ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅមិនពិតប្រាកដ ឪពុកឈ្មោះ (ស្លាប់) ម្តាយឈ្មោះ (ស្លាប់) នៅលីវ ជានីតិជនទោសពីមុន គ្មាន ។

ដីកាបង្គាប់ឃុំខ្លួនលេខ (ព) ដ.ឃ.ដ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។ មណ្ឌលអប់រំកែប្រែទី១ (ម១)

ជាប់ចោទពីបទ *រំលោភលើទំនុកចិត្ត* ប្រព្រឹត្តនៅចំណុចស្ថានីយ៍ប្រេងឥន្ធនៈ Lim Long ផ្លូវបេតុងព្រៃស ស្ថិតនៅភូមិព្រៃសខាងលិច សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ភេទប្រុស អាយុ៥០ឆ្នាំ ជនជាតិខ្មែរ មានអាសយដ្ឋានភូមិត្រពាំងស្វាយ សង្កាត់ព្រៃវែង ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

### អង្គហេតុនៃការចោទប្រកាន់មានដូចតទៅ៖

កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង០៨ និង០០ នាទី ជនរងគ្រោះឈ្មោះ ភេទប្រុស បានឱ្យឈ្មោះ ភេទប្រុស ទៅដឹកប្រេងពីស្ថានីយ៍ប្រេងឥន្ធនៈ Lim Long ផ្លូវបេតុងព្រៃស ស្ថិតនៅភូមិព្រៃសខាងលិច សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ដើម្បីចាក់គ្រឿងចាក់ តែទូទាត់លុយរួចហើយ ។ រហូតមកដល់ថ្ងៃទី០១ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង១៥ និង០០ នាទី ស្រាប់តែបុគ្គលិកស្ថានីយ៍ប្រេងឥន្ធនៈ Lim Long បានយកវិក័យបត្រចំនួន២៥បុង មកទូទាត់ប្រាក់ជាមួយជនរងគ្រោះ ពេលនោះជនរងគ្រោះបានពិនិត្យវិក្ក័យបត្រឃើញមានឈ្មោះ ចំនួន ១១ បុង ដោយមានការសង្ស័យជនរងគ្រោះក៏ប្រាប់បុគ្គលិកស្ថានីយ៍ប្រេងឥន្ធនៈ Lim Long បើឃើញឈ្មោះ មក យកប្រេងទៀតឱ្យទូរស័ព្ទប្រាប់គាត់ផង ។ លុះមកដល់០៥ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង០៩និង០០នាទី

ស្រាប់តែចៅហ្វាយស្តីទីហ៍ប្រេងឥន្ធនៈ Lim Long បានទូរស័ព្ទប្រាប់ជនរងគ្រោះ ថាជនសង្ស័យឈ្មោះ មកយកប្រេងទៀតហើយ ភ្លាមនោះជនរងគ្រោះក៏បានរាយការណ៍ប្រាប់សមត្ថកិច្ច ឱ្យជួយអន្តរាគមន៍ឃាត់ខ្លួនជនសង្ស័យ រួមទាំងវត្ថុតាងបានតែម្តង។

- បានឃើញរបាយការណ៍សំយោគលេខ ០៩២/២២ របក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២ របស់អធិការនគរបាលខណ្ឌដង្កោ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។
- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣៧២៤ អយឈ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៥៥០០ អ.យ.ឈ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៦០៨១ ឈ១.ដអ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញដីកាសម្រេចរក្សាទុកជនត្រូវចោទឱ្យនៅក្នុងឃុំបណ្តោះអាសន្នលេខ ៩៨៥៦ ឈ១.ដឃដ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

**នាពេលសវនាការ**

- ជនជាប់ចោទឈ្មោះ បានឆ្លើយនាពេលសវនាការថា៖

ខ្លួនធ្វើជាបុគ្គលិកនៅកាវ៉ាសសាំង Lim Long បានរយៈពេលចំនួន០២ខែ រួចក៏បានឈប់មួយរយៈ ។ ក្រោយមកក៏បានចូលទៅធ្វើការនៅកន្លែងដដែលវិញ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង១៧ និង០០នាទី ខ្លួនបានទៅកាវ៉ាស់សាំង Lim Long ស្ថិតនៅភូមិព្រៃសលិច សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ទៅយកប្រេងចំនួន០១កាន (៣០លីត្រ) ដោយប្រាប់ថាឈ្មោះ តាសក់ស (ម្ចាស់កាវ៉ាស់ជួសជុលរថយន្ត) ជាអ្នកឱ្យមកយក ហើយខ្លួនក៏បានស៊ីញ៉េទទួល ។ បន្ទាប់មកខ្លួនក៏បានយកបងទៅលក់នៅកន្លែងប៉ះកង់ឡាន នៅម្តុំព្រៃ បានប្រាក់ចំនួន ១២០,០០០ (ដប់ពីរម៉ឺន) រៀល ។

នៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង០៧ និង០០នាទី ខ្លួនក៏បានជិះម៉ូតូ របស់ម្ចាស់កាវ៉ាស់ជួសជុលរថយន្ត ទៅកាវ៉ាស់សាំង Lim Long ទៅយកប្រេងចំនួន០១កាន មកលក់នៅកន្លែង ប៉ះកង់ឡានដដែលបានប្រាក់ចំនួន ១២០,០០០ (ដប់ពីរម៉ឺន) រៀល ។ នៅថ្ងៃខែឆ្នាំដដែល វេលាម៉ោង១៧ និង០០នាទី ខ្លួនបានជិះម៉ូតូទៅយកប្រេង០១កានទៀត ដែលប្រាប់ម្ចាស់កាវ៉ាស់សាំង Lim Long ថាម្ចាស់កាវ៉ាស់ជួសជុលរថយន្តឱ្យមកយក ហើយខ្លួនបានយកទៅលក់នៅកន្លែងប៉ះកង់ឡាន នៅម្តុំព្រៃស បានប្រាក់ចំនួន ១២០,០០០ (ដប់ពីរម៉ឺន) រៀល ។ នៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២២ ខ្លួនបានជិះម៉ូតូរបស់ម្ចាស់កាវ៉ាស់ជួសជុលរថយន្តទៅយក ប្រេងនៅកាវ៉ាស់សាំង Lim Long ចំនួន០១កាន និងនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ ចំនួន០១កានទៀត រួចក៏យក ទៅលក់កន្លែងប៉ះកង់ឡានដដែលបានលុយចំនួន ២៤០,០០០ (ម្ភៃបួនម៉ឺន) រៀល ។

នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ ខ្លួនបាន ជិះម៉ូតូរបស់ម្ចាស់កាវ៉ាស់ជួសជុលរថយន្តទៅយកប្រេងនៅកាវ៉ាស់សាំង Lim Long ចំនួន០១កាន និងនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២ ចំនួន០១កានទៀត ហើយថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ ខ្លួនបានទៅយកប្រេងនៅកាវ៉ាស់សាំង Lim Long ចំនួន០២កាន រួចក៏យកទៅលក់នៅកន្លែងប៉ះកង់ឡាន ដដែលបានលុយចំនួនសរុប ៤៨០,០០០ (សែសិបប្រាំបីម៉ឺនរៀល) ។ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ខ្លួនបានជិះម៉ូតូរបស់ម្ចាស់កាវ៉ាស់ជួសជុលរថយន្តទៅយកប្រេងនៅកាវ៉ាស់សាំង Lim Long ចំនួន០១កាន រួចក៏យកទៅលក់នៅកន្លែងប៉ះកង់ឡានដដែលបានលុយចំនួន ១២០,០០០ (ដប់ពីរម៉ឺន) រៀល ។

នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០២២ ខ្លួនបានជិះម៉ូតូរបស់ម្ចាស់កាវ៉ាស់ជួសជុលរថយន្តទៅយកប្រេងនៅកាវ៉ាស់សាំង Lim Long ចំនួន០១កាន រួចក៏យកទៅលក់កន្លែងប៉ះកង់ឡានដដែលទៀត បានលុយចំនួន ១២០,០០០ (ដប់ពីរម៉ឺន) រៀល ។ នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២ ខ្លួនបានជិះម៉ូតូរបស់ម្ចាស់កាវ៉ាស់ជួសជុលរថយន្តទៅយកប្រេងនៅកាវ៉ាស់សាំង Logចំនួន ០២កាន ប៉ុន្តែពុំទាន់បានដឹកចេញផង ស្រាប់តែសមត្ថកិច្ចមកដល់ធ្វើការឃាត់ខ្លួនតែម្តង។ កន្លងមកឈ្មោះ ហៅតាសក់ស ធ្លាប់ប្រើខ្លួនឱ្យទៅដឹកសាំងពីកាវ៉ាស់សាំង Lim Long ចំនួន០៥ដង ដោយម្ចាស់កាវ៉ាស់ជួសជុលរថយន្តបាន

ខ្ទាត់ប្រាក់ឱ្យម្ចាស់ ការ៉ាស់សាំងរួចរាល់ហើយ។ ខ្លួនបានទៅយកសាំងដោយខ្លួនឯងចំនួន១១ដង មកហើយដោយម្ចាស់ការ៉ាស់ផ្លាស់ប្តូររថយន្ត មិនបានបើខ្លួនទៅយកនោះទេ ។ នៅពេលទៅយកសាំងម្ចាស់ការ៉ាស់សាំង Lim Long មិនបានសួរនាំនោះទេ គ្រាន់តែឱ្យខ្លួនស៊ីញ៉េនៅលើវិក័យបត្រ ។ សមត្ថកិច្ចដកហូតសម្ភារៈពីខ្លួនមានកាបូបលុយមួយ និងទូរស័ព្ទមួយគ្រឿងម៉ាក NOKIA អិនចុចពិល ។

- ចម្លើយដែលខ្លួនបានឆ្លើយនៅសមត្ថកិច្ច កាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២ និងចម្លើយបានឆ្លើយនៅ អយ្យការ ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២២ ព្រមទាំងចម្លើយដែលខ្លួនបានឆ្លើយនៅដំណាក់កាលស៊ើបសួរពិតជាចម្លើយត្រឹមត្រូវរបស់ខ្លួនប្រាកដមែន ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ អវត្តមាន ។

- តាមអំណានដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ បានឆ្លើយនៅសមត្ថកិច្ច និងចៅក្រមស៊ើបសួរប្រហាក់ប្រហែលគ្នាថា ៖ កាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង១៥និង០០នាទី ខ្លួនកំពុងធ្វើការនៅការ៉ាស់ផ្លាស់ប្តូរ រថយន្តស្ថិតនៅភូមិព្រៃសលិច សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ស្រាប់តែបុគ្គលិក ស្ថានីយ៍ប្រេងឥន្ធនៈ Lim Long បានយកវិក័យបត្រមកទូរទាត់ប្រាក់មានចំនួន១២បុង គិតជាប្រាក់ចំនួន ៤៤៣,៥ដុល្លារ ដោយមានឈ្មោះ

ភេទប្រុស អាយុ៣៥ឆ្នាំ មុខរបរនិងទីលំនៅ មិនពិតប្រាកដ ដែលជាអ្នកចុះហត្ថលេខា ដោយខ្លួនពុំបានប្រើឱ្យទៅ ទិញប្រេងពីការ៉ាស់សាំងនោះឡើយ ។ លុះដល់ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង០៨និង០០នាទី ស្រាប់តែឈ្មោះ បានទៅយកប្រេងពីការ៉ាស់សាំងខាងលើទៀត បន្ទាប់មកខ្លួនក៏បានរាយការណ៍ប្រាប់សមត្ថកិច្ច ដើម្បីជួយ អន្តរាគមន៍ឃាត់ខ្លួនឈ្មោះ ហើយខ្លួនក៏បានដាក់ពាក្យ បណ្តឹងតែម្តង ។

- តាមអំណានសាក្សីឈ្មោះ (ជានាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលព្រៃស) បានឆ្លើយនៅដំណាក់កាល ចៅក្រមស៊ើបសួរថា ៖ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង០៨ និង០០នាទី ជនរងគ្រោះឈ្មោះ

ភេទប្រុស អាយុ៥០ឆ្នាំ បានឱ្យឈ្មោះ ភេទប្រុស អាយុ៣៥ឆ្នាំ ទៅដឹកប្រេងស្ថានីយ៍ប្រេងឥន្ធនៈ Lim Long ផ្លូវបេតុង ព្រៃស ស្ថិតនៅភូមិព្រៃសខាងលិច សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ដើម្បីយកមកចាក់ឱ្យគ្រឿងចក្រ តែបានទូទាត់លុយរួចហើយ ។ រហូតដល់ថ្ងៃទី០១ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង១៥និង ០០នាទី ជនរងគ្រោះកំពុងធ្វើការនៅការ៉ាស់ផ្លាស់ប្តូររថយន្តខាងលើស្រាប់តែមានបុគ្គលិកស្ថានីយ៍ប្រេងឥន្ធនៈ Lim Long បានយកវិក័យបត្រមកទូរទាត់ប្រាក់មានចំនួន២៥បុង ហើយជនរងគ្រោះបានពិនិត្យវិក័យបត្រឃើញមានឈ្មោះ មាន ភាព ហៅ ក្រឹម ចំនួន១១បុង ដោយមានការសង្ស័យថាជនសង្ស័យលួចទៅយកប្រេងលក់យកលុយស៊ីចាយ ក៏បានប្រាប់បុគ្គលិក ប្រេងពីស្ថានីយ៍ប្រេង ឥន្ធនៈLim Long ថាបើថ្ងៃក្រោយឃើញជនសង្ស័យមកយកបុងទៀតឱ្យប្រាប់គាត់មុនសិន ។ លុះដល់ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង០៨និង០០នាទី ស្រាប់តែថៅកែស្ថានីយ៍ប្រេងឥន្ធនៈ Lim Long បានទូរស័ព្ទប្រាប់ថា ជនសង្ស័យបានយកប្រេងទៀតហើយ រួចជនរងគ្រោះក៏បានទូរស័ព្ទរាយការណ៍ប្រាប់សមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលព្រៃស ឱ្យជួយអន្តរាគមន៍ឃាត់ខ្លួនជនសង្ស័យរួមនឹង វត្ថុតាងមានវិក័យបត្រប្រេងចំនួន១២បុង និងកាបូបលុយចំនួន០១ ត្រង់ចំណុច ស្ថានីយ៍ប្រេងឥន្ធនៈ Lim Long ស្ថិតនៅភូមិព្រៃសខាងលិច សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ យកមកធ្វើការ សាកសួរនៅប៉ុស្តិ៍នគរបាលរដ្ឋបាលព្រៃស តាមផ្លូវច្បាប់ហើយជនរងគ្រោះ ក៏បានមកដាក់ពាក្យបណ្តឹងចំឈ្មោះ ជនសង្ស័យ ខាងលើនៅប៉ុស្តិ៍នគរបាលរដ្ឋបាលព្រៃស ដើម្បីឱ្យសមត្ថកិច្ចចាត់ការតាមនីតិវិធីច្បាប់តែម្តង ។ ក្រោយពីធ្វើការសាកសួរ ជនសង្ស័យក៏បានឆ្លើយសារភាពប្រាប់សមត្ថកិច្ចថា រូបគេពិតជាបានទៅយកប្រេងស្ថានីយ៍ប្រេងឥន្ធនៈ Lim Long ផ្លូវបេតុង ព្រៃស ស្ថិតនៅភូមិព្រៃសខាងលិច សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង១៥និង០០នាទី ប្រាកដមែន ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ និងស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី បង្ហាញថាពិតជាមានអំពើ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុច ស្ថានីយ៍ប្រេងឥន្ធនៈ Lim Long ផ្លូវបេតុងព្រៃស ស្ថិតនៅភូមិព្រៃសខាងលិច សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ

នៃក្រមព្រហ្មទណ្ឌ ប្រាកដមែន ។ តំណាងអយ្យការ តម្កល់បទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរ និងសុំឱ្យចៅក្រមជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

## សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ បាននិយាយសម្តីចុងក្រោយស្នើសុំឱ្យ តុលាការបន្ធូរបន្ថយទោស ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយបង្អស់របស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារភស្តុតាងនានា

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់រួចហើយ

## សំអាងហេតុ

១- តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៦០៨១ ឈ១.ដង ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានបញ្ជូនជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ៣៥ឆ្នាំ កើតឆ្នាំ១៩៨៧ ជនជាតិខ្មែរ ពីបទ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណតស្ថានីយ៍ប្រេងឥន្ធនៈ Lim Long ផ្លូវបេតុងព្រែស ស្ថិតនៅភូមិព្រែសខាងលិច សង្កាត់ព្រែស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ មកជំនុំជម្រះ ។

២- កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២២ ពិតជាមានអំពើ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណតស្ថានីយ៍ប្រេងឥន្ធនៈ Lim Long ផ្លូវបេតុងព្រែស ស្ថិតនៅភូមិព្រែសខាងលិច សង្កាត់ព្រែស ខណ្ឌដង្កោ រាជធានីភ្នំពេញ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ប្រាកដមែន។

៣- តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ បានឆ្លើយថា៖ ខ្លួនជាបុគ្គលិករបស់ស្ថានីយ៍ប្រេងឥន្ធ: Lim Long បានមកយកប្រេងពីស្ថានីយ៍នេះ ទៅឱ្យអតិថិជនឈ្មោះ នៅការ៉ាសជួសជុលរថយន្ត ប៉ុន្តែត្រូវបានឈ្មោះ ម្ចាស់ការ៉ាសបដិសេធថាមិនបានឱ្យជនជាប់ចោទឈ្មោះ នេះ ទៅយកប្រេងឱ្យខ្លួនដែលមានចំនួន ១១ធុង នោះទេ ហើយជនជាប់ចោទក៏បានសារភាពថា ឈ្មោះ ម្ចាស់ការ៉ាសជួសជុលរថយន្តមិនបានប្រើខ្លួនឱ្យទៅយកប្រេងនៅស្ថានីយ៍ប្រេងឥន្ធនៈ Lim Long ដែលស្ថិតនៅផ្លូវបេតុងព្រែស ភូមិព្រែសខាងលិច សង្កាត់ព្រែស ខណ្ឌដង្កោ រាជធានីភ្នំពេញ នោះទេ ហើយជនជាប់ចោទបានទៅយកប្រេងចំនួន ១១នោះ ដែលមានប៉ុងចំនួន១១នោះ គឺជាការពិត យកទៅលក់នៅកន្លែងផ្សេង ដើម្បីទទួលប្រយោជន៍ជាប្រាក់ ហេតុដូច្នេះតុលាការយល់ឃើញថា ជនជាប់ចោទឈ្មោះ ពិតជាមានចេតនាបានកែបំបាត់ប្រេង ដើម្បីយកទៅលក់ប្តូរជាប្រាក់ ដើម្បីប្រយោជន៍ខ្លួនឯងប្រាកដមែន ។ ចម្លើយនេះមានភាពស៊ីសង្វាក់ទៅនឹងអំណានចម្លើយរបស់ដើមបណ្តឹង និងជាជនរងគ្រោះ ឈ្មោះ ព្រមទាំងចម្លើយសាក្សីឈ្មោះ (ជានាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលព្រែស) អាចឱ្យតុលាការពិចារណា និងសម្រេច តាមច្បាប់បាន ។

៤- អំពើរបស់ជនជាប់ចោទឈ្មោះ គឺពិតមានចេតនាទុច្ចរិត គឺជាអំពើ រំលោភលើទំនុកចិត្ត ដែលអំពើនេះធ្វើឱ្យប៉ះពាល់ដល់ផល ប្រយោជន៍របស់ជនរងគ្រោះ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងអសន្តិសុខសង្គម ដែលច្បាប់កំណត់ថា បទល្មើសព្រហ្មទណ្ឌមានចែងក្នុង មាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌបញ្ញត្តិឱ្យផ្តន្ទាទោសដាក់ពន្ធនាគារពី ០៦ (ប្រាំមួយ) ខែ ទៅ ០៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១,០០០,០០០ (មួយលាន)រៀល ទៅ ៦,០០០,០០០ (ប្រាំមួយលាន) រៀល ។

៥- ជនជាប់ចោទឈ្មោះ ជាទិតិជន មានការយល់ដឹងចំពោះអំពើដែលខ្លួនបានប្រព្រឹត្តពេលគឺពុំមាន សញ្ញាណណាមួយ ដែលនាំឲ្យមានការសង្ស័យអំពីបញ្ហាស្មារតីឡើយ គប្បីទទួលខុសត្រូវនូវទង្វើរបស់ខ្លួនបានប្រព្រឹត្ត តាមច្បាប់ជាធរមាន ។

៦- តាមសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ វក្សាការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរនោះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីតុលាការពិចារណារ និងសម្រេចបាន ។

៧- មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ ពីបទ វំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចស្ថានីយ៍ប្រេងឥន្ធនៈ Lim Long ផ្លូវបេតុងព្រៃស ស្ថិតនៅភូមិព្រៃសខាងលិច សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២២ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

៨- វត្ថុតាងមានបញ្ជាក់ចាប់យកមានក្នុងកំណត់ហេតុទទួលវត្ថុចាប់យក (០១) លេខ ១៩០៥ រវត/២២ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២២ របស់ក្រឡាបញ្ជីទទួលបន្ទុកឃ្លាំង វត្ថុចាប់យកនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញមាន៖ វិក្កយបត្រប្រេង (ប៊ុងប្រេង) ចំនួន ១២ (ដប់ពីរ) សន្លឹក និងកាបូប (ដាក់លុយ) ចំនួន ០១ (មួយ) គ្មានប្រាក់ គប្បីរឹបអូសបំផ្លាញចោល ។

៩- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ បានឆ្លើយនៅដំណាក់កាលស៊ើបសួរមិនបានប្តឹងទាមទារសំណងអ្វីទេ គប្បីតុលាការពិចារណា តែក្នុងការដាក់ទោសតាមច្បាប់ ។

## ហេតុដូច្នេះសម្រេច

១- ផ្តន្ទាទោសឈ្មោះ ភេទប្រុស អាយុ៣៥ឆ្នាំ កើតឆ្នាំ១៩៨៧ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ រយៈពេល ១៨ (ដប់ប្រាំបី) ខែ និងពិន័យជាប្រាក់ ១.០០០.០០០ (មួយលាន) រៀល ពីបទ វំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុច ស្ថានីយ៍ប្រេងឥន្ធនៈ Lim Long ផ្លូវបេតុងព្រៃស ស្ថិតនៅភូមិព្រៃសខាងលិច សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

២- វត្ថុតាងមានបញ្ជាក់ក្នុងកំណត់ហេតុទទួលវត្ថុចាប់យក (០១) លេខ ១៩០៥ រវត/២២ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២២ របស់ក្រឡាបញ្ជីទទួលបន្ទុកឃ្លាំងវត្ថុចាប់យក នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ មាន៖ វិក្កយបត្រប្រេង (ប៊ុងប្រេង) ចំនួន ១២ (ដប់ពីរ) សន្លឹក និងកាបូប (ដាក់លុយ) ចំនួន ០១ (មួយ) គ្មានប្រាក់ ត្រូវរឹបអូសបំផ្លាញចោល ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ និងប្រកាសសាធារណៈ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣ ។

ភាគីមានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា ហត្ថលេខា និងត្រា

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃសុក្រ ៧កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤

បានឃើញ

ចៅក្រមជំនុំជម្រះ

ក្រឡាបញ្ជី

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

-លេខ ១២៣៤ "ឃ"
ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤
-សំណុំរឿងព្រហ្មទណ្ឌលេខ ១៥៤៧
ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២
-សំណុំរឿងស៊ើបសួរលេខ ១៧៣៧
ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២
-សំណុំរឿងជំនុំជម្រះលេខ ៦០២
ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# តាមនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង០៩ និង០០នាទី ព្រឹក នៅសាលសវនាការទី៧ ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

- លោក ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

-លោក ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោកស្រី ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៥៤៧ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

ឈ្មោះ ភេទប្រុស អាយុ៤១ឆ្នាំ កើតថ្ងៃទី១០ ខែមករា ឆ្នាំ១៩៨២ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១១២៨៤៧០៧៦ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅសង្កាត់លេខ៤ ក្រុងភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះលេខ៦៣BEo ផ្លូវលេខ១៣៨ ភូមិ៧ សង្កាត់ផ្សារដេប៉ូទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស្លាប់) ម្ដាយឈ្មោះ (រស់) មានប្រពន្ធឈ្មោះ ជានិតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

មានដីកាបង្គាប់ឲ្យនាំខ្លួនលេខ (ឃ១) ដ.ច.ន ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២ របស់ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ ។

មានដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្នលេខ ០៧៦ (ឃ១) ដ.ព.ស ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២៣ របស់ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ ។

ជាប់ចោទពីបទ បើកបរយានយន្តក្នុងស្ថានភាពស្រវឹង ប្រព្រឹត្តនៅចំណុចផ្លូវ៣០ម៉ែត្រ ប្រសព្វផ្លូវបេតុង ភូមិ

ម៉ាក HONDA C125 ពណ៌ខ្មៅ ពាក់ផ្លាកលេខ កំពង់ចាម 1K-6025 បើកបរដោយឈ្មោះ ភេទប្រុស កើតឆ្នាំ ១៩៩៤ ជនជាតិខ្មែរ រួមដំណើរជាមួយឈ្មោះ ភេទប្រុស កើតឆ្នាំ១៩៨៧ ជនជាតិខ្មែរ បានធ្វើដំណើរបញ្ច្រាសទិសចរាចរណ៍តាមបណ្តោយពាក់ម៉ិត ទិសដៅពីជើងទៅត្បូង លុះមកដល់ចំណុចកើតហេតុខាងលើ បានបុកជាមួយរថយន្ត០១ គ្រឿងម៉ាក HIGHLANDER ពណ៌ក្រហម ពាក់ផ្លាកលេខ ភ្នំពេញ បើកបរដោយឈ្មោះ ភេទប្រុស អាយុ៤១ឆ្នាំ កើតថ្ងៃទី១០ ខែមករា ឆ្នាំ១៩៨២ ជនជាតិខ្មែរ រួចរថយន្តរេចង្កូតទៅបុកខឿនមុខផ្ទះ បណ្តាលឱ្យអ្នកបើកបរម៉ូតូម៉ាក HONDA C125 ឈ្មោះ ស្លាប់នៅកន្លែងកើតហេតុ ចំណែកអ្នករួមដំណើរឈ្មោះ រងរបួសធ្ងន់។

- បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៣៦៧៦ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២០ ។
- បានឃើញសំណុំរឿងជំនុំជម្រះលេខ ៣៧៩០ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០ ។
- បានឃើញដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះផ្ទាល់លេខ ០៨៦ អ.យ.ត ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២០ របស់តំណាងអយ្យការនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញសាលក្រមចាត់របៀបលេខ ១២៣ (ឃ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញដីកាសម្រេចបញ្ចូលរឿងលេខ ១៥០៨ (ឃ) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ចៅក្រមជំនុំជម្រះនៃសាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញរបាយការណ៍របស់នាយផ្នែកដោះស្រាយគ្រោះថ្នាក់ចរាចរណ៍ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ របស់ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក ។
- បានឃើញរបាយការណ៍លេខ ២២២ ល.ស ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០ របស់ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក ។
- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៥៩៣ អ.យ.ឈ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៣៤៤ អ.យ.ឈ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញដីកាលើកលែងចោទប្រកាន់លេខ ៦១៨ (ឃ១) ដ.ឋ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

ពលរដ្ឋ ហើយខ្លួនក៏បានចុះទៅមើលជនរងគ្រោះដែលជាអ្នកបើកម៉ូតូនិងអ្នករួមដំណើរ ដោយពេលនោះពួកគេរបួសធ្ងន់ ហើយខ្លួនសុំឲ្យប្រជាពលរដ្ឋនៅក្បែរនោះជួយធ្វើចលនាបេះដូងឲ្យជនរងគ្រោះផង តែប្រជាពលរដ្ឋទាំងនោះពុំបានជួយទេ ទើបបណ្តាលឲ្យជនរងគ្រោះដែលជាអ្នកបើកម៉ូតូនោះស្លាប់នៅនឹងកន្លែងកើតហេតុតែម្តង។ចំណែកជនរងគ្រោះម្នាក់ទៀត ត្រូវបានគេបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យ ហើយខ្លួនក៏ត្រូវបានសមត្ថកិច្ចនាំទៅសាកសួរនិងធ្វើតេស្តរកសារធាតុស្រវឹងឃើញមានអត្រាជាតិអាកុល០,៦៣MgL ។ ក្រោយកើតហេតុដោយសារភាគីជនរងគ្រោះជាអ្នកជិះម៉ូតូបញ្ច្រាសផ្លូវមកបុករថយន្តរបស់ខ្លួន ទើបខាងគ្រួសារសពបានសុំឲ្យខ្លួនជួយលុយកាក់គាត់ខ្លះៗ ដើម្បីឲ្យគាត់យកទៅធ្វើបុណ្យឲ្យកូនគាត់ ទើបខ្លួនជួយគាត់ដោយការចូលបុណ្យគ្រួសារសព ចំនួន ២,០០០ ដុល្លារអាមេរិក និងជួយថ្លៃព្យាបាលរបួសជនរងគ្រោះម្នាក់ទៀតចំនួន៥០០ដុល្លារអាមេរិក ដើម្បីបញ្ចប់រឿង។

## សេចក្តីសន្និដ្ឋានស្នើសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ

ភេទប្រុស អាយុ៤១ឆ្នាំ ជនជាតិខ្មែរ និងភស្តុតាងនៅក្នុងសំណុំរឿង ឃើញថាពិតជាមានអំពើ បើកបរយានយន្តក្នុងស្ថានភាពស្រវឹង និងបើកបរបណ្តាលឲ្យស្លាប់ដល់អ្នកដទៃដោយអចេតនា ប្រព្រឹត្តនៅចំណុចផ្លូវ៣០ម៉ែត្រ ប្រសព្វផ្លូវបេតុងភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៧៧ និងមាត្រា ៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ប្រាកដមែន ដូច្នេះតំណាងអយ្យការរក្សាបទចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរដដែល ។

## សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ បាននិយាយសម្តីចុងក្រោយស្នើសុំឲ្យ តុលាការបន្ធូរបន្ថយទោស ។

បើកបញ្ច្រាសទិសរថយន្តរបស់ខ្លួន ហើយខ្លួនបឹងប្តូងចង្កូតរថយន្តគេចម៉ូតូនោះ តែគេចមិនផុតក៏ត្រូវបានម៉ូតូជនរងគ្រោះមកបុករថយន្តខ្លួនចំចំហៀងរថយន្តខាងឆ្វេងបណ្តាលឲ្យដួលម៉ូតូ ចំណែករថយន្តខ្លួនបានធ្លាក់ចៀនផ្លូវមុខ ផ្ទះប្រជាពលរដ្ឋ ហើយខ្លួនក៏បានចុះទៅមើលជនរងគ្រោះដែលជាអ្នកបើកម៉ូតូនិងអ្នករួមដំណើរ ដោយពេលនោះពួកគេរបួសធ្ងន់ ហើយខ្លួនសុំឲ្យប្រជាពលរដ្ឋនៅក្បែរនោះជួយធ្វើចលនាបេះដូងឲ្យជនរងគ្រោះផងតែប្រជាពលរដ្ឋទាំងនោះពុំបានជួយទេ ទើបបណ្តាលឲ្យជនរងគ្រោះដែលជាអ្នកបើកម៉ូតូនោះស្លាប់នៅនឹងកន្លែងកើតហេតុតែម្តង។ចំណែកជនរងគ្រោះម្នាក់ទៀត ត្រូវបានគេបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យ ។

៤- តាមមាត្រា ៧៧ ថ្មី ជនណាបើកបរយានយន្តនៅពេលដែលខ្លួនស្ថិតនៅក្នុងភាពស្រវឹង ដោយមានជាតិអាល់កុលចាប់ពី០,៤០(សូន្យក្បៀសសែសិប)មីលីក្រាមក្នុងមួយលីត្រខ្យល់ឬចាប់ពី ០,៨០ (សូន្យក្បៀសប៉ែតសិប) ក្រាម ក្នុងមួយលីត្រឈាមឡើងទៅ ត្រូវពិន័យអន្តរការណ៍តាមការកំណត់នៃអនុក្រឹត្យ។

៥- តាមមាត្រា ១០ ថ្មី ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរយានយន្តស្ថិតក្នុងភាពស្រវឹង ដែលមានអត្រាជាតិអាល់កុលចាប់ពី ០,៤០ (សូន្យក្បៀសសែសិប) មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី ០,៨០ (សូន្យក្បៀសប៉ែតសិប) ក្រាមក្នុងមួយលីត្រឈាមឡើងទៅ ដូចតទៅ៖

៨- ជនជាប់ចោទឈ្មោះ ជានីតិជន មានការយល់ដឹងចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត ហើយពុំមានសញ្ញាណណាមួយដែលនាំឲ្យមានការសង្ស័យអំពីបញ្ហាស្មារតីឡើយ គប្បីត្រូវទទួលខុសត្រូវនូវទង្វើរបស់ខ្លួនបានប្រព្រឹត្តតាមច្បាប់ជាធរមាន ។

៩- តាមសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការនាពេលសវនាការបានបញ្ជាក់ពីភស្តុតាងដាក់បន្ទុក ដែលកំណត់ពីពិរុទ្ធភាព និងរក្សាការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរដែលព្រមទាំងប្តឹងសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទឈ្មោះ លក្ខណៈត្រឹមត្រូវ តុលាការពិចារណាតាមច្បាប់ ។

១០- មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ៤១ឆ្នាំ កើតថ្ងៃទី១០ ខែមករា ឆ្នាំ១៩៨២ ជនជាតិខ្មែរ ពីបទ បើកបរយានយន្តក្នុងស្ថានភាពស្រវឹង ប្រព្រឹត្តនៅចំណុចផ្លូវ៣០ម៉ែត្រ ប្រសព្វផ្លូវបេតុង ភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៧៧ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងតាមមាត្រា ១០ថ្មី មាត្រា ១៤ថ្មី នៃអនុក្រឹត្យលេខ ៣៩ អន ក្របក ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៤ អនក្របក ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ ចរាចរណ៍ផ្លូវគោក ។

១១- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ និងឈ្មោះ បានដកពាក្យបណ្តឹងរបស់ខ្លួនឈប់ប្តឹងតាំងពីនៅសមត្ថកិច្ច កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២០ គប្បីតុលាការពិចារណាតាមច្បាប់ ។

## ហេតុដូច្នេះសម្រេច

ផ្តន្ទាទោសឈ្មោះ ភេទប្រុស អាយុ៤១ឆ្នាំ កើតថ្ងៃទី១០ ខែមករា ឆ្នាំ១៩៨២ ជនជាតិខ្មែរ ពិន័យជាប្រាក់ចំនួន ៦,០០០,០០០ (ប្រាំមួយលាន) រៀល ពីបទ បើកបរយានយន្តក្នុងស្ថានភាពស្រវឹង ប្រព្រឹត្តនៅចំណុចផ្លូវ៣០ម៉ែត្រ ប្រសព្វផ្លូវបេតុង ភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៧៧ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងតាមមាត្រា ១០ថ្មី និងមាត្រា ១៤ថ្មី នៃអនុក្រឹត្យលេខ ៣៩ អន ក្របក ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៤ អនក្របក ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ចរាចរណ៍ផ្លូវគោក ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ កំបាំងមុខជនជាប់ចោទឈ្មោះ
និងប្រកាសសាធារណៈ នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤។

ភាគីមានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃសុក្រ ៣រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ,ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤
ក្រឡាបញ្ជីសវនាការ

បានឃើញ
ចៅក្រមជំនុំជម្រះ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**
-លេខ ៥១៦ ក្រ១០"ឃ"
ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២
-សំណុំរឿងព្រហ្មទណ្ឌលេខ ៤៧៩៣
ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២
-សំណុំរឿងស៊ើបសួរលេខ ៣៥៩៦
ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០២២
-សំណុំរឿងជំនុំជម្រះលេខ ៤៥
ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៣

**គោរពនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ៩ និង ០០ នាទី ព្រឹក នៅសាលសវនាការទី២ ដោយមានសមាសភាព៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សា
-លោក អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា
-លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោក ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោកស្រី ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៧៩៣ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

ឈ្មោះ ភេទប្រុស អាយុ២៣ឆ្នាំ កើតឆ្នាំ១៩៩៩ ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរ កម្មករសំណង់ ទីកន្លែងកំណើតនៅភូមិម្លូងរៀវ ឃុំមួយរៀវ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះជួល សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (រស់) ម្ដាយឈ្មោះ (រស់) នៅលីវ ជានីតិជន ទោសពីគ្មាន ។

ដីកាបង្គាប់ឃុំខ្លួនលេខ (ថ) ដ.ឃ.ផ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។ មណ្ឌលអប់រំកែប្រែទី១ (ម១)

ជាប់ចោទពីបទ៖ លួចមានស្ថានទម្ងន់ទោស (ឆក់ខ្សែក) ប្រព្រឹត្តនៅចំណុចមុខធនាគារ MAY BANK អគារលេខ៤៣ ផ្លូវព្រះនរោត្តម ភូមិ០៩ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

មានលោក អគ្គលេខ ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ ។

**អង្គហេតុនៃការចោទប្រកាន់មានដូចតទៅ ៖**

កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ នៅចំណុចមុខធនាគារ MAY BANK អាគារលេខ៤៣ ផ្លូវព្រះនរោត្តម ភូមិ០៩ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ មានករណី៖ លួចមានស្ថានទម្ងន់ទោស (ឆក់ខ្សែរក) មួយបានកើតឡើងដែលបង្កឡើងដោយជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ២៣ឆ្នាំ (ឃុំខ្លួន) និង ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ២៤ឆ្នាំ (គេចខ្លួន) ។ កាលកំឡុងថ្ងៃកើតហេតុជនសង្ស័យឈ្មោះ ភេទប្រុស អាយុ២៣ឆ្នាំ បានដើរចេញទៅម្តុំច្បារអំពៅដើម្បីទិញទឹកក្រឡុក ពេលទៅដល់ក៏បានជួបជាមួយជនសង្ស័យឈ្មោះ ភេទប្រុស ដោយជិះម៉ូតូម៉ាក ហុងដា សេ១២៥ ពណ៌ខ្មៅ មិនចាំផ្លាកលេខបន្ទាប់ពីនិយាយគ្នាបានមួយសន្ទុះក៏បានបបួលគ្នាជិះម៉ូតូឆក់ទ្រព្យសម្បត្តិរបស់ ប្រជាពលរដ្ឋតាមដងផ្លូវដោយជនសង្ស័យឈ្មោះ ជាអ្នកបើកម៉ូតូហើយជនសង្ស័យឈ្មោះ ជាអ្នកអង្គុយពីក្រោយ លុះជិះមកដល់ចំណុចកើតហេតុខាងលើជនសង្ស័យឈ្មោះ បានឱ្យជនសង្ស័យឈ្មោះ ចុះពីលើម៉ូតូទៅឆក់ខ្សែរកពីជនរងគ្រោះ

ដែលកំពុងតែឈរនោះ ហើយជនសង្ស័យឈ្មោះ បានបើកទៅជិត ជនរងគ្រោះនោះបម្រុងនឹងឆក់ខ្សែកទាំងហើយ តែជនរងគ្រោះក៏បានដឹងខ្លួនទាន់ហើយក៏បានស្រែកឡើង ភ្លាមនោះជនសង្ស័យឈ្មោះ ក៏បានជិះម៉ូតូគេចខ្លួនបាត់ស្រប ពេលនោះក៏មានកម្លាំងសមត្ថកិច្ចល្បាតរបស់ប៉ុស្តិ៍នគរបាល រដ្ឋបាលផ្សារថ្មីឃើញ និងបានស្ទាក់ឃាត់ខ្លួនជនសង្ស័យនាំទៅកាន់ប៉ុស្តិ៍នគរបាលរដ្ឋបាលផ្សារថ្មី៣ ដើម្បីសាកសួរតែម្តងនៅចំពោះមុខសមត្ថកិច្ចជនសង្ស័យបានឆ្លើយសារភាពថា៖ នៅថ្ងៃកើតហេតុរូបខ្លួននិងបក្ខពួកឈ្មោះ ពិតជាបានធ្វើសកម្មភាពឆក់ខ្សែកជនរងគ្រោះប្រាកដមែន ។

- បានឃើញរបាយការណ៍លេខ ០៩៣/២២ រ.ប.ក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលខណ្ឌដូនពេញ នៃស្នងការនគរបាលរាជធានីភ្នំពេញ ។
- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣៦០៦ អយព ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៤៥៧០ អ.យ.ព ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២២ របស់អយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញដីកាបើកលែងចោទប្រកាន់លេខ ៦២៧៥ ដ.ដ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៦២៧៦ ញ.សដ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញដីការក្សាទុកជនត្រូវចោទឱ្យនៅក្នុងឃុំបណ្តោះអាសន្នលេខ ១០១៨៦ ដ.ឃ.ដ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ បានឆ្លើយនាពេលសវនាការថា ៖

កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង១៨ និង០០ នាទី ខ្ញុំបានចេញពីផ្ទះជួលមកផ្សារឡូរអំពៅ ដើម្បីទិញទឹកក្រឡុក ពេលមកដល់ខ្ញុំក៏បានជួបជាមួយឈ្មោះ ដែលជាអ្នកស្គាល់គ្នា ភេទប្រុស អាយុប្រហែល២៥ឆ្នាំ ក៏បាននិយាយគ្នាលេង ។ បន្តិចក្រោយមកឈ្មោះ បានហៅខ្ញុំឱ្យ ទៅលេងផ្ទះគាត់ ដោយគាត់ជិះតាមផ្លូវលេងជាមួយគ្នា រហូតដល់ម៉ោង ២២ និង ២៥នាទី បានមកដល់ចំណុចមុខធនាគារ MAY BANK ផ្លូវនរោត្តម ស្រាប់តែឈ្មោះ បានប្រាប់ខ្ញុំថា "ហែងមានឃើញកាបូបជនជាតិបរទេសនោះមាន លេចចេញខ្សែកមកក្រៅទេហែងចុះទៅយកខ្សែកនោះមកហើយចាំឡើងជិះម៉ូតូវិញមក"។ពេលនោះខ្ញុំក៏បានចុះពីលើម៉ូតូទៅជិត និងជនជាតិបរទេសនោះបម្រុងនឹងធ្វើសកម្មភាព ដូចដែលឈ្មោះ បានប្រាប់រួចហើយ ស្រាប់តែជនជាតិបរទេសនោះ បានឃើញខ្ញុំបម្រុងនិងធ្វើសកម្មភាព ឆក់យកខ្សែក នោះជនបរទេសនោះក៏បាន ស្រែកឱ្យជួយ ហើយពេលនោះឈ្មោះ បានជិះម៉ូតូចេញទៅបាត់រួចខ្ញុំបានរត់ចូលតាម បណ្តោយផ្លូវលេខ ១៥៤ ក៏ត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួនបានតែម្តង ។

ខ្ញុំស្គាល់ឈ្មោះ តាមរយៈធ្វើការសំណង់ជាមួយគ្នា អាសយដ្ឋានរបស់វា ខ្ញុំដឹងថារស់នៅម្តុំផ្សារសុរិយាម៉ល ។ ខ្ញុំពុំធ្លាប់ធ្វើសកម្មភាពឆក់យកទ្រព្យសម្បត្តិរបស់គេទេ ទើបតែលើកទីមួយនេះហើយ ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនបានតែម្តង ។ ឥឡូវជើងរបស់ខ្ញុំត្រូវបានឡានកិន ដើរបានតែជើងមួយចំហៀងទេ ខ្ញុំចេះប្រើប្រាស់គ្រឿងញៀនរយៈពេល២ឆ្នាំមកហើយប៉ុន្តែពុំធ្លាប់ជាប់ ពន្ធនាគារ ឡើយ ។ ខ្ញុំសូមសំណូមពរលោកចៅក្រមមេត្តាជួយយុត្តិធម៌ដល់រូបខ្ញុំផង ។

ចម្លើយដែលខ្ញុំបានឆ្លើយនៅសមត្ថកិច្ច និងនៅដំណាក់កាលស៊ើបសួរ ជាចម្លើយត្រឹមត្រូវរបស់ខ្ញុំពិតប្រាកដរបស់ខ្ញុំមែន ។

## សេចក្តីសន្និដ្ឋានស្នើសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ និងភស្តុតាងនៅក្នុងសំណុំរឿង ឃើញថាពិតជាមានអំពើ លួចមានស្ថានទម្ងន់ទោស (ឆក់ខ្សែក) ប្រព្រឹត្តនៅចំណុចមុខធនាគារ MAY BANK អគារលេខ៤៣ ផ្លូវព្រះនរោត្តម ភូមិ០៩ សង្កាត់ផ្សារថ្មី៣

ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ប្រាកដមែន ។ តំណាងអយ្យការរក្សាបទចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ៖ ឆ្លងតាមសវនាការសាកសួរដេញដោលនេះ កូនក្តីខ្លួនបានសារភាព នឹងកំហុសពីការដែលខ្លួនបានប្រព្រឹត្តក្នុងអំពើនេះតាំងពីដំណាក់កាលដំបូងរហូតពេលជំនុំជម្រះ រីឯក៏ជាការប្រព្រឹត្តលើកទីមួយ មានចំនេះដឹងទាប រស់ក្នុងជីវភាពលំបាក ដូច្នេះសុំតុលាការមេត្តាបន្ធូរបន្ថយទោសដោយអនុគ្រោះផងចុះ ។

## សម្តីចុងក្រោយរបស់ជនជាប់ចោទ

១. ជនជាប់ចោទឈ្មោះ បាននិយាយសម្តីចុងក្រោយស្នើសុំឱ្យ តុលាការបន្ធូរបន្ថយទោស ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយបង្អស់របស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារភស្តុតាងនានា

-ក្រោយពីបានពិនិត្យនិងពិចារណាតាមច្បាប់រួចហើយ

## សំអាងហេតុ

១- តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៦២៧៦ ញ.អឪ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានបញ្ជូនជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិខ្មែរ ពីបទ៖ លួចមានស្ថានទម្ងន់ទោស (ឆក់ខ្សែក) ប្រព្រឹត្តនៅចំណុចមុខធនាគារ MAY BANK អគារលេខ៤៣ ផ្លូវព្រះនរោត្តម ភូមិ០៩ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ មកជំនុំជម្រះ ។

២- កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ ពិតជាមានអំពើ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តដោយជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ២៣ កើតឆ្នាំ១៩៩៩ ជនជាតិខ្មែរ និងបក្ខពួកម្នាក់ឈ្មោះ ភេទប្រុស នៅចំណុចមុខធនាគារ MAY BANK អគារលេខ៤៣ ផ្លូវព្រះនរោត្តម ភូមិ០៩ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ប្រាកដមែន ។

៣- តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ បានឆ្លើយថា កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ ខ្លួន និងឈ្មោះ បាននាំគ្នាចេញ ធ្វើសកម្មភាពលួចយកទ្រព្យសម្បត្តិតាមដងផ្លូវ ត្រង់ចំណុចមុខធនាគារ MAY BANK ខ្លួនបានឃើញ ការបួបជនបរទេសមានពេលចេញខ្សែក ហើយខ្លួន និងឈ្មោះ ឃើញបែបនេះ ក៏ធ្វើសកម្មភាពឆក់ខ្សែក ប៉ុន្តែពេលនឹងធ្វើសកម្មភាព ស្រាប់តែជនបរទេសនោះបានស្រែកអោរឡោ ហើយក៏ខ្លួនត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួន ចំណែកឈ្មោះ បានរត់គេចខ្លួន ។

៤- ចំពោះបក្ខពួកឈ្មោះ ពុំមានសាវតាជាតិគ្រប់គ្រាន់ ត្រូវបានចៅក្រមស៊ើបសួរសម្រេចលើកលែងចោទប្រកាន់តាមដីកាលើកលែងចោទប្រកាន់លេខ ៦២៧៥ ដ.ដ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២២ ។

៥- អំពើរបស់ជនជាប់ចោទឈ្មោះ គឺពិតមានចេតនាទុច្ចរិតឆក់យកខ្សែក ដែលជនរងគ្រោះដាក់ក្នុងកាបូប គឺជាអំពើ លួចមានស្ថានទម្ងន់ទោស ដែលអំពើនេះធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ ជនរងគ្រោះ

៦- ជនជាប់ចោទឈ្មោះ ជាទីតិជន មានការយល់ដឹងចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត ហើយពុំមានសញ្ញាណណាមួយដែលនាំឲ្យមានការសង្ស័យអំពីបញ្ហាស្មារតីឡើយ គប្បីបន្ថយការទទួលខុសត្រូវទង្វើរបស់ខ្លួនបានប្រព្រឹត្តតាមច្បាប់ជាធរមាន ។

៧- តាមសេចក្តីសន្និដ្ឋានបួងសួងរបស់តំណាងអយ្យការរក្សាការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរ នោះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីតុលាការពិចារណារ និងសម្រេចបាន ។

៨- មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ ឈ្មោះ ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ ពីបទ លួចមានស្ថានទម្ងន់ទោស (ឆក់ខ្សែក) ប្រព្រឹត្តនៅចំណុចមុខធនាគារ MAY BANK អគារលេខ៤៣ ផ្លូវព្រះនរោត្តម ភូមិ០៩ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ បញ្ញត្តិឲ្យផ្តន្ទាទោសដាក់ពន្ធនាគារពី ០៣ (បី) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

៩- តាមរបាយការណ៍សំយោគលេខ ០៩៣/២២ រ.ប.ក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ របស់អធិការដ្ឋានខណ្ឌដូនពេញ នៃស្នងការនគរបាលរាជធានីភ្នំពេញ បានបញ្ជាក់ថាជនរងគ្រោះជាជនបរទេស ភេទស្រី ពេលជនសង្ស័យធ្វើសកម្មភាពឆក់ខ្សែកយកពុំបានឡើយ ហើយជនរងគ្រោះក៏បានដើរចេញពីកន្លែងកើតហេតុ មិនបានដាក់ពាក្យបណ្តឹងទេ គប្បីតុលាការពិចារណាតាមច្បាប់ ។

**ហេតុដូច្នេះសម្រេច**

- ផ្តន្ទាទោស ឈ្មោះ ភេទប្រុស អាយុ២៣ឆ្នាំ កើតឆ្នាំ១៩៩៩ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៣ (បី) ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោស (ឆក់ខ្សែក) ប្រព្រឹត្តនៅចំណុចមុខធនាគារ MAY BANK អគារលេខ៤៣ ផ្លូវព្រះនរោត្តម ភូមិ០៩ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទ ឈ្មោះ និងប្រកាសសាធារណៈ នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣ ។

បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃសុក្រ ៣កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤

ក្រឡាបញ្ជី

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

-លេខ ៥៨៥ ក្រ១០ "ឃ"

ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣

-សំណុំរឿងព្រហ្មទណ្ឌលេខ ៥៧៣២

ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២

-សំណុំរឿងស៊ើបសួរលេខ ៥២៨៧

ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២២

-សំណុំរឿងជំនុំជម្រះលេខ ៩៨១

ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣

## នាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង ០៩ និង០០នាទី នៅសាលសវនាការទី២ ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

-លោក ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញជាប្រធានក្រុមប្រឹក្សា

-លោក អនុប្រធាននៃសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

-លោក ចៅក្រមសាលានៃដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

-លោក ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោកស្រី ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៥៧៣២ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

១. ឈ្មោះ ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ កំរិតវប្បធម៌ថ្នាក់ទី៥ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅភូមិមានជ័យ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅមិនពិតប្រាកដ ឪពុកឈ្មោះ (រស់) ម្តាយឈ្មោះ (រស់) នៅលីវ ជាតិជន ទោសពីមុន គ្មាន ។

ដីកាបង្គាប់ឃុំខ្លួនលេខ (ម) ៨.ឃ.៨ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។ មណ្ឌលអប់រំកែប្រែទី១ (ម១)

២. ឈ្មោះ ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបររើសអេតចាយ

## អង្គហេតុនៃការចោទប្រកាន់មានដូចតទៅ ៖

កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោង០៤ និង ០០នាទី នៅចំណុចតាមស្ពានស្ទឹងមានជ័យ ផ្លូវ២៧១ ភូមិមានជ័យ សង្កាត់ស្ទឹងមានជ័យទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ មានករណី លួចមានស្ថានទម្ងន់ទោស (ឆក់ខ្សែក) មួយបានកើតឡើង ប្រព្រឹត្តដោយជនត្រូវចោទចំនួន០២នាក់មានឈ្មោះ ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ និងជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ ដោយមុនពេលកើតហេតុ ជនរងគ្រោះឈ្មោះ សេង ហួត បានជិះម៉ូតូមួយគ្រឿងម៉ាកស្កុបពីពណ៌សចេញពីមុខពេទ្យស្ត្រីតាមបណ្តោយផ្លូវ២៧១ ដើម្បីទៅលេងផ្ទះមិត្តភក្តិ លុះពេលជិះទៅដល់ចំណុចកើតហេតុខាងលើក៏បានជួបនឹងជនត្រូវចោទឈ្មោះ និងឈ្មោះ ដោយពេលនោះជនរងគ្រោះមិនស្គាល់ផ្លូវ ក៏បានឈប់ម៉ូតូដើម្បីសួររកផ្លូវពីជនត្រូវចោទទាំង០២នាក់ ស្រាប់តែជនត្រូវចោទឈ្មោះ បានធ្វើសកម្មភាពឆក់យកខ្សែកពីជនរងគ្រោះតែមិនបានសម្រេច ទើបជនត្រូវចោទឈ្មោះ ក៏បានធ្វើសកម្មភាពឆក់យកខ្សែកបន្តម្តងទៀតពីជនរងគ្រោះរហូតបានសម្រេច ហើយជនត្រូវចោទទាំង០២នាក់បាននាំគ្នាគេចខ្លួនបាត់ រីឯជនរងគ្រោះបានមកដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលស្ទឹងមានជ័យ១ ។ រហូតមកដល់ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោង០៧ និង០០នាទីព្រឹក កម្លាំងសមត្ថកិច្ចបានស្រាវជ្រាវឃាត់បានទាំង០២នាក់ខាងលើ រួមទាំងវត្ថុតាងនៅចំណុចផ្ទះជួលសង្កាត់បឹងសាឡាង ខណ្ឌទួលគោក នាំមកកាន់ប៉ុស្តិ៍នគរបាល ស្ទឹងមានជ័យ១ ដើម្បីធ្វើការសាកសួរ និងបានធ្វើតេស្តស្វែងរកសារធាតុញៀន ជាលទ្ធផលវិជ្ជមាន ។ រួចសមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធី។

- បានឃើញរបាយការណ៍សំយោគលេខ ១៤៥/២២ រ.ប.ក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលខណ្ឌមានជ័យ នៃស្នងការនគរបាលរាជធានីភ្នំពេញ ។
- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៤៣៣៨ អយង ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៥៥១ អ.យ.ង ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

...ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ (រស់) ម្ដាយឈ្មោះ (រស់) នៅលីវ ប្រាកដមែន ។

នៅថ្ងៃកើតហេតុ ម៉ោងប្រហែល៤ទៀបភ្លឺ ខ្លួន និងឈ្មោះ បានទៅជិះម៉ូតូទិកផឹកនៅក្បែរវត្តស្ទឹងមានជ័យ លុះដើរដល់ស្ពានអាកាសស្ទឹងមានជ័យ ស្រាប់តែឃើញមនុស្សម្នាក់ជិះម៉ូតូស្កុបពីមកសួរខ្លួនថាផ្លូវណាទៅសាលាសាមគ្គី? ពេលនោះខ្លួនឃើញបុរសម្នាក់នោះពាក់ខ្សែក ហើយយោយកខ្សែនោះមានសភាពស្ងាត់ផង ខ្លួននិងឈ្មោះ ក៏បានធ្វើសកម្មភាពឆក់ខ្សែកបានសម្រេច ។ លុះមកដល់ម៉ោង៧ព្រឹក ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្ដង ។

មុនពេលសមត្ថកិច្ចឃាត់ខ្លួន ធ្លាប់ប្រើប្រាស់គ្រឿងញៀនរហូតមករយៈពេល០៥(ប្រាំ)ខែមកហើយ។

ចម្លើយដែលខ្លួនបានឆ្លើយនៅសមត្ថកិច្ច និងនៅអយ្យការ ព្រមទាំងនៅដំណាក់កាលស៊ើបសួរ ជាចម្លើយដែលត្រឹមត្រូវពិតប្រាកដរបស់ខ្លួនមែន។

- អំណានចម្លើយរបស់ដើមបណ្ដឹង និងជាជនរងគ្រោះឈ្មោះ បានឆ្លើយថា៖ កាលពីវេលាម៉ោងប្រហែល ៥:០០នាទី នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ ខ្លួនបានជិះម៉ូតូម៉ាកស្កុបពី សេរីឆ្នាំ២០២១ ចេញពីមុំមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត ទៅគេងនៅផ្ទះមិត្តភក្ដិនៅមុំសាលាជាស៊ីមសាមគ្គី ពេលជិះម៉ូតូទៅដល់ស្ពានអាកាសស្ទឹងមានជ័យ ខ្លួនច្រឡំបត់ឆ្វេងចុះមកក្រោម ហើយក៏បត់ស្ដាំឡើងបញ្ច្រាស ស្រាប់តែឃើញមនុស្សប្រុស ០២នាក់ ក៏ឈប់សួរ ហើយជននោះក៏ឆក់ខ្សែកខ្លួន បានសម្រេចតែម្ដង ។

## សេចក្ដីសន្និដ្ឋានបឋមសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា: ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ

[illegible]

## សំអាងហេតុ

១- តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៨២០ ក.ជជ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានបញ្ជូនជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ និងជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ ពីបទ លួចមានស្ថានទម្ងន់ទោស (ឆក់ខ្សែក) ប្រព្រឹត្តនៅចំណុចជល់ស្ពានស្ទឹងមានជ័យ ផ្លូវ២៧១ ភូមិមានជ័យ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ មកជំនុំជម្រះ ។

៩- មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ

- ឈ្មោះ ភេទប្រុស អាយុ១៨ឆ្នាំ កើតឆ្នាំ២០០៤ ជនជាតិខ្មែរ

-ឈ្មោះ ៖ ភេទប្រុស អាយុ៣៨ឆ្នាំ កើតឆ្នាំ១៩៨៤ ជនជាតិខ្មែរ

ពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចតលស្ពានស្ទឹងមានជ័យ ផ្លូវ២៧១ ភូមិមានជ័យ សង្កាត់ស្ទឹងមានជ័យទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

១០- ដើមបណ្តឹងរដ្ឋប្បវេណី ដែលជាជនរងគ្រោះឈ្មោះ បានទទួលខ្សែករបស់ខ្លួនវិញហើយក្នុងរឿងហេតុនេះនៅសមត្ថកិច្ច ហើយក៏គ្រាន់តែដាក់ពាក្យបណ្តឹង និងឆ្លើយសុំឲ្យចាត់ការតាមច្បាប់ប៉ុណ្ណោះ មិនបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅដំណាក់កាលចៅក្រមស៊ើបសួរ ក៏ដូចជានៅដំណាក់កាលជំនុំជម្រះឡើយ គប្បីតុលាការពិចារណាតាមច្បាប់។

## ហេតុដូច្នេះសម្រេច

១- ផ្តន្ទាទោស៖

ក. ឈ្មោះ ភេទប្រុស អាយុ១៨ឆ្នាំ កើតឆ្នាំ២០០៤ ជនជាតិខ្មែរ

ខ. ឈ្មោះ ភេទប្រុស អាយុ៣៨ឆ្នាំ កើតឆ្នាំ១៩៨៤ ជនជាតិខ្មែរ

ដាក់ពន្ធនាគារម្នាក់ៗកំណត់រយៈពេល ០៣ (បី) ឆ្នាំ ។

ពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចតលស្ពានស្ទឹងមានជ័យ ផ្លូវ២៧១ ភូមិមានជ័យ សង្កាត់ស្ទឹងមានជ័យទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ និងជនជាប់ចោទឈ្មោះ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ និងប្រកាសសាធារណៈ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ។

ភាគីមានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃចន្ទ ៥រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៤

ក្រឡាបញ្ជី

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

-លេខ: ៧៨៤ "ឃ"

-ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២៣

-សំណុំរឿងព្រហ្មទណ្ឌលេខ ២៤០៣

ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២

-សំណុំរឿងស៊ើបសួរលេខ ១៨៤៧

ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២២

-សំណុំរឿងជំនុំជម្រះលេខ ៣៩៥០

ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក នៅសាលសវនាការទី៨ ដោយមានសមាសភាព៖

### ចៅក្រមជំនុំជម្រះ

-លោក ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

### តំណាងអយ្យការ

-លោក ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោកស្រី ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២៤០៣ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

១. ឈ្មោះ ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ (កើតឆ្នាំ១៩៨៧) កាន់សាសនាព្រះពុទ្ធ មុខរបរកម្មករសំណង់ កម្រិតវប្បធម៌ថ្នាក់៧ ទីកន្លែងកំណើតនៅភូមិភូមិថ្មី ឃុំសំរោង ស្រុកព្រៃឈរ ខេត្តកំពង់ចាម ទីលំនៅមុនពេលឃាត់ខ្លួននៅសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ 1 (រស់) ម្ដាយឈ្មោះ (រស់) នៅលីវ ជាទីតិជន ទោសពីមុនគ្មាន។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ (៩១) ដ.ឃ.ដ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញឃុំខ្លួននៅពន្ធនាគាររាជធានីភ្នំពេញ (PJ) ។

២. ឈ្មោះ ភេទប្រុស អាយុ៣៦ឆ្នាំ (កើតឆ្នាំ១៩៨៦) ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរសន្តិសុខ កម្រិតវប្បធម៌ថ្នាក់៩ ទីកន្លែងកំណើតនៅខេត្តកោះកុង ទីលំនៅមុនពេលឃាត់ខ្លួននៅភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះមិនស្គាល់ឈ្មោះ (ស្លាប់) ម្ដាយឈ្មោះ (រស់) នៅលីវ ជាទីតិជន ទោសពីមុនគ្មាន។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ (៩១) ដ.ឃ.ដ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញឃុំខ្លួននៅពន្ធនាគាររាជធានីភ្នំពេញ (PJ) ។

៣. ឈ្មោះ ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ (កើតឆ្នាំ១៩៩៦) កាន់សាសនាព្រះពុទ្ធ មុខរបរកម្មករសំណង់ កម្រិតវប្បធម៌ថ្នាក់៤ ទីកន្លែងកំណើតនៅខេត្តតាកែវ ទីលំនៅមុនពេលឃាត់ខ្លួននៅការដ្ឋានសំណង់ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ (រស់) ម្ដាយឈ្មោះ (រស់) នៅលីវ ជាទីតិជន ទោសពីមុនគ្មាន។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ (៩១) ដ.ឃ.ដ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញឃុំខ្លួននៅពន្ធនាគាររាជធានីភ្នំពេញ (PJ) ។

ជាប់ចោទពីបទ៖ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវបេតុងបឹងឈូក ភូមិបុរីកម្មករ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

### អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ១៨:០០នាទី កម្លាំងជំនាញផ្នែកគ្រឿងញៀននៃអធិការដ្ឋាននគរបាលខណ្ឌសែនសុខ សហការជាមួយប៉ុស្តិ៍នគរបាលរដ្ឋបាលទឹកថ្លា ល្បាតក្នុងមូលដ្ឋាន លុះមកដល់ចំណុចបឹងឈូក ផ្លូវ

បេតុង ស្ថិតនៅភូមិបុរីកម្មករ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ក៏ប្រទះឃើញជនសង្ស័យចំនួន០៣នាក់ មានឈ្មោះ ភេទប្រុស អាយុ ៣៩ឆ្នាំ, ឈ្មោះ ភេទប្រុស អាយុ ៣៦ឆ្នាំ និងឈ្មោះ ភេទប្រុស អាយុ ២៦ឆ្នាំ កំពុងធ្វើសកម្មភាពគួរឱ្យសង្ស័យ សមត្ថកិច្ចបានសុំឆែកឆេរត្រួតពិនិត្យ រកឃើញវត្ថុតាងជាគ្រឿងញៀន ក្រាមពណ៌ស ចំនួន ០៣កញ្ចប់ថង់តូច រក្សាទុកជាប់ខ្លួនម្នាក់មួយកញ្ចប់ថង់តូច (ដកហូតពីឈ្មោះ ០១កញ្ចប់ថង់ ទម្ងន់ស្មើនឹង ០,១៨ក្រាម, ដកហូតពីឈ្មោះ ០១កញ្ចប់ថង់ទម្ងន់ស្មើ ០,៧៦ ក្រាម និងដកហូតពីឈ្មោះ ទម្ងន់ស្មើនឹង ០,១៧ក្រាម) ទើបសមត្ថកិច្ចនាំយកទៅសាកសួរនៅអធិការដ្ឋាននគរបាលខណ្ឌសែនសុខ ។ បន្ទាប់ពីសាកសួរជនសង្ស័យទាំងបីនាក់ បានឆ្លើយសារភាពថាពួកខ្លួនធ្លាប់ជក់ប្រើប្រាស់គ្រឿងញៀន ប៉ុន្តែមិនធ្លាប់លក់ចែកចាយគ្រឿងញៀនទេ ហើយក៏មិនធ្លាប់ជាប់ពន្ធនាគារដែរ ។ នៅថ្ងៃដែលសមត្ថកិច្ចចាប់ឃាត់ខ្លួនពួកខ្លួនបានទៅទិញគ្រឿងញៀនពីជនមិនស្គាល់ឈ្មោះ នៅម្តុំផ្លូវបេតុងបឹងឈូក គ្រាប់តែពេលទិញបានហើយក៏ចេញមកវិញក៏ត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្តង ។

-បានឃើញ របាយការណ៍សំយោគលេខ ០៣៩/២០២២ រ.ប.ក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៨៤០ អ.យ.ណ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៣២៥២ អ.យ.ណ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤៦១២ "ថ" ស.ស ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចរក្សាជនត្រូវចោទឱ្យនៅក្នុងឃុំបណ្តោះអាសន្នលេខ ៧៥២៩ "ឃ១" ស.ឃ.ស ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចរក្សាជនត្រូវចោទឱ្យនៅក្នុងឃុំបណ្តោះអាសន្នលេខ ៧៥៣០ "ឃ១" ស.ឃ.ស ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

- បានឃើញ ដីកាសម្រេចរក្សាជនត្រូវចោទឱ្យនៅក្នុងឃុំបណ្តោះអាសន្នលេខ ៧៥៣១ "ឃ១" ស.ឃ.ស ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

**នាពេលសវនាការ**

- ជនត្រូវចោទឈ្មោះ បានឆ្លើយនាពេលសវនាការថា៖ កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ១៨ និង ០០ នាទី ខ្លួនបានជិះម៉ូតូចេញ ពីបន្ទប់ជួលរបស់ខ្លួន ក្នុងគោលបំណងទៅទិញគ្រឿងញៀន នៅម្តុំបឹងឈូក ដែលមានមនុស្សស្រីម្នាក់មិនស្គាល់ ឈ្មោះបានហៅខ្លួនឱ្យទិញថ្នាំញៀន ហើយខ្លួនក៏បានប្រាប់ថាទិញចំនួន ២ ម៉ឺនរៀលទិញរួចហើយមនុស្ស ស្រីនោះក៏បានហុចថ្នាំញៀននោះ ឱ្យខ្លួនចំនួន ០១ កញ្ចប់ថង់តូចមកឱ្យខ្លួន រួចខ្លួនក៏ត្រឡប់មកវិញ ក៏គ្រាប់តែ មានកម្លាំងសមត្ថកិច្ចបានធ្វើការចុះល្បាត និងធ្វើការឆែកឆេរខ្លួន រកឃើញថ្នាំញៀននៅនឹងខ្លួន និងនាំខ្លួនមកសាកសួរនៅប៉ុស្តិ៍តែម្តង ហើយខ្លួនចេះប្រើប្រាស់គ្រឿងញៀនតាំងពីឆ្នាំ ២០២០ រហូតមកដល់បច្ចុប្បន្ន

- ជនជាប់ចោទឈ្មោះ បានឆ្លើយនាពេលសវនាការថា៖ កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ ខ្លួនបានជិះម៉ូតូឌុបចេញពីកន្លែងធ្វើការ ពីម្តុំសំណង់១២ ក្នុងគោលបំណងទៅម្តុំពេទ្យលោកសង្ឃបឹងឈូក ដើម្បីទៅរកទិញថ្នាំញៀននៅទីនោះ ។ ពេលទៅដល់ទីតាំងខាងលើ ក៏មានមនុស្សប្រុសម្នាក់មិនស្គាល់ឈ្មោះបានសួរខ្មាំនថាយកថ្នាំញៀនអត់ ហើយខ្លួនថាទិញ ហើយមនុស្សនោះក៏បានហុចថ្នាំញៀន ០១ កញ្ចប់តូចមកឱ្យខ្លួនក្នុងតម្លៃ ៤ ម៉ឺនរៀល រួចខ្លួនក៏ត្រឡប់មកវិញក៏គ្រាប់តែមានកម្លាំងសមត្ថកិច្ចបានធ្វើការចុះល្បាត និងធ្វើការឆែកឆេរខ្លួនរកឃើញថ្នាំញៀននៅនឹងខ្លួន និងនាំខ្លួនមកសាកសួរនៅប៉ុស្តិ៍ ហើយខ្លួនចេះប្រើប្រាស់គ្រឿងញៀនតាំងពីឆ្នាំ ២០១៩ រហូតមកដល់បច្ចុប្បន្ន ។

- ជនជាប់ចោទឈ្មោះ បានឆ្លើយនាពេលសវនាការថា៖ កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ ខ្លួនបានជិះម៉ូតូឌុបចេញពីកន្លែងធ្វើការនៅការដ្ឋាន សំណង់ក្នុងគោលបំណងទៅម្តុំពេទ្យលោកសង្ឃបឹងឈូកដើម្បីទៅរកទិញថ្នាំញៀននៅទី

នោះ ។ ពេលទៅដល់ទីតាំងខាងលើក៏មានមនុស្សស្រីម្នាក់មិនស្គាល់ឈ្មោះបានសួរខ្លួនថាយកថ្នាំញៀនអត់ហើយខ្លួនថាចិញ ហើយបុរសនោះក៏បានហុចថ្នាំញៀន ០១ កញ្ចប់តូចមកឱ្យខ្លួនក្នុងតម្លៃ ១ ម៉ឺនរៀល រួចខ្លួនក៏ត្រឡប់មកវិញ ក៏ស្រាប់តែមានកម្លាំងសមត្ថកិច្ចបានធ្វើការចុះល្បាត និងធ្វើការឆែកឆេរខ្លួនរកឃើញថ្នាំញៀននៅនឹងខ្លួន និងនាំខ្លួនមកសាកសួរនៅប៉ុស្តិ៍ ហើយខ្លួនចេះប្រើប្រាស់គ្រឿងញៀនតាំងពីឆ្នាំ ២០២១ រហូតមកដល់បច្ចុប្បន្ន ។

-តាមអំណានសេចក្តីបញ្ជាក់ពីលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៣៧៤៦៤/២២ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី ០៩ ខែសីហា ឆ្នាំ២០២២ របស់អាជ្ញាធរប្រយុទ្ធប្រឆាំងគ្រឿងញៀន លើឈ្មោះ ឃើញថា: វិជ្ជមាន, វត្តមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន ដែលគិតជាភាគរយ ៧៩,២៦% នៃទម្ងន់សរុប ស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

-តាមអំណានសេចក្តីបញ្ជាក់ពីលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៣៧៤៦៥/២២ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី ០៩ ខែសីហា ឆ្នាំ២០២២ របស់អាជ្ញាធរប្រយុទ្ធប្រឆាំងគ្រឿងញៀន លើឈ្មោះ ឃើញថា: វិជ្ជមាន, វត្តមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន ដែលគិតជាភាគរយ ៧៩,២៦% នៃទម្ងន់សរុប ស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

-តាមអំណានសេចក្តីបញ្ជាក់ពីលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៣៧៤៦៥/២២ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី ០៩ ខែសីហា ឆ្នាំ២០២២ របស់អាជ្ញាធរប្រយុទ្ធប្រឆាំងគ្រឿងញៀន លើឈ្មោះ ឃើញថា: វិជ្ជមាន, វត្តមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន ដែលគិតជាភាគរយ ៧៩,២៦% នៃទម្ងន់សរុប ស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

- តាមកំណត់ហេតុទទួលវត្ថុចាប់យក (០១) លេខ ៩៤៣ វវត ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២២ របស់ក្រឡាបញ្ជីទទួលបន្ទុកឃ្លាំង ដែលមានវត្ថុចាប់យក៖

ក. ស្រោមសំបុត្រពណ៌ស ដែលមានសរសេរថា ក្រាមពណ៌សថ្លាចេញពណ៌លឿងទុំ សង្ស័យមានតម្រុយជាគ្រឿងញៀនមេតំហ្វេតាមីន ទម្ងន់ ០,១៨ (សូន្យក្បៀសដប់ប្រាំបី) ក្រាម និងសំបកថង់ប្លាស្ទិចចំនួន០១ ដោយមានការចូលរួមផ្តិតមេដៃឈ្មោះ និងមានការចូលរួមចុះហត្ថលេខាពីមន្រ្តីនគរបាលយុត្តិធម៌ ។

ខ. ស្រោមសំបុត្រពណ៌ស ដែលមានសរសេរថា ក្រាមពណ៌សថ្លាចេញពណ៌លឿងទុំ សង្ស័យមានតម្រុយជាគ្រឿងញៀនមេតំហ្វេតាមីន ទម្ងន់ ០,៧៦ (សូន្យក្បៀសចិតសិបប្រាំមួយ) ក្រាម និងសំបកថង់ប្លាស្ទិចចំនួន០១ ដោយមានការចូលរួមផ្តិតមេដៃឈ្មោះ និងមានការចូលរួមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ ។

គ. ស្រោមសំបុត្រពណ៌ស ដែលមានសរសេរថា ក្រាមពណ៌សថ្លាចេញពណ៌លឿងទុំ សង្ស័យមានតម្រុយជាគ្រឿងញៀនមេតំហ្វេតាមីន ទម្ងន់ ០,១៧ (សូន្យក្បៀសដប់ប្រាំពីរ) ក្រាម និងសំបកថង់ប្លាស្ទិចចំនួន០១ ដោយមានការចូលរួមផ្តិតមេដៃឈ្មោះ និងមានការចូលរួមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះ ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ ពិតជាបានប្រព្រឹត្តអំពើ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្ទះបេតុងបឹងឈូក ភូមិបុរីកម្មករ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ដូច្នេះតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទ តាមច្បាប់ជាធរមាន ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ បាននិយាយសំដីចុងក្រោយបង្អស់ថា: សុំឱ្យតុលាការបន្ធូរបន្ថយទោស ។

-ជនជាប់ចោទឈ្មោះ បាននិយាយសំដីចុងក្រោយបង្អស់ថា: សុំឱ្យតុលាការបន្ធូរបន្ថយទោស ។

-ជនជាប់ចោទឈ្មោះ បាននិយាយសំដីចុងក្រោយបង្អស់ថា: សុំឱ្យតុលាការបន្ធូរបន្ថយទោស ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១- តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤៦១២ "ឃ១" ដ.ដ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ  ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ , ឈ្មោះ  ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ  ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ ពីបទរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវបេតុងបឹងឈូក ភូមិបុរីកម្មករ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មកជំនុំជម្រះ ។

២- តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ  ដែលបានឆ្លើយថា ខ្លួនពិតបានបានទិញគ្រឿងញៀន ១កញ្ចប់ពីមនុស្សមិនស្គាល់ឈ្មោះ ក្នុងតម្លៃ ២០០០០៛ (ពីរម៉ឺន) រៀល យកមករក្សាទុកក្នុងគោលបំណងដើម្បីយកមកប្រើប្រាស់ ពេលសមត្ថកិច្ចឆែកឆេររកឃើញគ្រឿងញៀននោះនៅនឹងខ្លួនប្រាដកមែន ។

៣- តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ  ដែលបានឆ្លើយថា ខ្លួនពិតបានបានទិញគ្រឿងញៀន ១កញ្ចប់ពីមនុស្សមិនស្គាល់ឈ្មោះ ក្នុងតម្លៃ ៤០០០០៛ (បួនម៉ឺន) រៀល យកមករក្សាទុកក្នុងគោលបំណងដើម្បីយកមកប្រើប្រាស់ ពេលសមត្ថកិច្ចឆែកឆេររកឃើញគ្រឿងញៀននោះនៅនឹងខ្លួនប្រាដកមែន ។

៤- តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ  ដែលបានឆ្លើយថា ខ្លួនពិតបានបានទិញគ្រឿងញៀន ១កញ្ចប់ពីមនុស្សមិនស្គាល់ឈ្មោះ ក្នុងតម្លៃ ១០០០០៛ (មួយម៉ឺន) រៀល យកមករក្សាទុកក្នុងគោលបំណងដើម្បីយកមកប្រើប្រាស់ ពេលសមត្ថកិច្ចឆែកឆេររកឃើញគ្រឿងញៀននោះនៅនឹងខ្លួនប្រាដកមែន ។

៥- តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ  , ឈ្មោះ  និងឈ្មោះ  មានការស៊ីសង្វាក់ទៅនឹងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ កំណត់ហេតុទទួលវត្ថុចាប់យកដែលបានដកហូតគ្រឿងញៀន និងភស្តុតាងនានានៅក្នុងសំណុំរឿង អាចឱ្យតុលាការយកជាមូលដ្ឋានក្នុងការពិចារណាសម្រេចតាមច្បាប់ ។

៦- តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ៖ ៣៧៤៦៤/២២ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២២ របស់អាជ្ញាធរប្រយុទ្ធប្រឆាំងគ្រឿងញៀន លើឈ្មោះ  ឃើញថា: វិជ្ជមាន, វត្ថុមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន ដែលគិតជាភាគរយ ៧៩,២៦% នៃទម្ងន់សរុប ០,១៨ ក្រាម X ៧៩,២៦% = ០,១៤ក្រាម វាស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា គប្បីតុលាការពិចារណាផ្តន្ទាទោសលើជនជាប់ចោទផ្អែកទៅលើកត្តានៃសារធាតុញៀននេះ ។

៧- តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ៖ ៣៧៤៦៥/២២ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២២ របស់អាជ្ញាធរប្រយុទ្ធប្រឆាំងគ្រឿងញៀន លើឈ្មោះ  ឃើញថា: វិជ្ជមាន, វត្ថុមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន ដែលគិតជាភាគរយ ៧៩,២៦% នៃទម្ងន់សរុប ០,៧៦ ក្រាម X ៧៩,២៦% = ០,៦០ក្រាម វាស្ថិតក្នុងតារាង

ហេរ៉ូអាុីន ដែលគិតជាភាគរយ ៧៩,២៦% នៃទម្ងន់សរុប ០,១៧ ក្រាម X ៧៩,២៦% = ០,១៣ក្រាម  វាស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា គប្បីតុលាការពិចារណាផ្តន្ទាទោសលើជនជាប់ចោទផ្អែកទៅលើកត្តានៃសារធាតុញៀននេះ ។

៩- ទង្វើរបស់ជនជាប់ចោទឈ្មោះ ឈ្មោះ និងឈ្មោះ ដែលបានទិញគ្រឿងញៀន រួចរក្សាទុកសម្រាប់ប្រើប្រាស់ គឺជាអំពើ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងអសន្តិសុខសង្គម ដែលច្បាប់តម្រូវឱ្យផ្តន្ទាទណ្ឌតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដាក់ពន្ធនាគារពី ០២ (ពីរ) ឆ្នាំ ទៅ ០៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤,០០០,០០០ (បួនលាន) រៀល ទៅ ១០,០០០,០០០ (ដប់លាន) រៀល ។

១០- ជនជាប់ចោទ ជានីតិជន មានកាយសម្បទាគ្រប់គ្រាន់ ពុំមានសញ្ញាណណាមួយដែលនាំឱ្យមានមន្ទិលសង្ស័យថា ជនទាំងនេះមានបញ្ហាវិបល្លាសស្មារតី ក្នុងពេលកំពុងប្រព្រឹត្តបទល្មើសនោះទេ ម្យ៉ាងវិញទៀតជនជាប់ចោទមានលទ្ធភាពអាចពិចារណា និងដឹងយ៉ាងច្បាស់ថាអំពើដែលខ្លួនបានប្រព្រឹត្ត គប្បីផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

១១- តាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ នាពេលសវនាការបានបញ្ជាក់ពីភស្តុតាងដាក់បន្ទុក ដែលកំណត់ពីពិរុទ្ធភាព និងរក្សាការចោទប្រកាន់ជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះ ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ តាមដីកាសន្និដ្ឋានស្ថាពរ ពីបទរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មានលក្ខណៈត្រឹមត្រូវ គប្បីតុលាការពិចារណាសម្រេចតាមច្បាប់ ។

១២- មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះ ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ ពីបទរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវបេតុងបឹងឈូក ភូមិបុរីកម្មករ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៣- វត្ថុចាប់យកនៅក្នុងកំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ ៩៤៣ រ.វ.ត ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២២ ដែលវត្ថុចាប់យករួមមាន៖

ក. ស្រោមសំបុត្រពណ៌ស ដែលមានសរសេរថា ក្រាមពណ៌សថ្លាចេញពណ៌លឿងទុំ សង្ស័យមានតម្រុយជាគ្រឿងញៀនមេតំហ្វេតាមីន ទម្ងន់ ០,១៨ (សូន្យក្បៀសដប់ប្រាំបី) ក្រាម និងសំបកថង់ប្លាស្ទិចចំនួន០១ ដោយមានការចូលរួមផ្តិតមេដៃឈ្មោះ និងមានការចូលរួមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ ។

ខ. ស្រោមសំបុត្រពណ៌ស ដែលមានសរសេរថា ក្រាមពណ៌សថ្លាចេញពណ៌លឿងទុំ សង្ស័យមានតម្រុយជាគ្រឿងញៀនមេតំហ្វេតាមីន ទម្ងន់ ០,៧៦ (សូន្យក្បៀសចិតសិបប្រាំមួយ) ក្រាម និងសំបកថង់ប្លាស្ទិចចំនួន០១ ដោយមានការចូលរួមផ្តិតមេដៃឈ្មោះ និងមានការចូលរួមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ ។

គ. ស្រោមសំបុត្រពណ៌ស ដែលមានសរសេរថា ក្រាមពណ៌សថ្លាចេញពណ៌លឿងទុំ សង្ស័យមានតម្រុយជាគ្រឿងញៀនមេតំហ្វេតាមីន ទម្ងន់ ០,១៧ (សូន្យក្បៀសដប់ប្រាំពីរ) ក្រាម និងសំបកថង់ប្លាស្ទិចចំនួន០១ ដោយមានការចូលរួម

ជីវភាព កំរិតវប្បធម៌ថ្នាក់ទាប ដែលមិនអាចថ្លឹងថ្លែងនូវផលប៉ះពាល់នៃទង្វើរបស់ខ្លួនដែលបានប្រព្រឹត្តបានឡើយ ដូច្នេះ តុលាការបាន ពិនិត្យរួចពិចារណាសម្រេចក្នុងការដាក់តែទោសពន្ធនាគារតាមច្បាប់ មិនពិន័យជាប្រាក់ទេ ។

**ហេតុដូច្នេះសម្រេច**

១- ផ្តន្ទាទោស៖

ក. ឈ្មោះ ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ (កើតឆ្នាំ១៩៨៧)

ខ. ឈ្មោះ ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ (កើតឆ្នាំ១៩៨៦)

គ. ឈ្មោះ ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ (កើតឆ្នាំ១៩៩៦)

ដាក់ពន្ធនាគារកំណត់ម្នាក់ៗរយៈពេល ០២ (ពីរ) ឆ្នាំ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវបេតុងបឹងឈូក ភូមិបុរីកម្មករ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២- រឹបអូសបំផ្លាញចោលវត្ថុចាប់យករួមមាន ៖

ក. ស្រោមសំបុត្រពណ៌ស ដែលមានសរសេរថា ក្រាមពណ៌សថ្លាចេញពណ៌លឿងទុំ សង្ស័យមានតម្រុយជាគ្រឿងញៀនមេតំហ្វេតាមីន ទម្ងន់ ០,១៨ (សូន្យក្បៀសដប់ប្រាំបី) ក្រាម និងសំបកថង់ប្លាស្ទិចចំនួន០១ ដោយមានការចូលរួមផ្តិតមេដៃឈ្មោះ និងមានការចូលរួមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ ។

ខ. ស្រោមសំបុត្រពណ៌ស ដែលមានសរសេរថា ក្រាមពណ៌សថ្លាចេញពណ៌លឿងទុំ សង្ស័យមានតម្រុយជាគ្រឿងញៀនមេតំហ្វេតាមីន ទម្ងន់ ០,៧៦ (សូន្យក្បៀសចិតសិបប្រាំមួយ) ក្រាម និងសំបកថង់ប្លាស្ទិចចំនួន០១ ដោយមានការចូលរួមផ្តិតមេដៃឈ្មោះ និងមានការចូលរួមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ ។

គ. ស្រោមសំបុត្រពណ៌ស ដែលមានសរសេរថា ក្រាមពណ៌សថ្លាចេញពណ៌លឿងទុំ សង្ស័យមានតម្រុយជាគ្រឿងញៀនមេតំហ្វេតាមីន ទម្ងន់ ០,១៧ (សូន្យក្បៀសដប់ប្រាំពីរ) ក្រាម និងសំបកថង់ប្លាស្ទិចចំនួន០១ ដោយមានការចូលរួមផ្តិតមេដៃឈ្មោះ និងមានការចូលរួមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២៣ ។

ភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

**ក្រឡាបញ្ជី** **ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា ហត្ថលេខា និងត្រា

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ
ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០១៤
ជំនុំជម្រះលេខ
ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០១៥
សាលក្រមលេខ ១ ត.ព.ព្រ.ឧ
ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០១៥

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០១៥ វេលាម៉ោង ២ និង ០០ នាទីរសៀល ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក ៖ ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៧៥ ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០១៤ ដែលមានជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ៣៩ ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើត ភូមិអំពិល ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ផ្លូវលេខ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ (រ) ម្តាយឈ្មោះ នង ណេង (រ) ប្រពន្ធឈ្មោះ (រ) មានកូន ០១ នាក់ ទោសពីមុនគ្មាន ។

**ពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៣ តាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

លោក ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ភេទប្រុស អាយុ ៣៩ ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ភូមិដីថ្មី សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

លោក ជាតំណាងដោយអាណត្តិឲ្យដើមបណ្តឹងរដ្ឋប្បវេណី

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ អ.យ.ណ ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ជ.ជ.រ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ ។

**អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៣ ជនជាប់ចោទឈ្មោះ ភេទ ប្រុស អាយុ ៣៩ឆ្នាំ បានចេញមូលប្បទានប័ត្រមួយសន្លឹកលេខ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៣ មានទឹកប្រាក់ចំនួន ១១,៦៣០ (មួយម៉ឺនមួយពាន់ប្រាំមួយរយសាមសិប) ដុល្លារអាមេរិក របស់ធនាគារភ្នំពេញ ពាណិជ្ជ ទៅឲ្យដើមបណ្តឹងឈ្មោះ ភេទប្រុស អាយុ ៣៨ ឆ្នាំ ។ លុះដល់ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៣ ឈ្មោះ បានយកមូលប្បទានប័ត្រ ទៅបើកប្រាក់នៅធនាគារខាងលើ ស្រាប់តែ ធនាគារបញ្ជាក់ថា មូលប្បទានប័ត្រខាងលើពុំមានទឹកប្រាក់ទេ ។

**នាពេលសវនាការ**

ក្រឡាបញ្ជីអានកំណត់ហេតុស្តីពីការសួរចម្លើយជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ៣៩ ឆ្នាំ នៅដំណាក់កាលអយ្យការថាៈ កាលពីអំឡុងខែមីនា ឆ្នាំ ២០១៣ ខ្លួននិងឈ្មោះ ជានាយកក្រុមហ៊ុនដឹកជញ្ជូន បានទំនាក់ទំនងគ្នា ដើម្បីដឹកជញ្ជូនរថយន្តពីប្រទេសអាឡឺម៉ង់មកកាន់ប្រទេសកម្ពុជា ដោយខ្លួនឲ្យគាត់ដឹកឡានពីប្រទេសអាឡឺម៉ង់ចំនួន ០៧ គ្រឿង សរុបទឹកប្រាក់ចំនួន ១១.៦៣០ (មួយម៉ឺនមួយពាន់ប្រាំមួយរយសាមសិប) ដុល្លាអាមេរិក ពេលនោះខ្លួនបានប្រាប់ទៅឈ្មោះ ថា ខ្លួនគ្មានប្រាក់ទេ តែឈ្មោះ ប្រាប់ថា ឲ្យខ្លួនចេញមូលប្បទានប័ត្រដើម្បីតម្កល់ និងទូទាត់សាច់ប្រាក់ជាដំណាក់កាលតាមក្រោយ ។ នៅថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០១៣ ខ្លួនបានទូទាត់ប្រាក់ឲ្យឈ្មោះ ចំនួន ៤.០០០ (បួនពាន់) ដុល្លាអាមេរិក សំរាប់ថ្លៃជញ្ជូននោះ និងត្រូវដកចេញពីចំនួន ជាក់ស្តែង នៅក្នុងមូលប្បទានប័ត្រដូចសរសេរក្នុងប័ណ្ណចំណាយ ។ នៅថ្ងៃទី ៣០ ខែតុលា ឆ្នាំ ២០១៣ ខ្លួនបានទូទាត់ប្រាក់ឲ្យឈ្មោះ ចំនួន ២.០០០ (ពីរពាន់) ដុល្លាអាមេរិក សំរាប់ថ្លៃដឹកជញ្ជូននោះ និងត្រូវដកចេញពីចំនួនជាក់ស្តែងនៅក្នុងមូលប្បទានប័ត្រដូចមាននៅក្នុងប័ណ្ណចំណាយ។ នៅមុនថ្ងៃចូលឆ្នាំចិន ឆ្នាំ ២០១៤ ប្រពន្ធខ្លួនបានយកប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លាអាមេរិក យកទៅសងឈ្មោះ តែគាត់មិនព្រមទទួលទេ ដោយប្រាប់ថា ប្រាក់តិចពេក យ៉ាងហោចណាស់ក៏មាន ពីរទៅបីពាន់ ដុល្លាអាមេរិកដែរទើបព្រមទទួល ហើយប្រពន្ធខ្លួនក៏ យកប្រាក់ត្រឡប់មកវិញ ។ ខ្លួននៅខ្វះប្រាក់ចំនួន ៥.៦៣០ (ប្រាំពាន់ប្រាំមួយរយសាមសិប) ដុល្លាអាមេរិក ដើម្បីទូទាត់ថ្លៃ ដឹកជញ្ជូន ពេលដែលខ្លួនទូទាត់ប្រាក់គ្រប់ចំនួន ១១.៦៣០ (មួយម៉ឺនមួយពាន់ប្រាំមួយរយសាមសិប) ដុល្លាអាមេរិក ឈ្មោះ និងប្រគល់មូលប្បទានប័ត្រជូនខ្លួនវិញ ដូចមានសរសេរក្នុងប័ណ្ណចំណាយស្រាប់ ។ មូលហេតុដែលខ្លួន ទូទាត់ប្រាក់យឺតដោយសារឈ្មោះ ពុំបានបំពេញកាតព្វកិច្ចដឹកជញ្ជូនតាមការព្រមព្រៀងគ្នារយៈពេល កន្លះខែ ដោយជាក់ស្តែងឈ្មោះ ដឹកជញ្ជូនប្រើរយៈពេលដល់ទៅបីខែកន្លះ បណ្តាលឲ្យភ្ញៀវដែលកុម្ម៉ង់រថយន្តឈប់ទិញ ហើយរថយន្តត្រូវលក់ក្នុងតម្លៃថោក ឲ្យអ្នកផ្សេង។ មូលប្បទានប័ត្រដែលខ្លួនចេញឲ្យឈ្មោះ គឺចេញដើម្បីតម្កល់ ថ្លៃដឹកជញ្ជូនរថយន្តប៉ុណ្ណោះ ។ ប្រាក់ដែលនៅខ្វះចំនួន ៥.៦៣០ (ប្រាំពាន់ប្រាំមួយរយសាមសិប)ដុល្លាអាមេរិក នោះខ្លួននឹងសងទៅឲ្យឈ្មោះ គ្រប់ចំនួនឲ្យបានមុន ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០១៤ ។

ក្រឡាបញ្ជីអានកំណត់ហេតុស្តីពីការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ភេទប្រុស អាយុ ៣៨ឆ្នាំ នៅដំណាក់កាលអយ្យការនិងចៅក្រមស៊ើបសួរ បានឆ្លើយថាៈ កាលពីអំឡុងខែមីនា ឆ្នាំ២០១៣ ឈ្មោះ បានមកទំនាក់ទំនងជាមួយខ្លួន ដើម្បីទិញសេវាកម្មដឹកជញ្ជូនពីក្រុមហ៊ុនរបស់ខ្លួន ក្នុងគោលបំណងឲ្យក្រុមហ៊ុនខ្លួនផ្តល់សេវាកម្មដឹកជញ្ជូនរថយន្តជូនគាត់ពីទីក្រុងប៊ែកឡាំងប្រទេសអាឡឺម៉ង់ មកកាន់កំពង់ផែខេត្តព្រះសីហនុប្រទេសកម្ពុជា ។ សរុបជាទឹកប្រាក់ចំនួន ១២.០១៥ (មួយម៉ឺនពីរពាន់ដប់ប្រាំ) ដុល្លាអាមេរិកដកថ្លៃចំនួន ១១.៦៣០ (មួយម៉ឺនមួយពាន់ប្រាំមួយរយសាមសិប) ដុល្លាអាមេរិក ដកថ្លៃចំនួន ៣៨៥ (បីរយប៉ែតសិបប្រាំ) ដុល្លាអាមេរិក ។ ខ្លួនសុំបញ្ជាក់ថាឈ្មោះ ត្រូវទូទាត់ថ្លៃសេវាកម្មឲ្យមកខ្លួន ខណៈពេលដែលទំនិញ (រថយន្ត) ត្រូវបានដឹកមកដាក់នៅលើកំពង់ផែ ប្រទេសអាឡឺម៉ង់ ។ ប៉ុន្តែឈ្មោះនេះយកលេសថារង់ចាំទំនិញមកដល់កំពង់ផែខេត្តព្រះសីហនុហើយ ខ្លួនបានសម្របសម្រួលឲ្យគាត់យកទំនិញចេញពីកំពង់ផែ ។ ក្រោយពីបានទទួលទំនិញហើយឈ្មោះ នៅតែមិនព្រមទូទាត់ ប្រាក់មកឲ្យខ្លួនដដែល ។ នៅថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៣ ឈ្មោះ បានប្រគល់មូលប្បទានប័ត្រលេខ ០៦៦៨៥៨ មានគណនីលេខ ១១៤០១០១៩៥៨៥៥ មានទឹកប្រាក់ចំនួន ១១,៦៣០ (មួយម៉ឺនមួយពាន់ប្រាំមួយរយសាមសិប) ដុល្លាអាមេរិក ។ ក្រោយពីបានទទួលមូលប្បទានប័ត្រ ពីឈ្មោះ ខ្លួនបានទៅដកប្រាក់នៅធនាគារភ្នំពេញពាណិជ្ជចំនួន ០២ ដង លើកទីមួយ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៣ និងលើកទី២ នៅថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០១៣ ប៉ុន្តែត្រូវបានមន្ត្រីធនាគារឆ្លើយតប តាមលិខិតមូលប្បទានប័ត្របញ្ជូនត្រឡប់បញ្ជាក់ថា មិនមានសាច់ប្រាក់នៅក្នុងគណនីលេខ ១១៤០១០១៩៥៨៥៥ របស់ឈ្មោះ ឡើយ ។ ដំបូងឈ្មោះ សងបាន ៤.០០០ (បួនពាន់) ដុល្លាអាមេរិក ក្រោយមក

សង ២.០០០ (ពីរពាន់) ដុល្លាអាមេរិក និងចំនួន ១០០០ (មួយពាន់) ដុល្លាអាមេរិក ទៀត ។ ទង្វើរបស់ឈ្មោះ ជាចេតនាបោកប្រាស់ ដែលជាហេតុធ្វើឲ្យខាតពេលវេលា និងផលប្រយោជន៍ជាច្រើន ។ សំណូមពរៈ ផ្តន្ទាទោសឈ្មោះ តាមច្បាប់ ។ ទាមទារសំណងចំនួន ៥.៦៣០ (ប្រាំពាន់ប្រាំមួយរយសាមសិប) ដុល្លាអាមេរិក និងទាមទារជម្ងឺចិត្តព្រមទាំងខាតបង់ពេលវេលាចំនួន១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លាអាមេរិក ។

**លោក ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋានថា៖** នៅថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៣ ឈ្មោះ បានប្រគល់មូលប្បទានប័ត្រលេខ ០៦៦៨៥៨ មានគណនីលេខ ១១៥០១០១៩៥៨៥៥ មានទឹកប្រាក់ចំនួន ១១.៦៣០ (មួយម៉ឺនមួយពាន់ប្រាំមួយរយសាមសិប) ដុល្លាអាមេរិក តែនៅពេលដែលកូនក្តីខ្លួនទៅបើកប្រាក់នៅធនាគារភ្នំពេញពាណិជ្ជ ក៏ត្រូវបានមន្ត្រីធនាគារឆ្លើយតបតាមលិខិតមូលប្បទានប័ត្របញ្ជូនត្រឡប់បញ្ជាក់ថា មិនមានសាច់ប្រាក់នៅក្នុងគណនីខាងលើនេះទេ ទង្វើរបស់ឈ្មោះ ជាចេតនាបោកប្រាស់ ដែលជាហេតុធ្វើឲ្យខាតពេលវេលា និងផលប្រយោជន៍ជាច្រើន ។ សំណូមពរៈ ផ្តន្ទាទោសឈ្មោះ តាមច្បាប់ ។ ទាមទារសំណងចំនួន ៥.៦៣០ (ប្រាំពាន់ប្រាំមួយរយសាមសិប) ដុល្លាអាមេរិក និងទាមទារជម្ងឺចិត្តព្រមទាំងខាតបង់ពេលវេលាចំនួន ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លាអាមេរិក ។

**តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ**

ក្រោយពីស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងពិនិត្យភស្តុតាងជាឯកសារទាក់ទិននៅក្នុងសំណុំរឿងរួចមកឃើញថានៅក្នុងរឿងនេះ ជនជាប់ចោទឈ្មោះ ពិតជាប្រព្រឹត្តអំពើ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៣ ប្រាកដមែន ។ ដូច្នេះតំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ អ.យ.ណ ចុះថ្ងៃទី ០៧ ខែឧសភា ឆ្នាំ ២០១៥ នៅដដែល ទុកជូនតុលាការពិចារណា និងសម្រេចតាមច្បាប់ ។

- ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានពិនិត្យភស្តុតាង
- ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សំអាងហេតុ</u>

១. កាលពីថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៣ ឈ្មោះ ភេទប្រុស អាយុ ៣៩ ឆ្នាំ ពិតជាបានចេញមូលប្បទានប័ត្រលេខ ០៦៦៨៥៨ មានគណនីលេខ ១១៥០១០១ របស់ធនាគារភ្នំពេញពាណិជ្ជ មកឲ្យឈ្មោះ ដើម្បីទូទាត់ប្រាក់ថ្លៃ សេវាកម្មដឹកជញ្ជូនរថយន្តចំនួន ១១.៦៣០ (មួយម៉ឺនមួយពាន់ប្រាំមួយរយសាមសិប) ដុល្លាអាមេរិក ។ លុះដល់ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០១៣ ទៅបើកប្រាក់ខាងធនាគារបញ្ជាក់ថា មូលប្បទានប័ត្រនេះ គ្មានទឹកប្រាក់ក្នុងគណនី ប្រាកដមែន។

២. តាមចម្លើយរបស់ជនជាប់ចោទបានឆ្លើយសារភាពថា ខ្លួនពិតជាបានចេញមូលប្បទានប័ត្រដើម្បីតម្កល់ និងទូទាត់សាច់ប្រាក់ទៅឲ្យឈ្មោះ ដែលចម្លើយនេះស្របទៅនឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី នឹងស្របទៅនឹងឯកសារផ្សេងៗទៀតដែលមាននៅក្នុងសំណុំរឿងអាចបញ្ជាក់បានថាឈ្មោះ ពិតជាបានប្រព្រឹត្តអំពើ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ប្រាកដមែន ។ ភស្តុតាងទាំងអស់ខាងលើនេះ អាចឱ្យតុលាការពិចារណាបាន តាមមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣. ជនជាប់ចោទជានីតិជនដែលមានសមត្ថភាពទទួលខុសត្រូវខាងព្រហ្មទណ្ឌ ពោលគឺពុំមានភស្តុតាងណាមួយ បញ្ជាក់ថាមានបញ្ហាខាងស្មារតីឡើយ ដូច្នេះ ជនជាប់ចោទពិតជាមានស្មារតីយល់ដឹងពីផលវិបាកដែលកើតចេញពីការប្រព្រឹត្តរបស់ខ្លួន ស្របតាមមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ។

៤. អំពើប្រព្រឹត្តរបស់ជនជាប់ចោទ គឺបានធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ និងសណ្ដាប់ធ្នាប់ដ៏ល្អរបស់សង្គម ដែលមាត្រា២ និងមាត្រា៣ នៃក្រមព្រហ្មទណ្ឌ បានហាមឃាត់ជាដាច់ខាត និងត្រូវតែផ្ដន្ទាទោស ។

៥. ហានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ឈាង សុផល ភេទប្រុស អាយុ ៣៩ ឆ្នាំ សញ្ជាតិខ្មែរ ពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោស តាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្ដីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

៦. ដើមបណ្ដឹងរដ្ឋប្បវេណី បានប្ដឹងទាមទារប្រាក់ចំនួន ៥.៦៣០ (ប្រាំពាន់ប្រាំមួយរយសាមសិប) ដុល្លាអាមេរិក និងជម្ងឺចិត្តចំនួន ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លាអាមេរិក។ គប្បីតុលាការពិនិត្យពិចារណា តាមព្យសនកម្មរបស់ជនរងគ្រោះ និងលទ្ធភាពរបស់ជនជាប់ចោទ ដើម្បីឲ្យស្របតាមមាត្រា ១៤ និងមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

១. ផ្ដន្ទាទោសឈ្មោះ                ភេទប្រុសអាយុ ៣៩ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ២ (ពីរ) ឆ្នាំ ពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍ដែលអាចជួញដូរបាន ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្ដីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

២. បង្គាប់ឲ្យចាប់ និងឃុំខ្លួនឈ្មោះ                នៅមណ្ឌលអប់រំកែប្រែ ម១ នៃក្រសួងមហាផ្ទៃ ។

៣. បង្គាប់ឲ្យឈ្មោះ                សងប្រាក់ចំនួន ៥.៦៣០ (ប្រាំពាន់ប្រាំមួយរយសាមសិប) ដុល្លារអាមេរិក និងជម្ងឺចិត្តចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល ឲ្យឈ្មោះ                ។ ច្រានចោលការទាមទារលើសពីនេះ ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៥ កំបាំងមុខជនជាប់ចោទ មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ចំពោះមុខមេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្ដឹងរដ្ឋប្បវេណី និង ដើមបណ្ដឹងរដ្ឋប្បវេណី និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០១៥ ។

បើកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

បានឃើញ

**ចៅក្រមជំនុំជម្រះ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០១៥

**ក្រឡាបញ្ជីសវនាការ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

# តាមនាមប្រជារាស្ត្រខ្មែរ

# សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

-លេខ

ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២

-សំណុំរឿងព្រហ្មទណ្ឌលេខ

ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០

-សំណុំរឿងស៊ើបសួរលេខ

ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០

-សំណុំរឿងជំនុំជំរះលេខ

ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង៨ និង០០ នាទី ព្រឹក នៅសាលសវនាការទី៩ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ ២០២២ ដោយមានសមាសភាពជំនុំជម្រះដូចតទៅ ៖

## ចៅក្រមជំនុំជម្រះ

-លោក ជាចៅក្រម នៃសាលាដំបូងរាជធានីភ្នំពេញ

## តំណាងអយ្យការ

-លោក ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

## ក្រឡាបញ្ជីសវនាការ

-លោកស្រី ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះ លើបណ្តឹងទាស់នឹងសាលក្រមកំបាំងមុខលេខ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ ២០២១ ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ ដែលមានជនជាប់ចោទ ៖

ឈ្មោះ ភេទប្រុស អាយុ៧១ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ លេខ ផ្លូវលំ ភូមិ សង្កាត់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

ជាប់ចោទពីបទ ៖ ធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះមានក្បាលដីលេខ ផ្លូវលំ ភូមិ សង្កាត់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៤១១ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ភេទស្រី អាយុ៤១ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ ភេទប្រុស អាយុ៥១ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ផ្លូវលំ ភូមិ សង្កាត់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

មេធាវីលោក អត្តលេខ និងមេធាវី អត្តលេខ ជាមេធាវីការពារក្តីឲ្យដើមបណ្តឹងរដ្ឋប្បវេណី។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ អ.ឃ.ខ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ (ង)ដ.ដ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ 'ឃ" ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលវិនិច្ឆ័យសេចក្តីដូចតទៅ ៖

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ៧១ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល២ឆ្នាំ (ពីរឆ្នាំ) តែទោសនេះត្រូវអនុវត្តទោសព្យួរធម្មតា និងពិន័យជាប្រាក់ចំនួន៤.០០០.០០០(បួនលាន)រៀល បង់ចូលថវិការរដ្ឋ ពីបទ ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះមានក្បាលដីលេខ ផ្លូវលំ ភូមិ សង្កាត់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា១០៧ និងមាត្រា៤១១ នៃក្រមព្រហ្មទណ្ឌ។

២.បង្គាប់ឱ្យជនជាប់ចោទឈ្មោះ សងសំណងការខូចខាត និងជម្ងឺចិត្តសរុបចំនួន៨.០០០.០០០ (ប្រាំបីលាន) រៀល ទៅអោយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ និងឈ្មោះ ។ ការទាមទារលើសពីនេះបដិសេធចោល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ កំបាំងមុខជនជាប់ចោទ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

-បានឃើញ សេចក្តីចម្លងបណ្តឹងទាស់លេខ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ ដោយសុំប្តឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌលេខ ឃ" ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០ នៅចំណុចផ្ទះដែលមានក្បាលដីលេខ ផ្លូវលំ ភូមិ សង្កាត់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ មានករណីគប់ និងវៃបំផ្លាញកាំម៉ារ៉ាសុវត្ថិភាពរបស់ជនរងគ្រោះឈ្មោះ និងឈ្មោះ ដែលបំពាក់ជាប់នឹងផ្ទះ ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ បណ្តាលឱ្យខូចខាតទាំងស្រុង ដែលករណីនេះផ្តើមចេញពីទំនាស់ នៃការសាងសង់ផ្ទះ ដែលមានព្រំជាប់គ្នា។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ បានឆ្លើយថា ខ្ញុំបាទប្តឹងទាស់នឹងសាលក្រមកំបាំងមុខ ដោយហេតុថា ខ្ញុំបាទពុំបានដឹងពីការកោះហៅរបស់តុលាការនោះទេ ទើបខ្ញុំបាទប្តឹងទាស់ ហើយរឿងហេតុនេះកើតឡើងដោយសាការឈ្លោះគ្នាជាមួយដើមបណ្តឹងរដ្ឋប្បវេណីពីរឿងធ្វើផ្ទះ ហើយខ្ញុំបាទមិនឱ្យដើមបណ្តឹងដាក់កាំម៉ារ៉ាសុវត្ថិភាពបែមកផ្ទះរបស់ខ្ញុំបាទ ដោយខ្ញុំបាទបានធ្វើកិច្ចសន្យាជាមួយដើមបណ្តឹងទៀត ប៉ុន្តែដើមបណ្តឹងនៅតែដាក់កាំម៉ារ៉ាសុវត្ថិភាពបែមកផ្ទះខ្ញុំដដែល ធ្វើឱ្យមានជម្លោះនឹងគ្នា ហើយខ្ញុំក៏ទៅកាច់កាំម៉ារ៉ាសុវត្ថិភាពនោះចោលតែម្តង។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

តំណាងអយ្យការសុំតម្កល់សាលក្រមព្រហ្មទណ្ឌកំបាំងមុខលេខ ឃ" ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ទុកជាបានការដដែល និងសុំឱ្យតុលាការសម្រេចតាមច្បាប់។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

ខ្ញុំបាទសូមឱ្យតុលាការបន្ធូបន្ថយទោស ខ្ញុំបាទដឹងកំហុសហើយ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

១-ពាក្យបណ្តឹងទាស់របស់ជនជាប់ចោទឈ្មោះ ប្តឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌលេខ "ឃ" ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

២.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ បានឆ្លើយថា ខ្លួនប្តឹងទាស់នឹងសាលក្រមកំបាំងមុខនេះ ដោយហេតុថា ខ្លួនពុំបានដឹងពីការកោះហៅរបស់តុលាការនោះទេ ទើបខ្លួនប្តឹងទាស់ ហើយរឿងហេតុនេះកើតឡើងដោយសាការឈ្លោះគ្នាជាមួយដើមបណ្តឹងរដ្ឋប្បវេណីពីរឿងធ្វើផ្ទះ ហើយខ្លួនមិនឱ្យដើមបណ្តឹងដាក់កាំម៉ារ៉ាសុវត្ថិភាពបែមកផ្ទះរបស់ខ្លួន ដោយខ្លួនបានធ្វើកិច្ចសន្យាជាមួយដើមបណ្តឹងទៀត ប៉ុន្តែដើមបណ្តឹងនៅតែដាក់កាំម៉ារ៉ាសុវត្ថិភាពបែមកផ្ទះរបស់ខ្លួនដដែល ធ្វើឱ្យមានជម្លោះនឹងគ្នា ហើយខ្លួនក៏ទៅកាច់កាំម៉ារ៉ាសុវត្ថិភាពនោះចោលតែម្តង។ ហេតុដូច្នេះតាមចម្លើយរបស់ជនជាប់ចោទ និងតាមភស្តុតាងនៅក្នុងសំណុំរឿង អាចឱ្យតុលាការជឿបានថាជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន។

៣.អំពើរបស់ជនជាប់ចោទឈ្មោះ ពិតជាបានប្រព្រឹត្តអំពើ **ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស** ទៅលើជនរងគ្រោះឈ្មោះ និងឈ្មោះ ប្រាកដមែន ដោយជនជាប់ចោទឈ្មោះ បានធ្វើសកម្មភាពចូលក្នុងរបងផ្ទះជនរងគ្រោះ យកដុំថ្ម និងឈើជ្រុងទៅវៃកម្ទេចកាំម៉ារ៉ាសុវត្ថិភាពបណ្តាលឱ្យខូចខាត។ ដូចនេះអំពើរបស់ជនជាប់ចោទឈ្មោះ បានរំលោភទៅលើមាត្រា៤១១ នៃក្រមព្រហ្មទណ្ឌ។

៤-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ៖ តំណាងអយ្យការសុំតម្កល់សាលក្រមព្រហ្មទណ្ឌកំបាំងមុខលេខ "ឃ" ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ទុកដដែល និងសុំឱ្យតុលាការសម្រេចតាមច្បាប់ គប្បីតុលាការពិចារណាតាមច្បាប់។

៥-សំដីចុងក្រោយរបស់ជនជាប់ចោទ សុំឱ្យតុលាការបន្ធូរបន្ថយទោស ខ្លួនដឹងកំហុសហើយ គប្បីតុលាការពិចារណា និងសម្រេចតាមច្បាប់។

៦-ជនជាប់ចោទមានស្មារតី និងសមត្ថភាពទទួលខុសត្រូវអំពីទង្វើរបស់ខ្លួន ដែលខ្លួនបានប្រព្រឹត្ត រួមទាំងផ្នែកព្រហ្មទណ្ឌ និងរដ្ឋប្បវេណី ។

៧-តាមភស្តុតាងជាសត្យានុម័ត បញ្ជាក់ថា: ជនជាប់ចោទពិតជា មានចេតនាពិតប្រាកដ ក្នុងការធ្វើឱ្យខូចខាតទ្រព្យសម្បត្តិអ្នកដទៃមែន ។

៨-អំពើល្មើសពិតជាធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូ ទ្រព្យសម្បត្តិរបស់អ្នកដទៃ និងរបៀបរៀបរយសង្គម ហើយអំពើនេះវាផ្ទុយនឹងមាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌ។

៩-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ពីបទ: **ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្ទះមានក្បាលដីលេខ ផ្លូវលំ ភូមិ សង្កាត់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤១១ នៃក្រមព្រហ្មទណ្ឌ ដែលគប្បីតុលាការសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌកំបាំងមុខលេខ "ឃ" ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការទាំងមូល។

## ហេតុដូច្នេះសម្រេច

១-ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌកំបាំងមុខលេខ "ឃ" ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការទាំងមូល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២ ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២
**ក្រឡាបញ្ជី**

# ឧបសម្ព័ន្ធទី៣

# សាលដីកាព្រហ្មទណ្ឌ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សាលក្រមឧទ្ធរណ៍
សំណុំរឿងព្រហ្មទណ្ឌ
លេខ ២០៣
ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩
សាលដីកា
លេខ ០៤ "ឋ"
ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០

## សាលដីកា

## តាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០
ដោយអង្គជំនុំជម្រះមានសមាសភាពចៅក្រមដូចខាងក្រោម ៖

១. លោកស្រី [redacted] ជាប្រធាន
២. លោក [redacted] ជាចៅក្រម
៣. លោក [redacted] ជាចៅក្រម
៤. លោក [redacted] ជាចៅក្រម
៥. លោក [redacted] ជាចៅក្រម

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**តំណាងមហាអយ្យការ**

លោក [redacted] ឋានៈជាព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ២៥២ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ របស់ទណ្ឌិតឈ្មោះ [redacted] វិច្ឆិកា ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ០៥ ក្រ៧ (ជ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលមាន ៖

- ទណ្ឌិតឈ្មោះ [redacted] វិច្ឆិកា ភេទប្រុស អាយុ២២ឆ្នាំ សញ្ជាតិខ្មែរ មុខរបរជាងកាត់កញ្ចក់ មានទីកន្លែងកំណើតនៅភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទីលំនៅមុនពេលចាប់ខ្លួន [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន។ ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ (ម១) នៃអគ្គនាយកដ្ឋានពន្ធនាគារក្រសួងមហាផ្ទៃ។ (អ្នកប្តឹងសុំស្រួបទោស)



Scanned with CamScanner

- កម្មវត្ថុ ប្ដឹងសុំស្រូបទោសបញ្ចូលគ្នា ។

**និពីមូលហេតុនៃបណ្ដឹង**

តាមពាក្យសុំឱ្យស្រូបទោសបញ្ចូលគ្នា ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩ របស់ទណ្ឌិតឈ្មោះ [redacted] វិច្ឆិកា បានលើកឡើងថា ខ្លួនមានសំណុំរឿងព្រហ្មទណ្ឌចំនួន០២ ករណីដែលមានសាលដីកាបានចូលជាស្ថាពរទាំងពីររួចហើយ។

សំណុំរឿងទី១

-សំណុំរឿងព្រហ្មទណ្ឌលេខ ១៤៩៦ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ។

-សាលក្រមលេខ ៨៨ "ម" ក្រ៦ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ចំនួន ០៦ឆ្នាំ (ប្រាំមួយឆ្នាំ) ពីបទ លួចមានស្ថានទម្ងន់ទោស (ប្រើអាវុធខ្លីភ្ជង់ជនរងគ្រោះ) ប្រព្រឹត្តនៅចំណុចមុខសាលាបឋមសិក្សាពញាក្រែក ផ្លូវលេខ៩៣ ក្រុមទី១៩ ភូមិទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥។

-សំណុំរឿងព្រហ្មទណ្ឌលេខ ៧៩៨ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ របស់សាលាឧទ្ធរណ៍។

-សាលដីកាស្ថាពរលេខ ៣១ ក្រVI "ប.ស" ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ បានសម្រេចតម្កល់សាលក្រមលេខ ៨៨ "ម" ក្រ៦ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

សំណុំរឿងទី២

-សំណុំរឿងព្រហ្មទណ្ឌលេខ ១៤៨១ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ។

-សាលក្រមលេខ ៤៧២ "ក្រ១ន" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ចំនួន ០៦ឆ្នាំ (ប្រាំមួយឆ្នាំ) ពីបទ លួចមានស្ថានទម្ងន់ទោស (ប្រើអាវុធខ្លីភ្ជង់ជនរងគ្រោះ) ប្រព្រឹត្តនៅចំណុចមុខសាលាបឋមសិក្សាពញាក្រែកផ្លូវលេខ ៩៣ ក្រុមទី១៩ ភូមិទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥។

-សំណុំរឿងព្រហ្មទណ្ឌលេខ ១៣៣៧ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍។

-សាលដីកាស្ថាពរលេខ ២៣ ក្រV "វ" ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ បានសម្រេចតម្កល់សាលក្រមលេខ ៤៧២ "ក្រ១ន" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

ដោយឆ្លងកាត់តាមការអប់រំ ក្នុងមណ្ឌលអប់រំកែប្រែទី១ នាពេលកន្លងមកខ្លួនបានដឹងពីកំហុសរបស់ខ្លួន បានគោរពប្រតិបត្តិយ៉ាងហ្មត់ចត់ ត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់មណ្ឌល និងបានយកចិត្ត



Scanned with CamScanner

ទុកដាក់បំពេញការងារពលកម្ម យ៉ាងសកម្មទៀងទាត់ដែលជាគំរូដល់ទណ្ឌិតដទៃទៀត។ ខ្លួនមានស្មារតីភ្ញាក់រលឹក ខិតខំលត់ដំកែប្រែខ្លួនបានល្អ និងបានប្តេជ្ញាចិត្ត ខិតខំរៀនសូត្រអប់រំខ្លួនឱ្យក្លាយជាពលរដ្ឋសុចរិតមានប្រយោជន៍ដល់សង្គមជាតិ។

សំណូមពរ ខ្លួនស្នើសុំអនុវត្តឱ្យស្រូបទោសបញ្ចូលគ្នា ដោយសុំឱ្យសាលក្រមលេខ ៨៨ "ម" ក្រ៦ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ និងសាលដីកាស្ថាពរលេខ ៣១ ក្រVI "ប.ស" ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ និងសាលក្រមលេខ ៤៧២ "ក្រ១ន" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ និងសាលដីកាស្ថាពរលេខ ២៣ ក្រV "រ" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ស្រូបទោសបញ្ចូលគ្នាទាំងមូល។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម ឯកឧត្តមប្រធាន មេត្តាពិនិត្យ និងលើកយកសាលក្រម និងសាលដីកាស្ថាពរទាំង០២ នេះមកធ្វើការជំនុំជម្រះ ដោយស្រូបទោសបញ្ចូលគ្នា ដល់ខ្លួនដោយក្តីអនុគ្រោះ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ០៥ ក្រVII (ធ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ទទួលពាក្យសុំស្រូបទោសបញ្ចូលគ្នា ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩ របស់ទណ្ឌិតឈ្មោះ [redacted] វិច្ឆិកា ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២.ស្រូបទោសក្នុងសាលដីកាស្ថាពរលេខ ២៣ ក្រV (រ) ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ចំនួន០២ (ពីរ)ឆ្នាំ បញ្ចូលមកក្នុងសាលដីកាស្ថាពរលេខ ៣១ ក្រVI "ប.ស" ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ដូច្នេះទោសដែលត្រូវអនុវត្តគឺ ចំនួន១០ (ដប់) ឆ្នាំ។

៣.សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នាថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងសាទុក្ខលេខ ២៥២ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩ របស់ទណ្ឌិតឈ្មោះ [redacted] វិច្ឆិកា ប្តឹងមិនសុខចិត្តទៅនឹងសាលដីកាព្រហ្មទណ្ឌលេខ ០៥ ក្រVII (ធ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

**នាពេលសវនាការ**

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋានថា ទណ្ឌិតឈ្មោះ [redacted] វិច្ឆិកា បានប្តឹងសុំស្រូបទោសបញ្ចូលគ្នា លើសាលក្រមស្ថាពរចំនួន ២ ដែលមានទណ្ឌកម្ម សរុបមានចំនួន ១២ឆ្នាំ ហើយសាលាឧទ្ធរណ៍បានសម្រេចស្រូបទោសមកត្រឹម១០ឆ្នាំ ឃើញថាការសម្រេចនេះមានលក្ខណៈត្រឹម

Scanned with CamScanner

ត្រូវហើយ ព្រោះថាបើយោងតាមមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌ បានកំណត់ថា ទោសដែលត្រូវប្រកាសអនុវត្តត្រួតគ្នា នៅក្នុងព្រំដែននៃអតិបរិមាស្របច្បាប់ខ្ពស់ជាងគេ។ ហើយការផ្តន្ទាទោសលើទណ្ឌិតពីបទលួចមានស្ថានទម្ងន់ទោស ហេតុនេះ ទណ្ឌកម្មខ្ពស់ជាងគេគឺ ១០ឆ្នាំ ឃើញថាមានលក្ខណៈត្រឹមត្រូវហើយ។ តំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេច តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ០៥ ក្រVII (ធ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

-លោកមេធាវី [redacted] ផានិត បានធ្វើសេចក្តីសន្និដ្ឋានការពារទណ្ឌិត [redacted] វិច្ឆិកា ថា យើងឃើញហើយថាបទល្មើសរបស់គាត់ គឺបទល្មើសដូចគ្នា ហើយនៅក្នុងអំឡុងឆ្នាំតែមួយ។ បើគិតពីការព្យសនកម្មវិញ គឺមានព្យសនកម្មតិចតួចទៅនឹងទំហំនៃការប្រព្រឹត្ត។ ទាក់ទងទៅនឹងការស្រូបទោស គឺ ដើម្បីស្រូបទោសឱ្យមានភាពយុត្តិធម៌សម្រាប់អ្នកសុំ យល់ឃើញថាគួរតែយកទោសតូចស្រូបចូលទោសធំ មានន័យថាទណ្ឌកម្មដែលធំ។ អ៊ីចឹងយើងឃើញថា សាលក្រមចំនួន២ និងសាលដីកាដែលចូលជាស្ថាពរ មានកម្រិតទណ្ឌកម្មស្មើគ្នា គឺ៦ឆ្នាំ ខ្លួនយល់ឃើញថាគួរស្រូបបញ្ចូលទៅសាលក្រម ឬ សាលដីកាណាមួយ មានន័យថាយកទោស ៦ ឆ្នាំ ស្រូបចូលទោស ៦ ឆ្នាំ។ ក្នុងនាមខ្លួនជាមេធាវីការពារឱ្យទណ្ឌិត [redacted] វិច្ឆិកា សូមសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះ តុលាការកំពូលដែលជាតុលាការសម្រេចចុងក្រោយ សុំមេត្តាស្រូបទោសទណ្ឌកម្ម នៅក្នុងសាលដីកាណាមួយចូលទៅក្នុងសាលដីកាណាមួយ ដើម្បីឱ្យត្រឹមត្រូវតាមគតិនៃច្បាប់ដែលចែងថា ការស្រូបទោសគឺ ពីតូច ទៅធំ។

- ទណ្ឌិត គង់ វិច្ឆិកា បានឆ្លើយថា ខ្លួនសុំស្រូបទោសចូលទៅក្នុងសាលដីកាតែមួយបានហើយ និងសុំស្រូបទោសត្រឹម ៦ឆ្នាំ។

## តុលាការកំពូល

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារទណ្ឌិត [redacted] វិច្ឆិកា
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៥២ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩ របស់ទណ្ឌិត [redacted] វិច្ឆិកា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ការដែលមេធាវីរបស់ទណ្ឌិត [redacted] វិច្ឆិកា សុំឱ្យតុលាការកំពូលទទួលស្រូបទោសទាំងមូលឱ្យកូនក្តីរបស់ខ្លួន ដោយលើកឡើងថាករណីរបស់កូនក្តីខ្លួន គួរតែតុលាការកំពូលស្រូបបញ្ចូលទោស

Scanned with CamScanner

៦ឆ្នាំ ទៅក្នុងទោសមួយទៀត ៦ឆ្នាំដែរនោះ ទើបជាការសមស្រប។ តុលាការកំពូលពិនិត្យឃើញថា ទណ្ឌិត [redacted]វិច្ឆិកា ត្រូវបានតុលាការផ្តន្ទាទោសពីបទល្មើស លួចមានស្ថានទម្ងន់ទោសទាំងពីរសាលក្រម ជាបទល្មើសកំពុងកើតមានពេលបច្ចុប្បន្ន។ ដូច្នេះការដែលសាលាឧទ្ធរណ៍បានទទួលឱ្យស្រុបទោស ត្រឹមព្រំដែនអតិបរិមាស្របច្បាប់ លើទោសដែលកំណត់ក្នុងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ គឺទោសត្រូវអនុវត្ត ១០ឆ្នាំ នោះជាការត្រឹមត្រូវហើយ។

៣-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ០៥ "ក្រVII(ធ)" ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ត្រឹមត្រូវនឹងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១- បដិសេធបណ្តឹងសាទុក្ខលេខ ២៥២ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩ របស់ទណ្ឌិត [redacted]វិច្ឆិកា ។

២- តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ០៥ ក្រVII (ធ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទាំងមូល។

*សាលដីកានេះ បានជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០។*

Scanned with CamScanner

# ឧបសម្ព័ន្ធទី៤
# សារាចរសារាចរស្តីពីការអនុវត្តបទប្បញ្ញត្តិនៃការអនុវត្តទោសការងារសហគមន៍ ឆ្នាំ២០១៤។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ : ០៣ [illegible]/១៤

## សារាចរ
## ស្តីពី
## ការអនុវត្តបទប្បញ្ញត្តិនៃ ការអនុវត្តទោសការងារសហគមន៍

ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា បទប្បញ្ញត្តិ និងគោលការណ៍ស្តីពីការអនុវត្តទោសការងារសហគមន៍ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌចាប់ពីមាត្រា ៧២ ដល់មាត្រា ៧៥ មាត្រា ៨៨ មាត្រា ១០១ ដល់ ១០៣ និងមាត្រា ១៦២ មិនទាន់អនុវត្តបានគ្រប់ជ្រុងជ្រោយនៅឡើយ ដែលជាហេតុធ្វើឲ្យការអនុវត្តទោសការងារសហគមន៍ មិនទាន់មានប្រសិទ្ធិភាព និងមិនទាន់មានភាពរលូន។

ដើម្បីធានាការអនុវត្តបទប្បញ្ញត្តិ និងគោលការណ៍ទាំងនេះឲ្យមានប្រសិទ្ធភាព ក្រសួងយុត្តិធម៌សូមធ្វើការណែនាំដូចខាងក្រោម ៖

**ក-ចៅក្រមជំនុំជម្រះ**

១-គប្បីធានាឲ្យបាននូវការអនុវត្តតាមបទប្បញ្ញត្តិ និងគោលការណ៍ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌស្តីពីទោសការងារសហគមន៍ ចំពោះទណ្ឌិតណាដែលតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើ ៣ (បី) ឆ្នាំ ។

២-តុលាការត្រូវប្រគល់សម្រង់សាលក្រម ជូនព្រះរាជអាជ្ញាមួយច្បាប់ និងប្រគល់ឲ្យទៅទណ្ឌិតមួយច្បាប់។

**ខ-ព្រះរាជអាជ្ញា**

១-ត្រូវសហការជាមួយអង្គការរដ្ឋ សមាគមន៍ ឬអង្គការមិនមែនរដ្ឋាភិបាល ដើម្បីកសាង និងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះនីតិបុគ្គល និងប្រភេទការងារ ដែលមានតម្រូវការផ្តល់ការងារឲ្យទណ្ឌិតធ្វើ។ បញ្ជីនេះត្រូវដាក់បង្ហាញជូនតុលាការដើម្បីជ្រើសរើសការងារ ឲ្យទណ្ឌិតដែលយល់ព្រមទទួលយក។

២-ការផ្តល់ការងារសហគមន៍ដល់អនីតិជន ត្រូវពិភាក្សាបន្ថែមជាមួយមន្ត្រីសង្គមកិច្ចអំពីការងារដែលមានលក្ខណៈជាការងារបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ។

៣-ត្រូវរៀបចំបែបបទនៃការអនុវត្តទោសការងារសហគមន៍ សម្រាប់នីតិបុគ្គលដែលទទួលទណ្ឌិតឲ្យធ្វើការងារ ដោយឲ្យនីតិបុគ្គលនោះ បំពេញនូវភារកិច្ចដូចតទៅ ៖

-ណែនាំដល់ទណ្ឌិតអំពីការបំពេញភារកិច្ច និងអប់រំទណ្ឌិតឲ្យយកចិត្តទុកដាក់ក្នុងការកសាងខ្លួនចូលក្នុងសង្គមវិញ

-គ្រប់គ្រងតាមដានសកម្មភាពរបស់ទណ្ឌិត ក្នុងពេលបំពេញភារកិច្ច

-ធ្វើរបាយការណ៍អំពីសកម្មភាពរបស់ទណ្ឌិតជូនដល់ព្រះរាជអាជ្ញា

-ត្រូវចុះហត្ថលេខាលើកំណត់ហេតុទទួលស្គាល់ អំពីការអនុវត្តការងាររបស់ទណ្ឌិត

៤-ត្រូវយកចិត្តទុកដាក់តាមដានត្រួតពិនិត្យការអនុវត្តការងាររបស់ទណ្ឌិតដែលមានដូចខាងក្រោម ៖

-គ្រប់គ្រង តាមដាន រក្សាទុករបាយការណ៍ កំណត់ហេតុអំពីការអនុវត្តការងារសហគមន៍

-តាមដានការអនុវត្តរបស់ទណ្ឌិតទៅតាមលក្ខខណ្ឌរបស់សាលក្រម

-ណែនាំទណ្ឌិតអំពីការអនុវត្តការងារសហគមន៍ និងភារកិច្ចដែលត្រូវអនុវត្ត

-ណែនាំដល់នីតិបុគ្គលដែលទទួលទណ្ឌិត អំពីបែបបទអនុវត្តការងារគ្រប់គ្រង

-ចេញដីកាសម្រេចបញ្ចប់ការអនុវត្តទោសរបស់ទណ្ឌិត ដែលបានអនុវត្តទោសការងារសហគមន៍ដោយជោគជ័យ។

សូមលោក លោកស្រី ជាចៅក្រម ព្រះរាជអាជ្ញា គ្រប់ស្ថាប័នតុលាការ និងអយ្យការត្រូវអនុវត្តសារាចរនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី..២២..ខែ..មករា.. ឆ្នាំ..២០១៤

រដ្ឋមន្ត្រី

អង្គ វង្សវឌ្ឍានៈ

**ចម្លងជូន ៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី

ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-តុលាការ និងមហាអយ្យការអមតុលាការកំពូល

-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍

-សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត

-ឯកសារ-កាលប្បវត្តិ